ទស្សនាវដ្ដីស្រាវជ្រាវ

# រាជបណ្ឌិត្យសភាកម្ពុជា

# Royal Academy of Cambodia Journal

លេខ១០ ខែកញ្ញា ឆ្នាំ២០២៣ | Vol.10-September-2023



រក្សាសិទ្ធិគ្រប់យ៉ាង

**នាយកការផ្សាយ**

ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច**

**និពន្ធនាយក**

ឯកឧត្តមបណ្ឌិត **យង់ ពៅ**

**គណៈកម្មការនិពន្ធ**

ឯកឧត្តមបណ្ឌិត **នូ ចាន់សុភី**
ឯកឧត្តមបណ្ឌិត **ផុន កសិកា**
ឯកឧត្តមបណ្ឌិត **អ៊ាប បុណ្ណា**
ឯកឧត្តមបណ្ឌិត **នុត សម្បត្តិ**
ឯកឧត្តមបណ្ឌិត **គិន ភា**
ឯកឧត្តមបណ្ឌិត **មាយ បូរ៉ា**
ឯកឧត្តមបណ្ឌិត **គី សេរីវឌ្ឍន៍**
ឯកឧត្តម **សូត្រ សំណាង**
ឯកឧត្តមបណ្ឌិត **ហ៊ាន សុខុម**
លោក **ហេង វីរិទ្ធិ**
លោក **សាន សុរាវនិត**

**លេខាធិការដ្ឋានបោះពុម្ពផ្សាយ**

លោកស្រី **កែវ ខេមរា**
លោក **ធឿន សុត្ថា**
លោក **ហេង ហុកវេន**
លោកស្រី **សំរិទ្ធ ចរិយា**
លោក **កៅ សុម៉ាឡេត**
លោក **ឡឿង មករា**
លោក **ភួយ បញ្ញា**

# អារម្ភកថា

ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងការបោះពុម្ពផ្សាយជាកត្តារួមចំណែកមួយក្នុងការអភិវឌ្ឍសង្គមជាតិដែលក្នុងនោះរាជបណ្ឌិត្យសភាកម្ពុជាបានធ្វើការសិក្សាស្រាវជ្រាវលើជំនាញផ្សេងៗនិងបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដីស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជាជាច្រើនលេខរួចមកហើយ។ នៅក្នុងលេខទីដប់នេះមានអត្ថបទជាច្រើនទៀតដែលទាក់ទងនឹងអប់រំ នយោបាយ អក្សរសិល្ប៍ ទស្សនវិជ្ជា និងរដ្ឋបាលសាធារណៈជាដើម សុទ្ធសឹងជាអត្ថបទសិក្សាស្រាវជ្រាវ និងវិភាគបែបវិទ្យាសាស្ត្រ ដែលអាចជាជំនួយស្មារតីដល់អ្នកសិក្សាស្រាវជ្រាវផងដែរ។

ទស្សនាវដ្ដីស្រាវជ្រាវ នៃរាជបណ្ឌិត្យសភាកម្ពុជាបានរួមចំណែកផ្សព្វផ្សាយស្នាដៃស្រាវជ្រាវបែបវិទ្យាសាស្ត្ររបស់បណ្ឌិត្យសភាចារ្យ អ្នកស្រាវជ្រាវ និងអត្ថបទសិក្សាស្រាវជ្រាវរបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងបេក្ខជនបណ្ឌិត។ ការបោះពុម្ពផ្សាយនូវស្នាដៃស្រាវជ្រាវថ្មីៗបែបវិទ្យាសាស្ត្រគឺដើម្បីផ្ដល់នូវចំណេះដឹងបែបវិទ្យាសាស្ត្រជូនដល់សង្គមជាតិ និងជួយសម្រួលដល់អ្នកសិក្សាស្រាវជ្រាវស្វែងយល់ ក៏ដូចជាជួយជំរុញដល់អ្នកស្រាវជ្រាវទាំងឡាយកាន់តែមានឆន្ទៈស្រាវជ្រាវប្រកបដោយវិទ្យាសាស្ត្រ។

គណៈកម្មការរៀបចំទស្សនាវដ្ដីសង្ឃឹមថា អត្ថបទទាំងអស់ដែលបានចុះផ្សាយក្នុងទស្សនាវដ្ដីស្រាវជ្រាវនេះនឹងក្លាយជាឯកសារដ៏សំខាន់មួយ សម្រាប់ការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ។

គណៈកម្មការរៀបចំរង់ចាំទទួលមតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់អ្នកអាននិងអ្នកស្រាវជ្រាវគ្រប់មជ្ឈដ្ឋានដើម្បីកែលម្អនូវចំណុចខ្វះខាតនិងកំហុសឆ្គងដែលអាចកើតមានដោយអចេតនា ទាំងលើខ្លឹមសារ និងផ្នែកបច្ចេកទេសឱ្យកាន់តែមានសុក្រិតភាព។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣

**គណៈកម្មការទស្សនាវដ្ដីស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា**

# មាតិកា

១. តួនាទីរបស់ព្រះពុទ្ធសាសនានៅក្នុងសង្គម បេក្ខជនបណ្ឌិត **សាម សំបូរ**---------------------------- ១

២. វិចយការតម្លៃអក្សរសិល្ប៍ក្នុងនាដ្យកថាល្ខោនបាសាក់ បេក្ខជនបណ្ឌិត **តាំង វ៉ាំងថង**----------- ១៣

៣. ទស្សនាទានអប់រំចរិយាធម៌តាមរយៈរឿងមហាវេស្សន្តរជាតក បេក្ខជនបណ្ឌិត **យ៉ា សារុន** ------២៤

៤. វិវត្តន៍ និងនិន្នាការអក្សរសិល្ប៍ បេក្ខជនបណ្ឌិត **ឡុច សំបូរ**-------------------------------------- ៣២

៥. រៀនតាមរយៈការលេងនៅមត្តេយ្យសិក្សា បេក្ខជនបណ្ឌិត **ប្រាក់ កុសល**------------------------៤៥

៦. ការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សានៅកម្ពុជា ឆ្នាំ២០០៩- ២០១៨ បេក្ខជនបណ្ឌិត **ឆាយ គឹម សុទ្ធារី** -------------------------------------------------------------------------------------៥១

៧. ឥទ្ធិពលហ្វេសប៊ុកលើឥរិយាបថមន្ត្រីផ្តល់សេវាសាធារណៈរបស់រដ្ឋ និងការអនុវត្តច្បាប់នៅកម្ពុជា បេក្ខជនបណ្ឌិត **ឆាយ សុផល** ----------------------------------------------------------------------៥៩

៨. យន្តការសម្របសម្រួលរបស់អង្គការសហប្រជាជាតិលើវិស័យសិទ្ធិមនុស្សនៅកម្ពុជា បេក្ខជនបណ្ឌិត **ហេង ស៊ីឡេង** -----------------------------------------------------------------------------------៨៤

៩. យុត្តិធម៌ក្នុងប្រព័ន្ធតុលាការកម្ពុជា និស្សិត **ខេង សុវណ្ណតារា** ------------------------------------៩៦

# តួនាទីរបស់ព្រះពុទ្ធសាសនានៅក្នុងសង្គម

បេក្ខជនបណ្ឌិតៈ **សាម សំបូរ**
ជំនាញៈ រដ្ឋបាលសាធារណៈ

អស់រយៈកាលនៃសង្គ្រាម ដែលធ្វើឱ្យប្រទេសកម្ពុជាស្ទើរតែសាបសូន្យនោះ ការស្តាបនាឡើងវិញនូវខឿនសេដ្ឋកិច្ច ជំនឿសាសនា និងសេចក្តីទុកចិត្តចំពោះគ្នាទៅវិញទៅមកពុំមែនជាការងាយស្រួល និងឆាប់ហ័សនោះទេ ។ ការខិតខំព្យាយាមរបស់ខ្មែរទូទាំងប្រទេស ដើម្បីផ្លាស់ពីសង្គ្រាមទៅសន្តិភាព និងអភិវឌ្ឍសង្គមសព្វថ្ងៃនេះ យើងបាននិងកំពុងពង្រឹងសន្តិភាព ដែលទទួលបានក្រោយពីការរៀបចំរបស់អង្គការសហប្រជាជាតិពីភាពឱនថយឈានទៅរកភាពរីកចម្រើន និងភាពរឹងមាំ ។ នៅក្នុងការកសាងសង្គមមួយឱ្យមានការអភិវឌ្ឍន៍ទៅបាន គឺវាអាស្រ័យលើកត្តាជាច្រើន ដូចជាៈកត្តាមនុស្ស កត្តាអប់រំ កត្តាធម្មជាតិ និងកត្តាសាសនាជាដើម ។ យ៉ាងណាមិញ សង្គមមនុស្សទាំងអស់នៅក្នុងពិភពលោកដែលអាចមានការអភិវឌ្ឍន៍ ក៏មានការចូលរួមចំណែកយ៉ាងច្រើនពីកត្តាសាសនាផងដែរបើនិយាយជារួម តែបើនិយាយដោយឡែកវិញសង្គមកម្ពុជាមានការអភិវឌ្ឍន៍មកដល់សព្វថ្ងៃនេះក៏អាស្រ័យលើកត្តាសាសនា ជាពិសេសព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ ។ ព្រះពុទ្ធសាសនា គឺជាមូលដ្ឋានគ្រឹះនៃវប្បធម៌ជាតិ និងសីលធម៌ គតិបណ្ឌិត វិថីជីវិត ដើម្បីជួយដល់ប្រជាជនឱ្យមានជីវិតរុងរឿង សាមគ្គីធម៌ ភារតភាព សុខុមាលភាពសង្គម ការអភិវឌ្ឍន៍ និងការផ្សះផ្សារជាតិ តាមរយៈវិធានអប់រំរបស់ព្រះពុទ្ធសាសនាស្តីពី **សីល សមាធិ បញ្ញា** ។ ព្រះពុទ្ធសាសនាបានចូលរួមវិភាគទានយ៉ាងច្រើនចំពោះសង្គមជាតិស្ទើរតែគ្រប់វិស័យ ជាពិសេសនោះ គឺការរក្សាអភិរក្សសម្បត្តិវប្បធម៌ជាតិឲ្យបានគង់វង្សរហូតមកដល់សព្វថ្ងៃ ។

## ១.១. ស្ថានភាពទូទៅនៃព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនា ជាសាសនាមួយសម្បូរពាក្យប្រៀនប្រដៅដែលប្រកបដោយខ្លឹមសារ និងមានសារៈប្រយោជន៍ មានតម្លៃខ្ពង់ខ្ពស់បំផុត ហើយផ្តល់នូវអត្ថប្រយោជន៍ជាច្រើនឥតគណនាសម្រាប់មនុស្សជាតិក្នុងសកលលោក[១]។ ព្រះពុទ្ធសាសនាមានទិសដៅសំខាន់ដោយធ្វើឱ្យអ្នកប្រតិបត្តិតាមឱ្យឡើងពីហីនភាពទៅកាន់ឧត្តមភាព ពីមូឡ្ហភាព ទៅកាន់បណ្ឌិតភាព ពីទុក្ខភាព ទៅកាន់សុខភាព ឬពីអន្ធបុថុជ្ជន ទៅកាន់កល្យាណបុថុជ្ជន និងពីកល្យាណបុថុជ្ជន ទៅកាន់អរិយជន ។ ចំណែកបុគ្គលដែលមិនកាន់តាម និងប្រតិបត្តិតាមនូវពុទ្ធឱវាទដែលព្រះអង្គសម្តែងទេនោះ ចូរយើងកុំបន្ទោសទៅលើសាសនាថាមិនបានជួយ

---

[១] សម្តេចព្រះមង្គលទេពាចារ្យ អ៊ុម ស៊ុមៈ *ទស្សនព្រះពុទ្ធសាសនា* បោះពុម្ពចែកជាធម្មទាន ព.ស.២៥៤២ គ.ស.១៩៩៩ ទំព័រ១

យើង និងនាំឱ្យមនុស្សក្រីក្រឱ្យសោះ ។ ព្រះពុទ្ធសាសនាមានគុណភាពណាស់អាចដឹកនាំមនុស្សឱ្យគោរពរាប់អានប្រកបដោយគុណគឺសេចក្ដីល្អ ដោយឱ្យសត្វលោកវៀរចាកនូវអំពើបាបគ្រប់យ៉ាង ពោលគឺគោលសំខាន់របស់ព្រះពុទ្ធសាសនាចង់បង្ហាញនូវអ្វីដែលគួរធ្វើ និងអ្វីដែលមិនគួរធ្វើ អ្វីដែលជាមង្គល និងអ្វីដែលជាអពមង្គល នេះជាផ្លូវទៅកាន់ស្ថានសួគ៌និព្វាន នេះជាផ្លូវទៅកាន់អបាយភូមិជាដើម ។ អាស្រ័យដោយការខិតខំព្យាយាមគោរពប្រតិបត្តិរបស់បុគ្គលម្នាក់ៗ (**អត្តាហិ អត្តនោ នាថោ**) គេពិតជាអាចស្វែងរកត្រើយសុកមង្គលជាពិតប្រាកដ ។ ដូច្នេះ ព្រះពុទ្ធគ្រាន់តែជាអ្នកបង្ហាញផ្លូវប៉ុណ្ណោះ (**អក្ខាតារោ តថាគតា**) ព្រះអង្គមិនអាចទទួលបាបជំនួសយើងទេ ឬក៏ជួយយើងឱ្យបានដល់សួគ៌និព្វានបានឡើយមានតែខ្លួនយើងខំប្រតិបត្តិដើរតាមអ្វីដែលព្រះអង្គបានសម្ដែងបង្ហាញនោះទេ ទើបយើងអាចបានដល់សួគ៌និព្វានបាន ។

ព្រះពុទ្ធសាសនា ជាកម្រងជំបូន្មាន ជាកម្រងឱវាទ ជាពុទ្ធវចនៈ ជាទ្រឹស្ដី ជាព្រះធម៌ទាំង ៨៤០០០ ធម្មក្ខន្ធ ជាពុទ្ធដីកាទាំងឡាយទាំងពួងដែលព្រះសក្យមុនីបានសម្ដែងហើយអស់រយៈកាល ៤៥ ព្រះវស្សា ចាប់ពីថ្ងៃដែលព្រះអង្គបានត្រាស់ដឹងរហូតដល់ថ្ងៃទ្រង់ចូលបរិនិព្វាន ។ ព្រះពុទ្ធសាសនាជាសាសនាចង្អុលបង្ហាញប្រាប់ពីហេតុផល ណែនាំអប់រំឱ្យសត្វលោកដើរនៅក្នុងផ្លូវត្រូវ ផ្លូវនៃសេចក្ដីសុខចម្រើនដែលសត្វលោកខ្លួនឯងប្រាថ្នាចង់បាន ព្រះពុទ្ធសាសនាគឺជាផែនទីនៃជីវិតសត្វលោក ឯការប្រព្រឹត្តរបស់សត្វលោកគឺជាការដើរផ្លូវ[២]។ ជារួមឱវាទដែលព្រះពុទ្ធទ្រង់ប្រៀនប្រដៅដោយសង្ខេបមាន៣យ៉ាងគឺ៖

**ទី១- សព្វបាបស្ស អករណំ** ហាមមិនឱ្យធ្វើអំពើបាបទាំងពួង

**ទី២- កុសលស្សូបសម្បទា** ឱ្យបំពេញនូវកុសលឱ្យដល់ព្រម

**ទី៣- សចិត្តបរិយោទបនំ** ឱ្យជម្រះចិត្តរបស់ខ្លួនឱ្យស្អាតផូរផង់ ។

ដោយសារទ្រឹស្ដីព្រះពុទ្ធសាសនាមានទស្សនៈនិងខ្លឹមសារសម្រាប់មនុស្ស និងសង្គមយ៉ាងជ្រាលជ្រៅនេះហើយ ទើបតម្លៃនៃការប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ទោះបីកន្លងទៅជាង២៥៦៧ឆ្នាំហើយក៏ដោយ ក៏ពុទ្ធឱវាទទាំងនោះនៅតែស្ថិតជាមធុរសវាចាដ៏មានប្រសិទ្ធភាព សម្រាប់ការអប់រំសង្គមយើងនាបច្ចុប្បន្នកាលនិងទៅអនាគតកាលយូរអង្វែង ។

## ១.២. ព្រះពុទ្ធសាសនា និងការអប់រំ

ព្រះពុទ្ធសាសនា គឺជាសាសនាមួយដែលមានវ័យចំណាស់ ត្រូវបានបង្កើតឡើងអស់រយៈពេល ២៥៦៧ឆ្នាំកន្លងមកហើយ ដោយមហាក្សត្រ១ព្រះអង្គមានព្រះនាមថា " **សិទ្ធត្ថ** "[៣]ដែលត្រូវបានអ្នកកាន់

---

[២]លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស៖ *ព្រះពុទ្ធសាសនា* ភ្នំពេញ បោះពុម្ព៥០.០០០ក្បាល ចែកជាធម្មទាន ព.ស.២៥៤៦ ទំព័រ១

[៣] ***សិទ្ធត្ថ*** (ន)មានន័យថាអ្នកដែលមានប្រយោជន៍ឬមានបំណងសម្រេចហើយ (ជួនណាត៖ ***វចនានុក្រមខ្មែរ*** បោះពុម្ពគ្រាទី៥ គ.ស .១៩៦៧)

ព្រះពុទ្ធសាសនាគោរពថ្វាយបង្គំជាព្រះពុទ្ធក្រោយព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌៤គឺៈ ទុក្ខសច្ចៈ១ សមុទយសច្ចៈ១ និរោធសច្ចៈ១ និងមគ្គសច្ចៈ១ ហើយព្រះអង្គបានបង្ហាញដល់ពិភពលោកនូវអ្វីៗដែលព្រះអង្គបានត្រាស់ដឹង បង្កើតបានជាព្រះពុទ្ធសាសនាដែលជាប្រភព ឬជាបណ្តុំនៃទស្សនវិជ្ជាជីវិតនិងវិធីសាស្ត្រជាច្រើនជួយអភិវឌ្ឍសក្តានុពល និងភាពជាមនុស្សឱ្យបានបរិបូណ៌ពេញលេញដោយមានការយល់ដឹងនូវធម្មជាតិតាមសភាវៈពិត ។ សាសនានេះបានបង្រៀន និងប្រៀនប្រដៅមនុស្សឱ្យលះបង់នូវ **លោភៈ ទោសៈ មោហៈ** ដែលជាឫសគល់នៃបញ្ហាក្នុងលោក ព្រមទាំងបានបង្រៀននូវមេត្តាធម៌ដែលជាសីលធម៌ដ៏កំពូលរបស់ព្រះពុទ្ធសាសនាដើម្បីរក្សានៅសន្តិភាពបុគ្គល គ្រួសារ សង្គម និងពិភពលោកទាំងមូល[៤]។

### ១.២.១. ការអប់រំអំពីភាគព្វកិច្ចមនុស្សនៅក្នុងសង្គម

មនុស្សគ្រប់គ្នាមានកាតព្វកិច្ចសម្រាប់បំពេញតម្រូវទៅតាមឋានៈនៅក្នុងសង្គម ។ ប្រសិនបើមនុស្សម្នាក់ៗបានបំពេញនៅកាតព្វកិច្ចនោះល្អហើយ ឈ្មោះថាមិនបានធ្វើខ្លួនឱ្យក្លាយជាមនុស្សវិនាសឡើយ ។ វិនាសក្នុងទីនេះមានសេចក្តីថា វិនាសសាបសូន្យចាកតម្លៃ និងគុណធម៌ជាដើម ។ ព្រះពុទ្ធអង្គមិនដែលមានបំណងដាក់កំហិតមនុស្ស ហើយមិនដែលត្រាស់ថា អ្នកទាំងឡាយត្រូវតែធ្វើតាមឱវាទរបស់ព្រះអង្គដោយមិនធ្វើពិសោធន៍ដោយខ្លួនឯងឡើយ ។ ព្រះពុទ្ធអង្គទ្រង់តែងតែលើកទឹកចិត្តដល់មនុស្សឱ្យធ្វើការសង្កេតប្រកបដោយបញ្ញាជាមុនសិន ហើយចាំធ្វើការសម្រេចចិត្តក្នុងការប្រតិបត្តិតាមឱវាទនោះដោយខ្លួនឯង ។ ជាតុដែលបង្កើតសង្គមមានលក្ខណៈចម្រុះ ប្តី និងប្រពន្ធដែលបានរួមរស់ជាមួយគ្នា ត្រូវបានចាត់ទុកថាជាអង្គភាពសង្គមដ៏សំខាន់បំផុតដែលមានទំនាក់ទំនងទៅវិញទៅមក ។ ឪពុកម្តាយនិងកូន គ្រូនិងសិស្ស ស្វាមីនិងភរិយា មិត្តភក្តិនិងមិត្តភក្តិ និយោជកនិងនិយោជិត បរិស័ទនិងបព្វជិត បង្កើតបានជារចនាសម្ព័ន្ធសង្គមមួយ ដែលបង្ហាញពីទំនាក់ទំនងរវាងសមាជិកសង្គមទាំងអស់ដែលមានលក្ខណៈជាបណ្តាញ ដោយសមាជិកនីមួយៗសុទ្ធតែមានកាតព្វកិច្ចប្រទាក់ក្រឡាគ្នាតែម្តង ។ យោងតាមព្រះពុទ្ធអង្គ គ្រប់អង្គភាពសង្គមទាំងអស់តម្រូវឱ្យមានការប្តេជ្ញាចិត្តទ្វេដង ក្នុងការបំពេញនូវកាតព្វកិច្ចទៅវិញទៅមកចំពោះគ្នាទៅវិញទៅមក ។ ដូច្នេះហើយសង្គមមនុស្សត្រូវបានបែងចែកយ៉ាងទូលំទូលាយទាក់ទង នឹងអន្តរទំនាក់ទំនងនៃរចនាសម្ព័ន្ធសង្គមទាំងមូល ។

សង្គមទាំងមូលត្រូវបានបែងចែកជា ៦ យោងតាមកាតព្វកិច្ចសង្គមនៃបុគ្គលម្នាក់ៗដែលបានបែងចែកដោយព្រះពុទ្ធអង្គ[៥] ។ អង្គភាពនីមួយៗដែលមានទំនាក់ទំនងទៅវិញទៅមក តាមរយៈការបែងចែកទិសទាំង៦ ដូចខាងក្រោមៈ

---

[៤] សាស្ត្រាចារ្យ ស៊ិន គង់ៈ *ទស្សនអប់រំព្រះពុទ្ធសាសនា* ការផ្សាយរបស់គ្រឹះស្ថានបោះពុម្ពបំណិនជីវិត ព.ស.២៥៦៥ គ.ស.២០២១ ទំព័រ២

[៥] ភិក្ខុ កែវ សុវណ្ណារ៉ាៈ *តួនាទីមនុស្សក្នុងសង្គមតាមបែបព្រះពុទ្ធសាសនា* ព.ស.២៥៥៦ គ.ស.២០១២ ទំព័រ៦




ទិសទាំង៦ គឺជាតំណាងឱ្យសមាជិកសង្គមទាំង៦ក្រុម ដែលត្រូវបានបែងចែកជា១២មណ្ឌល ហើយសមាជិកសង្គមទាំងនេះត្រូវបំពេញកាតព្វកិច្ចសង្គមរៀងៗខ្លួនដូចខាងក្រោមៈ

**១.ទិសខាងលើ** តំណាងឱ្យទំនាក់ទំនងរវាង បព្វជិតនិងបរិស័ទ

**២.ទិសខាងជើង** តំណាងឱ្យទំនាក់ទំនងរវាង មិត្តភក្តិនិងមិត្តភក្តិ

**៣.ទិសខាងកើត** តំណាងឱ្យទំនាក់ទំនងរវាង ឪពុកម្តាយនិងកូន

**៤.ទិសខាងត្បូង**តំណាងឱ្យទំនាក់ទំនងរវាង គ្រូនិងសិស្ស

**៥.ទិសខាងក្រោម** តំណាងឱ្យទំនាក់ទំនងរវាង និយោជកនិងនិយោជិត

**៦.ទិសខាងលិច**តំណាងឱ្យទំនាក់ទំនងរវាង ស្វាមីនិងភរិយា ។

## ១.២.២. ការអប់រំសីលធម៌ និងសុជីវធម៌

ព្រះពុទ្ធអង្គ គឺជាកំពូលសាស្ត្រាចារ្យដ៏ជំនាញមួយអង្គ ហើយព្រះអង្គយល់យ៉ាងច្បាស់ថា អានុភាពនៃការបង្រៀន គឺអាចធ្វើឲ្យមនុស្សមានការផ្លាស់ប្តូរបែបបទនៃការរស់នៅនិងការប្រព្រឹត្ត ។ ព្រះពុទ្ធបរមគ្រូបានបង្រៀនមេរៀនជីវិតគ្រប់បែបយ៉ាងប្រកបដោយបំណងល្អ និងមេត្តាសាកល ដោយមិនមានរំពឹងចង់បានការតបស្នងពីអ្នកទទួលឡើយ ។

ការអប់រំតាមបែបព្រះពុទ្ធសាសនា បានកើតឡើងនិងវិវត្តតាមវិធីសាស្ត្រ និងដំណាក់កាលផ្សេងៗ សូម្បីតែនៅក្នុងសម័យព្រះពុទ្ធអង្គគង់ព្រះធរមាននៅឡើយ ក៏ព្រះពុទ្ធបានកសាងមូលដ្ឋានដ៏រឹងមាំ ដោយការបង្កើតនូវគណៈសង្ឃដ៏ច្រើនលើសលប់ ហើយព្រះអង្គបានបង្ហាញនៅទស្សនៈជីវិតយ៉ាងច្បាស់ និងពោរពេញដោយខ្លឹមសារសម្រាប់សាវកប្រតិបត្តិតាម ។

យើងអាចសន្និដ្ឋានបានថា ការបង្រៀនរបស់ព្រះសម្មាសម្ពុទ្ធក្នុងសម័យព្រះអង្គគង់នៅបរិយាយពីរូបភាពមួយដ៏លេចធ្លោក្នុងការអប់រំដោយផ្អែកលើកត្តាដ៏សំខាន់ដែលជាប់ពាក់ព័ន្ធជាទូទៅជាមួយប្រព័ន្ធអប់រំសម័យទំនើបនេះគឺ៖

-ព្រះពុទ្ធ គឺជាគ្រូដ៏ផ្ដើម( សត្ថា ទេវមនុស្សានំ )

-ចំនួននៃអ្នកសិក្សាក៏ច្រើនសន្ធឹកសន្ធាប់( សង្ឃ )

-វត្តអារាមនានាដូចជាវត្តជេតវនារាម វត្តវេឡុវនារាមជាដើម គឺជាមជ្ឈមណ្ឌលនៃការសិក្សាដ៏សំខាន់

-លទ្ធផលចុងក្រោយនៃការសិក្សានេះ គឺអ្នកសិក្សាទាំងអស់បានរួចចាកទុក្ខទាំងពួង គឺដល់ព្រះនិព្វាន

-ការអប់រំបាននាំមកនូវការអភិវឌ្ឍន៍បុគ្គល និងសង្គម ហើយជួយស្មារតីយ៉ាងពេញលេញ[៦]។

ពាក្យប្រៀនប្រដៅរបស់ព្រះអង្គមានឥទ្ធិពលលើជីវិតមនុស្សរាប់រយលាននាក់អស់រយៈជាង ២៥៦៧ឆ្នាំមកហើយ ។ ព្រះពុទ្ធសាសនា គឺជាមាគ៌ាជីវិតដែលប្រកបដោយមេត្តាធម៌ ខន្តីធម៌ សច្ចធម៌ និងបំណងល្អក្នុងការនាំមកនូវសន្តិភាព និងភាពស្រុះស្រួលគ្នា ។ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធបរមគ្រូ ត្រូវបានប្រៀបទៅនឹងឱសថសម្រាប់ព្យាបាលជំងឺពិភពលោក ហើយត្រូវបានទទួលការកោតសរសើរស្ញប់ស្ញែងអំពីសំណាក់អ្នកប្រាជ្ញយ៉ាងច្រើនដូចជា៖ លោកសាស្ត្រាចារ្យ Max Muller បានពោលថា ក្រមសីលធម៌របស់ព្រះពុទ្ធ ល្អឥតខ្ចោះបំផុត ដែលពិភពលោកមិនធ្លាប់ស្គាល់ឡើយ ។

## ក. ការគួរសមចំពោះមនុស្សទូទៅ

បាទ ចាស់ អរគុណ សុំទោស ជាពាក្យសំដីគួរសមរបស់ខ្មែរ សម្រាប់ប្រើទូទៅ ។ បាទ ចាស ជាពាក្យសំដីឆ្លើយទទួល ចំណែកពាក្យអរគុណ ជាពាក្យសំដីពោលទៅកាន់អ្នកធ្វើអំពើល្អចំពោះខ្លួន និងសុំទោស ជាពាក្យសំដីពោលទៅកាន់អ្នកដែលខ្លួនបានធ្វើអំពើខុសឆ្គងទៅលើ ។ ការគួរសមទាំងនោះដូចជា៖ ១-ការគោរពឪពុកម្ដាយ ២-ការគោរពព្រះសង្ឃ ៣-ការគោរពគួរសមរវាងបងប្អូនប្រុសស្រី ៤-ការគោរពចំពោះភ្ញៀវ ៥-ការគួរសមរវាងសិស្សនិងសិស្ស ៦-ការគោរពនិងបម្រើជីដូនជីតា ៧-គោរពព្រឹទ្ធាចារ្យ ៨-ការគោរពស្ត្រីភេទ ៩-ការគោរពជនពិការ ជាដើម ។

## ខ. សុជីវធម៌នៃការរស់នៅ

---

[៦] សាស្ត្រាចារ្យ ស៊ិន គង់៖ *ទស្សនអប់រំព្រះពុទ្ធសាសនា* ជ.ឯ.ម ៥៦៥ ទំព័រ១៤៩

សុជីវធម៌ គឺជាច្បាប់សម្រាប់ទូន្មានមនុស្សឱ្យរស់នៅបានសុខស្រួលនៅក្នុងសង្គម ឬច្បាប់គួរសមក្នុងជីវិតរស់នៅ ។ មនុស្សម្នាក់ៗ ត្រូវមានសុជីវធម៌ ព្រោះសុជីវធម៌អាចធ្វើឱ្យយើងមានតម្លៃ សុជីវធម៌ទាំងនោះ ដូចជា៖ ១-នៅទីសាធារណៈ ២-នៅតាមដណ្ដើរ ៣-នៅតាមរោងទស្សនីយភាព ៤-នៅក្នុងទីអារាម ៥-ក្នុងរថយន្តឈ្នួល ៦-ក្នុងការសសេរសំបុត្រ ៧-ការខាកស្ដោះ និងកណ្ដាស់ ៨-គ្រោះថ្នាក់និងសេចក្ដីទុក្ខរបស់អ្នកដទៃ ៩ -សុភាវធម៌ចំពោះអ្នកជិតខាង ជាដើម[៧] ។

## ១.៣. ព្រះពុទ្ធសាសនា និងសេដ្ឋកិច្ច

សេដ្ឋកិច្ចមកពីពាក្យ " **សេដ្ឋ + កិច្ច** " គឺជាសកម្មភាពទាំងឡាយណាដែលដើរឆ្ពោះទៅរកការបង្កើត ការប្រើប្រាស់ ការប្ដូរ និងការបែងចែកផលសម្រាប់តម្រូវការរបស់សង្គមមនុស្ស[៨]។ ព្រះធម៌ទេសនាដែលព្រះពុទ្ធបរមគ្រូ ទ្រង់សម្ដែងអស់រយៈកាល ៤៥ឆ្នាំនេះ បើរាប់ជាធម្មក្ខន្ធមានទាំងអស់ ៨៤០០០ ព្រះធម្មក្ខន្ធ ដែលមានបែងចែកជា៣ ផ្នែកគឺ ព្រះសូត្រ ព្រះវិន័យ និងព្រះអភិធម្ម ដែលមានតម្កល់ទុកក្នុងព្រះត្រៃបិដកទាំង ៣ សព្វថ្ងៃនេះ ។ តាមរយៈការអប់រំមនុស្ស ព្រះពុទ្ធសាសនាបានសង្កត់ធ្ងន់ក្នុងផ្នែកជីវភាពបច្ចុប្បន្ន ។ មានការបញ្ជាក់អំពីទោសនៃសេចក្ដីវិនាសផ្សេងៗ ការប្រកបមុខរបរនាំឱ្យមានទោស កត្តាដែលជាមធ្យោបាយនាំឲ្យទ្រព្យសម្បត្តិចម្រើនគង់វង្ស និងមាគ៌ាជាផ្លូវប្រតិបត្តិដើម្បីរស់នៅក្នុងជីវភាពបច្ចុប្បន្ន ជាដើម ។ តាមការសិក្សាស្រាវជ្រាវ បានបង្ហាញឱ្យឃើញថា ព្រះពុទ្ធសាសនាពុំមែនមានទ្រឹស្ដីសម្រាប់តែមនុស្សអ្នកបួសឬមនុស្សចាស់ និងពុំមែនធ្វើឱ្យអ្នកប្រព្រឹត្តប្រតិបត្តិសម្រាប់តែទៅកាន់ព្រះនិព្វាននោះទេ ។

តាមពិត ព្រះពុទ្ធសាសនាបានលាតត្រដាងនូវមធ្យោបាយ និងណែនាំអប់រំមនុស្សជាពុទ្ធបរិស័ទឱ្យមានសកម្មភាពរស់រវើក ឱ្យយល់ពីការប្រព្រឹត្តទៅនៃជីវភាពបច្ចុប្បន្នរបស់មនុស្សដែលធ្វើឡើងដើម្បីរស់ក្នុងបច្ចុប្បន្ន និងជៀសវាងនូវគ្រប់អំពើអាក្រក់មានការបៀតបៀនអ្នកដទៃឱ្យក្ដៅក្រហាយជាដើម នោះគឺជាវត្ថុបំណងនៃពុទ្ធសាសនា ។ ឯមជ្ឈដ្ឋានដែលរិះគន់ និងចោទប្រកាន់ព្រះពុទ្ធសាសនាប្រកបដោយមាគ៌ាដឹកនាំមនុស្សឱ្យទន់ជ្រាយ ឱ្យទ្រមក់ ឱ្យទឹកចិត្តគ្មានសកម្ម គ្មានសេចក្ដីក្លាហានក្នុងកិច្ចប្រកបការងារដែលជាមូលដ្ឋាននាំឱ្យសេដ្ឋកិច្ចចុះទន់ខ្សោយ រហូតដល់មានតំបន់ខ្លះ ពិសេសសង្គមខ្មែរពុំព្រមយកអ្នកបួសយូរហើយសឹកទៅវិញធ្វើជាកូនប្រសារថែមទៀត ដោយគេមានជំនឿថា ជាមនុស្សទម្រន់ខ្ជិលធ្វើការងារនោះក៏ព្រោះមជ្ឈដ្ឋាននោះពុំបានសិក្សា ពុំបានចេះដឹងទ្រឹស្ដីពុទ្ធសាសនា មិនដឹងវត្ថុបំណងនៃពុទ្ធសាសនា មិនយល់ពីជម្រៅនៃពុទ្ធសាសនាឱ្យបានច្បាស់លាស់ ។ តាមរឿងដែលយើងបានសិក្សារួចមកហើយ យើងពុំដែលឃើញពុទ្ធដីកា អដ្ឋកថា ដីកា ឬយោជនា ត្រង់ប្រការណាមួយល្មមលើកយកមកជាឧទាហរណ៍

---

[៧] កិត្តិវជិរប្បញ្ញោ គូ សុភាព៖ ***សីលធម៌ព្រះពុទ្ធសាសនា*** បោះពុម្ពលើកទី១ ព.ស.២៥៤៨ គ.ស.២០០៤ ទំព័រ១៥

[៨] បណ្ឌិត ក្លាន់ ធុល៖ ***អរិយធម៌ខ្មែរ*** រាជបណ្ឌិត្យសភាកម្ពុជា ព.ស.២៥៦១ គ.ស.២០១៨ ទំព័រ២៣៩

បញ្ជាក់ថាពុទ្ធសាសនាធ្វើឱ្យខ្វះសកម្មភាពក្នុងកិច្ចការឡើយ មានឃើញតែពាក្យទូន្មានប្រៀនប្រដៅមនុស្ស ឱ្យមានសេចក្តីព្យាយាម ប្រឹងប្រែងធ្វើការ តស៊ូអត់ធន់នឹងហេតុការណ៍តាមមុខនាទីរៀងខ្លួនៗ ។

## ១.៣.១. សេដ្ឋកិច្ចនៅក្នុងសង្គមគ្រួសារ

មនុស្សទាំងអស់ត្រូវធ្វើការ គឺការស្វែងរកគ្រឿងឧបភោគ និងបរិភោគ មកបំរើនិងបំពេញសេចក្តីត្រូវការរបស់រាងកាយ គឺអាហារសម្រាប់បំបាត់ការស្រេកឃ្លាន សម្លៀកបំពាក់ សម្រាប់បិទបាំងអត្តភាព ទីលំនៅសម្រាប់ជ្រកកោនបំបាត់ក្តៅត្រជាក់ ការពារភ័យវិបត្តិផ្សេងៗ ហើយនឹងថ្នាំរក្សារោគសម្រាប់បំបាត់ជម្ងឺដែលកើតព្រោះអាស្រ័យរាងកាយនេះ ។ មនុស្សគ្រប់រូបត្រូវតែខំធ្វើការដើម្បីឱ្យបាននូវវត្ថុទាំងនេះមកបម្រុងរក្សាជីវិត ព្រះពុទ្ធសាសនាសំដែងធម៌អប់រំមនុស្សមិនបានរំលងរឿងសដ្ឋកិច្ចនេះដែរ ។ ក្នុងគ្រួសារនីមួយៗដើម្បីរស់រានមានជីវិត ចិញ្ចឹមប្តីប្រពន្ធកូនចៅទាំងក្នុងបច្ចុប្បន្នក៏ដូចជាក្នុងអនាគតនោះ គ្រួសារនោះៗត្រូវធ្វើយ៉ាងណាឱ្យសេដ្ឋកិច្ចរបស់ខ្លួនដើរជានិច្ច ។ ព្រោះថា ជាការចាំបាច់យើងត្រូវចំណាយថវិការបស់យើងរាល់ថ្ងៃតាមសេចក្តីត្រូវការតិច ឬច្រើន ។ ពេលណាមួយប្រសិនបើសេដ្ឋកិច្ចយើងគាំងឈប់លែងដើរ សង្គមគ្រួសារដ៏តូចរបស់យើងក៏ត្រូវដាច់ខ្យល់ស្លាប់ ។ ព្រះពុទ្ធសម្តែងថា សត្វទាំងឡាយរស់បានដោយសារអាហារ ឬ " **សព្វេ សត្តា អាហារដ្ឋិតិកា** "[៩]។

ព្រះពុទ្ធមិនមែនជាអ្នកសេដ្ឋកិច្ចទេ ប៉ុន្តែព្រះអង្គជាគ្រូបង្រៀនមនុស្សឱ្យចេះរៀបចំចាត់ចែងស្វែងរក និងដោះស្រាយបញ្ហាសេដ្ឋកិច្ចតាមរបៀបសាមញ្ញ និងងាយយល់ ។ ថ្វីបើព្រះអង្គបានសម្តែងថា ជីវិតជាទុក្ខក្តីក៏ទ្រង់ទទួលស្គាល់ថា មានសេចក្តីសុខសុភមង្គលខ្លះដែរនៅក្នុងលោកនេះ គ្រាន់តែជាសុភមង្គលក្នុងវដ្តសង្សារមិនអាចស្ថិតស្ថេរជារៀងរហូតទេ ។ ព្រះពុទ្ធទ្រង់បានបង្រៀនមនុស្សឱ្យចេះរក និងចែករំលែកនូវវត្ថុដែលជាតម្រូវការចាំបាច់ ៤យ៉ាង (ចតុប្បច្ច័យ) របស់មនុស្សគឺៈ

-សម្លៀកបំពាក់ (**ចីវរប្បច្ច័យ**)
-អាហារសម្រាប់បរិភោគ (**បិណ្ឌបាតប្បច្ច័យ**)
-លំនៅឋាន ឬទីស្នាក់អាស្រ័យ (**សេនាសនប្បច្ច័យ**)
-គឿងសម្រាប់ថែរក្សាសុខភាព (**គិលានភេសជ្ជប្បច្ច័យ**) ។

ព្រះសម្មាសម្ពុទ្ធលោកសម្តែងថា ដើម្បីរកសេចក្តីសុខក្នុងលោកបានមនុស្សគ្រប់រូបត្រូវតែមានវត្ថុ៤យ៉ាងនេះឱ្យគ្រប់គ្រាន់មិនអាចខ្វះមួយណាឡើយ ។ ម្យ៉ាងទៀត ក្នុងទិដ្ឋធម្មិកត្ថប្រយោជន៍ ទ្រង់បញ្ជាក់ពីហេតុដែលនាំឱ្យសម្រេចប្រយោជន៍ក្នុងបច្ចុប្បន្ន ។

---

[៩] លោក ចាប ពិន៖ *អានិសង្សព្រះ* ផ្សាយចេញពីបណ្ណាគារ ជីង-ប៉ោ-ហួត បោះពុម្ពលើកទី២ ព.ស.២៥១៣ គ.ស.១៩៦៩ ទំព័រ១៥

**ក. ទិដ្ឋធម្មិកត្ថប្រយោជន៍(ប្រយោជន៍បច្ចុប្បន្ន)៤យ៉ាងគឺ៖**

**១- ឧដ្ឋានសម្បទា** ដល់ព្រមដោយសេចក្តីប្រឹងប្រែងរកទ្រព្យ

**២- អារក្ខសម្បទា** ដល់ព្រមដោយការរក្សាទុកនៅទ្រព្យដែលរកបានមកកុំឱ្យសាបសូន្យ

**៣- កល្យាណមិត្តតា** ភាពជាអ្នកសេពគប់មិត្តល្អដើម្បីឱ្យមានភាពចម្រុងចម្រើន

**៤- សមជីវិតា** ការចិញ្ចឹមជីវិតតាមសមគួរដល់កម្លាំងទ្រព្យ គឺមិនត្បិតត្បៀតពេក ។

ធម៌ ៤ ប្រការនេះ ជាបដិបទា នាំឱ្យសម្រេចនូវប្រយោជន៍បច្ចុប្បន្ន គឺយសស័ក្តិ ទ្រព្យសម្បត្តិ និងឥដ្ឋផល ដែលមនុស្សសាមញ្ញតែងប្រាថ្នាចង់បាន[១០] ។

ទិដ្ឋធម្មិកត្ថប្រយោជន៍ទាំង ៤ ប្រការនេះ ជាគោលមូលដ្ឋានសម្រាប់ដោះស្រាយបញ្ហាជីវិតតាមបែបព្រះពុទ្ធសាសនា អ្នកដែលបានដើរតាមវិធីនេះ ឈ្មោះថាបានកែបញ្ហាជីវិតរួចមួយជំហានយ៉ាងធំឆ្ពោះទៅរកសេចក្តីចម្រើន ។

**ខ. អបាយមុខ(ផ្លូវដែលនាំឱ្យវិនាស) ៤ យ៉ាងគឺ៖**

**១. ឥត្ថីធុត្ត** ការលេងស្រី

**២. សុរាធុត្ត** ការលេងសេពគ្រឿងស្រវឹង

**៣. អក្ខធុត្ត** ការលេងល្បែងភ្នាល់ឬល្បែងស៊ីសង

**៤. បាបមិត្ត** សេពគប់មនុស្សអាក្រក់ជាមិត្រ ។

ធម៌ទាំង ៤ យ៉ាងនេះ ព្រះអង្គទ្រង់សម្តែងដើម្បីប្រដៅមនុស្សឱ្យចេះប្រយ័ត្ន មិនបណ្តោយខ្លួនឱ្យធ្លាក់ទៅក្នុងការធ្វើទ្រព្យសម្បត្តិឱ្យអន្តរាយ ។ មនុស្សម្នាក់ៗ រហូតដល់មនុស្សទូទាំងប្រទេស សូម្បីមានទ្រព្យយសស័ក្តិច្រើនយ៉ាងណាក៏ដោយ បើនិយមតែស្រី, សុរា, ល្បែងភ្នាល់, ហើយនឹងស្ម័គ្របក្សពួកជាមួយមនុស្សខូច មិនយូរប៉ុន្មានទេគង់ឃើញផលនៃសេចក្តីវិនាស ព្រោះហេតុទាំង ៤ យ៉ាងនេះ ត្រូវចាយវាយទ្រព្យយ៉ាងច្រើនផង ខាតទាំងពេលវេលាផង ។ ឧទាហរណ៍ ដូចជាបុរសមានចិត្តឈ្លក់នឹងស្ត្រីណាមួយហើយ តែងទៅរកគេជានិច្ច យកទព្យទៅបម្រើគេ យូរៗទៅអាចដល់ថ្នាក់លះការងារចោល ទីបំផុតរកសេចក្តីចំរើនក្នុងមុខតំណែងមិនបាន បើខ្លាំងទៅទៀតអាចដេញពីមុខតំណែងចេញ ។ ទ្រព្យ យសស័ក្តិកេរ្តិ៍ឈ្មោះរមែងអន្តរាយទៅតាមការប្រព្រឹត្តនោះៗទីបំផុតក្លាយខ្លួនជាមនុស្សអស់សេចក្តីសង្ឃឹមក្នុងជីវិត ។

## ១.៣.២. សេដ្ឋកិច្ចនៅក្នុងសង្គមជាតិ

ក្នុងគ្រួសារដ៏តូចមួយ ឬក្នុងប្រទេសនីមួយៗ រហូតដល់ពិភពលោកទាំងមូល ដែលនឹងរស់រានមានជីវិតទៅបាន ក៏ដោយអាស្រ័យនូវសេដ្ឋកិច្ចនេះដែរ ។ គ្រួសារដែលគ្មានសេដ្ឋកិច្ច ប្រទេសដែលគ្មានសេដ្ឋកិច្ច គឺជាគ្រួសារ ជាប្រទេសរស់នៅក្នុងទាសភាពនៃអ្នកដទៃ ឬប្រទេសដទៃ ។ ប្រទេសទាំងឡាយក្នុង

---

[១០] ព្រះមហា ជា សុខះ *ពុទ្ធសាសនា(ធ្វើប្រយោជន៍ដល់សង្គមមនុស្សអ្វីដែរ?)* បោះពុម្ពគ្រាទី២ ព.ស.២៥៤១ គ.ស.១៩៩៧ ទំព័រ៦

សកលលោកដែលបង្កបង្កើតជាភ្លើងសង្គ្រាម ចម្បាំងរាំងជលរវាងគ្នានឹងគ្នាក៏ព្រោះតែបញ្ហាសេដ្ឋកិច្ច ។ តើសេដ្ឋកិច្ចក្នុងសង្គមខ្មែរមានលក្ខណៈបែបណា? ប្រទេសកម្ពុជា ជាប្រទេសកាន់ព្រះពុទ្ធសាសនា ។ ប្រជាពលរដ្ឋភាគច្រើនលើសលប់ជាពុទ្ធសាសនិក របរអាជីវកម្មនៃពលរដ្ឋខ្មែរភាគច្រើនគឺកសិកម្ម ព្រោះប្រទេសកម្ពុជាមានស្ថានភាពដីជាប្រភពនៃកសិកម្ម ។ ឯឧស្សាហកម្ម និងពាណិជ្ជកម្ម ពលរដ្ឋកម្ពុជាមិនសូវប្រកបទេ គឺច្រើនតែធ្លាក់ទៅលើដៃនៃជនជាតិបរទេសមានជនជាតិចិនជាដើម ។ ជាការពិតណាស់ នៅគ្រប់ទីប្រជុំជននានា ទោះក្នុងទីក្រុងធំៗក៏ដូចជាទីជនបទ យើងឃើញមានសុទ្ធតែអាណិកជនជាតិចិនកាន់កាប់មុខរបរពាណិជ្ជកម្ម ។ ឯពលរដ្ឋកម្ពុជាសុទ្ធសាធ មានចំនួនតិចតួចណាស់ដែលប្រកបរបរប្រភេទនេះ ។ យើងអាចដឹងបានថា សេដ្ឋកិច្ចជាតិដែលចម្រើនលូតលាស់ ឬ អន់ថយ អាស្រ័យទៅលើកត្តាច្រើនយ៉ាងមានជាអាទិ ដូចជា បញ្ហារបបគ្រប់គ្រង បញ្ហាអប់រំ បញ្ហាសង្គ្រាម បញ្ហានយោបាយអាណានិគមនិយម បញ្ហានយោបាយសេដ្ឋកិច្ច ជាដើម[១១]។

**-ដើម្បីឱ្យសេដ្ឋកិច្ចដើរគ្រួសារនីមួយៗឬជាតិនីមួយៗ ត្រូវបំពេញលក្ខណៈ៣យ៉ាងគឺ៖**

**១-មានសកម្មភាព**

**២-មានមូលធន**

**៣-មានគំនិតប្រាជ្ញា**

ប្រទេសទាំងឡាយជាច្រើនក្នុងសកលលោក គេបានគោរពកាន់ជឿតាមព្រះពុទ្ធសាសនាដែរ ប៉ុន្តែសេដ្ឋកិច្ចរបស់គេហាក់ដូចជាមានដំណើរលឿនជាងសេដ្ឋកិច្ចខ្មែរ ។ ត្រង់នេះយើងឃើញប្រទេសជប៉ុនដែលជាប្រទេសកាន់ពុទ្ធសាសនាដូចយើងដែរ តែសេដ្ឋកិច្ចរបស់គេវិវត្តិទៅដល់ដំណាក់កាលបំផុត ។ ប្រមាណជាង ២០ឆ្នាំ ក្រោយសង្គ្រាមលោកលើកទី២ប៉ុណ្ណោះ ជនជាតិជប៉ុនបានក្លាយទៅជាជនជាតិលេខ ១ ក្នុងទ្វីបអាស៊ីក្នុងវិស័យសេដ្ឋកិច្ច ។ ព្រោះអ្វី? ព្រោះសង្គមបរិយាកាសជប៉ុន នយោបាយសេដ្ឋកិច្ចជប៉ុន ការអប់រំជនជាតិជប៉ុន បានតម្រូវឱ្យពលរដ្ឋរបស់គេស្រឡាញ់ការងារ ចូលចិត្តមុខរបរបង្កើតផល ។ តាមពិតទឹកដីនិងសម្បត្តិធម្មជាតិជប៉ុនមានលក្ខណៈពុំប្រសើរជាងសម្បត្តិធម្មជាតិខ្មែរយើងប៉ុន្មានទេ ប៉ុន្តែដោយគេអនុវត្តនយោបាយសេដ្ឋកិច្ចទើបផលិតផល កសិកម្មក្តី ផលិតផលឧស្សាហកម្មក្តី ពាណិជ្ជកម្មក្តី បានទទួលភាគផលយ៉ាងច្រើនជាអតិបរិមាអាចបម្រើសេចក្តីត្រូវការនៃជនជាតិគេបានយ៉ាងគ្រប់គ្រាន់ ហើយបញ្ចេញទៅលក់នៅបរទេសយ៉ាងច្រើនលើសលប់ថែមទៀត ដែលជាហេតុធ្វើឱ្យសេដ្ឋកិច្ចរបស់គេរិតតែចម្រើនរុងរឿងគ្រប់វិស័យ តាមន័យនេះយើងឃើញថា ព្រះពុទ្ធសាសនាប្រាកដជាពុំមានទ្រឹស្តីទំនាស់ក្នុងការលូតលាស់នៃសេដ្ឋកិច្ចទេ ។ យើងដឹងថា គ្រប់សាសនាទាំងអស់សុទ្ធតែមានវត្ថុបំណងដើម្បីស្វែងរកសុខសន្តិភាព និងសេចក្តីចម្រុងចម្រើនដល់សត្វលោកទាំងអស់ ។ ប្រទេសកម្ពុជាបានប្រកាសខ្លួនថា

---

[១១] លោក ងារ គាន៖ ***ពុទ្ធសាសនានិងសេដ្ឋកិច្ច*** ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥១៨ គ.ស.១៩៧៤ ទំព័រ២៦

ជាប្រទេសកាន់ព្រះពុទ្ធសាសនា ។ ទាំងច្បាប់រដ្ឋធម្មនុញ្ញចែងថា "**ពុទ្ធសាសនាជាសាសនាសម្រាប់រដ្ឋ**" ។ យើងអាចចោទសួរបានថា តើពលរដ្ឋខ្មែរបានគោរពត្រឹមត្រូវហ្មត់ចត់តាមទ្រឹស្តីពុទ្ធសាសនាហើយឬនៅ? យើងឆ្លើយបានភ្លាមថា (នៅឡើយទេ) ។ ព្រោះអ្វី? ព្រោះតាមការសង្កេតរបស់យើង ឃើញពលរដ្ឋខ្មែរភាគច្រើនប្រកបដោយ លោភៈ ទោសៈ មោហៈ រហូតដល់ទៅប្រព្រឹត្តអំពើអបាយមុខផ្សេងៗ ឆបោកទ្រព្យសម្បត្តិអ្នកដទៃ ខ្ជិលច្រអូស ធ្វេសប្រហែស មិនប្រកបការងារ ចូលចិត្តប្រព្រឹត្តល្បែងពាលាដែលជាប្រធាននៃសេចក្តីវិនាសផ្សេងៗជាដើម ។ យើងឃើញគោលការណ៍ ៣ នៃរដ្ឋាភិបាលសាធារណៈរដ្ឋគឺៈ

**-ប្រជារាស្ត្រអ្នកធ្វើ**

**-អ្នកបច្ចេកទេសបង្ហាញផ្លូវ**

**-រដ្ឋាភិបាលជួយឧបត្ថម្ភ**

គោលការណ៍ ៣ នេះ ប្រសិនបើអនុវត្តបានពិតប្រាកដតទៅយើងសង្ឃឹមថា សេដ្ឋកិច្ចខ្មែរនឹងពុំចាញ់សេដ្ឋកិច្ចនៃជនជាតិដទៃឡើយ ។ យើងយល់ថា ប្រសិនបើពលរដ្ឋខ្មែរគោរពតាមទ្រឹស្តីពុទ្ធសាសនាឱ្យបានហ្មត់ចត់ហើយសង្គមខ្មែរបានផ្តល់មធ្យោបាយគ្រប់គ្រាន់ តាមបច្ចេកទេសនៃវិទ្យាសាស្ត្រទំនើបផងនោះ សេដ្ឋកិច្ចខ្មែរប្រាកដជាបានទទួលការរីកចម្រើនលូតលាស់ដូចអារ្យប្រទេសជាមិនខាន[១២]។

សេចក្តីរៀបរាប់ដូចខាងលើនេះ បង្ហាញឱ្យយើងស្គាល់នូវលក្ខណៈពុទ្ធសាសនាដែលទាក់ទងទៅនឹងសេដ្ឋកិច្ចដែលអាចយើងធ្វើសេចក្តីសន្និដ្ឋានបានថាៈ

-ព្រះពុទ្ធសាសនា ជាសាសនាបង្ហាញហេតុផលច្បាស់លាស់ក្នុងការរស់នៅនៃមនុស្សបច្ចុប្បន្នក៏ដូចជាក្នុងការអប់រំមនុស្សដើម្បីប្រយោជន៍អនាគត ។

-ការថយចុះ និងឱនភាពនៃសេដ្ឋកិច្ច គឺប្រាកដជាអ្នកកាន់ពុទ្ធសាសនាពុំបានគោរពឱ្យបានហ្មត់ចត់ដល់កម្រិតច្បាប់សាសនាទេ ។

ដូច្នេះ ការថយចុះនៃសេដ្ឋកិច្ច គឺបណ្តាលមកពីបញ្ហាសង្គម បរិយាកាស របបគ្រប់គ្រង នយោបាយសេដ្ឋកិច្ច ការអប់រំមនុស្សនៃប្រទេសនីមួយៗ ឬគ្រួសារនីមួយៗដែលពុំព្រមអនុវត្តតាមមាគ៌ាពុទ្ធសាសនា ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះរួចមក យើងឃើញថា ព្រះពុទ្ធសាសនាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍប្រទេសជាតិ ។ គុណតម្លៃនៃព្រះពុទ្ធសាសនា និងវិសាលភាពនៃការចូលរួមអភិវឌ្ឍសង្គមខ្មែរនេះពិតជាធ្វើឱ្យមានភាពស្ញប់ស្ញែង និងរកអ្វីប្រៀបផ្ទឹមពុំបានឡើយ ។ តួនាទីវត្តអារាម និងព្រះសង្ឃតាំងពីសម័យបុរាណរហូតមកដល់បច្ចុប្បន្ន នៅតែដើរតួយ៉ាងសំខាន់ចំពោះ

---

[១២] លោក ដារ គានៈ *ពុទ្ធសាសនានិងសេដ្ឋកិច្ច* ដ.ឯ.ម ទំព័រ៤១

ការអភិវឌ្ឍន៍សង្គមជាតិលើគ្រប់វិស័យ ជាពិសេសការចូលរួមអប់រំសីលធម៌សង្គម ដោយឈរលើគោលការណ៍ធ្វើយ៉ាងណាឱ្យពុទ្ធបរិស័ទ និងប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈទាំងអស់ចេះរស់នៅក្នុងសាមគ្គីភាព ភាតរភាព រវាងគ្នានឹងគ្នា មានមេត្តាធម៌ ហើយការរស់នៅក្នុងជីវភាពប្រចាំថ្ងៃ ត្រូវប្រាសចាកអំពើអបាយមុខ មាន ស្រី ស្រា ល្បែងពាលា សេពគប់បាបមិត្ត និងប្រកបដោយកតញ្ញូតាធម៌ ការដឹងគុណចំពោះមាតាបិតា គ្រូបាអាចារ្យ អ្នកដឹកនាំប្រទេសជាតិជាដើម ។ ជារួម ធ្វើយ៉ាងណាឱ្យប្រទេសជាតិស្ថិតនៅក្នុងសន្តិភាព វឌ្ឍនភាព ដែលជាបំណងប្រាថ្នារបស់មនុស្សគ្រប់រូប ។ ព្រះពុទ្ធសាសនា ពិតជាបាននាំមកនូវប្រយោជន៍យ៉ាងច្រើនមិនអាចកាត់ថ្លៃបាន ។ យ៉ាងណាមិញសង្គមខ្មែរបច្ចុប្បន្ន ចាំបាច់ណាស់នូវការកសាងវប្បធម៌សន្តិភាព ស្របតាមគោលការណ៍អប់រំព្រះពុទ្ធសាសនា ។ ជាពិសេសសម្រាប់យុវជនខ្មែរនាពេលបច្ចុប្បន្ន ត្រូវការអប់រំដើម្បីអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់ខ្លួនឱ្យមានសីលធម៌ ជាសសរទ្រូងរបស់ប្រទេសជាតិ ។

# គន្ថនិទ្ទេស

## ក-ឯកសារជាភាសាខ្មែរ

១. សម្តេចព្រះមង្គលទេពាចារ្យ អ៊ុម ស៊ុម៖ ***ទស្សនព្រះពុទ្ធសាសនា*** បោះពុម្ពចែកជាធម្មទាន ព.ស.២៥៤២ គ.ស.១៩៩៩

២. លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស៖ ***ព្រះពុទ្ធសាសនា*** ភ្នំពេញ បោះពុម្ព៥០.០០០ក្បាល ចែកជាធម្មទាន ព.ស.២៥៤៦

៣. ជួន ណាត៖ ***វចនានុក្រមខ្មែរ*** ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពគ្រាទី៥ ព.ស.២៥១១ គ.ស.១៩៦៧

៤. សាស្ត្រាចារ្យ ស៊ិន គង់៖ ***ទស្សនវិជ្ជាអប់រំព្រះពុទ្ធសាសនា*** ការផ្សាយរបស់គ្រឹះស្ថានបោះពុម្ពបំណិនជីវិត ព.ស.២៥៦៥ គ.ស.២០២១

៥. ភិក្ខុរតនឃោសកោ កែវ សុវណ្ណារ៉ា៖ ***តួនាទីមនុស្សក្នុងសង្គមតាមបែបព្រះពុទ្ធសាសនា*** ព.ស.២៥៥៦ គ.ស.២០១២

៦. ភិក្ខុវជិរប្បញ្ញោ គូ សុភាព៖ ***សីលធម៌ព្រះពុទ្ធសាសនា*** បោះពុម្ពលើកទី១ វត្តនិគ្រោធវ័ន " គល់ទទឹង " ព.ស.២៥៤៨ គ.ស.២០០៤

៧. បណ្ឌិត ក្ដាន់ ធុល៖ ***អរិយធម៌ខ្មែរ*** រាជបណ្ឌិត្យសភាកម្ពុជា ព.ស.២៥៦១ គ.ស.២០១៨

៨. ចាប ពិន៖ ***អានិសង្ស៣០*** ផ្សាយចេញពីបណ្ណាគារ ជីង-ប៉ៅ-ហួត បោះពុម្ពលើកទី២ ព.ស.២៥១៣ គ.ស.១៩៦៩

៩. ព្រះមហា ជា សុខ៖ ***ពុទ្ធសាសនា ( ធ្វើប្រយោជន៍ដល់សង្គមមនុស្សអ្វីដែរ? )*** ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពគ្រាទី២ ព.ស.២៥៤១ គ.ស.១៩៩៧

១០. លោក ជារ គាន៖ ***ពុទ្ធសាសនានិងសេដ្ឋកិច្ច*** ភ្នំពេញ ការផ្សាយពីពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥១៨ គ.ស.១៩៧៤ ។

# វិចយការតម្លៃអក្សរសិល្ប៍ក្នុងនាដ្យកថាល្ខោនបាសាក់

បេក្ខជនបណ្ឌិតៈ **តាំង វ៉ាំងថង**

## ១. លំនាំដើម

នាដ្យកថាល្ខោនបាសាក់ បានកសាងតួសម្តែងនីមួយៗ ឱ្យមានការរួមសម្តែងយ៉ាងសកម្ម ដើម្បីបង្កើតបានជានាដ្យកថាល្ខោនបាសាក់មួយពោរពេញទៅដោយទស្សនិយភាព។ ការរួមបញ្ចូលសិល្បៈប្រពៃណី របាំ ចម្រៀង តន្ត្រីក្នុងនាដ្យកថាល្ខោនបាសាក់ ដែលដកស្រង់ពីស្នាដៃអក្សរសិល្ប៍បានបង្ហាញពីតម្លៃអក្សរសិល្ប៍ ក្នុងការរៀបរៀងរឿង រៀបរៀងនាដ្យកថាល្ខោនបាសាក់។ ចំពោះទស្សនិកជនវិញ ពេលទស្សនាល្ខោនបាសាក់ គឺគេនឹងបានទស្សនាអ្វីដែលជាការសម្តែងយ៉ាងប្រមូលផ្តុំ គឺទស្សនាល្ខោនបាសាក់ បានទស្សនារបាំបុរាណផង របាំប្រជាប្រិយផង បានស្តាប់ចម្រៀងប្រជាប្រិយផង អាយ៉ៃឆ្លងឆ្លើយផង។ល។ ដូច្នោះហើយការសម្តែងល្ខោនបាសាក់ ក៏បានក្លាយជាអាហារខាងស្មារតីមួយមុខមិនអាចខ្វះបានសម្រាប់ប្រជាទស្សនិកជននិយាយរួម ពិសេសគឺជនរួមជាតិខ្មែរតំបន់វាលរាបទន្លេមេគង្គ។

នាដ្យកថាល្ខោនបាសាក់ដកស្រង់ពីស្នាដៃពីអក្សរសិល្ប៍ បានរួមចំណែកក្នុងការបញ្ចាំងបង្ហាញ និងលើកស្ទួយការផ្សព្វផ្សាយតម្លៃអក្សរសិល្ប៍ទៅសព្វទិសទី។ បច្ចុប្បន្ននេះខ្លឹមសារនាដ្យកថាល្ខោនបាសាក់ ដែលដកស្រង់ពីស្នាដៃអក្សរសិល្ប៍ត្រូវបានស្តារយ៉ាងទូលំទូលាយដើម្បីកម្លាយស្នាដៃអក្សរសិល្ប៍ឱ្យទៅជានាដ្យកអក្សរសិល្ប៍ប្រកបដោយសិល្បវិធី ដើម្បីផ្ញើសារតម្លៃអក្សរសិល្ប៍ដល់ទស្សនិកជន ដោយមិនចាំបាច់អានអត្ថបទអក្សរសិល្ប៍ ដែលសមស្របនឹងសម័យកាលបច្ចេកវិទ្យា៤.០នេះ។ កត្តាទាំងអស់ក្នុងសិល្បវិធីនៃអក្សរសិល្ប៍ គឺជាមូលដ្ឋានសម្រាប់ពង្រីកសិល្បៈសម្តែង ដែលមានលក្ខណៈរួមបញ្ចូលរវាងអត្ថបទអក្សរសិល្ប៍និងសិល្បវិធីសម្តែង បានរួមចំណែកឱ្យសិល្បៈល្ខោនបាសាក់បង្កើតបានទស្សនិយភាពសិល្បៈ ផ្សព្វផ្សាយខ្លឹមសារ ផ្សព្វផ្សាយតម្លៃអក្សរសិល្ប៍ឆ្លើយតបនឹងតម្រូវការនិងក្តីបំណងនៃ ការទស្សនារបស់ប្រជាទស្សនិកជនទូទៅ។

## ២. លើកកម្ពស់ស្មារតីមនុស្សធម៌ និងជំនឿសាសនា

តម្លៃមនុស្សធម៌ក្នុងនាដ្យកថាល្ខោនបាសាក់ តែងបានលើកឡើងនូវការអាណិតស្រឡាញ់រវាងមនុស្សនិងមនុស្ស បានបង្ហាញក្នុងនាដ្យកថាល្ខោនបាសាក់ដូចជាពិធីបូជាយញ្ញ សបញ្ជាក់អំពីទឹកចិត្តអាណិតស្រឡាញ់មនុស្សស្លូតត្រង់ដែលមិនអាចយកជីវិតមនុស្ស ដើម្បីទៅប្តូរយកសេចក្តីសុខរបស់សាសនា ឬ បុគ្គលណាមួយបានឡើយ។

តម្លៃមនុស្សធម៌ក៏នៅបានបង្ហាញតាមរយៈសកម្មភាពបរិច្ចាគទាន តួយ៉ាងដូចជានាដ្យកថាល្ខោនបាសាក់រឿងព្រះបាទវេស្សន្តរជាដើម។ ចាប់តាំងពីឆាកដំបូងនៃនាដ្យកថាបានបង្ហាញពីការអត់ឃ្លានរបស់ប្រជានុរាស្ត្រ និងការប្រជែងដណ្តើមតំណែង ទ្រព្យសម្បត្តិនៃមន្ត្រីរាជការ និងមនុស្សទាំងឡាយក្នុងសង្គម ជាហេតុបណ្តាលឱ្យព្រះបាទវេស្សន្តរ សម្រេចចិត្តតបនូវតម្រូវការនោះ ដោយការបរិច្ចាគទានដោយឥតញញើត ព្រះអង្គបរិច្ចាគជូនមនុស្សទាំងក្នុង

និងក្រៅរាជវាំងដោយមិនរើសអើងបុគ្គលណាមួយឡើយ រហូតដល់ព្រះអង្គត្រូវប្រជានុរាស្ត្រមានចិត្តខឹង ដោយសារព្រះអង្គបានដាក់ទានទាំងដំរីនាគេន្ទ្រ ដែលជាសត្វតំណាងប្រចាំព្រះនគរ ទីបំផុតគឺដល់ត្រូវបំបរបង់បណ្តេញឱ្យចេញទៅនៅក្នុងព្រៃជ្រៅ។ ព្រះអង្គសុខចិត្តបួសជាឥសីក្នុងព្រៃជ្រៅតែម្នាក់ឯង ដោយមានការបម្រើព្រឹកល្ងាចពីអគ្គមហេសីរបស់ព្រះអង្គ។ ក្រោយមកព្រះអង្គក៏បានដាក់ទានកូនទាំងពីររបស់ព្រះអង្គ ទៅឱ្យស្វាមជូជកទៀត នេះបញ្ជាក់ពីទឹកចិត្តអាណិតស្រឡាញ់មនុស្សរបស់ព្រះអង្គដោយស្មោះ អស់ពីហឫទ័យ។ ឆ្លងតាមរយៈនាដ្យកថានេះ អ្នករៀបរៀងបានបញ្ចូលនូវបំណងប្រាថ្នារបស់ខ្លួនក៏ដូចជាបំណងប្រាថ្នារបស់ប្រជានុរាស្ត្រពីក្តីប្រាថ្នាក្នុងជីវភាពរស់នៅប្រកបដោយសមភាព មិនមានការអត់ឃ្លានឃារឃើ និងសង្គមមានសន្តិភាពសុភមង្គល។

នាដ្យកថាដែលមានទាក់ទងនឹងទំនាស់រវាងមនុស្សនឹងយក្ស ប្តីនឹងប្រពន្ធ បងប្អូននឹងគ្នា តែងទទួលបានការសង្គ្រោះពីព្រះមុនីតាឥសី។ ក្នុងសតិអារម្មណ៍នៃប្រជាជនខ្មែរយើងព្រះមុនីតាឥសីគឺជាអាទិទេពដ៏អាថ៌កំបាំង តែមានអត្ថន័យសំខាន់ក្នុងការរស់នៅរបស់ប្រជាជន រូបភាពឥសីជានិម្មិតរូបការអប់រំមនុស្សឱ្យរស់នៅប្រកបដោយសុចរិតធម៌ អប់រំមនុស្សឱ្យរស់នៅប្រកាន់យកកុសលធម៌ជៀសវាងអំពើបាបទាំងពួង ចេះជួយសង្គ្រោះគ្នាទៅវិញទៅមកក្នុងសហគមន៍ ដើម្បីឈានទៅរកការរស់នៅប្រកបដោយសុខសន្តិភាពនិងសុភមង្គល។ នាដ្យកថាប្រភេទនេះ តែងបញ្ចប់រឿងដោយដំណោះស្រាយទំនាស់តាមវិធីមនុស្សធម៌ បង្ហាញពីទស្សនៈកម្មផល "ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់" ប្រកបដោយតម្លៃមនុស្សធម៌ខ្ពង់ខ្ពស់ផង ព្រមទាំងលើកកំហុសសង្គមសក្តិភូមិផង។

ប្រវត្តិនៃប្រជាជនខ្មែរនិយមកាន់សាសនាធំៗពីរ សុទ្ធតែមានលំហូរពីប្រទេសឥណ្ឌា។ ដំណាក់កាលផ្លាស់ប្តូរជំនឿសាសនាពីព្រហ្មញ្ញសាសនា មកពុទ្ធសាសនាសតវត្សទី៨។ ជំនឿសាសនាបានបង្ហាញច្បាស់ក្នុងនាដ្យកថាល្ខោនបាសាក់រឿង រូបចម្លាក់ថ្មកែវ ឆ្លងតាមរយៈពិធីបូជាយញ្ញចំពោះអាទិទេពសាសនាព្រាហ្មណ៍។ ប៉ុន្តែពិធីទាំងនោះទទួលបានការមិនពេញចិត្ត និងមានការជំទាស់យ៉ាងខ្លាំងក្លាពីប្រជានុរាស្ត្រ រហូតដល់ប្រជានុរាស្ត្រមិនព្រមស្តាប់ និងអនុវត្តអ្វីដែលជាការបង្គាប់របស់ស្តេច។ ការបដិសេធរបស់ប្រជានុរាស្ត្រ បានបណ្តាលឱ្យព្រះរាជាទ្រង់ខ្ញាល់ជាខ្លាំង ហើយបានក្លាយជាស្តេចមួយអង្គដែលមិនប្រកបដោយទសពិធរាជធម៌ បានដាក់និងចែងច្បាប់ ប្រសិនបើមានប្រជានុរាស្ត្រ ឬបុគ្គលណាមិនអនុវត្ត ឬប្រឆាំងជំទាស់នឹងពិធីបូជាយញ្ញ នឹងមានទោសប្រហារជីវិត។ ការប្រឆាំងជំទាស់របស់ប្រជានុរាស្ត្រចំពោះពិធីបូជាយញ្ញ បញ្ជាក់ពីបំណងលុបបំបាត់ពិធីនៃសាសនាព្រាហ្មណ៍ ដែលមិនសមស្របនឹងសម័យកាលបច្ចុប្បន្ននោះ។ នាដ្យកថានេះបានបញ្ជាក់ពីការផ្លាស់ប្តូរជំនឿសាសនាក្នុងសង្គមខ្មែរពីសាសនាព្រាហ្មណ៍មកកាន់ពុទ្ធសាសនាវិញ។

ជំនឿសាសនារបស់ប្រជាជនខ្មែរ តែងបានបង្ហាញច្បាស់តាមរយៈនាដ្យកថាល្ខោនបាសាក់ ដែលដកស្រង់ពីស្នាដៃអក្សរសិល្ប៍ពុទ្ធនិយម។ នាដ្យកថាល្ខោនបាសាក់ប្រភេទនេះ គឺជាស្នាដៃដែលលើកឡើងពីការសេជាតិរបស់ព្រះសម្មាសម្ពុទ្ធ កាលទ្រង់យោងយកកំណើតជាព្រះ

ពោធិសត្វដើម្បីបំពេញបារមី នាដ្យកថាទាំងនេះ ច្រើនតែបង្កប់នូវទស្សនៈអប់រំតាមដំបូន្មាននៃព្រះពុទ្ធសាសនា ជាពិសេស គឺទស្សនៈកម្មផលដូចជានាដ្យកថារឿង "សព្វសិទ្ធ" ត្រឹមតែពាក្យសច្ចៈរបស់សត្វសកុណីមុនពេលស្លាប់ក៏បានក្លាយជាចំណងមេត្រីភាពក្នុងជាតិបន្ត។ តាមរយៈនាដ្យកថានេះបានអប់រំមនុស្សជាតិរស់នៅត្រូវប្រកាន់យកភាពស្មោះត្រង់ក្នុងជាតិនេះ ហើយជាតិបន្តទៀតនឹងអាចជួបជុំផងដែរ។

ជំនឿសាសនាក្នុងសង្គមខ្មែរតាមរយៈនាដ្យកថាល្ខោនបាសាក់ បានស្តែងឡើងយ៉ាងច្បាស់លាស់ក្នុងរាល់ស្រទាប់វណ្ណៈនៃសង្គម។ បុរាណសម័យ យើងកម្រប្រទះឃើញនូវការចងស្ពានមេត្រីរវាងមនុស្សជាអ្នកមានស្តុកស្តម្ភ ជាមួយនឹងអ្នកក្រខ្សត់ទុគ៌ត។ កាលដែលមានជំនឿសាសនាចូលមកក្នុងសង្គមរួច បំណងប្រាថ្នានៃសមភាពសង្គមក៏បានកើតឡើងជាបណ្តើរ មនុស្សក៏បានរួចផុតពីនឹមវណ្ណៈសង្គម បញ្ជាក់ដោយការចងស្ពានមេត្រីរវាងមនុស្សអ្នកមាននឹងអ្នកក្រ មន្ត្រី ឬត្រកូលក្សត្រ ជាមួយប្រជានុរាស្ត្រសាមញ្ញ ដោយទស្សនៈសម្គាល់ថា ទោះជាស្ថិតនៅក្នុងវណ្ណៈណាក៏ដោយក៏មនុស្សគ្រប់រូបសុទ្ធតែមានសិទ្ធិដូចគ្នាគឺមានសិទ្ធិរស់ មានសិទ្ធិទទួលសុខសន្តិភាព និងសុភមង្គលរបស់ពួកគេ។

ស្មារតីមនុស្សធម៌ ជំនឿសាសនាតាមរយៈនាដ្យកថាល្ខោនបាសាក់ ដែលដកស្រង់ពីស្នាដៃអក្សរសិល្ប៍ នៅទាំងឆ្លុះបញ្ចាំងទស្សនៈអប់រំមនុស្សពីចំណងមិត្តភាពសាមគ្គីភាពរវាងមនុស្សនឹងមនុស្សក្នុងសង្គម អប់រំមនុស្សឱ្យចេះប្រមូលផ្តុំកម្លាំងរួមគ្នាធ្វើបដិវត្ត ដើម្បីប្រឆាំងនឹងអំពើឃោរឃៅ ការប្រព្រឹត្តរបស់ពួកមន្ត្រីសក្តិភូមិ ពួកអាយ៉ងចក្រពត្តិគ្រប់សម័យកាលរហូតដល់ទទួលបានជ័យជំនះ សុខសន្តិភាព និងសុភមង្គលជូនជាតិមាតុភូមិ។

## ៣. ឆ្លុះបញ្ចាំងអំពីទំនាស់ស្មុគស្មាញក្នុងសង្គម

ទំនាស់គឺជាកត្តាដ៏សំខាន់ក្នុងនាដ្យកថាល្ខោនបាសាក់ នាដ្យកថានីមួយៗ បើមិនមានទំនាស់ទេ នឹងមិនអាចកើតជានាដ្យកថាបានឡើយ ឬនាដ្យកថានោះមិនអាចមានចំណាប់អារម្មណ៍ពីទស្សនិកជនបានដែរ។ ទំនាស់អាចឆ្លុះបញ្ចាំងពីទំនាក់ទំនងក្នុងសង្គម រវាងវណ្ណៈផ្សេងគ្នាក្នុងសង្គម រួមមានដូចជាទំនាស់ក្នុងរាជវង្សានុវង្ស ទំនាស់ក្នុងគ្រួសារ បងប្អូន ប្តីប្រពន្ធ អ្នកមានអ្នកក្រ អំពើល្អអំពើអាក្រក់ជាដើម។

ទំនាស់ក្នុងរាជវង្សមានដូចជា ទំនាស់រវាងតួអង្គព្រះរាជា អគ្គមហេសី ស្រីស្នំ រាជបុត្រា បុត្រី មន្ត្រីនាម៉ឺន បរោហិត ឧបរាជ ហោរា តួអង្គជាមនុស្ស តួអង្គជាយក្ស ជាដើម ដូចជានាដ្យកថារឿង លិនថោងកុមារ ទិពសង្វារ ពុទ្ធវង្ស ដំរីសភ្លុកខៀវ ស័ង្ខសិល្ប៍ជ័យ ចន្ទវង្ស ។ល។

ទំនាស់ផ្ទៃក្នុងនៃរាជវង្សានុវង្ស ច្រើនតែជាទំនាស់ដែលកើតឡើងរវាងអគ្គមហេសី និងស្នំឯក ចួនកាលទំនាស់កើតឡើងទាំងពីរភាគី ដែលប្រណាំងប្រជែងគ្នាដើម្បីដណ្តើមយករាជសម្បត្តិសម្រាប់បុត្រារៀងៗខ្លួន ចួនកាលទំនាស់កើតឡើងតែចំពោះភាគីម្ខាងគឺស្នំឯក ដោយការច្រណែនឈ្នានីសរបស់ស្នំឯកដែលមិនមានបុត្រា ឬដោយសារមិនអាចទាក់ទាញមនោសញ្ចេតនាពីព្រះរាជាបានដូចជាអគ្គមហេសី ដូចជានាដ្យកថារឿង ស័ង្ខសិល្ប៍ជ័យ ដំរីក្បាលបី ចន្ទវង្ស ។ល។ ទំនាស់ទាំងនោះកើតឡើងដោយការធ្វើទុក្ខទារុណកម្មចំពោះអគ្គ

មហេសី និងបុត្រ ដោយមានការបណ្ដេញចេញពីព្រះនគរ ឬបញ្ជូនទៅសម្លាប់ចោលក្នុងព្រៃ ដោយជឿពាក្យចាញ់បោក បន្តិចក្រោយមករបស់ស្ដេចយកតែបានយកអាសារស្រោចស្រង់ជីវិតវិញ ដោយព្រះមុនីតាឥសី ឬទេវតា នៅទីបញ្ចប់នៃនាដ្យកថា ទំនាស់ត្រូវបានដោះស្រាយ ដោយការព្រះរាជាជ្រាបដឹងការពិតនៅពេលអគ្គមហេសី និងបុត្រារកឃើញហេតុផល ភស្តុតាង ឬព្រះរាជាត្រូវស្ដេចឯក និងឪពុក ឬសាហាយនាងក្បត់ ពេលនោះ អគ្គមហេសី និងបុត្រាទទួលបានការណែនាំ ឬការប្រោះព្រំពីទេវតា ឬព្រះមុនីតាឥសី ក៏ត្រឡប់ចូលមកព្រះនគរវិញដើម្បីរំដោះព្រះរាជានិងព្រះនគរ ហើយអ្នកដែលមានទោសនឹងត្រូវទទួលនូវបាបកម្មទាំងអស់ ដែលពួកគេបានសាង។

ទំនាស់រវាងមនុស្សជាតិ នឹងយក្ស គឺជាទំនាស់តំណាងឱ្យអំពើល្អ និងអំពើអាក្រក់ តួអង្គជាយក្ស តែងរកវិធីឈ្លានពានយាយីទឹកដីនគរមនុស្ស ឬស្វែងរកចាប់មហេសីព្រះរាជា ដើម្បីយកទៅធ្វើជាប្រពន្ធខ្លួន ប៉ុន្តែទីបំផុតអំពើល្អតែងយកឈ្នះលើអំពើអាក្រក់ ដូចគ្នានឹងបរាជ័យរបស់ក្រុមតួអង្គយក្ស ចំពោះក្រុមតួអង្គមនុស្សដែលមានឫទ្ធិដៃ និងបារមីអស្ចារ្យ ដូចនាដ្យកថាល្ខោនបាសាក់រឿងលិនថោងកុមារ រឿងទិពសង្វារ រឿងពុទ្ធវង្ស រឿងនាងសេតា។ល។ តួអង្គតំណាងអំពើអាក្រក់គឺតួអង្គយក្ស តួអង្គតំណាងឱ្យអំពើល្អគឺតួអង្គមនុស្ស ទំនាស់នៃនាដ្យកថាប្រភេទនេះ បានបំពាក់ជំនឿសាសនាយ៉ាងច្បាស់លាស់ត្រង់ទស្សនៈកម្មផល អំពើល្អតែងប្រឆាំង និងយកឈ្នះលើអំពើអាក្រក់ជានិច្ច។

ទំនាស់វណ្ណៈកើតមានឡើងជារឿយៗក្នុងនាដ្យកថាល្ខោនបាសាក់ភាគច្រើន ប៉ុន្តែទំនាស់វណ្ណៈក្នុងនាដ្យកថាល្ខោនបាសាក់តែងមានកត្តាអស្ចារ្យដោះស្រាយទំនាស់ ព្រោះនោះក៏ជាក្ដីប្រាថ្នារបស់ប្រជនជនក្រីក្រ ដោយជីវិតរស់នៅរបស់ពួកគេតែងបានផ្សារភ្ជាប់ជាមួយនឹងជំនឿប្រជាប្រិយ និងជំនឿសាសនា បានយកនិងពឹងពាក់លើជំនឿទាំងនោះដើម្បីជាកម្លាំង និងជាការលើកទឹកចិត្តសម្រាប់ការប្រឆាំងតស៊ូដើម្បីក្ដីសុខសន្តិភាពរបស់ពួកគេ។ ដូចជានាដ្យកថាល្ខោនបាសាក់រឿង ទិព្វសុជាចន្ទ ស្នេហានិងកែវភ្នែក ចំណងស្នេហ៍សុវណ្ណបុប្ផា។ អត្ថន័យផ្ទៃរឿងទាំងអស់ គឺបញ្ជាំងអំពីទំនាស់វណ្ណៈសង្គមក្នុងសម័យសក្តិភូមិ រវាងវណ្ណៈជិះជាន់ នឹងវណ្ណៈត្រូវជិះជាន់ រវាងថៅកែ និងអ្នកបម្រើ។ ទីបំផុតវណ្ណៈក្រីក្រទ្រាំនៅលែងបាន ក៏ស្រុះស្រួលគ្នាក្រោកឈរឡើងដើម្បីប្រឆាំងទាមទារសិទ្ធិសេរីភាពមកវិញ។ នាដ្យកថាចាប់ផ្ដើមពីការស្រមើស្រមៃ ដល់ការពិត ពីអសមភាពទៅកាន់សមភាព ដោយសារការជិះជាន់យ៉ាងឃោរឃៅ ដែលមិនអាចទ្រាំបានរបស់វណ្ណៈអ្នកមាន មកលើវណ្ណៈក្រីក្រ បានចាប់បង្ខំឱ្យវណ្ណៈក្រីក្រត្រូវតែសាមគ្គីព្រួតដៃគ្នាតស៊ូប្រឆាំងស្វែងរកយុត្តិធម៌ជូនប្រជាជនក្រីក្រ។

ទំនាស់រវាងបងប្អូនក្នុងបរិវេណវង្សត្រកូល គ្រួសារ កើតឡើងពីការយល់ច្រឡំគ្នាទៅវិញទៅមក ដោយសារពាក្យញុះញង់នៃបុគ្គលទីបី នាំឱ្យកើតទំនាស់រហូតដល់មិនអាចផ្សះផ្សារគ្នាវិញបាន ដល់មានអ្នកស្លាប់អ្នករស់ ពេលនោះអ្នករស់ទើបយល់ពីហេតុផល ហើយទទួលរងនូវវិប្បដិសារីយ៉ាងខ្លោចផ្សា។ ដូចនាដ្យកថារឿងនាយដាមម៉ាក់ភូយ៉ុងកែវ រឿងរាជបុត្រីឋានបាតាល រឿងក្រុងសុភមិត្ត រឿងតំណាលអ្នកតា រឿងជ័យសូរ្យវង្ស រឿងដារាវិជ័យ

មាល័យសុរិយា រឿងនាងសេតា។ល។ នាដ្យកថាទាំងនេះឆ្លុះបញ្ចាំង ពីការខ្វះពិចារណាស្វែងរកហេតុផលឱ្យបានហ្មត់ចត់មុននឹងចេញសេចក្តីសម្រេចអ្វីម្យ៉ាងនិងលើកកម្ពស់ភាពស្មោះត្រង់របស់ជនរងគ្រោះ។

ទំនាស់ប្តីប្រពន្ធកូនក្នុងគ្រួសារ ឆ្លុះបញ្ចាំងការភិតក្បត់របស់បុរសជាប្តី ពេលដែលមានបុណ្យស័ក្តិ ក៏ក្បត់ប្រពន្ធកូនក្រីក្ររៀបការជាមួយនឹងកូនស្រីរបស់ព្រះរាជា ឬនាម៉ឺនមន្ត្រី ដូចជានាដ្យកថារឿង មេទ័ពឫទ្ធិស័ក្តិ រឿងផ្លែដាវជំបៅចិត្ត។ អត្ថន័យផ្ទៃរឿងនៃនាដ្យកថាទាំងពីរដូចគ្នា ប្លែកត្រង់ទីបញ្ចប់មេទ័ពរិទ្ធិស័ក្តិត្រូវកាត់ទោសបណ្តេញចេញពីព្រះនគរឯមេទ័ពជីវកុនក៏ស្លាប់ជាមួយគ្នា ក្នុងខណៈប្រយុទ្ធសិល្បវិជ្ជាជាមួយប្រពន្ធដើមរបស់ខ្លួន។ នាដ្យកថាអប់រំមនុស្សត្រូវរក្សាភាពស្មោះត្រង់រវាងប្តីប្រពន្ធនឹងគ្នា ទោះក្នុងគ្រាមាន ឬក្រ។

## ៤. ឆ្លុះបញ្ចាំងអំពីការស្ងើចសរសើរអំពីឫកពាសុចរិត

ស្ត្រីភេទក្នុងសង្គមនៃសម័យកាលសក្តិភូមិ តាមរយៈនាដ្យកថាល្ខោនបាសាក់ភាគច្រើន ជួបរឿងអភ័ព។ ពួកគេជួបស្នេហាមេត្រីភាព ស្មោះស្ម័គ្ររវាងគ្នានឹងគ្នា ប៉ុន្តែវាសនាកំណត់ពួកគេជួបសុទ្ធតែសោកនាដកម្មក្នុងសង្គមដ៏ខ្លោចផ្សាបំផុត ស្នេហាត្រូវរារាំង ត្រូវបង្ខំឱ្យបែក លទ្ធផលចុងក្រោយបានដល់នូវសេចក្តីស្លាប់ដ៏អាណោចអាធ័ម តួយ៉ាងដូចជានាដ្យកថា ល្ខោនបាសាក់រឿងទុំទាវ និងរឿងនាងបដាចារ ។ល។

នាងទាវ និងនាងបដាចារ ទោះជាបានរស់នៅក្នុងគ្រួសារអ្នកមានស្តុកស្តម្ភក៏ដោយ ប៉ុន្តែតែងមានក្តីស្មោះស្វាមីភក្តិជានិច្ចជាមួយនឹងគូស្នេហ៍ជាបុរសក្រខ្សត់របស់គេ។ គុណសម្បត្តិរបស់នាងទាវនិងនាងបដាចារជាគុណសម្បត្តិដែលគួរស្ងើចសរសើរ និងជាគុណសម្បត្តិសំខាន់ក្នុងសម័យកាលនោះ។ ឆ្លងតាមរយៈនាដ្យកថាល្ខោនបាសាក់ទាំងពីរ អ្នកនិពន្ធចង់ស្ងើចសរសើរចំពោះគុណសម្បត្តិរបស់ស្ត្រីភេទ ដែលបង្កើតបានជាតម្លៃរបស់នាដ្យកថា នោះគឺជាការតស៊ូប្រឆាំងនឹងអំពើអសីលធម៌ អ្នកនិពន្ធបានឱ្យតួអង្គជ្រើសរើសយកភាពស្មោះត្រង់ដើម្បីស្វែងរកសុភមង្គលក្នុងការរស់នៅ និងថ្កោលទោសចំពោះអំពើឃោរឃៅ លោភលន់ចង់បានងារស័ក្តិ ទ្រព្យសម្បត្តិចាកសច្ចៈធម៌ ដើម្បីប្តូរយកសេចក្តីស្នេហា។ តម្លៃនៃគុណសម្បត្តិមិនមែនត្រឹមតែស្វាមីភាពរវាងប្តីប្រពន្ធប៉ុណ្ណោះទេ ប៉ុន្តែក៏ជាតម្លៃនៃការលះបង់ ដែលបានបង្ហាញបន្ទាប់ពីការតស៊ូប្រឆាំងអំពើអយុត្តិធម៌របស់ប្រជាជនក្រីក្រ ដែលប្រឆាំងសម្រាប់ខ្លួនឯងផង សម្រាប់សង្គមផង។ ការស្លាប់ខ្លួនរបស់តួអង្គនាងទាវ និងតួអង្គនាងបដាចារ គឺជាការឆ្លុះបញ្ចាំងនូវទំនាក់ទំនងគ្រួសារក្នុងសង្គមនៃសម័យកាលសក្តិភូមិ ដែលរហូតមកដល់បច្ចុប្បន្ននេះមនុស្សនៅតែញញើតក្រែង និងនៅតែស្ងើចសរសើរនាងទាវ និងនាងបដាចារជានិច្ច។

ការលះបង់ដើម្បីស្នេហាស្មោះស្ម័គ្រ ស្វាមីភក្តិ និងសុភមង្គល នៅទាំងបានបង្ហាញក្នុងនាដ្យកថាល្ខោនបាសាក់រឿងម៉ាក់ថឺង រឿងសុវណ្ណផលា។ ចំណងស្នេហាជនក្រីក្រត្រូវបានការពារទទួលស្គាល់ពីមន្ត្រីរាជការ និងកាត់ទោសអ្នកមាន ដែលមានគំនិតបំពានគ្រួសារអ្នកដទៃ។ ដោយមាននាម៉ឺនមន្ត្រីប្រកាន់ខ្ជាប់តាមច្បាប់ផែនដី គឺជាគោលបំណងប្រាថ្នារបស់ប្រជា

ជនទូទៅ ដែលចង់បានរស់នៅក្នុងសង្គមដែលជឿនលឿន ពោរពេញទៅដោយយុត្តិធម៌ សមភាព សច្ចៈធម៌។ ទំនាស់កើតឡើងដោយសារស្នេហា និងឋានៈ ស្នេហាស្មោះស្ម័គ្រ និងស្វាមីភក្តិតែងយកឈ្នះជានិច្ច តាំងពីក្នុងរាជវង្សរហូតដល់ប្រជាជនសាមញ្ញ ពីអ្នកមាន ដល់អ្នកក្រ ពួកគេតែងតស៊ូប្រឆាំងនឹងអ្វីដែលជាអំពើអយុត្តិធម៌ ដើម្បីធ្វើឱ្យជីវិតកាន់ស្រស់បំព្រង តាមរយៈការបណ្តុះនូវចំណងស្នេហាដ៏ស្វាមីភក្តិ និងមនោសញ្ចេតនាដោយសុទ្ធចិត្ត។

នាដ្យកថារឿងទុំទាវ និងរឿងនាងបឋាចារ បញ្ចប់ដោយសោកនាដកម្ម រីឯនាដ្យកថារឿងម៉ាកបឺង និងរឿងសុវណ្ណផលាបានបញ្ចប់ក្នុងភាពរីករាយពោរពេញទៅដោយមនោសញ្ចេតនា និងមោទនភាព។ នាដ្យកថាបញ្ជាំងឱ្យយើងឃើញថា សង្គមមានការជឿនលឿន រីកចម្រើនលូតលាស់ពីមួយថ្ងៃទៅមួយថ្ងៃ ទស្សនៈរស់នៅ និងទស្សនៈពីទំនាក់ទំនងក្នុងគ្រួសារ និងក្នុងសង្គម។ តួអង្គបានឈានឡើងដោយខ្លួនឯងតស៊ូប្រឆាំង ដើម្បីសុភមង្គលខ្លួន និងមហាជន។ រូបភាពមន្ត្រីកាត់ក្តីដោយយុត្តិធម៌ សុចរិត ជ្រាបហេតុផល ស្គាល់ខុសត្រូវក្នុងនាដ្យកថារឿងម៉ាក់បឺង គឺជាអ្វីដែលប្រជាជនទូទៅតែងប្រាថ្នានៅគ្រប់សម័យកាលនោះ។

គុណសម្បត្តិនៃចំណងស្នេហាស្វាមីភក្តិតាមរយៈនាដ្យកថាល្ខោនបាសាក់ មិនត្រឹមតែបង្ហាញពីចំណងស្នេហាស្ពានមេត្រីរវាងមនុស្ស នឹងមនុស្សប៉ុណ្ណោះទេ ប៉ុន្តែក៏បានបង្ហាញនូវចំណងស្នេហាស្វាមីភក្តិរវាមនុស្សធម្មតា នឹងមនុស្សមិនធម្មតាទៀតផង (មនុស្សមានអវយវៈមិនគ្រាប់គ្រាន់ មនុស្សពិការ មនុស្សមានអវយវៈជាសត្វ) ដូចជានាដ្យកថាល្ខោនបាសាក់រឿងរាជបុត្រត្រចៀកលា រឿងរាជបុត្រឃ្លង់ ក្អមទឹកទិព ស្នេហានិងកែវភ្នែក ចំណងស្នេហ៍បញ្ញាសុភាព ។ល។ នាដ្យកថាល្ខោនបាសាក់ទាំងនោះបញ្ជាំងឱ្យឃើញពីគុណសម្បត្តិមនុស្សដែលមិនរើសអើងមានក្រ មិនរើសអើងជនពិការ មិនរើសអើងមនុស្សតែមានអវយវៈសត្វ ដោយសារទោះបីពួកគេជាមនុស្សចាកប្រក្រតីក៏ពិតមែន ប៉ុន្តែជាមនុស្សដែលប្រកបសុចរិត សច្ចៈធម៌ និងមនុស្សធម៌ជានិច្ច។ ទីបំផុតនៃនាដ្យកថាល្ខោនបាសាក់ទាំងនោះ តែងតែមានភាពអស្ចារ្យកើតឡើង គឺទីបំផុតពួកគេបានក្លាយជាមនុស្សធម្មតាដូចប្រក្រតីវិញ ហើយទទួលបានសុភមង្គលដ៏គួរកោតសរសើរ។ ប្រការនោះបញ្ជាក់ឱ្យឃើញថា ការមើលមនុស្ស មិនអាចផ្អែកលើតែរូបភាព និងសម្បត្តិខាងក្រៅបានឡើយ ត្រូវច្បាមយកទាំងរូបសម្បត្តិ និងអត្តចរិតទៀតទើបអាចឱ្យតម្លៃលើមនុស្សម្នាក់បានប្រាកដប្រជា។

ឆ្លងតាមរយៈនាដ្យកថាល្ខោនបាសាក់ ដែលដកស្រង់ពីស្នាដៃអក្សរសិល្ប៍ដែលមានភាពអស្ចារ្យកើតឡើងសម្រាប់ដោះស្រាយបញ្ហា និងយកអាសាមនុស្សបែបនេះ គឺចង់បញ្ជាំងឱ្យឃើញថា អ្នកនិពន្ធប្រជាប្រិយចង់បង្ហាញពីគំនិត និងក្តីប្រាថ្នារបស់ប្រជាជនទូទៅគឺមានគោលបំណងចង់លុបបំបាត់របបសង្គមសក្តិភូមិ ដែលពោរពេញទៅដោយអំពើអយុត្តិធម៌ ការគាបសង្កត់ ជិះជាន់ និងអសមភាពសង្គម ដើម្បីឈានទៅរកសង្គមលូតលាស់រីកចម្រើន ដែលពោរពេញដោយសច្ចៈធម៌ យុត្តធម៌ និងសមភាពសង្គម។ នាដ្យកថាស្ងើចសរសើរគុណសម្បត្តិមនុស្ស បុគ្គលម្នាក់ៗមានតួនាទីចំពោះជាតិមាតុភូមិ និងគ្រួសារ។ សោភ័ណភាពនៃអំពើសុចរិតតែងបានលើកកម្ពស់ និងគោរពសរសើរ តួអង្គនីមួយៗជាតំណាងឱ្យសហគមន៍ និង

សង្គមជាតិទាំងមូល សុខចិត្តលះបង់ខ្លួនដើម្បីសុភមង្គលជូនសហគមន៍ ជូនជាតិ នោះគឺជាពន្លឺ និងជាត្រីវិស័យសម្រាប់បញ្ចាំងជីវិតនៃប្រជាជនទាំងមូល។

## ៥. ឆ្លុះបញ្ចាំងអំពីការរិះគន់អំពើអាក្រក់ទុច្ចរិត

នាដ្យកថាល្ខោនបាសាក់និយាយរួម ជាពិសេសគឺនាដ្យកថាល្ខោនបាសាក់ដែលដកស្រង់ពីស្នាដៃអក្សរសិល្ប៍ សុទ្ធតែមានបង្កប់នូវការរិះគន់អំពើអាក្រក់ទុច្ចរិត ដែលមានក្នុងសង្គម។ ក្នុងនាដ្យកថាល្ខោនបាសាក់នីមួយៗ ភាគច្រើនមានតួអង្គតំណាងអំពើអាក្រក់ តួអង្គតំណាងអំពើល្អ។ តាមរយៈសកម្មភាពតួអង្គនីមួយៗ អ្នករៀបរៀងបានបង្កប់នៅអត្តចរិតរបស់មនុស្សដែលមានចិត្តលោភលន់ កេងប្រវ័ញ្ច អាត្មានិយម ចិត្តក្បត់ សម្រាប់ជាទស្សនៈអប់រំ។

តាមរយៈនាដ្យកថាល្ខោនបាសាក់រឿងព្រះវេស្សន្តរ លើកកម្ពស់ទស្សនៈអប់រំមនុស្សឱ្យចេះអាណិតស្រឡាញ់រាប់អានមនុស្សជាតិដូចគ្នាក្នុងពេលមានលំបាក។ ទន្ទឹមនឹងនោះ ក៏បានរិះគន់យ៉ាងធ្ងន់ធ្ងរលើអំពើដ៏ឃោរឃៅរបស់តាជូជក ដែលជាអ្នកទទួលបានទានពីព្រះវេស្សន្តរ គឺក្រឹស្នា និងជាលី តែបែរជាមិនចេះលើកស្ទួយនៅអំណោយដ៏ខ្ពង់ខ្ពស់ ហើយធ្វើទារុណកម្មដ៏ព្រៃផ្សៃលើទាននោះ ទីបំផុតក៏ទទួលនូវកម្មដែលគាត់បានសាង។

នាដ្យកថាល្ខោនបាសាក់រឿងទុំទាវ ថ្កោលទោសម្ដាយនាងទាវជាតំណាងអំពើ ដែលលោភលន់ហួសប្រមាណចំពោះទ្រព្យសម្បត្តិ ងារសក្តិ ហើយមិនមានចិត្តអាណិតស្រឡាញ់រាប់អានជនក្រីក្រតិចតួចណាឡើយ។ អត្តចរិតរបស់យាយផាន់ ផ្ទុយទាំងស្រុងពីអត្តចរិតរបស់នាងទាវ ដែលជាហេតុបណ្ដាលឱ្យមានការស្លាប់ដ៏ខ្លោចផ្សារបស់នាងទាវ។ រីឯនាដ្យកថារឿងនាងបដាចារ ក៏ជាសោកនាដកម្មមួយស្រដៀងនឹងនាដ្យកថារឿងទុំទាវដែរ។ ខ្សែជីវិតរបស់នាងបដាចារក៏រស់នៅយ៉ាងជូរចត់វេទនា ក៏មកពីភាពលោភលន់ និងមាក់ងាយអ្នកក្រីក្រនៃម្ដាយឪពុកនាង ទីបំផុតបណ្ដាលឱ្យនាងក្លាយជាមនុស្សវិកលចរិត ដោយសារប្ដី និងកូនទាំងពីត្រូវស្លាប់បាត់បង់ទៅ។

នាដ្យកថាល្ខោនបាសាក់ ដែលមានអត្ថន័យផ្ទៃរឿងទាក់ទងនឹងសម័យកាលសង្គមសក្តិភូមិ អប់រំមនុស្សក្នុងគ្រួសារ និងសង្គមនាសម័យនោះពិត ប៉ុន្តែទស្សនៈអប់រំនៅតែមានឥទ្ធពល និងមានប្រយោជន៍អប់រំនាសម័យបច្ចុប្បន្នផងដែរ។ បច្ចុប្បន្ននេះ ក៏ព្រោះតែចិត្តលោភលន់ អាត្មានិយម បង្ខិតបង្ខំឱ្យសមាជិកក្នុងគ្រួសារធ្វើតាមនូវអំពើដែលគេមិនពេញចិត្ត ឬមិនសមស្របនឹងសម័យកាល ក៏ជាហេតុបណ្ដាលឱ្យកើតមានទំនាស់ មានហិង្សាក្នុងគ្រួសារ ឬក្នុងសង្គមផងដែរ។

អំពើភិតក្បត់របស់មេទ័ពរិទ្ធិស័កជាប្ដីរបស់នាងជីវកុន ក្នុងនាដ្យកថាល្ខោនបាសាក់រឿងផ្លែដាវជំបោចិត្ត មេទ័ពរិទ្ធិស័កមានចិត្តលោភហាម ពុលនឹងងារសក្តិ ទ្រព្យសម្បត្តិនាពេលដែលប្រឡងជាប់ រួចរៀបការជាមួយរាជបុត្រីនៃព្រះមហាក្សត្រ ក្បត់ប្រពន្ធកូនក្រីក្រ។ អំពើក្បត់ប្ដីរបស់នាងអមរា ជាប្រពន្ធរបស់រាជបុត្រចន្ទគោរព ក្នុងនាដ្យកថារឿងចន្ទគោរព នាងអមរាក្បត់ប្ដីទៅសាហាយជាមួយនឹងមេចោរ។ តាមរយៈនាដ្យកថាទាំងពី បានបញ្ចាំងពីការរិះគន់នូវអំពើក្បត់របស់ប្ដី ឬ ប្រពន្ធ ដែលមានមានភាពស្មោះស្ម័គ្រ ស្វាមីភក្តិរវាងគ្នានឹងគ្នា បំភ្លេច

ចំណងស្នេហាដែលពួកគេបានសាងជាមួយគ្នា ដើម្បីអប់រំបច្ឆាជនត្រូវជុសខាត់គំនិត សិក្សាស្វែងយល់ និងមានទស្សនៈរឹងមាំរក្សាភក្តីភាព ស្វាមីភក្តិរវាងប្ដីប្រពន្ធនឹងគ្នា ព្រោះនោះក៏ជាទំនៀមទម្លាប់ប្រពៃណីដ៏ត្រចះត្រចង់របស់ខ្មែរយើងតាំងពីបុរាណបានបន្សល់មកផង។

## ៦. ឆ្លុះបញ្ចាំងអំពីតថភាពសង្គម

តថនិយមមានតួនាទីដូចជាការចលនាមួយ ជាវិធីសាស្ត្រតំណែងនិពន្ធថ្មី ដែលធ្លាប់តែមានក្នុងសតវត្សទី១៩នៃប្រទេសលោកខាងលិចមួយចំនួន ក្រោយមកក៏ពង្រីកឥទ្ធិពលលើប្រទេសនានាផ្សេងទៀត។ ប៉ុន្តែចំពោះប្រទេសមួយចំនួននៅលោកខាងកើតវិញ ជាពិសេស គឺប្រទេសក្នុងភាគអាស៊ីអាគ្នេយ៍យើងនេះ តំណែងនិពន្ធបែបតថនិយមមានវត្តមានជាយូរលង់ណាស់មកហើយ។ រីឯនាដ្យកថាល្ខោនបាសាក់ដែលដកស្រង់ពីស្នាដៃអក្សរសិល្ប៍ក៏មិនមានគម្លាតពីនិយមនោះដែរ ពោលគឺនាដ្យកថាល្ខោនបាសាក់ក៏តែងតែប្រមូលផ្តុំនូវអ្វីដែលជាបាតុភូតនៃលោកទស្សនៈ ដើម្បីដោះស្រាយពន្យល់នូវអ្វីដែលជាតថភាព ហើយទស្សនៈទាំងអស់នោះសុទ្ធតែប្រឈម និងសំដៅរកប្រជាជនក្រីក្រ បង្កើតជាផ្ទាំងទស្សនិយភាពដ៏រស់រវើក និងជាសច្ចភាពនៃជីវិតសាមញ្ញរបស់ប្រជាជន។

តម្លៃតថភាពនៃនាដ្យកថាល្ខោនបាសាក់ បានបន្ថែមពណ៌ជាលក្ខណៈតំណាងពិសេសខាងអាហារវិញ្ញាណ ទាំងអស់សុទ្ធតែតម្រង់ទិសជីវិតបច្ចុប្បន្នរបស់មនុស្ស ការពេញចិត្តបំពេញតម្រូវការសម្រាប់សោភ័ណភាព និងភាពថ្លៃថ្នូរ។ តម្លៃនៃនាដ្យកថាល្ខោនបាសាក់ ដរាបណាក៏បានបង្កប់នូវតថភាពពិតនៃសង្គម។

អត្ថន័យផ្ទៃរឿងនៃនាដ្យកថាល្ខោនបាសាក់ បានបញ្ចាំងតថភាពសង្គមតាំងពីសង្គមសក្តិភូមិ រហូតដល់សង្គមបច្ចុប្បន្ន ហើយតម្លៃនោះក៏មានប្រយោជន៍សម្រាប់លោកទស្សនៈដដែល។ ប្រការនោះបណ្តាលឱ្យយើងមានការមើលឃើញថាតថភាពសង្គមបច្ចុប្បន្ន អ្នកដែលមានទេពកោសល្យ អ្នកមានថ្វីដៃ មានអត្តចរិតល្អតែងតែទទួលបានការគោរពស្រឡាញ់រាប់អាន និងមានតួនាទីសំខាន់សម្រាប់សង្គម។ តួអង្គនៃនាដ្យកថាល្ខោនបាសាក់មួយចំនួន ទោះបីត្រូវទទួលទារុណកម្មជាច្រើនលើកក៏ដោយ ប៉ុន្តែទីបំផុត នៅតែទទួលបាននូវភាពជោគជ័យរស់រានមានជីវិត រស់នៅដោយសុខសន្តិភាព និងសុភមង្គល។

តថភាពទាំងអស់ក្នុងតថភាពនៃនាដ្យកថាល្ខោនបាសាក់ ក៏ជាតថភាពពិតនៃសង្គម ហើយក៏ជាទស្សនៈ ជាក្តីប្រាថ្នានៃវណ្ណៈប្រជាជនក្រីក្រ ដែលបានផ្ញើបំណងប្រាថ្នារបស់ខ្លួន ហើយចង់បាននូវអ្វីៗដែលជាក្តីប្រាថ្នាទាំងនោះក្លាយជាការពិត។ នោះគឺជាចំណង់ចំណូលចិត្ត ជាក្តីជំនឿថា មនុស្សជាតិនឹងមានសេរីភាព សុខសន្តិភាព និងសុភមង្គល។

## ៧. ឆ្លុះបញ្ចាំងអំពីការឆ្ពោះទៅរកអំពើសុចរិត

ភាគច្រើននៃនាដ្យកថាល្ខោនបាសាក់ បានឆ្លុះបញ្ចាំងអំពីភាពអយុត្តិធម៌សង្គម ប្រជាជនក្រីក្ររស់នៅយ៉ាងលំបាក រងទុក្ខវេទនា រស់នៅដោយអសន្តិភាព ហើយក៏បានបញ្ចាំងពីការស្ញើចសរសើរ គាំទ្រតម្លៃសោភ័ណ អំពើសុចរិត ក្នុងទំនាក់ទំនងរបស់មនុស្សជាតិ ថ្កោលទោសរិះគន់អំពើទុច្ចរិតក្នុងតថសង្គម។ នាដ្យកថាល្ខោនបាសាក់ជាសំឡេងគាំទ្រ និងសង្គ្រោះភាពក្រ

លំបាកតោកយ៉ាក និងបំណងប្រាថ្នា ចំណង់ចំណូលចិត្តរបស់មនុស្សជាតិ។ នាដ្យកថាល្ខោនបាសាក់ បានបកអាក្រាតរូបភាពដ៏រស់រវើក អប់រំមនុស្សរស់នៅក្នុងសង្គមត្រូវតែគោរពសីលធម៌ មានចិត្តមេត្តា និងមានគោលការណ៍នៃអាកប្បកិរិយារវាងមនុស្ស និងមនុស្សក្នុងសង្គមបច្ចុប្បន្ន។

តម្លៃមនុស្សធម៌ តម្លៃសុចរិតក្នុងនាដ្យកថាល្ខោនបាសាក់បានបង្ហាញច្បាស់ក្នុងការបញ្ចប់រឿងដោយរីករាយ អ្នករងទុក្ខតែងទទួលបានសេរីភាព សុភមង្គល និងសុខសន្តិភាពឡើងវិញ ដូចជានាដ្យកថារឿងមេទ័ពរិទ្ធិស័ក រឿងចៅស្រទបចេក រឿងមរណមាតា រឿងចំណងស្នេហាបញ្ញាសុភាព ។ល។ មនុស្សធម៌ សុចរិតធម៌ កើតចេញពីស្នាដៃអ្នកនិពន្ធប្រជាប្រិយ ទោះបីមានលក្ខណៈបំពាក់ទស្សនៈសាសនា ឬតថភាព សុទ្ធតែបាននាដ្យកថាល្ខោនបាសាក់កម្លាយជាទស្សនៈអប់រំមនុស្សជាតិឱ្យចេះស្រឡាញ់រាប់អានគ្នា ជួយសង្គ្រោះគ្នាទៅវិញទៅមក ហើយជៀសវាងការសាងអំពើអាក្រក់ទុច្ចរិត និងមិនប្រព្រឹត្តិអ្វីដែលផ្ទុយនឹងសច្ចធម៌។

នាដ្យកថាល្ខោនបាសាក់ដែលដកស្រង់ពីស្នាដៃអក្សរសិល្ប៍ពុទ្ធនិយម មានតម្លៃពិតប្រាកដក្នុងវិធីបញ្ជាំងបង្ហាញពីការឆ្ពោះទៅរកអំពើសុចរិត កសាងអំពើល្អ ដោយប្រជាជនខ្មែរទោះជារស់នៅទីណា ឬក្នុងសម័យកាលណាក៏មានប្រមាណ៩០%ជាអ្នកមានជំនឿសាសនាដូច្នេះហើយអាទិទេពសាសនាតែងមានឥទ្ធិពលមកលើទស្សនៈរបស់ប្រជាជនជានិច្ច។ ប្រការនេះបញ្ជាក់ឱ្យឃើញថា ការឆ្ពោះទៅរកអំពើសុចរិត តែងបានផ្តួបផ្សំជាមួយទស្សនៈអប់រំតាមរយៈនាដ្យកថាល្ខោនបាសាក់យ៉ាងច្បាស់លាស់នូវអ្វីដែលទាក់ទងដល់អំពើល្អ និងអំពើអាក្រក់។ អំពើល្អតែងរំដោះមនុស្ស និងជនរងគ្រោះតាមរយៈការបរិច្ចាគ សង្គ្រោះមនុស្សដែលត្រូវគាបសង្កត់ជិះជាន់ដោយសិទ្ធអំណាច។ ទស្សនៈសាសនា បានស៊ីជម្រៅចូលក្នុងចិត្តគំនិតរបស់ប្រជាពលករ ពួកគេសម្គាល់ និងយកធ្វើជាទីពឹងពំនាក់។ នាដ្យកថាល្ខោនបាសាក់ស្ទើរតែទាំងអស់បានដាក់ចេញនូវបញ្ហាសាសនា និងវណ្ណៈសង្គម នោះគឺជាបញ្ហាសំខាន់ទាំងពីរ ដែលតែងតែដើរទន្ទឹមគ្នា បំពេញគ្នាទៅវិញទៅមក ដើម្បីឈានទៅរកសុខសន្តិភាព និងសមភាពសង្គម។

## ៨. សេចក្តីសន្និដ្ឋាន

ក្នុងជីវភាពសាមញ្ញរបស់ប្រជាជនខ្មែរ សិល្បៈល្ខោនបាសាក់ គឺជាឧបករណ៍សម្រាប់ការកម្សាន្ត បង្កើតបាននូវអ្វីដែលល្អៗសម្រាប់ជីវិតផង និងអប់រំសីលធម៌សម្រាប់បុគ្គល និងសហគមន៍ផង។ ប្រការដែលគួរកត់ត្រាក្នុងនាដ្យកថាល្ខោនបាសាក់ បានបង្ខិត និងកាត់បន្ថយគម្លាតសម័យបុរាណ នឹងបច្ចុប្បន្ន បាននាំមកនូវខ្លឹមសារ និងអត្ថន័យក្នុងសង្គមមនុស្សបុរាណមកអប់រំសង្គមមនុស្សបច្ចុប្បន្ន។ ឆ្លងតាមរយៈការសិក្សាអំពីតម្លៃអក្សរសិល្ប៍ ដែលបានរឿងល្ខោនបាសាក់យកមកឆ្លុះបញ្ចាំង យើងឃើញថា ល្ខោនបាសាក់ពិតជាមានសារៈសំខាន់ក្នុងការផ្សព្វផ្សាយអំពីតម្លៃអក្សរសិល្ប៍។ លក្ខណៈពិសេសនៃវប្បធម៌ខ្មែរគឺការរួបរួមផ្សះផ្សារសាសនាព្រាហ្មណ៍ សាសនាព្រះពុទ្ធ ជំនឿប្រជាប្រិយ ទាំងបីឲ្យជាផ្លូងមួយ ហើយបានបង្ហាញវត្តមាននៃសកម្មភាពទាំងគ្រប់របស់ជនរួមជាតិខ្មែរ នៅក្នុងនាដ្យកថាល្ខោនបាសាក់ ឆ្លុះបញ្ចាំងពីទឹកចិត្ត

ក្តីប្រាថ្នារបស់ប្រជាជនយើង អ្នករៀបរៀងប្រជាប្រិយបានខ្ចីស្នាដៃអក្សរសិល្ប៍ យកមកកម្លាយឱ្យទៅជានាដ្យកថាល្ខោនបាសាក់ដ៏មានទស្សនិយភាពគួរជាទីជាប់ចិត្ត។

ដើម្បីឲ្យសិល្បៈល្ខោនបាសាក់ពិតជាបានស្ថិតស្ថេរជានិរន្តរ៍ និងមានទស្សនិយភាពក្នុងជីវភាពរស់នៅរបស់ជនរួមជាតិខ្មែរ ការអភិរក្ស និងអភិវឌ្ឍតម្លៃបេតិកភណ្ឌវប្បធម៌អរូបីរបស់ជនជាតិខ្មែរ គឺជាខ្លឹមសារសំខាន់មួយក្នុងកម្មវិធីគោលដៅជាតិ។ អាស្រ័យនៃអត្ថបទនេះ យើងខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួនដូចខាងក្រោម៖

- ឃោសនា និងផ្សព្វផ្សាយក្នុងសហគមន៍ជនរួមជាតិខ្មែរអំពីតម្លៃនៃទម្រង់សិល្បៈល្ខោនបាសាក់ តម្រង់ទិសការអប់រំសោភ័ណភាពសម្រាប់យុវជនជំនាន់ក្រោយនៅតាមគ្រឹះស្ថានអប់រំរដ្ឋ និងក្រៅរដ្ឋ ក្នុងសហគមន៍ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់យុវជនអំពីភាពស្រស់ស្អាត និងតម្លៃនៃសិល្បៈល្ខោនបាសាក់។

- បួរថ្មី និងលើកកម្ពស់គុណភាពបណ្តុះបណ្តាល និងបង្ហាត់បង្រៀនពីសិល្បៈល្ខោនបាសាក់ដល់យុវវ័យជំនាន់ក្រោយ ដល់ក្រុមសិល្បៈល្ខោន គ្រឹះស្ថានអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ សាកលវិទ្យាល័យវប្បធម៌វិចិត្រសិល្បៈ ។ល។

- អនុវត្តយន្តការលើកទឹកចិត្តសង្គមនីយកម្ម ដើម្បីបវារណាធនធានទាំងអស់ក្នុងសង្គម រក្សាស្ថេរភាពការសម្តែងសិល្បៈល្ខោនបាសាក់បម្រើមហាជន។ កែលម្អ រៀបចំឡើងវិញនូវអង្គភាពសិល្បៈល្ខោនបាសាក់តាមមូលដ្ឋាននានា។

- វិនិយោគដោយផ្តោតអារម្មណ៍ដោយមានគុណភាពខ្ពស់ ចំពោះនាដ្យកថាដែលមានតម្លៃសិល្បវិធីសំដែងខ្ពស់ ដើម្បីឧទ្ទេសនាមសិល្បៈល្ខោនបាសាក់អាចផ្សាព្វផ្សាយបានទាំងក្នុង និងក្រៅប្រទេស។ មួយជំហានម្តងៗ ពង្រឹងមូលដ្ឋានគ្រឹះ សម្ភារ និងបច្ចេកទេសសម្តែងល្ខោនបាសាក់ ព្រមទាំងពង្រីកសកម្មភាពធ្វើសមុច្ច័យ និងការសិក្សាស្រាវជ្រាវបន្ត៕

ក្នុងវិសាលភាពនៃអត្ថបទនេះ គ្រាន់តែជាខ្លឹមសារមួយចំណែកតូចក្នុងនិក្ខេបបទ "**តម្លៃអក្សរសិល្ប៍ខ្មែរក្នុងល្ខោនបាសាក់**" ដែលផ្តោតសិក្សាស្រាវជ្រាវលើនាដ្យកថាល្ខោនបាសាក់ ដែលក្រុមសិល្បៈល្ខោនបាសាក់ ខេត្តត្រាវិញ (ក្រុមសិល្បៈរស្មីប្រទីប) បានរៀបរៀងសម្តែងជាផ្លូវការ ដើម្បីស្វែងយល់តម្លៃអក្សរសិល្ប៍ ដែលល្ខោនបាសាក់បានបញ្ចាំង។ ឆ្លងតាមរយៈអត្ថបទនេះ ស្មេរសង្ឃឹមថា នឹងទទួលបានមតិយោបល់បំពេញពីអ្នកអាន អ្នកស្តាប់ជាច្រើន ដើម្បីអត្ថបទមានភាពពេញលេញជាង៕

# គន្ថនិទ្ទេស


## ភាសាខ្មែរ

១.	នួន កន **ល្ខោនក្នុងជីវភាពខ្មែរ** ភ្នំពេញ ឆ្នាំ១៩៧៣។

២.	ក្រុមសិក្សាស្រាវជ្រាវអំពីសិល្បៈប្រជាប្រិយខ្មែរតំបន់វាលរាបទន្លេមេគង្គ របស់សាកលវិទ្យាល័យត្រាវិញ ឆ្នាំ ២០១៨។

៣.	គណៈកម្មការស្រាវជ្រាវសិល្បៈវប្បធម៌ **ទស្សនីភាពខ្មែរ** ភ្នំពេញ ឆ្នាំ២០០៣។

៤.	លី ធេមតេង **ការស្រាវជ្រាវល្ខោនខ្មែរ** ការផ្សាយរបស់កម្ពុជសុរិយា ភ្នំពេញ។

៥.	វ៉ៃ យំ **ខ្មែរប្រឈមមុខនឹងវប្បធម៌** ភ្នំពេញ ឆ្នាំ២០០១។

៦.	ពេជ្រ ទុំក្រវិល **ទស្សនិយភាពសិល្បៈខ្មែរ** ភ្នំពេញ ឆ្នាំ២០០៣។

៧.	ថាច់ សេដ្ឋ **ការកកើត និងអភិវឌ្ឍនៃក្រុមសិល្បៈរស្មីប្រទីបខេត្តត្រាវិញ** ការផ្សាយរបស់សមាគមអ្នកអក្សរសិល្ប៍វៀតណាម ឆ្នាំ២០១៩។

## ភាសាវៀតណាម

៨.	Mai Mỹ Duyên, (2014), *Đôi điều về nghệ thuật sân khấu Dù kê*, Nghệ thuật sân khấu Dù kê Khmer Nam Bộ Di sản văn hóa dân tộc, Tạp chí khoa học, Trường Đại học Trà Vinh (số 13) tr. 64 - 67.

៩.	Đoàn nghệ thuật Khmer Ánh Bình Minh, (2014), *Quá trình hình thành và hoạt động biểu diễn nghệ thuật sân khấu Dù kê tỉnh Trà Vinh*, Nghệ thuật sân khấu Dù kê Khmer Nam Bộ Di sản văn hóa dân tộc, Tạp chí Khoa học, Trường Đại học Trà Vinh (số 13) tr. 176 - 181.

១០.	Phạm Tiết Khánh, (2014), *Nghệ thuật Sân khấu Dù kê Khmer Nam Bộ-Vấn đề và suy nghĩ*, Nghệ thuật sân khấu Dù kê Khmer Nam Bộ Di sản văn hóa dân tộc, Tạp chí Khoa học, Trường Đại học Trà Vinh (số 13) tr.5-10.

១១.	Kịch bản Sân khấu Dù kê Đoàn Nghệ thuật Khmer Ánh Bình Minh tỉnh Trà Vinh.

១២.	Nhiều tác giả, (1998), ***Về sân khấu truyền thống Khmer Nam Bộ,*** NXB Phân Viện Văn hóa Nghệ thuật Việt Nam tại Tp Hồ Chí Minh và Sở Văn hóa Thông tin tỉnh Sóc Trăng tr. 31

១៣.	Thạch Sết, (2019), *Tìm hiểu sự hình thành và phát triển nghệ thuật Sân khấu Dù Kê dân tộc Khmer Nam Bộ*, NXB Sân khấu.

១៣.	Thạch Sết, (2020) *Nội dung 72 vở diễn ca kịch Dù Kê Dân tộc Khmer Nam Bộ* Nxb Hội Văn học.

# ទស្សនាទានអប់រំចរិយាធម៌តាមរយៈរឿងមហាវេស្សន្តរជាតក

បេក្ខជនបណ្ឌិតៈ **យ៉ា សារុន**

## ១-សេចក្តីផ្តើម

រឿងមហាវេស្សន្តរជាតក ជាប្រភេទស្នាដៃពុទ្ធនិយមមួយ ក្នុងចំណោមស្នាដៃពុទ្ធនិយមដទៃទៀតនៅក្នុងចរន្តអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម។ រឿងនេះ ប្រភពដើមកើតចេញពីការនិទានផ្ទាល់របស់ព្រះពុទ្ធ ក្នុងដំណើរយាងប្រោសពុទ្ធបិតា និងក្រុមញាតិរបស់ព្រះអង្គ ឯនគរកបិលពស្តុ។ ក្រោយវត្តមានពុទ្ធសាសនាបានចូលមកក្នុងសង្គមខ្មែរ រឿងនេះត្រូវបានអ្នកប្រាជ្ញខ្មែរកត់ត្រាចម្លងចូលក្នុងគម្ពីរសាស្ត្រាស្លឹករឹត ក្រោយមកទើបមានការចម្លងបោះពុម្ពចេញជាគម្ពីរក្បួនខ្នាត ផ្នែកពុទ្ធសាសនា។ ក្នុងពេលបច្ចុប្បន្ន រឿងមហាវេស្សន្តរជាតកនេះ មាននៅក្នុងគម្ពីរព្រះត្រៃបិដក ត្រង់ខុទ្ទនិកាយ ជាតក ទ្វាទសមភាគ ៦៣ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ព.ស.២៥០៣។ បើតាមអ្នកប្រាជ្ញអក្សរសាស្ត្រ បានបញ្ជាក់ថាគម្ពីរដើមបង្អស់ប្រហែលជាកើតនៅក្នុងគ្រិស្តសតវត្សន៍ទី១៨ ឬ១៩ (ប្រហែលក្នុងរជ្ជកាលព្រះបាទអង្គឌួង គ.ស.១៧៩៦-១៨៦០)[១]។ រឿងនេះ ឯកសារដើមជាភាសាបាលី ក្រោយមកទើបមានការប្រែសម្រួលជាភាសាខ្មែរដោយព្រះគ្រូបុរត្ថិមវាសីអ៊ូ ចៃវ វត្តលង្កា ក្នុងព.ស.២៤៨៩។ ក្រោយមកទើបមានការបោះពុម្ពផ្សាយក្នុងឆ្នាំ១៩៥៨។ ក្នុងគ.ស.១៩៥៨ ដដែល រឿងនេះត្រូវបានគណៈកម្មការរៀបចំកម្មវិធីសិក្សានៃក្រសួងអប់រំជាតិ បានបញ្ចូលទៅក្នុងកម្មវិធីសិក្សាថ្នាក់ទី២ទំនើប។ ក្រោយមកលោក ញ៉ុក ថែម បានរួបរួមសម្រួលគម្ពីរបុរាណទាំងឡាយ ដើម្បីចងក្រងជាសៀវភៅមួយឈ្មោះថា *មហាវេស្សន្តរជាតក* បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យឆ្នាំ១៩៥៣ (លើកទី២)។ លោក ញ៉ុក ថែម ដដែលក៏បានសង្ខេបរឿងនេះពីស្នាដៃរបស់លោកមុន ហើយចងក្រងជាសៀវភៅមួយទៀតដាក់ឈ្មោះថា *មហាជាតក* បោះពុម្ពផ្សាយនៅឆ្នាំ១៩៦០ តម្រូវទៅតាមកម្រិតសមត្ថភាពសិស្សនៅមធ្យមសិក្សាមធ្យមភូមិ ដោយកាត់ចោលនូវពាក្យបាលីអស់ច្រើន។ នៅគ.ស.១៩៥៩ រឿងមហាវេស្សន្តរនេះដែរ ត្រូវបានបណ្ឌិតមហាឈឹម សុមន៍ យកមកសិក្សាជាថ្មី ដោយបញ្ចូលជាមួយរឿងឯទៀតៗក្នុងស្នាដៃ *សង្ខេបទសជាតក* របស់លោក និងបានបោះពុម្ពផ្សាយចំនួន៦លើកកន្លងមកហើយ។

គួរកត់សម្គាល់ថា រឿងមហាវេស្សន្តរនេះ ត្រូវបានជ្រាបចូលក្នុងចិត្តសន្តាននៃប្រជាជនខ្មែរទាំងចាស់ក្មេងស្ទើរទូទាំងប្រទេសផងដែរ។ មិនតែប៉ុណ្ណោះ ស្នាដៃជាតកនេះ ក៏បានជ្រួតជ្រាបក្នុងសន្តានចិត្តនៃប្រជាជនមួយចំនួននៅតំបន់អាស៊ីភាគអាគ្នេយ៍ផងដែរ ជាពិសេសគឺបណ្តាប្រទេសដែលនិយមគោរពបដិបត្តិតាមពុទ្ធសាសនា ដូចជា ថៃ ឡាវ ភូមា ជាដើម។

---

[១] លាង ហាប់ អាន *អត្ថាធិប្បាយកថា រឿងមហាវេស្សន្តរជាតក* ភ្នំពេញ ផ្សាយចេញពីរោងពុម្ពសឹង-ហេង គ.ស.១៩៦៥ ទំព័រ ៣-៤ ។

## ២-សិក្សារឿងមហាវេស្សន្តរជាតក

ចំពោះការសិក្សាលើស្នាដៃមហាវេស្សន្តរនេះ គ្រាន់តែជាផ្នែកមួយនៃការស្រាវជ្រាវរបស់យើងខ្ញុំនៅលើប្រធានបទ «**ទស្សនាទានអប់រំចរិយាធម៌តាមរយៈអក្សរសិល្ប៍ពុទ្ធនិយមខ្មែរ**» (Khmer Ethics Education Perspective Through Buddhism Literature) តែប៉ុណ្ណោះ ហើយក្នុងសិក្សានេះទៀតសោត យើងខ្ញុំផ្ដោតទៅលើតែតម្លៃអប់រំចរិយាធម៌ក្នុងស្នាដៃ និងស្វែងយល់ពីលក្ខណៈឆ្លុះបញ្ចាំងក្នុងសង្គមខ្មែរតែប៉ុណ្ណោះ។

ក្នុងការសិក្សាស្វែងយល់ពីតម្លៃចរិយាធម៌តាមរយៈរឿងមហាវេស្សន្តរនេះ យើងបានមើលឃើញនូវតម្លៃអប់រំមួយចំនួនដែលបង្ហាញពីចរិយាធម៌របស់តួអង្គដូចជា ការធ្វើទាន ការមាននូវព្រហ្មវិហារធម៌របស់មាតាបិតា និងការបណ្ដុះនូវស្មារតីសន្តិភាពរបស់តួអង្គ ជាដើម ហើយតម្លៃទាំងនេះយើងនឹងធ្វើការបង្ហាញលម្អិតដូចខាងក្រោមៈ

### ក-ការធ្វើទានរបស់តួអង្គព្រះវេស្សន្តរ

រឿងមហាវេស្សន្តរជាតក បានបង្ហាញនូវតម្លៃអប់រំពីការធ្វើទាន។ ការធ្វើទានរបស់តួអង្គព្រះវេស្សន្តរ បានបង្ហាញត្រង់ចំណុចការលះបង់នូវទ្រព្យសម្បត្តិ ប្រពន្ធ កូន និងអវយវៈរបស់ទ្រង់ឱ្យជាទានដល់ស្មូមយាចកទាំងឡាយ។ ការធ្វើទានរបស់តួអង្គព្រះវេស្សន្តរ មានពីរកម្រិត គឺកម្រិតស្រាល និងកម្រិតធ្ងន់។ កម្រិតស្រាល បានដល់ការបរិច្ចាគនូវគ្រឿងឧបភោគបរិភោគដល់ស្មូមយាចកទាំងឡាយ ដូចជា ការឱ្យនូវបាយ ទឹក នំ ចំណី គោ ក្របី ដំរី សេះ ។ល។ ហើយការបរិច្ចាគនេះមិនមានលក្ខណៈអស្ចារ្យអ្វីប៉ុន្មាននោះទេ ព្រោះថាជាទង្វើដែលអ្នកដទៃក៏អាចធ្វើបានដូចលោកដែរ។ កម្រិតធ្ងន់ បានដល់ការហ៊ានបរិច្ចាគនូវសម្បត្តិទ្រព្យដែលកម្រឱ្យទៅជាទាន ដូចជា ដំរីមង្គល ប្រពន្ធ កូន និងអវយវៈជាដើម។ ការធ្វើទាននេះមានលក្ខណៈខ្លាំងក្លាកម្រមានបុគ្គលធ្វើបានដូចជាទ្រង់។

ការបរិច្ចាគនូវសម្បត្តិទ្រព្យ ក៏ដូចជា ប្រពន្ធ កូន និងអវយវៈជាដើមឱ្យទៅជាទាននេះ បានបង្ហាញនូវព្រះទ័យករុណាដ៏ខ្លាំងក្លារបស់ព្រះពោធិសត្វ ដែលតែងមានចិត្តអាណិតអាសូរចំពោះអ្នកក្រកំសត់ទុគ៌តគ្មានទីពឹង។ នេះជាតម្លៃចរិយាធម៌ដែលកើតមានតាមរយៈចិត្តមេត្តាករុណារបស់តួអង្គព្រះវេស្សន្តរ។ គ្រាមួយនៅពេលរដ្ឋក្លិង្គរាស្ត្រកើតទុរភិក្ស ព្រោះតែអត់ទឹកភ្លៀង មានព្រាហ្មណ៍៨នាក់ បានចូលមកសូមដំរីបច្ច័យនាគេន្ទ្រពីព្រះវេស្សន្តរ ទ្រង់បានលះបង់ឱ្យព្រាហ្មណ៍ទាំងនោះដោយគ្មានចិត្តស្ដាយស្រណោះ។ ដំណឹងនេះបានធ្វើឱ្យពួកអ្នកស្រីពិរាស្ត្រកើតការក្ដៅក្រហាយនឹងព្រះអង្គ រហូតសូមឱ្យបំបរបង់ទ្រង់ចេញពីព្រះនគរទៀតផង។ ដូចសម្ដីអាមាត្យបានក្រាបទូលទៅកាន់ព្រះវេស្សន្តរថា «*...បពិត្រព្រះទេវៈ ពួកអ្នកសិវិរាស្ត្រ ពួកអ្នកនិគម ពួកអ្នកមានកេរ្តិ៍ឈ្មោះ ពួករាជបុត្ត ពួកអ្នកជំនួញ នឹងពួកព្រាហ្មណ៍ ប្រជុំគ្នា ខឹងនឹងព្រះអង្គហើយ។ លុះរាត្រីនោះអស់ហើយ ព្រះអាទិត្យក៏រះឡើង ពួកអ្នកសិវិរាស្ត្រ ព្រមព្រៀង*

*គ្នានឹងបណ្ដេញព្រះអង្គចាកដែនព្រោះតែការប្រទានដំរី...*»។ ទោះបីការធ្វើទានរបស់ព្រះវេស្សន្តរ ធ្វើឱ្យប្រជារាស្ត្រមួយចំនួនមិនសប្បាយចិត្ត ដែលបញ្ហានេះគឺជាឧបសគ្គសម្រាប់ទ្រង់ក៏ដោយក៏ព្រះវេស្សន្តរមិនបញ្ឈប់ក្នុងការឱ្យទានដែរ។ ដូចសម្ដីរបស់លោកពោលទៅកាន់អាមាត្យថា «...*យើងចង់ឱ្យបេះដូង ឬភ្នែកផង, ទ្រព្យជាខាងក្រៅរបស់យើង គឺប្រាក់ មាស កែវមុក្តា កែវ ពិទូរ្យ នឹងកែវមណី ជាប្រយោជន៍អ្វី បើយើងបានឃើញស្មូមមកសុំដៃស្តាំ ឬដៃឆ្វេង គួរតែឱ្យមិនគប្បីរំភើបទេ(ព្រោះថា)ចិត្តរបស់យើងរីករាយក្នុងការឱ្យ(ទាន)*[៣]...»។ នេះជាទំហំទឹកចិត្តរបស់តួអង្គពោធិសត្វ ដែលតែងតែមានសេចក្ដីករុណាចំពោះសព្វសត្វ ដែលជួបប្រទះនូវទុក្ខលំបាកក្នុងជីវិត។ ព្រះទ័យករុណានេះ មានលក្ខណៈធំធេងបើប្រៀបនឹងទឹកចិត្តមនុស្សទូទៅ ព្រោះទំហំនៃការលះបង់របស់លោកអាចសបញ្ជាក់ពីចិត្តដែលខ្ពស់ពីអ្នកដទៃត្រឹមកម្រិតណា យើងឃើញទោះបីប្រពន្ធ កូន អវយវៈ ក៏ទ្រង់សុខចិត្តលះបង់ដែរឱ្យតែគេបានសុខ។ ម្យ៉ាងទៀត គោលដៅដ៏ចម្បងបំផុតនៃការធ្វើទានរបស់តួអង្គព្រះវេស្សន្តរ គឺដើម្បីការត្រាស់ដឹងជាព្រះពុទ្ធ នាំសព្វសត្វចេញចាកកងទុក្ខ។ ដូច្នេះការលះបង់ទ្រព្យសម្បត្តិ ប្រពន្ធ កូន និងជីវិតរបស់ទ្រង់មួយ ដើម្បីដូរមកវិញនូវការត្រាស់ដឹងគឺជារឿងដែលទ្រង់គួរតែបំពេញហើយ។ នេះជាព្រះទ័យករុណារបស់តួអង្គព្រះពោធិសត្វ ដែលមានចំពោះមនុស្សសត្វទូទៅ។

### ខ-អំពីព្រហ្មវិហារធម៌

រឿងមហាវេស្សន្តរជាតក បានបង្ហាញនូវតម្លៃអប់រំអំពីព្រហ្មវិហារធម៌របស់មាតាបិតាផងដែរ។ ព្រហ្មវិហារធម៌នេះបានបង្ហាញតាមរយៈទឹកចិត្តមេត្តា ករុណា និងសេចក្ដីសន្តោសរបស់តួអង្គមួយចំនួននៅក្នុងរឿង ដូចជា ព្រះបាទស្រីសញ្ជ័យ នាងផុស្សតី ព្រះវេស្សន្តរ នាងមទ្រី ដែលតែងមានចិត្តករុណា អធ្យាស្រ័យ និងក្តីសន្តោសចំពោះជនជាទីស្រឡាញ់របស់ខ្លួនដូចជា ប្រពន្ធ កូន ជាដើម។

តាមរយៈតួអង្គព្រះបាទស្រីសញ្ជ័យ និងព្រះនាងផុស្សតី បានបង្ហាញពីព្រហ្មវិហារធម៌ តាមរយៈទឹកចិត្តដែលអាណិតស្រឡាញ់បុត្រ ពិសេសទៅលើតួអង្គព្រះវេស្សន្តរផ្ទាល់តែម្តង។ ចាប់តាំងពីព្រះពោធិសត្វចុះចាប់បដិសន្ធិក្នុងផ្ទៃកាលណា ព្រះនាងផុស្សតី និងព្រះស្វាមី តែងយកព្រះទ័យទុកដាក់មើលថែបុត្ររហូតដល់ធំពេញវ័យ។ ក្រោយព្រះជន្មបាន១៦ព្រះវស្សា ព្រះមាតាបិតាបានរៀបអភិសេក ហើយប្រគល់រាជសម្បត្តិឱ្យគ្រងរាជ្យជំនួសទ្រង់រហូតទៅ។ ពេលមួយ ព្រះវេស្សន្តរបានប្រទាននូវដំរីមង្គលឈ្មោះបច្ច័យនាគេន្ទ្រ ដល់ពួកព្រាហ្មណ៍នៃរដ្ឋក្លិង្គរាស្ត្រ។ ដំណើរនេះបានឮទៅដល់ពួកអ្នកស្រីពិរាស្ត្រៗ បានមកប្រជុំគ្នាតវ៉ាប្រឆាំង ទីបំផុតសូមឱ្យព្រះបាទស្រីសញ្ជ័យ ជាព្រះបិតា បំបរបង់ព្រះវេស្សន្តរចេញពីព្រះនគរ។ ព្រះបាទស្រី

---

[២] ពុទ្ធសាសនបណ្ឌិត្យ *ព្រះត្រៃបិដកបាលី និង សេចក្ដីប្រែជាភាសាខ្មែរ សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទ្វាទសមភាគ៦៣* ភ្នំពេញ ព.ស.២៥០៣ ទំព័រ១០២-១០៣។

[៣] -ដ- ទំព័រ១០៣។

សញ្ជ័យបានបដិសេធ ដោយទ្រង់ត្រាស់ថា «...*ជនបទសាបសូន្យទៅចុះ ទាំងដែនទៀតក៏វិនាសទៅចុះ យើងមិនបណ្ដេញរាជបុត្រ ដែលជាអ្នកមិនប្រទូស្ត ឱ្យចេញចាកដែនរបស់ខ្លួនតាមសំដីពួកអ្នកសិវិរាស្ត្រទេ ដ្បិតកូនប្រុសនេះ ពិតជាកើតពីទ្រូងយើង។ ...មួយទៀត យើងមិនគួរប្រទូស្តចំពោះកូនយើងនោះទេ ព្រោះថាកូនយើងនោះ ជាអ្នកមានសីលនិងវត្តដ៏ប្រសើរ ដំណេះដំនៀលនឹងមានដល់យើងផង យើងត្រូវសោយបាបច្រើនផង យើងនឹងសម្លាប់វេស្សន្តរជាកូនដោយគ្រឿងសស្ត្រាដូចម្ដេចបាន*[៤]»។ នេះជាអារម្មណ៍ឃាំងឃាបង្ហាញពីទឹកចិត្តព្រហ្មវិហារធម៌របស់តួអង្គព្រះបាទស្រីសញ្ជ័យ។

ចំណែកព្រះនាងផុស្សតី ជាព្រះមាតា ក្រោយបានដំណឹងថាព្រះវេស្សន្តរ ត្រូវបានប្រជារាស្ត្រខឹងស្អប់ហើយបំបរបង់ចេញពីព្រះនគរ ព្រះនាងមានព្រះហឫទ័យតក់ស្លុតខ្សឹកខ្សួលអួលអាក់តឹងណែនព្រះឱរាសោយសោកជាអនេក ព្រះនាងបានពោលឡើងថា« *ឱ!អាត្មាអញអើយ! ពុំគួររស់នៅឡើយ គួរតែបរិភោគថ្នាំពិស ឬលោតទម្លាក់ក្នុងជ្រោះ ពុំនោះចងកនឹងខ្សែឱ្យស្លាប់គ្រាប់ប្រសើរជាងរស់នៅ, ម្ដេចឡើយក៏ពួកស្រីពិរាស្ត្រ បណ្ដេញបាវេស្សន្តរជាកូនអញ ជាអ្នកមិនប្រទូស្តសោះដូច្នោះ។ ព្រះនាងទ្រង់ព្រះកន្សែង ថ្លែងសេចក្ដីទោមនស្សច្រើនប្រការ* [៥]...»។ នេះជាព្រះទ័យខ្វល់ខ្វាយបង្ហាញពីព្រហ្មវិហារធម៌របស់តួអង្គព្រះនាងផុស្សតី។

ចំពោះតួអង្គព្រះវេស្សន្តរ និងនាងមទ្រី វិញ ក៏បានបង្ហាញនូវទឹកចិត្តមេត្តាករុណាជាតួនៃព្រហ្មវិហារធម៌នេះដែរ។ ចំណុចដែលបង្ហាញពីព្រហ្មវិហារធម៌នេះ គឺតាមរយៈការនៅរួមរស់ដោយសុខសាន្តក្នុងព្រះនគរ និងភាពកក់ក្ដៅក្នុងព្រៃហេមពាន្តនៃកុមារទាំងពីរ( ជាលីក្រិស្ណា )។ ការរស់នៅក្នុងព្រះនគរ ជាក្ដីសុខសាន្តមួយបែបដែលកើតចេញពីការមានសព្វមានគ្រប់ និងដោយទឹកចិត្តមេត្តាករុណារបស់មាតាបិតា និងព្រះអយ្យកោ អយ្យិកា ទៅលើកុមារទាំងពីរ តែបើទោះបីជានៅក្នុងព្រៃភ្នំគិរីវង្កតហើយ ក៏កុមារទាំងពីរមានភាពកក់ក្ដៅដែរព្រោះបានមាតាបិតាមើលថែដោយយកចិត្តទុកដាក់។ នេះជាច្បាប់ធម្មជាតិ ទោះបីរស់នៅទីណាក៏ដោយសម្រាប់កុមារដែលមានឪពុកម្ដាយនៅរួមរស់ជាមួយ គឺមានភាពកក់ក្ដៅជានិច្ច មិនថាមានឬក្រ។ នេះជាសច្ចភាពនៃច្បាប់ធម្មជាតិ។ យ៉ាងណាមិញកុមារទាំងពីរដែលរួមរស់ជាមួយមាតាបិតាក៏ដូចគ្នាដែរ។ ព្រះវេស្សន្តរ បើទោះបីក្នុងលក្ខខណ្ឌខ្លះលោកត្រូវតែបរិច្ចាគបុត្រទៅជាទាន តែមិនមែនមានន័យថាលោកគ្មានមេត្តាចំពោះបុត្រនោះទេ។ មានហេតុផលជាច្រើនដែលបង្ហាញពីចិត្តមេត្តាករុណារបស់តួអង្គព្រះវេស្សន្តរមានចំពោះបុត្រដូចជាៈ

មុនពេលទ្រង់ចាកចេញពីព្រះនគរឆ្ពោះទៅភ្នំគិរីវង្កត ទ្រង់បានផ្ដែផ្ដាំទៅនាងមទ្រីជាមហេសីថា « *ម្នាលនាងមទ្រី នាងត្រូវមេត្តាបុត្ត ព្រះមាតាក្មេកនឹងព្រះបិតាក្មេក មួយទៀតបើអ្នក*

---

[៤] ពុទ្ធសាសនបណ្ឌិត្យ ***ព្រះត្រៃបិដកបាលី និង សេចក្ដីប្រែជាភាសាខ្មែរ សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទ្វាទសមភាគ៦៣*** ដ.ឯ.ម. ទំព័រ១០០-១០១។

[៥] ឈឹម ស៊ុម ***សង្ខេបទសជាតក*** ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ គ.ស.១៩៥៩ ទំព័រ៣១៨។

*ណាសំគាល់ថានឹងធ្វើជាប្តីនាង នាងចូរបំរើអ្នកនោះដោយគោរពចុះ។ បើគ្មានគេសំគាល់ថានឹងធ្វើជាប្តីនាងទេ កាលនាងព្រាត់ប្រាស់អំពីយើងទៅហើយ នាងចូរស្វែងរកប្តីដទៃទៀតចុះ កុំឱ្យនាងលំបាក ព្រោះព្រាត់ប្រាស់អំពីយើងឡើយ*[៦]»។ តាមរយៈពាក្យសម្តីដែលលោកពោលខាងលើ បានបង្ហាញពីអារម្មណ៍ខ្វល់ខ្វាយចំពោះសុខទុក្ខ ប្រពន្ធ កូន ក្រោយអត់អំពីលោកទៅ។

ចំណុចមួយទៀត ក្រោយពេលព្រះវេស្សន្តរប្រទានបុត្រទាំងពីរឱ្យទៅជូជកព្រាហ្មណ៍ហើយ ជូជកបណ្តើរកុមារទៅបានបន្តិចក៏ជម្ពប់ជើងដួល កុមារទាំងពីររត់ត្រឡប់មកវិញ ហើយចូលពួនក្នុងស្រះទឹក ពេលនោះព្រះវេស្សន្តរ បានលួងលោមបុត្រទាំងពីរឱ្យត្រឡប់មកវិញដោយពោលថា «*ហៃកូនទាំងពីរជាទីស្រឡាញ់របស់បិតា ចូរកូនមកអាយ ចូរបំពេញបារមីរបស់បិតា ចូរស្រោចស្រពហឫទ័យរបស់បិតា ចូរកូនតាំងខ្លួនជាយាននាវា ឱ្យបិតានាំសត្វជិះឆ្លងចាកជាតិ ជរាព្យាធិមរណៈ ទៅកាន់ត្រើយនាយគឺព្រះនិព្វានណ៎ាកូន!*[៧]»។ ក្រោយបានកុមារទាំងពីរមកហើយ ជូជកបានវាយធ្វើបាបឥតត្រាប្រណីនៅចំពោះព្រះភក្ត្រព្រះវេស្សន្តរ។ ព្រះពោធិសត្វឃើញអាកប្បកិរិយាជូជកព្រាហ្មណ៍ ដែលសាហាវឃោឃៅ ទ្រង់ទប់ចិត្តមិនបានស្ទុះទៅកញ្ឆក់ព្រួញព្រះខ័ន បម្រុងតាមប្រហារជូជកព្រាហ្មណ៍ចោល តែដោយរលឹកដឹងទាន់ថាវិស័យព្រះពុទ្ធទាំងឡាយពីបុរាណក៏លោកបំពេញមហាបរិច្ចាគទាំងប្រាំដែរ[៨]។ គិតដូច្នេះហើយ ទ្រង់ក៏ដាក់គ្រឿងសស្ត្រាវុធចុះវិញហើយចូលទៅក្នុងព្រះបរមសាលាពោលរៀបរាប់តែម្នាក់ឯងថា«...*កោតតែព្រាហ្មណ៍នោះហ៊ានវាយកូនទាំងពីររបស់អញ ជាអ្នកមិនមានកំហុសក្នុងទីចំពោះមុខអញមិនអៀនខ្មាស់ ព្រាហ្មណ៍នេះ ហៅពេញជាមនុស្សឥតអៀនខ្មាស់។ អ្នកមានសេចក្តីអៀនខ្មាស់ពុំហ៊ានវាយពួកជនសូម្បីជាខ្ញុំប្រុសស្រី ឬអ្នកបម្រើដទៃរបស់អញដែលលះឱ្យហើយនោះទេ។ ព្រាហ្មណ៍នេះហ៊ានដេរ ហ៊ានវាយដំកូនសម្លាញ់របស់អញនៅចំពោះមុខអញ*[៩]»។ នេះជាព្រះទ័យករុណាបង្ហាញពីព្រហ្មវិហារធម៌របស់តួអង្គព្រះវេស្សន្តរ។

ចំពោះព្រះនាងមទ្រីវិញ ក៏មិនខុសប្លែកគ្នាពីព្រះវេស្សន្តរដែរ នៅពេលព្រះនាងសម្រេចព្រះទ័យយាងទៅតាមព្រះវេស្សន្តរ, ព្រះមាតាបិតាបានប្រាប់ថាបើនាងទៅតាមព្រះស្វាមី ចូរនាងទុកកូនតូចទាំងពីរ យើងជាអ្នកចិញ្ចឹម កុំឱ្យមានការព្រួយលំបាក។ នាងមទ្រីតបថា កូនតូចទាំងពីរនឹងញ៉ាំងហឫទ័យនៃយើងខ្ញុំ ដែលក្រំដោយសំណោកឱ្យត្រេកអរក្នុងព្រៃបាន។ ទោះដឹងថាការរស់នៅក្នុងព្រៃលំបាក មានបញ្ហាច្រើនត្រូវដោះស្រាយ តែការទ្រាំលំបាកដើម្បីកូន

---

[៦] ពុទ្ធសាសនបណ្ឌិត្យ ***ព្រះត្រៃបិដកបាលី និង សេចក្តីប្រែជាភាសាខ្មែរ សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទ្វាទសមភាគ៦៣*** ជ.ឯ.ម. ទំព័រ១០៥។

[៧] ឈឹម ស៊ុម ***សង្ខេបទសជាតក*** ជ.ឯ.ម. ទំព័រ៣៣៩។

[៨] មហាបរិច្ចាគទាំង៥មានៈ ធនបរិច្ចាគ១ បុត្តបរិច្ចាគ១ ភរិយាបរិច្ចាគ១ អង្គបរិច្ចាគ១ ជីវិតបរិច្ចាគ១។

[៩] ពុទ្ធសាសនបណ្ឌិត្យ ***ព្រះត្រៃបិដកបាលី និង សេចក្តីប្រែជាភាសាខ្មែរ សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទ្វាទសមភាគ៦៣*** ជ.ឯ.ម. ទំព័រ១៧១-១៧២។

ក៏ជាការសប្បាយចិត្តរបស់តួអង្គនាងមទ្រី។ ត្រង់ចំណុចនេះ បើនិយាយក្នុងន័យទូទៅចំពោះមាតាបិតាដែលស្រឡាញ់កូនដោយពិតប្រាកដ ទោះបីបិតក្នុងកាលៈទេសៈបែបណាក៏ដោយក៏មិនរួញរាចិត្តដែរ ឱ្យតែកូនបានសុខ។ នេះជាទឹកចិត្តរបស់មាតាបិតាដែលស្រឡាញ់កូនដោយពិតប្រាកដ។ ចំណុចមួយទៀត ក្រោយពេលនាងមទ្រីយាងត្រឡប់ពីរកបេះផ្លែឈើវិញមិនឃើញបុត្រទាំងពីររត់មកទទួលដូចសព្វដង ព្រះនាងមានពិភាល់សង្ស័យ ចូលទៅសួរព្រះស្វាមីតែព្រះពោធិសត្វមិនតប ព្រះនាងមានការព្រួយបារម្ភជាខ្លាំង ដើររកសព្វកន្លែងដែលបុត្រទាំងពីរធ្លាប់លេង ព្រះនាងកើតទុក្ខខ្លាំងក្លា ដើរស្រែករកកូនទាំងយប់អាធ្រាត្រ ត្រាតែអស់កម្លាំងដួលសន្លប់បាត់ស្មារតីនៅមុខព្រះបរមសាលា កន្លែងព្រះពោធិសត្វចម្រើនភាវនា។ នេះជាព្រះរាជហឫទ័យបង្ហាញពីព្រហ្មវិហារធម៌របស់តួអង្គនាងមទ្រី។

តាមរយៈទង្វើរបស់តួអង្គខាងលើ ពិតជាបានបង្ហាញនូវលក្ខណៈនៃព្រហ្មវិហារធម៌របស់មាតាបិតាយ៉ាងពិតប្រាកដ ព្រោះតាមរយៈសកម្មភាពរបស់តួអង្គសុទ្ធតែបង្ហាញពីទឹកចិត្តខ្វល់ខ្វាយចំពោះសុខទុក្ខរបស់កូនជានិច្ចកាល។

### គ-ការបណ្តុះស្មារតីសន្តិភាពតាមរយៈតួអង្គព្រះវេស្សន្តរ

តាមរយៈរឿងព្រះវេស្សន្តរជាតក បានឆ្លុះបញ្ចាំងពីស្មារតីសន្តិភាព។ ស្មារតីសន្តិភាពតាមរយៈរឿងនេះ បានបង្ហាញត្រង់ឥរិយាបថផ្ទាល់របស់ព្រះពោធិសត្វដែលប្រកាន់យកនូវគោលគំនិតសន្តិភាពនិយមក្នុងការដោះស្រាយបញ្ហា។ ក្រោយពេលទ្រង់បានប្រទាននូវដំរីបច្ច័យនាគេន្ទ្រ (ជាដំរីមង្គលប្រចាំព្រះនគរពិជ័យជេតុត្តរ) ដល់ពួកព្រាហ្មណ៍នៃរដ្ឋកលិង្គរាស្ត្រ ប្រជារាស្ត្រក្នុងព្រះនគរ មួយអន្លើដោយមន្ត្រីយោធាបាននាំគ្នាធ្វើបាតុកម្មប្រឆាំងនឹងព្រះអង្គ ទីបំផុត ប្រជារាស្ត្រទាំងនោះសូមឱ្យបំបរបង់ទ្រង់ចេញពីព្រះនគរ។ ព្រះវេស្សន្តរ ក្រោយដឹងពីបំណងរបស់រាស្ត្រ មិនចង់ឱ្យទ្រង់គង់នៅក្នុងព្រះនគរ ទ្រង់ក៏ព្រមចាកចេញទៅគង់នៅភ្នំគិរីវង្កត។ ពេលទ្រង់យាងដល់នគរចេតរាស្ត្រ ស្តេចចេតរាស្ត្រទាំង១០១នគរ បានព្រមថ្វាយរាជសម្បត្តិដល់ទ្រង់ តែទ្រង់បដិសេធមិនទទួល ព្រោះមិនចង់ឱ្យមានជម្លោះកើតឡើងដោយសារតែទ្រង់ម្នាក់។ ដូចសេចក្តីបញ្ជាក់ថា «*...(ពួកព្រះរាជាចេតៈ) បពិត្រព្រះអង្គអ្នកញ៉ាំងដែនឱ្យចំរើន បើដំណើរហ្នឹងមានក្នុងដែននុ៎ះមែន សូមព្រះអង្គដែលពួកព្រះរាជាចេតៈចោមរោម ទ្រង់សោយរាជ្យក្នុងដែននេះចុះ។ ឯដែននេះជាដែនស្តុកស្តម្ភទូលាយ ជនបទក៏ស្តុកស្តម្ភធំ បពិត្រព្រះវេៈ សូមព្រះអង្គទ្រង់ធ្វើសេចក្តីពេញព្រះទ័យដើម្បីនឹងគ្រប់គ្រងរាជ្យ។ (ព្រះវេស្សន្តរ...) យើងដែលគេបណ្តេញអំពីដែនហើយមិនប្រាថ្នា មិនមានសេចក្តីពេញចិត្ត ដើម្បីនឹងគ្រងរាជ្យទេ ម្នាលពួកចេតបុត្រ អ្នកចូរស្តាប់ខ្ញុំ។ បើពួកព្រះរាជាចេតៈអភិសេកយើង ដែលគេបណ្តេញចាកដែនក្នុងរាជ្យហើយ ពួកអ្នកសិវិរាស្ត្រណា ជានាយពលក្តី ជាអ្នកនិគមក្តី ពួកអ្នកសិវិរាស្ត្រនោះមិនត្រេកអរទេ។ ទាំងមិនមានសេចក្តីស្នេះស្និទ្ធនឹងអ្នកទាំងឡាយ ព្រោះហេតុតែខ្ញុំដោយពិតខ្ញុំមិនគាប់ចិត្តនឹងកើតមានការប្រេកួតប្រកាន់ដ៏ពន្លឹក ការវាយដំគ្នាយ៉ាងសម្បើមនឹងមានមិន*

*ខាន ជនជាច្រើនគប្បីបៀតបៀនគ្នា ព្រោះហេតុតែខ្ញុំម្នាក់ឯង។ វត្ថុណាដែលអ្នកទាំងអស់គ្នាធ្វើឱ្យជារបស់មានតម្លៃបានដល់ខ្ញុំ វត្ថុនោះខ្ញុំបានទទួលហើយ ព្រះរាជាទ្រង់បណ្តេញខ្ញុំ ខ្ញុំនឹងទៅភ្នំវង្កត ម្នាលសំឡាញ់ទាំងឡាយ អ្នកទាំងឡាយ ចូរដឹងឱកាសជាទីនៅក្នុងព្រៃ*[១០]»។ តាមរយៈពាក្យសម្តីខាងលើអាចបញ្ជាក់បានថា ក្នុងស្មារតីរបស់តួអង្គព្រះវេស្សន្តរពិតជាចង់រក្សានូវសន្តិភាព ស្ថេរភាព នៃព្រះនគរទាំងមូល។ ទ្រង់មិនអាចឱ្យព្រះនគរមានជម្លោះព្រោះតែទ្រង់ម្នាក់នោះទេ។ នេះជាស្មារតីសន្តិភាពមួយតាមរយៈតួអង្គព្រះវេស្សន្តរ។

## ៣-សេចក្តីសន្និដ្ឋាន

ក្រោយការសិក្សាលើរឿងមហាវេស្សន្តរជាតករួចមក យើងឃើញតាមរយៈអក្សរសិល្ប៍នេះ បានបង្ហាញនូវតម្លៃអប់រំមួយចំនួន ដែលឆ្លុះបញ្ចាំងពីតថៈភាពរស់នៅជាក់ស្តែងរបស់មនុស្សក្នុងសង្គម ដូចជា ការធ្វើទាន ការមាននូវព្រហ្មវិហារធម៌របស់មាតាបិតា និងការបង្ហាញពីស្មារតីសន្តិភាព ជាដើម ហើយតម្លៃទាំងនេះក៏បានឆ្លុះបញ្ចាំងពីជីវភាពរស់នៅរបស់មនុស្សក្នុងសង្គមយ៉ាងពិតប្រាកដទៀតផង។ នេះជាតម្លៃចរិយាធម៌យ៉ាងពិតប្រាកដដែលឆ្លុះបញ្ចាំងតាមរយៈស្នាដៃរឿងមហាវេស្សន្តរជាតក។

ដូច្នេះ តាមខ្លឹមសារដូចបានរៀបរាប់ខាងលើយើងអាចធ្វើសេចក្តីសន្និដ្ឋានបានថា រឿងមហាវេស្សន្តរជាតក ពិតជាបានផ្តល់នូវតម្លៃអប់រំចរិយាធម៌ដល់មនុស្សជាតិយ៉ាងពិតប្រាកដ ហើយតម្លៃនេះ ក៏បានឆ្លុះបញ្ចាំងពីសង្គមជាក់ស្តែងរបស់មនុស្សផងដែរ។

---

[១០] ពុទ្ធសាសនបណ្ឌិត្យ *ព្រះត្រៃបិដកបាលី នឹងសេចក្តីប្រែជាភាសាខ្មែរ សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទ្វាទសមភាគ ៦៣* ភ្នំពេញ ព.ស.២៥០៣ ទំព័រ១៣៣-១៣៤។

# គន្ថនិទ្ទេស


**១-ឯកសារតែងនិពន្ធជាភាសាខ្មែរ៖**

១- គឹម សែត *ប្រវត្តិអក្សរសាស្ត្រខ្មែរ* ភ្នំពេញ ឆ្នាំ១៩៧១

២- ឃីង ហុកឌី *ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ*, Paris, L'Harmattan, 1997

៣- ឈឹម សុមន៍ *សង្ខេបទសជាតក៍* ភ្នំពេញ ការផ្សាយរបស់ក្រសួងពុទ្ធិសាសន បណ្ឌិត្យ ឆ្នាំ១៩០២

៤- ញ៉ុក ថែម *បញ្ញាសជាតក* ភ្នំពេញ មហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្ស សាស្ត្រ ឆ្នាំ១៩៦៣

៥- ត្រឹង ងា *អរិយធម៌ខ្មែរ* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ១៩៧៤

៦- ធសោ *អក្សរសិល្ប៍ពុទ្ធនិយម* ភ្នំពេញ ឆ្នាំ១៩៩៤

៧- ប៉ាង ខាត់ *ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ* ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសន បណ្ឌិត្យ ព.ស.២៥០៤

៨- ពុទ្ធសាសនបណ្ឌិត្យ *ព្រះត្រៃបិដកបាលី នឹងសេចក្តីប្រែជាភាសាខ្មែរ សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទ្វាទសមភាគ៦៣* ភ្នំពេញ ព.ស.២៥០៣

៩- ពុទ្ធសាសនបណ្ឌិត្យ *ព្រះត្រៃបិដកបាលី នឹងសេចក្តីប្រែជាភាសាខ្មែរ សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ឯកាទសមភាគ៦២* ភ្នំពេញ ព.ស.២៥០០

១០- ភាជ ណាង *អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម* ភ្នំពេញ ឆ្នាំ២០១៥

១១- យិន នឿន *មហាវេស្សន្តរជាតក*, USA, ឆ្នាំ១៩៩១

១២- លី ធាមតេង *អក្សរសាស្ត្រខ្មែរ* ភ្នំពេញ បណ្ណាគារសេង ងួន ហ៊ួត ឆ្នាំ១៩៦០

១៣- លាង ហាប់អាន *អត្ថាធិប្បាយកថា រឿងមហាវេស្សន្តរជាតក* ភ្នំពេញ ផ្សាយ ចេញពីរោងពុម្ព សឹង ហេង ឆ្នាំ១៩៦៥

១៤- សែម សូរ *អធិប្បាយមហាវេស្សន្តរជាតក* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ១៩៦៨

**២-ឯកសារជាភាសាបរទេស៖**

១៥- King Hoc Dy, *Khmer Literature since 1975,* in: Cambodia Culture since 1975, Cornell University Press, London, 1994.

១៦- Jacquie Nepot: *Literature and society in modern Cambodia.* Singapore University Press, 1981.

# ទិដ្ឋភាព និងនិន្នាការអក្សរសិល្ប៍

បេក្ខជនបណ្ឌិតៈ **ឡុច សំបូរ**

## ១.និន្នាការ

ពាក្យ«**និន្នាការ**»តាមន័យដែលបានកំណត់ក្នុងវចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជ**ជួន ណាត** បោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យឆ្នាំ១៩៦៧ថា*គឺអាការដែលទេតទៅ ឬដែលលម្អៀងទៅម្ខាងៗ(ប្រទេសនេះមាននិន្នាការទៅខាងឆ្វេង ប្រទេសនោះមាននិន្នាការទៅខាងស្ដាំ ប្រទេសនោះអព្យាក្រឹត្យឋិតនៅត្រង់កណ្ដាលឥតមាននិន្នាការទៅ ខាងឆ្វេង ឬទៅខាងស្ដាំឡើយ*[១] *)*។

## ២.និន្នាការអក្សរសិល្ប៍

**និន្នាការ**នៅក្នុងអក្សរសិល្ប៍គឺសំដៅទៅលើភាពទោរទន់ឬលម្អៀងទៅម្ខាងៗមែន ប៉ុន្តែមិនមែនទោរទន់ ឬលម្អៀងដូចទំនោរនយោបាយនោះទេ ពោលគឺវាគ្រាន់តែជាការទោរទន់ ឬលម្អៀងទៅខាងផ្នែកទស្សនៈឬគំនិតប៉ុណ្ណោះ។ និន្នាការនៅក្នុងអក្សរសិល្ប៍គឺជាចរន្តមួយដែលអ្នកនិពន្ធទោរទន់ទៅរកទស្សនៈ ឬលំនាំទ្រឹស្ដីណាមួយទៅតាមការនិយមចូលចិត្តផ្ទាល់របស់ខ្លួន ហើយរចនាស្នាដៃទៅតាមទស្សនៈ ឬលំនាំនៃទ្រឹស្ដីនោះ ។

នៅពេលដែលសង្គមកម្ពុជាគោរពជឿលើព្រហ្មញ្ញសាសនា ជំនឿនឹងការគោរពប្រតិបត្តិរបស់សង្គម បានជះឥទ្ធិពលទៅដល់អ្នកនិពន្ធដែលជាហេតុនាំឱ្យស្នាដៃរបស់ពួកគេមានទំនោរឬនិន្នាការទៅរកលទ្ធិព្រាហ្មណ៍។ដូច្នេះហើយបានជាគេឃើញអក្សរសិល្ប៍ខ្មែរសម័យកាលនោះភាគច្រើន លើកយករឿងរ៉ាវរបស់អាទិទេពធំៗក្នុងព្រហ្មញ្ញសាសនា មានជាអាទិ៍ ព្រះព្រហ្ម ព្រះសិវៈ ព្រះវិស្ណុជាដើម មកធ្វើជាកម្មវត្ថុនៅក្នុងនិម្មិតកម្មស្នាដៃរបស់ខ្លួន ជាហេតុនាំឱ្យគេកំណត់ថាអក្សរសិល្ប៍សម័យកាលនោះ ជាអក្សរសិល្ប៍ព្រាហ្មណ៍និយម។ ក្រោយមកទៀត ព្រះពុទ្ធសាសនាត្រូវបានគេគោរពប្រតិបត្តិជំនួសព្រហ្មញ្ញសាសនា ពេលនោះឥទ្ធិពលនៃជំនឿនិងការគោរពប្រតិបត្តិចំពោះព្រះពុទ្ធសាសនាបានជះទៅលើអ្នកនិពន្ធដូចសម័យកាលដែលគេគោរពប្រតិបត្តិព្រហ្មញ្ញសាសនា ដែលជាហេតុនាំឱ្យអ្នកនិពន្ធមានទស្សនៈទោរទន់ទៅរកពុទ្ធសាសនា ហើយជ្រើសរើសយករឿងរ៉ាវរបស់ព្រះពុទ្ធអង្គ មកធ្វើជាកម្មវត្ថុក្នុងនិម្មិតកម្មស្នាដៃរបស់ខ្លួនហើយចរន្តអក្សរសិល្ប៍សម័យកាលនោះត្រូវបានគេកំណត់ថាអក្សរសិល្ប៍ពុទ្ធនិយម។

ក្រោយមកទៀត ការវិវត្តរបស់សង្គមមនុស្សក៏បានជះឥទ្ធិពលដល់ផ្នត់គំនិត និងការ

---

[១] ជួន ណាត *វចនានុក្រមខ្មែរ* ភាគទី១,២ បោះពុម្ពគ្រាទី៥ ភ្នំពេញ គ.ស.១៩៦៧ ទំព័រ៥១០។

យល់ឃើញរបស់អ្នកនិពន្ធ ហើយអ្នកនិពន្ធម្នាក់ៗមានសិទ្ធិបញ្ចេញទ្រឹស្តីតាមការយល់ឃើញរបស់គេដោយមានហេតុផលច្បាស់លាស់។ ពេលនោះអ្នកនិពន្ធបានងាកចេញពីការយកលទ្ធិសាសនាធ្វើជាកម្មវត្ថុក្នុងនិម្មិតកម្មស្នាដៃ មកចាប់យកតថភាពសង្គមធ្វើជាកម្មវត្ថុនៃនិម្មិតកម្មស្នាដៃវិញ បង្កើតបានចរន្តអក្សរសិល្ប៍មួយទៀតដែលគេកំណត់ថាតថនិយមឬខេមរនិយម។

### ៣. វិវត្តន៍ និងនិន្នាការសំខាន់ៗក្នុងអក្សរសិល្ប៍ខ្មែរ

### ២.១.អក្សរសិល្ប៍សម័យបុរាណ

កាលពីសម័យបុរាណ ខ្មែរបានទទួលឥទ្ធិពលសាសនាពីប្រទេសឥណ្ឌា គឺព្រហ្មញ្ញសាសនានិងពុទ្ធសាសនាមហាយាន។ព្រហ្មញ្ញសាសនាចូលមកប្រទេសខ្មែរតាមរយៈពួកឈ្មួញឥណ្ឌា ដែលជាអ្នកចេះដឹងអំពីសាសនានេះ ហើយធ្វើដំណើរតាមសំពៅមកលក់ដូរជាមួយអ្នកស្រុកខ្មែរគឺក្នុងអំឡុងស.វ.ទី១នៃគ.ស.។ ចំណែកឯពុទ្ធសាសនាវិញ នាំចូលមកតំបន់នេះតាំងពីសម័យបុរេប្រវត្តិសាស្ត្រនៃកម្ពុជា គឺតាំងពីព.ស.ទី៣ (ឆ្នាំ២៣៤[២]) មុនគ.ស.មកម្ល៉េះ។ អ្នកសិក្សាអំពីពុទ្ធសាសនានៅប្រទេសកម្ពុជាបានយកគម្ពីរ «មហាវង្ស» ប្រភពមកពីកោះលង្កាជាអំណះអំណាងបានឱ្យដឹងថា ក្រោយព្រះពុទ្ធបរិនិព្វាន២៣៤ឆ្នាំ ក្នុងរជ្ជកាលស្តេចធម្មាសោកមហារាជនៃប្រទេសឥណ្ឌាបានបញ្ជូនសមណត្ថេរពីរអង្គគឺព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរ មកផ្សព្វផ្សាយពុទ្ធសាសនានៅសុវណ្ណភូមិ គឺទឹកដីខ្មែរបុរាណ[៣]។ សម័យបុរាណសាសនានីមួយៗមានឥទ្ធិពលខ្លាំង និងមានតួនាទីសំខាន់ណាស់ក្នុងការកំណត់មនសិកាសង្គម។ លក្ខណៈសាសនាមាននៅលើគ្រប់វិស័យក្នុងស្ថាប័នរដ្ឋដូចជាប្រពៃណី ទំនៀមទម្លាប់ ជំនឿ អក្សរសិល្ប៍ ភាសា សិល្បៈ ស្ថាបត្យកម្ម រហូតដល់របៀបរស់នៅសាមញ្ញក៏បង្ហាញនូវលក្ខណៈសាមញ្ញដែរ។ ដោយឡែកក្នុងវិស័យអក្សរសិល្ប៍ សាសនា មានតួនាទីសំខាន់បំផុតក្នុងបញ្ហានិម្មិតកម្ម។ សាសនាជាប្រភពផ្តល់ឥទ្ធិពលដល់អ្នកនិពន្ធដូចជា ជួយផ្តល់ចំណេះដឹងខាងភាសា និងខាងវិធីសាស្ត្រតែងនិពន្ធព្រោះការអប់រំសិក្សា មានតែក្នុងមជ្ឈដ្ឋានសាសនា។ សាសនាជាកត្តាកំណត់គោលនិយមអក្សរសិល្ប៍ ព្រោះវាបានសណ្ឋិតក្នុងលោកទស្សនៈអ្នកនិពន្ធ[៤]។ គម្ពីរសាសនាជាប្រភពនៃដំណើររឿងជាច្រើនសម្រាប់និម្មិតកម្មអក្សរសិល្ប៍។ តែសាសនាក៏បង្កឱ្យមានលក្ខណៈអសកម្មក្នុងវិវត្តន៍អក្សរសិល្ប៍ដែរ។ ក្នុងសម័យកាលដែលសាសនា មួយគ្របដណ្តប់វាដូចជាបានកំណត់ហើយស្រេចនូវដែនគំនិតអ្នកនិពន្ធវិធីសាស្ត្រតែងនិពន្ធ និងដំណើររឿងដែលត្រូវតែងនិពន្ធស្នាដៃមានឯកភាពទូទាំងសម័យកាល។ យើងហៅស្នាដៃដែលមាន

[២] ភិក្ខុ ប៉ាង ខាត់ *ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ* ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥០៤ ទំព័រ៣៥។

[៣] ស៊ិន សំណាង *ប្រវត្តិសាស្ត្រខ្មែរ* ភ្នំពេញ គ.១៩៨៨ ទំព័រ ១-២។

[៤] ទស្សនៈផ្សេងៗរបស់អ្នកនិពន្ធលើពិភពលោក។

ឯកភាពតាមលក្ខណៈព្រាហ្មណ៍សាសនាថា ជាស្នាដៃព្រាហ្មណ៍និយម ឯស្នាដៃដែលមានឯកភាពតាមលក្ខណៈពុទ្ធសាសនាថាជាស្នាដៃពុទ្ធនិយម។

នៅសម័យអង្គរ ពេលដែលអ្នកនិពន្ធខ្មែរចាប់ផ្ដើមតាក់តែងស្នាដៃប្រលោមលោកនេះ យើងឃើញជាបឋម គឺលក្ខណៈព្រាហ្មណ៍និយមដែលកំណត់និម្មិតកម្មសម័យនោះ។ ជាទូទៅ យើងឃើញមានស្នាដៃពាក្យកាព្យបី[៥]នៃសម័យកាលនោះ ដែលកំណត់សុទ្ធសឹងត្រូវបានតាក់តែងឡើងតាមលំនាំរឿងដែលមានក្នុងព្រហ្មញ្ញសានាទាំងអស់ដូចជា៖

- រឿងរាមកេរ្តិ៍ តែងតាមលំនាំរឿងរាមាយណៈឥណ្ឌា ដែលនិយាយពីសកម្មភាពរបស់រាម អវតារទី៧របស់ព្រះវិស្ណុ(ព្រះនារាយពណ៍)អាទិពខាងទ្រទ្រង់ពិភពលោកក្នុងសាសនាព្រាហ្មណ៍។

- រឿងមហាភារតៈតែងតាមលំនាំជីវិត និងសកម្មភាពក្រឹស្ណៈអវតាទី៨របស់ព្រះវិស្ណុ។ ក្រឹស្ណៈជាតួអង្គឯកក្នុងរឿងមហាភារតៈបានសម្លាប់ឪពុកមាឈ្មោះកម្សៈដែលបានក្បត់ដណ្ដើមរាជ្យសម្បត្តិ ។

- រឿងត្រៃភព និយាយពីប្រវត្តិដើមកំណើតមនុស្ស និងសត្វលោកក្នុងភពទាំងបី គឺឋានសួគ៌ ឋានកណ្ដាល និងឋានបាដាល(ឋាននរក)តាមទស្សនៈសាសនាព្រាហ្មណ៍។

យោលតាមចំណុចព្រាហ្មណ៍និយមដែលមានក្នុងស្នាដៃទាំងនោះ យើងអាចថាគោលនិយមសំខាន់នៃអក្សរសិល្ប៍ខ្មែរសម័យអង្គរ គឺព្រាហ្មណ៍និយម។ *តែបើយើងសិក្សាបន្ថែមអំពីរឿងរាមកេរ្តិ៍នោះ យើងនឹងឃើញមានចំណុចពុទ្ធនិយមជាច្រើនក្នុងស្នាដៃបែបព្រាហ្មណ៍និយមសម័យនោះ។ ពិនិត្យលើការបង្ហាញតួអង្គព្រះរាម ជាពិសេសនោះ យើងនឹងឃើញថារឿងរាមកេរ្តិ៍ខ្មែរមិនមែនជាស្នាដៃព្រាហ្មណ៍និយមសុទ្ធសាធឡើយ ព្រោះថាតួអង្គព្រះរាមរបស់អ្នកនិពន្ធខ្មែរមិនមានលក្ខណៈជាអទិទេពតាំងពីដើមដល់ចប់ដូចក្នុងការបង្ហាញរបស់សាសនាព្រាហ្មណ៍ និងដូចលក្ខណៈ តួអង្គរាមាក្នុងរឿងរាមាយណៈរបស់ឥណ្ឌាឡើយ*[៦]។

តាមលទ្ធិព្រាហ្មណ៍ព្រះវិស្ណុ ជាព្រះអាទិទេពគ្រប់គ្រងថែរក្សាលោកឱ្យគង់វង្សសុខសាន្ត និងមានរបៀបរៀបរយ។ ក្នុងមុខងារនេះ ព្រះវិស្ណុតែងតែបែងភាគជាអវតារចុះមកឋានមនុស្សលោកដើម្បីបង្ក្រាបសភាវៈអាក្រក់ដែលតែងតែបំផ្លាញសេចក្ដីសុខរបស់មនុស្ស។ ក្នុងន័យនេះ រាមក្នុងលទ្ធិព្រាហ្មណ៍ និងក្នុងរឿងរាមាយណៈរបស់ឥណ្ឌាជាអវតារទី៧មានភារកិច្ចពីឋានលើមកច្បាស់លាស់ គឺបង្ក្រាបពួកយក្សដែលបៀតបៀនមនុស្សស្លូតត្រង់។ តែព្រះរាមតួអង្គក្នុងរឿងរាមកេរ្តិ៍ខ្មែរ មិនមានគ្រប់លក្ខណៈទាំងអស់នោះទេ។

អ្នកនិពន្ធរឿងរាមកេរ្តិ៍បានបង្ហាញតួអង្គព្រះរាមតាមលក្ខណៈមនុស្សដែលកើតក្នុងសង្គមមនុស្សរស់នៅបែបមនុស្សជួបបញ្ហាមនុស្ស ហើយដោះស្រាយបញ្ហាតាមវិធីនិងតាមសមត្ថភាព

---

[៥]សោម សុមុនី ***វិវត្តន៍អក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី២០*** ភ្នំពេញ គ.ស.២០០៤ ទំព័រ២៥។

[៦] -ដ-ទំព័រ២៥។

បែបមនុស្ស។តាមរយៈសកម្មភាពរបស់តួអង្គព្រះរាមនោះ យើងឃើញថាព្រះរាមមានលក្ខណៈ ជាអទិទេពតិចតួចប៉ុណ្ណោះតែមានលក្ខណៈមនុស្សច្រើន។ ពិសេសជាងនេះទៅទៀតលក្ខណៈ តួអង្គព្រះរាមជាលក្ខណៈអន់ខ្សោយបំផុតរបស់មនុស្សដូចជា៖

-ឱ្យគេបញ្ឆោតលួចប្រពន្ធបានរួចស្រែកយំដូចក្មេង គ្មានសមត្ថភាពរំដោះប្រពន្ធមក វិញដោយខ្លួនឯង។

-ប្រើគ្រប់មធ្យោបាយថោកទាបដូចជាគំរាមកំហែងអ្នកដទៃ ញុះញង់អ្នកដទៃឱ្យទាស់ គ្នាដើម្បីប្រមូលកម្លាំងគេឱ្យជួយរំដោះប្រពន្ធខ្លួន។

-ប្រចណ្ឌប្រពន្ធរួចបញ្ជាឱ្យគេយកទៅសម្លាប់ ច្បាំងជាមួយកូនឯងមិនស្គាល់ថាកូន មានចិត្តច្រណែនឈ្នានីសក្មេង។

-ទីបំផុតពុតធ្វើស្លាប់ចូលកោដ្ឋដើម្បីបញ្ឆោតចាប់នាងសីតាតែចាប់មិនបាន។ និយាយ រួមក្នុងរឿងរាមកេរ្តិ៍ខ្មែរដែលតែងតាមលំនាំរឿងក្នុងព្រហ្មញ្ញសាសនា ហើយមានលក្ខណៈខ្លះ ស្របនឹងព្រាហ្មណ៍និយមផង និងមានលាយឡំនឹងលក្ខណៈមនុស្សនិយមផង។មានលាយឡំ នឹងលក្ខណៈមនុស្សព្រោះ អ្នកនិពន្ធខ្មែរបានប្រែក្លាយតួអង្គអាទិទេពរបស់ព្រហ្មញ្ញសាសនាឱ្យ មកជាតួអង្គមនុស្សសាមញ្ញ។

ចំពោះលក្ខណៈក្លាយក្នុងចលនាព្រាហ្មណ៍និយមនេះ យើងមានសម្មតិកម្មពីរគឺ៖

- ទីមួយដោយពីបុរាណ ស្តេចក្នុងសម័យកាលនីមួយៗ និយមគោរពសាសនាផ្សេងៗ គ្នានោះ យើងមានការរុះរើសាសនាជាញឹកញាប់ ហើយតែងតែបំផ្លាញទាំងរូបភាពទាំងខ្លឹមសារ នៃសាសនាមួយទៀតដែលគេមិនគោរព។ តែទោះជាយ៉ាងនេះក្តីក៏សាសនានីមួយៗ មិនដែល រលាយសូន្យសុងនោះឡើយគឺគ្រាន់តែចុះខ្សោយប៉ុណ្ណោះ ព្រោះរូបភាពនៃលទ្ធិមួយអាចរលាយ បាន តែខ្លឹមសាររបស់វានៅតែមានអត្ថិភាពយ៉ាងយូរ។ មិនតែប៉ុណ្ណោះខ្លឹមសារនៃលទ្ធិសាសនា ទាំងពីរបានលាយឡំចូលគ្នាក្នុងព្រលឹងខ្មែរធ្វើឱ្យបាត់លក្ខណៈបរិសុទ្ធនៃសាសនានីមួយៗ។ ឯ ស្នាដៃអក្សរសិល្ប៍ដែលជាផ្នែកមួយនៃមនសិការសង្គមក៏អាចមានលក្ខណៈលាយឡំនេះដែរ។

- ទីពីរតាមប្រវត្តិសាស្ត្រ យើងដឹងថាក្នុងសម័យអង្គរចាប់ពីស.វទី១០ មកមានភាពមិន ចុះសម្រុងគ្នាក្នុងការកាន់សាសនាគឺស្តេច និងមន្ត្រីកាន់សាសនាមិនឯកភាពគ្នា។

ឧទាហរណ៍៖បើស្តេចកាន់សាសនាព្រាហ្មណ៍ មន្ត្រីកាន់ពុទ្ធសាសនាមហាយាន។ ផ្ទុយ ទៅវិញបើស្តេចកាន់ពុទ្ធសាសនាមហាយាន នោះមន្ត្រីកាន់ព្រហ្មញ្ញសាសនា។ ប៉ុន្តែជារួមស្តេច ភាគច្រើនកាន់សាសនាព្រាហ្មណ៍ដូចនោះឥទ្ធិពលនៃលទ្ធិនេះមានប្រៀបជាង។ បញ្ហានេះទាក់ ទងយ៉ាងសំខាន់ដល់ការប្រែប្រួលខាងនិន្នាការអក្សរសិល្ប៍ព្រោះអ្នកនិពន្ធសម័យនោះសុទ្ធសឹង ជាមនុស្សក្នុងវណ្ណៈខ្ពស់ជាស្តេចឬជាមន្ត្រី។ ដូចនេះហើយទើប យើងឃើញមានលក្ខណៈក្លាយ ក្នុងគោលនិយមក្នុងស្នាដៃខ្លះ ទោះបីស្នាដៃទាំងអស់ក្នុងសម័យនោះ មានឯកភាពខាងអត្ថរូប ក៏ដោយ។

ក្នុងបញ្ហានេះយើងយល់ឃើញថា អ្នកនិពន្ធរឿងរាមកេរ្តិ៍ខ្មែរប្រាកដជាពុទ្ធសាសនិកជនម្នាក់ដែលមានគំនិតចង់បន្ទុះបង្អាប់អាទិទេពក្នុងលទ្ធិព្រាហ្មណ៍ ព្រោះតាមដំណើររឿង យើងឃើញថា ពេលណាព្រះរាមធ្វើល្អ ដូចជាព្រះរាមព្រមលះបង់រាជសម្បត្តិ ហើយទៅបួសក្នុងព្រៃអ្នកនិពន្ធថាព្រះរាមជាព្រះពុទ្ធ លុះពេលណាព្រះរាមប្រព្រឹត្តកំហុស នោះអ្នកនិពន្ធថាព្រះរាមជាវិស្ណុ។ ដូចនេះ ហើយទើបរឿងរាមកេរ្តិ៍ខ្មែរខុសពីរឿងរាមាយណៈឥណ្ឌា វាជាស្នាដៃមួយដែលមានលក្ខណៈជានិម្មិតកម្មពិតប្រាកដ ពោលគឺមិនមែនជាស្នាដៃបកប្រែ ឬចម្លងទាំងដុលនោះឡើយ។ ជាតុថ្មីរបស់អ្នកនិពន្ធខ្មែរដែលជាកត្តាមូលដ្ឋាននៃនិម្មិតកម្មនោះ គឺចំណុចឬលក្ខណៈមនុស្សក្នុងអក្សរសិល្ប៍ព្រាហ្មណ៍និយមនោះឯង។ ដូចនេះលក្ខណៈព្រាហ្មណ៍និយមដែលមិនបរិសុទ្ធនេះ វាមិនមែនជាប្រការអាក្រក់ឡើយក្នុងការវាយតម្លៃពីវិវត្តន៍អក្សរសិល្ប៍ខ្មែរ។

### ២.២.អក្សរសិល្ប៍សម័យកណ្តាល

ក្រោយការឡោមព័ទ្ធអស់រយៈពេលមួយឆ្នាំ សៀមវាយយកអង្គរបានជាលើកទីមួយនាឆ្នាំ១៣៥៣[៧]ក្នុងរជ្ជកាលព្រះឧបរាជស្រីសុរិយោទ័យ រួចត្រួតត្រារហូតដល់ឆ្នាំ១៣៥៤ ទើបខ្មែររំដោះអង្គរបានវិញ។

ឆ្នាំ១៤១៧ចំបាំងខ្មែរសៀមដ៏ធំមួយទៀតបានផ្ទុះឡើង ហើយសៀមបានដណ្តើមត្រួតត្រាអង្គរជាលើកទី២។ ស្តេចពញាយ៉ាតបានរំដោះអង្គរ ក្រោយពេលសៀមត្រួតត្រាអស់រយៈពេល៥ខែ ហើយសោយរាជ្យនៅអង្គររហូតដល់ឆ្នាំ១៤៣១ ដោយខ្លាចសៀមមកវាយទៀតក៏លើករាជធានីមកតាំងនៅភាគខាងត្បូងប្រទេសវិញ។ សម័យអង្គរដែលសម័យដ៏រុងរឿងត្រូវបញ្ចប់រួចចាប់ផ្តើមសម័យអាប់ឱនដោយការវាយប្រហារពីប្រទេសជិតខាង និងទំនាស់ផ្ទៃក្នុង។ ព្រឹត្តិការណ៍ដែលជូរចត់បំផុតនាសម័យកណ្តាលនោះ ការធ្លាក់ក្រោមការត្រួតត្រារបស់សៀមក្នុងអំឡុងពេលប្រហែល៧០ឆ្នាំ ក្រោយដែលសៀមវាយបែករាជធានីលង្វែកនាឆ្នាំ១៥៩៣[៨]។

ស្ថានភាពបែបនេះរបស់ប្រទេស បានកប់លប់ខឿនអក្សរសាស្ត្រជាតិឱ្យបាត់ដានបាត់ស្រមោលអស់ប្រមាណពីរបីស.វពោលគឺយើងគ្មានប្រវត្តិអក្សរសិល្ប៍ទេក្នុងអំឡុងស.វ១៥-១៦ គ្មានឈ្មោះអ្នកនិពន្ធ គ្មានឈ្មោះស្នាដៃ។ យើងយល់ថាការបាត់ដាននេះ មិនមែនដោយគ្មានអ្នកនិពន្ធទេ តែដោយសារស្នាដៃរបស់អ្នកនិពន្ធទាំងឡាយត្រូវបំផ្លាញដោយសង្គ្រាម។ ពិសេសត្រូវខ្មាំងប្រមូលយកទៅនៅពេលវាត្រួតត្រារាជធានីលង្វែក។

ស្នាដៃទាំងឡាយដែលយើងរកឃើញ ដែលបញ្ជាក់ថាជាស្នាដៃសម័យកណ្តាលនោះមានតែស្នាដៃក្នុងស.វ.ទី១៧ និង១៨តែប៉ុណ្ណោះ។ អ្នកសិក្សាទាំងឡាយច្រើនកំណត់ព្រមៗគ្នាថាស.វទី១៧ ជាសម័យកំណើតថ្មីនៃអក្សរសិល្ប៍ខ្មែរ។ ពិនិត្យស្នាដៃទាំងឡាយយើងឃើញ

---

[៧] លាង ហាប់អាន *ប្រវត្តិអក្សរសាស្ត្រខ្មែរ* ភ្នំពេញ គ.ស.១៩៦៧ ទំព័រ ១៧៩។

[៨] -ដ-ទំព័រ១៨៩។

ថាក្នុងសម័យកំណើតថ្មីនោះ អក្សរសិល្ប៍ខ្មែរបានវិវត្តមួយជំហានថ្មី ទាំងខាងវិធីសាស្ត្រតែងនិពន្ធទាំងគោលនិយមស្នាដៃ។ ការវិវត្តនេះទាក់ទងទាំងស្រុងដល់ឥទ្ធិពលសាសនា។ ពេលនោះខ្មែរឈប់កាន់សាសនាព្រាហ្មណ៍ព្រមទាំងពុទ្ធសាសនាមហាយានរួចទៅកាន់ពុទ្ធសាសនាហីនយានដែលនាំពីលង្កាវិញ។ ពុទ្ធសាសនាហីនយានសម័យកាលនោះ រីកចម្រើនលូតលាស់យ៉ាងខ្លាំង ហើយមានឥទ្ធិពលលើជីវភាពសង្គមទាំងមូល ព្រមទាំងលើនិម្មិតកម្មអក្សរសិល្ប៍។ ក្នុងមជ្ឈដ្ឋានអ្នកសិក្សា គេបានជ្រើសរើសយកភាសាបាលីដែលប្រើក្នុងគម្ពីរពុទ្ធសាសនាហីនយាន រួចបោះបង់ចោលភាសាបាលីសំស្ក្រឹតនៃព្រហ្មញ្ញសាសនា។ កវីខ្មែរសម័យនោះបានរចនាពាក្យពេចន៍បាលីលាយខ្មែរឱ្យក្លាយជាឃ្លាកាព្យ និងស្នាដៃពាក្យកាព្យយ៉ាងពីរោះរណ្ដំ។ យើងសង្កេតឃើញថាឃ្លាកាព្យបាលី-ខ្មែរសម័យនោះមានលក្ខណៈអណ្ដែតអណ្ដូងបម្រើឱ្យបទវិណាកថាផ្ទុយទាំងស្រុងពីឃ្លាកាព្យសំស្ក្រឹត-ខ្មែរនាសម័យអង្គរដែលស្របនឹងខ្លឹមសារវីរកថា។

ក្នុងប្រវត្តិអក្សរសិល្ប៍ខ្មែរ យើងឃើញក្នុងសម័យកណ្ដាលនេះ មានវិវត្តខាងវិធីសាស្ត្រពីរដំណាក់កាលផ្សេងៗគ្នា៖

- ដំណាក់កាលដំបូងគឺស.វ.ទី១៧យើងឃើញមានតែអត្ថបទពាក្យកាព្យបែបរឿងនិទាន និងអត្ថបទកំណាព្យបែបមនោសញ្ចេតនាតែប៉ុណ្ណោះ។កវីសំខាន់ៗនៃដំណាក់កាលនោះមាន៖

• អ្នកប៉ង សរសេររឿងល្បើក ជាពាក្យកាព្យឈ្មោះល្បើកអង្គរ នៅឆ្នាំ១៦០៩និទានរៀបរាប់ពីរឿងរ៉ាវដែលនាំឱ្យមានការកសាងប្រាសាទអង្គរ។

• ព្រះរាជសម្ភារ សរសេរកំណាព្យមនោសញ្ចេតនាកំណាព្យហេមន្តមាសឆ្នាំ១៦២៩ កំណាព្យកាព្យនិរាស្ត្រឆ្នាំ១៦៦០ កំណាព្យព្រះរាជសម្ភារជាអត្ថបទកំណាព្យដែលលាតត្រដាងតែអំពីមនោសញ្ចេតនាកវីម្ចាស់អត្ថបទចំពោះនារី និងធម្មជាតិដែលលោកស្រឡាញ់ប៉ុណ្ណោះ។

- ដំណាក់កាលទី២ គឺចាប់ពីស.វទី១៨ ទើបយើងឃើញមានការតាក់តែងស្នាដៃបែបប្រលោមលោកជាពាក្យកាព្យ។ ជាទូទៅយើងឃើញថានិម្មិតកម្មអក្សរសិល្ប៍សម័យនោះ ស្ថិតទាំងស្រុងលើមូលដ្ឋានគម្ពីរពុទ្ធសាសនា ជាពិសេសគម្ពីរបញ្ញាសជាតក បានក្លាយជាប្រភពនៃនិម្មិតកម្មចំណងជើងរឿង និងនិម្មិតកម្មដំណើររឿងជាច្រើនរបស់អ្នកនិពន្ធខ្មែរ។ តាមប្រភពឯកសារខ្លះយើងបានដឹងថាគម្ពីរនេះ ជាស្នាដៃរបស់ព្រះសង្ឃនៅស្រុកឆៀងម៉ៃ(ប្រទេសថៃ) ដែលបាននិពន្ធតាំងពីអំឡុងឆ្នាំ១៤៥៧-១៦៥៧ តាមបែបជាតក របស់ពួកអ្នកប្រាជ្ញពុទ្ធសាសនានៅលង្កា[៩]។ គម្ពីរនោះគឺបញ្ញាសជាតក មានច្បាប់ដើមជាភាសាបាលី ជាគម្ពីរសាស្ត្រាស្លឹករឹត មាននៅតែក្នុងប្រទេសបួននៅឥណ្ឌូចិនគឺខ្មែរ ថៃ ឡាវ និងភូមា។ *ក្នុងអំឡុងស.វទី១៨-១៩ អ្នកនិពន្ធខ្មែរខ្លះបានដកស្រង់យករឿងក្នុងជាតកមួយចំនួន មកប្រែសម្រួលជាភាសាខ្មែរដោយរក្សាទុកភាសាបាលីខ្លះ។ ហើយអ្នកនិពន្ធខ្លះទៀតបានដកស្រង់ តែដំណើររឿងក្នុងជាតកខ្លះ មកតែងនិពន្ធតាមគំនិតរបស់ខ្លួន។ ស្នាដៃទាំងនោះត្រូវបានចារលើស្លឹករឹត*

[៩] ញ៉ុក ថែម *បញ្ញាសជាតកសង្ខេប* ភ្នំពេញ គ.ស.១៩៥៩ ទំព័រ២។

*ហៅថាសាស្ត្រាល្បែង រួចចម្លងផ្សព្វផ្សាយសុសសាយទូទាំងប្រទេស។ ស្នាដៃសំខាន់ៗដែលយើងរកឃើញមានឈ្មោះអ្នកនិពន្ធនិងកាលបរិច្ឆេទមានមួយចំនួនមានចំណងជើងនិងដំណើររឿងដូចគ្នាទាំងស្រុងនឹងរឿងក្នុងជាតក*[១០]ដូចជា៖

**ស្នាដៃរបស់ឧកញ៉ាកោសាធិបតីកៅ តែងនៅឆ្នាំ១៧៩៨**

- រឿងសមុទ្ទឃោស ត្រូវនឹងជាតកទី១ ឈ្មោះសមុទ្ទឃោស
- រឿងព្រះសុធន ត្រូវនឹងជាតកទី២ ឈ្មោះសុធនកុមារ
- រឿងក្រុងសុភមិត្រ ត្រូវនឹងជាតកទី៩ ឈ្មោះសព្វមិត្ត

**ស្នាដៃរបស់ម៉ឺនភក្តីអក្សរតន់ តែងឆ្នាំ១៨៩៩**

- រឿងសព្វសិទ្ធិ ត្រូវនឹងជាតកទី១១ ឈ្មោះសព្វសិទ្ធិ

ឯស្នាដៃមួយចំនួនទៀត គ្រាន់តែមានដំណើររឿងដូចគ្នាខ្លះនឹងដំណើររឿងក្នុងជាតកតែមានចំណងជើង និងតួអង្គមិនដូចរឿងក្នុងបញ្ញាសជាតកឡើយ។ស្នាដៃទាំងនោះមាន៖

- រឿងភោគកុលកុមារ ស្នាដៃព្រះឃ្លាំងនង ១៨០៤
- រឿងកាកី ស្នាព្រះហស្ដព្រះអង្គឌួង ១៨១៥
- រឿងមរណមាតា ស្នាដៃធម្មបញ្ញាអ៊ុក ១៨៧៧
- រឿងសង្ខសិល្ប៍ជ័យ ស្នាដៃឧកញ៉ាវង្សាធិបតីអ៊ុក ១៨៨២

ក្រៅពីនោះ យើងឃើញមានស្នាដៃមួយចំនួនទៀត ដែលគ្មានឈ្មោះអ្នកនិពន្ធ និងកាលបរិច្ឆេទតែង ដែលអាចរាប់ចូលក្នុងសម័យកណ្ដាលដែរ ព្រោះមានលក្ខណៈដូចគ្នានឹងស្នាដៃទាំងឡាយខាងលើដូចជា រឿងហង្សយន្ត ពុទ្ធសែននាងកង្រី ចៅស្រទបចេក វរវង្សសូរវង្ស ទិព្វសង្វារ ជិនវង្ស រតនាវង្ស សុវណ្ណវង្ស ភិនវង្សជាដើម។

អំពីប្រលោមលោកពាក្យកាព្យ ជាទូទៅអ្នកនិពន្ធបានតាក់តែងតាមគំរូតំណែងនិពន្ធនៃរឿងក្នុងបញ្ញាសជាតកទាំងអស់ ទោះបីស្នាដៃនេះមិនដកស្រង់ពីបញ្ញាសជាតក ក៏ដោយ។ លក្ខណៈសម្គាល់នៃតំណែងនិពន្ធតាមបែបបញ្ញាសជាតកនោះមានបីចំណុចដូចតទៅ៖

- ផ្ដើមរឿងដោយដំណាលពីអតីតជាតិរបស់ព្រះពុទ្ធកាលនៅជាព្រះពោធិសត្វ។
- ដំណើររឿង ផ្ដើមដោយឃ្លាថាក្នុងអតីតកាលនោះមានដំណាលថា...
- បញ្ចប់រឿងដោយបញ្ជាក់ការសជាតិរបស់តួអង្គនីមួយនាសម័យពុទ្ធកាល។

ដោយអ្នកនិពន្ធទាំងអស់ សុទ្ធតែបានបញ្ចូលចំណុចទាំងបីនេះ ក្នុងស្នាដៃរបស់ខ្លួននោះយើងអាចសន្និដ្ឋានបានថាលក្ខណៈជាតក គឺជាគំរូតំណែងនិពន្ធនៃអក្សរសិល្ប៍ខ្មែរសម័យកណ្ដាល។អាចនិយាយបានថាអ្នកនិពន្ធបានអនុវត្តតាមគំរូនេះ ដើម្បីតម្រូវតាមលោកទស្សនៈសង្គមទាំងមូល ដែលកំពុងនិយមស្នាដៃក្នុងគម្ពីរបញ្ញាសជាតក ដែលជាគម្ពីរសំខាន់មួយក្នុង

---

[១០] សោម សុមុនី ***វិវត្តន៍អក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី២០*** ភ្នំពេញ គ.ស.២០០៤ ទំព័រ៣៥។

លទ្ធិសាសនា។ មូលហេតុនេះហើយ ដែលនាំឱ្យមានការឯកភាពនៃតំណែងនិពន្ធសម្រាប់សម័យកាលទាំងមូល។

ក្នុងការសិក្សាពីគោលនិយមអក្សរសិល្ប៍ បើយើងយោលតាមគំរូតំណែងនិពន្ធ តាមបែបគម្ពីរពុទ្ធសាសនានោះ យើងអាចកំណត់បានថា ស្នាដៃអក្សរសិល្ប៍ទាំងអស់នាសម័យកណ្ដាលនោះ ជាស្នាដៃអក្សរសិល្ប៍បែបពុទ្ធនិយម។ *តែតាមការពិតចំណោទ និងសម្រាយបញ្ហារឿង និងសកម្មភាពតួអង្គជាពិសេសនោះ យើងឃើញថាស្នាដៃមួយចំនួនមាននិន្នាការងាកចេញពីមូលដ្ឋានទ្រឹស្ដីរបស់លពុទ្ធសាសនា*[១១] ពោលគឺវាមិនមែនជាស្នាដៃពុទ្ធនិយមបរិសុទ្ធឡើយ។ ដូចនេះ វាមានបញ្ហាគោលនិយមក្លាយក្នុងសម័យកាលពុទ្ធនិយម ដូចក្នុងសម័យព្រាហ្មណ៍និយមដែរ។ បើយោលតាមគោលការណ៍សាសនា ស្នាដៃដែលអាចចាត់ទុកថាជាស្នាដៃពុទ្ធនិយម បានលុះត្រាតែបានឆ្លុះបញ្ចាំងពីទស្សនកម្មផល និងលាតត្រដាងអំពីសន្តិសកម្មភាពរបស់តួអង្គឯកដែលជាព្រះពោធិសត្វនោះ។ ទស្សនៈកម្មផលគឺជាទស្សនៈយ៉ាងសំខាន់មួយនៃលទ្ធិពុទ្ធសាសនា។ ការឆ្លុះបញ្ចាំងពីទស្សនៈនេះអាចចាត់ទុកថាជាធាតុសំខាន់មួយនៃអក្សរសិល្ប៍ពុទ្ធនិយម។ជាតុសំខាន់មួយទៀតរបស់អក្សរសិល្ប៍ពុទ្ធនិយម គឺសន្តិសកម្មភាពរបស់តួអង្គឯក។ សន្តិសកម្មភាពផ្ដើមចេញពីទស្សនៈកម្មផល ហើយវាជាអំណះអំណាងបញ្ជាក់លើជំនឿក្នុងទស្សនៈនេះ ពោលគឺគេធ្វើអំពើល្អ ព្រោះគេជឿថានឹងបានផលល្អ។ ដូចនេះសន្តិសកម្មភាពជាចំណុចសំខាន់បំផុតរបស់ចលនាពុទ្ធនិយម ដែលអាចជួយយើង ឱ្យឃើញស្នាដៃពុទ្ធនិយម ពិតប្រាកដ និងស្នាដៃដែលស្ថិតក្នុងនិន្នាការផ្សេងៗទៀត។ ជាក់ស្ដែងនៅក្នុងស្នាដៃមួយចំនួនៈ

- ក្នុងរឿងភោគកុលកុមារ ទោះបីសត្រូវបំពានមកលើសិទ្ធិរបស់ខ្លួនយ៉ាងណាក៏ដោយ ក៏ចៅភោគកុលកុមារមិនតបតដោយហិង្សាវិញដែរ។
- ក្នុងរឿងស័ង្ខសិល្ប៍ជ័យ យើងឃើញថាតួអង្គស័ង្ខសិល្ប៍ជ័យដែលអ្នកនិពន្ធបញ្ជាក់ថាជាព្រះពោធិសត្វនោះ បានសម្លាប់ទ័ពយក្សរាប់ម៉ឺននាក់ ដើម្បីរំដោះម្ដាយមីងម្នាក់ដែលយក្សចាប់យកទៅ។ យើងឃើញថានិន្នាការដែលលាយឡំក្នុងចលនាពុទ្ធនិយមសម័យកណ្ដាលនេះ គឺនិន្នាការព្រាហ្មណ៍និយម ព្រោះដំណោះស្រាយបញ្ហាដោយសង្គ្រាមនេះ គឺជាដំណោះស្រាយតាមទស្សនៈនៃលទ្ធិព្រាហ្មណ៍ដែលឆ្លុះបញ្ចាំងតាំងពីក្នុងអក្សរសិល្ប៍សម័យអង្គរមកម្ល៉េះ។

លក្ខណៈពិសេសមួយទៀត ដែលអាចចាត់ទុកបានថាជាលក្ខណៈពិសេសនៃអក្សរសិល្ប៍សម័យនោះគឺចំណុចអច្ឆរិយៈក្នុងស្នាដៃទាំងឡាយ។ យើងថាវាជាលក្ខណៈពិសេសនៃអក្សរសិល្ប៍សម័យកណ្ដាលព្រោះចំណុចអច្ឆរិយៈទាំងនោះវាខុសពីចំណុចអច្ឆរិយៈសម័យបុរាណ។ ក្នុងសម័យអង្គរ អ្នកនិពន្ធបង្ហាញចំណុចអច្ឆរិយភាពរបស់អទិទេព ឯងច្ឆរិយៈភាពសម័យកណ្ដាលគឺអច្ឆរិយៈភាពរបស់មនុស្ស។ តាមន័យនេះ យើងឃើញថាអ្នកនិពន្ធបានងាកមករក

---

[១១] សោម សុមុនី *វិវត្តន៍អក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី២០* ភ្នំពេញ គ.ស.២០០៤ ទំព័រ៣៧។

ការដោះស្រាយបញ្ហាមនុស្សវិញហើយ គ្រាន់តែដំណោះស្រាយនោះ ត្រូវតែផ្អែកលើជំនឿសាសនា ឬផ្អែកលើភាពអស្ចារ្យ។ យើងឃើញភាពអស្ចារ្យត្រូវបានលាតត្រដាងគ្រប់ការបង្ហាញរឿងដូចជា៖

- ការបង្ហាញតួអង្គអស្ចារ្យ ជាមនុស្សមានបុណ្យបារមី ជាមនុស្សចេះហោះ ចេះដើរលើសមុទ្រ ចេះយុទ្ធសិល្ប៍តាំងពីកំណើត ជាយក្សមានកម្ពស់មួយមេឃ អាចមុជទឹកជ្រែកដី...។

- ការបង្ហាញទីកន្លែងអស្ចារ្យដូចជាឋានសួគ៌ ឋាននរក ព្រៃហេមពាន្ត សមុទ្រ៧ជាន់ ឋានកុដង្គនាគ....។

- ការបង្ហាញព្រឹត្តិការណ៍អស្ចារ្យ ដូចជាស្លាប់ហើយអាចរស់ឡើងវិញ ហែលទឹកសមុទ្រពីត្រើយម្ខាងដល់ត្រើយម្ខាង មនុស្សតូចប្រយុទ្ធជាមួយយក្សធំ យក្សស្រឡាញ់មនុស្ស នាគស្រឡាញ់មនុស្ស សត្វអាចកាឡាខ្លួនជាមនុស្ស មនុស្សកាឡាខ្លួនជាសត្វ...។ល។

យើងយល់ថាភាពអស្ចារ្យទាំងនោះ វាស្របស្រួលជាមួយលោកទស្សនៈអ្នកនិពន្ធដែលកំពុងស្រមៃរកសុភមង្គលមួយ ក្នុងពិភពផ្សេងៗ ក្នុងពេលដែលខ្លួនកំពុងរស់ក្នុងស្ថានភាពលំបាកវេទនាដោយជំងឺតំកាត់ ការព្រាត់ប្រាស ទុរ្ភិក្សដែលកំពុងរាលដាលពេញប្រទេសដោយសង្គ្រាមរ៉ាំរ៉ៃរបស់ស.វ។ឯលក្ខណៈប្រលោមនៃស្នាដៃពាក្យកាព្យទាំងនោះ រួមជាមួយភាពអស្ចារ្យទាំងឡាយ ក៏ក្លាយជាចម្រៀងបំពេអារម្មណ៍ប្រជាជនឱ្យអណ្តែតត្រសែតភ្លេចការឈឺចាប់ក្នុងជីវភាពជាក់ស្តែង។ នោះគឺសម័យកាលដែលអក្សរសិល្ប៍ខ្មែរទទួលឥទ្ធិពលសាសនាបានដើរតួនាទីសំខាន់ ក្នុងការកំណត់មនសិការសង្គមឆ្ពោះទៅរកជំនឿស៊ប់ ក្នុងលទ្ធិពុទ្ធសាសនា ជាអក្សរសិល្ប៍បម្រើសាសនា។ ចំពោះប្រជាជនគេយល់ថាអច្ឆរិយភាពនោះ គឺសច្ចភាពនៃសម័យពុទ្ធកាល ដោយជឿថាដំណើរជីវិតព្រះពុទ្ធពោរពេញដោយអច្ឆរិយភាពនោះ ហើយទើបនាំឱ្យគេគោរពជឿព្រះពុទ្ធសាសនា។ ចំណុចព្រាហ្មណ៍និយមដែលមានខ្លះក្នុងស្នាដៃមួយចំនួននោះ វាមិនរំខានដល់ជំនឿនោះទេ តែវារលាយចូលគ្នាធ្វើឱ្យពុទ្ធសាសនាក្នុងសង្គមខ្មែរមានលក្ខណៈពិសេសមួយរបស់ខ្លួនមិនដូចប្រភពដើម។

ទស្សនៈកម្មផលបាននាំឱ្យគេមើលមិនឃើញ បុព្វហេតុពិតប្រាកដនៃទុក្ខវេទនាដូចជាសង្គ្រាមឈ្លានពាននិងរបបនយោបាយមិនត្រឹមត្រូវរបស់អ្នកដឹកនាំរួចទ្រាំរស់ទាំងវេទនាដោយគិតថានោះគឺជាកម្មពីអតីតជាតិ។

- អន្តរាគមន៍របស់ទេវៈទាំងឡាយ ដែលជួយតួអង្គសំខាន់ៗឱ្យរួចពីគ្រោះថ្នាក់ ឬការប្រមាថរបស់សត្រូវនាំឱ្យគេអសកម្មដេកចាំព្រេងវាសនា។

- ឯភាពអស្ចារ្យទាំងឡាយបាននាំឱ្យគេស្រមៃទៅរកពិភពមួយ ដែលមានតែនៅក្នុងរឿងនិទាន ពោលគឺគេគ្រាន់តែបានលួងលោមសតិអារម្មណ៍តាមជីវភាពក្នុងអក្សរសិល្ប៍ ឯក្នុងជីវភាពពិតគេនៅតែវេទនាដដែល។ ប្រការទាំងនេះហើយដែលនាំឱ្យអ្នកសិក្សាមួយចំនួនវាយតម្លៃថាអក្សរសិល្ប៍ខ្មែរអាចនាំឱ្យអ្នកអានគេចចេញពីបញ្ហាសង្គម ហើយទៅពួនក្នុងពិភពយល់

សប្តិមួយយ៉ាងកុំសាកបំផុត[១២]។ ស.វ.ទី១៨-១៩ជាសម័យកាលខ្លាំងក្លាបំផុតនៃឥទ្ធិពលសាសនា ក្នុងការវិវត្តនៃអក្សរសិល្ប៍ខ្មែរ តែយើងក៏អាចចាត់ទុកថា ជាសម័យកាលចុងក្រោយបំផុតដែរ។

*ក្នុងចំណោមស្នាដៃទាំងឡាយដែលយើងសន្និដ្ឋានថាស្ថិតក្នុងចលនាពុទ្ធនិយម ឬមានលាយឡំនិន្នាការព្រាហ្មណ៍និយមនោះ យើងឃើញមានស្នាដៃពីរដែលមាននិន្នាការងាកចេញពីការឆ្លុះបញ្ចាំងលក្ខណៈសាសនាសុទ្ធសាធ*[១៣]៖

- ទីមួយរឿងហង្សយន្ត ដែលឈប់បង្ហាញពីការហោះហើរដោយមន្តអាគម ហើយចាប់ផ្តើមបង្ហាញពីការហោះហើរដោយគ្រឿងយន្ត គឺហង្សយន្តផលិតដោយស្នាដៃមនុស្ស ហើយយើងយល់ថា នេះជាស្នាដៃមួយដែលនាំខ្មែរឱ្យស្រមៃទៅរកវិទ្យាសាស្ត្រ ដូចនេះវាជាការស្រមៃទៅរកការពិតដែលផ្ទុយទាំងស្រុងពីការស្រមើលស្រមៃទៅរកភាពទេទេតាមទ្រឹស្តីសាសនា។
- ទីពីររឿងកាកី ដែលលាតត្រដាងពីជីវភាពពិតប្រាកដ ក្នុងសង្គមគ្រួសារខ្មែរតាមរយៈអច្ឆរិយភាព។នោះគឺជាស្នាដៃមួយដែលអ្នកនិពន្ធតាក់តែងឡើងដោយផ្សំអច្ឆរិយៈ ជាមួយនឹងលោកិយសច្ចៈ។ តាមរយៈស្នាដៃនោះ យើងឃើញផ្លូវបត់មួយយ៉ាងខ្លាំងក្នុងវិវត្តអក្សរសិល្ប៍ខ្មែរ វាជាមូលដ្ឋាននៃកំណើតគោលនិយមថ្មី ឬសម័យកាលថ្មីនៃអក្សរសិល្ប៍ខ្មែរ។ ស.វ.ទី១៩ បានឆ្លងផុតទៅដោយបញ្ចប់សម័យដ៏វែងអន្លាយនៃអក្សរសិល្ប៍និយមលទ្ធិសាសនា។

## ២.៣.អក្សរសិល្ប៍សម័យទំនើប

មកដល់ដើមសតវត្សរ៍ទី២០ ពុទ្ធសាសនា និងព្រាហ្មណ៍សាសនាបានបាត់បង់ឥទ្ធិពលរបស់ខ្លួនទាំងស្រុងទៅលើនិម្មិតកម្មអក្សរសិល្ប៍ខ្មែរ ទោះបីស្នាដៃចាស់ៗបែបពុទ្ធនិយម និងព្រាហ្មណ៍និយមនៅតែជាទីពេញចិត្តរបស់ប្រជាជនទូទៅក៏ដោយ។ ពេលនោះស្នាដៃថ្មីៗបានកើតឡើងដោយងាកចេញពីនិន្នាការសាសនា ហើយបានចាប់ផ្តើមឆ្លុះបញ្ចាំងពីលក្ខណៈជីវិតក្នុងមជ្ឈដ្ឋាន និងសម័យកាលដែលគេរស់នៅ។យើងកំណត់ថានោះ ជាការចាប់ផ្តើមនៃសម័យកាលថ្មីដែលអាចមានឈ្មោះថាសម័យកាលជីវិតនិយមក្នុងវិវត្តអក្សរសិល្ប៍ខ្មែរ។ យើងយល់ថានិន្នាអក្សរសិល្ប៍ថ្មីដែលលុបចោលលក្ខណៈសាសនា មិនអាចបង្កើតលក្ខណៈប្រជាជនបានភ្លាមៗឡើយ ព្រោះក្នុងសង្គមខ្មែររហូតដល់ទ.វទី៥-៦នៃស.វទី២០ ប្រជាជននៅតែមានជំនឿយ៉ាងខ្លាំងលើព្រះពុទ្ធសាសនានៅឡើយ។ ដូចនេះគោលនិយមថ្មីនេះ មិនមែនកើតឡើងតាមសំណូមពរប្រជាជនទេ តែវាបង្ហាញពីលទ្ធផលនៃវិវត្តន៍មនសិការអ្នកនិពន្ធដែលតែងតែឈានមុនមនសិការប្រជាជនជានិច្ច។ ជាទូទៅយើងសង្កេតឃើញថាក្នុងនិម្មិតកម្ម វាទាមទារធាតុថ្មីជានិច្ច។ ដូច្នេះគម្ពីរសាសនាមិនអាចនៅជាប្រភពនិម្មិតកម្មអក្សរសិល្ប៍បានរៀងរហូតឡើយ។ ការតាក់តែងស្នាដៃតាមលំនាំរឿងក្នុងគម្ពីរជាតកយូរទៅវាក្លាយទៅជារឿងប្រចាំដែលព្រោះ សូម្បី

---

[១២] ទស្សនាវដ្តី *មហាវិទ្យាល័យអក្សរសាស្ត្រមនុស្សសាស្ត្រ* លេខ១៨ ភ្នំពេញ គ.ស.១៩៧៤ ទំព័រ៨។

[១៣] ភាជ ណាង *អក្សរសិល្ប៍ខ្មែរបែបពុទ្ធិនិយម* ភ្នំពេញ គ.ស.២០១៥ ទំព័រ៥៤។

តែនៅក្នុងបញ្ញាសជាតកដែលជាគម្ពីរដើម ក៏មានរឿងប្រហាក់ប្រហែលគ្នា មិនតិចដែរ។ ម្យ៉ាងទៀត សម័យនោះរបបសេដ្ឋកិច្ចនយោបាយ និងប្រព័ន្ធអប់រំសិក្សាបែបថ្មីរបស់អាណានិគមនិយមបារាំង(១៨៦៣-១៩៥៣) បានធ្វើឱ្យមានការផ្លាស់ប្តូរទាំងជីវភាព ទាំងស្មារតីអ្នកនិពន្ធរួចបើកទូលាយលោកទស្សនៈ អ្នកនិពន្ធឱ្យឃើញលោកកិយសច្ចៈ ហើយចាប់ផ្តើមចោទ និងស្រាយបញ្ហាក្នុងជីវភាពសង្គមមនុស្ស។ ដូចនេះហើយទើបអ្នកនិពន្ធឈប់រវល់នឹងលំនាំរឿងក្នុងគម្ពីរសាសនា ហើយយកជីវភាពសង្គមធ្វើជាកម្មវត្ថុនៃការឆ្លុះបញ្ចាំង ក្នុងនិម្មិតកម្មអក្សរសិល្ប៍វិញ។ ការឈានផុតពីឥទ្ធិពលសាសនានេះ បានបើកទូលាយសមត្ថភាពអ្នកនិពន្ធ ឱ្យរកឃើញវិធីសាស្ត្រតែងនិពន្ធថ្មីៗខុសពីគំរូអក្សរសិល្ប៍សម័យបុរាណ និងសម័យកណ្តាល។ម្យ៉ាងទៀតគឺបានបើកផ្លូវឱ្យអ្នកនិពន្ធឈានទៅរកនិន្នាការផ្សេងៗ តាមការផ្លាស់ប្តូរសង្គម។ យើងសង្កេតឃើញថាក្នុងបញ្ញាស្នាដៃថ្មីៗដែលលាតត្រដាងពីជីវភាពសាមញ្ញរបស់មនុស្សក្នុងសង្គមអ្នកនិពន្ធបានប្រើប្រាស់តែភាពសាមញ្ញងាយស្តាប់ងាយយល់ជាទីបំផុត។

បើពីនិត្យស្នាដៃទាំងឡាយនៅដើមស.វ.ទី២០នោះ យើងឃើញថានិន្នាការដំបូងបំផុតរបស់អ្នកនិពន្ធខ្មែរ ដែលងាកចាកចេញពីឥទ្ធិពលសាសានានោះគឺ ការនិយមបង្ហាញលក្ខណៈខ្មែរសុទ្ធសាធក្នុងអក្សរសិល្ប៍។និន្នាការនោះគឺជាចលនាសំខាន់បំផុតក្នុងអក្សរសាស្ត្រខ្មែរព្រោះវាបានបញ្ចប់តួនាទីសាសនា ដែលមានឥទ្ធិពលលើអក្សរសិល្ប៍ តាំងពីសម័យបុរាណមក។ យោលតាមការនិយមបង្ហាញលក្ខណៈខ្មែរនេះ អ្នកសិក្សាទាំងឡាយបានកំណត់ ឈ្មោះចលនានោះថា ***ខេមរនិយម*** ។ យើងយល់ថា ***ខេមរនិយម*** ជាចលនាអក្សរសិល្ប៍ដោយឡែករបស់ខ្មែរដែលផ្តើមចេញពីចំណាប់អារម្មណ៍របស់អ្នកនិពន្ធខ្មែរ ទៅលើជីវភាពសង្គម និងបញ្ហាសំខាន់ៗក្នុងសម័យកាលដែលខ្លួនរស់នៅ។ ជាទូទៅស្នាដៃអក្សរសិល្ប៍ក្នុងចលនាខេមរនិយម ជាស្នាដៃដែលមានលក្ខណៈជាតិខ្មែរយ៉ាងជ្រាលជ្រៅ និងមានលក្ខណៈតថៈព្រោះ វាបានឆ្លុះបញ្ចាំងយ៉ាងជ្រាលជ្រៅពីតថភាពក្នុងសង្គមខ្មែរដូចជា៖

- បង្ហាញពីជីវភាព របបគ្រប់គ្រង ប្រពៃណីទំនៀមទម្លាប់ បញ្ហាសំខាន់ៗក្នុងសង្គមខ្មែរ។
- ការបង្ហាញតួអង្គដែលមានឈ្មោះ មានចរិត ឬផ្នត់គំនិតរបៀបខ្មែរ។
- ការបង្ហាញទីកន្លែងរឿងដែលជាភូមិសាស្ត្រនៃប្រទេសខ្មែរ។ល។

យោងតាមលក្ខណៈពិសេសនេះ យើងឃើញថាចលនានេះ មានទំនាក់ទំនងនឹងនិន្នាការរឿង«កាកី»របស់ព្រះបាទអង្គឌួង ដែលជាស្នាដៃពុទ្ធនិយម ក្លាយទៅជាលក្ខណៈខ្មែរដែលកើតឡើងតាំងពីឆ្នាំ១៨១៥។ បានន័យថាខេមរនិយមនេះបានចាប់កំណើតតាំងពីចុង សម័យកាលស្នាដៃពុទ្ធនិយមនាសតវត្សរ៍ទី១៩។ តាមប្រវត្តិអក្សរសិល្ប៍យើងឃើញថា ក្នុងជំហានដំបូងដែលអ្នកនិពន្ធចាប់ផ្តើមតាក់តែងស្នាដៃក្នុងនិន្នាការថ្មីគឺខេមរនិយមនេះគេនៅនិយមតែងជាប្រលោមលោកពាក្យកាព្យនៅឡើយ គ្រាន់តែប្រើកាព្យមាត្រថ្មីប៉ុណ្ណោះ។ ស្នាដៃសំខាន់ៗមួយចំនួនដែលជាភស្តុតាងក្នុងរឿងនេះ គឺរឿង«***ទុំទាវ***» និពន្ធដោយ ***ភិក្ខុសោម*** ឆ្នាំ ១៩១៥។

រហូតមកដល់ទ.វទី៣ ទើបយើងឃើញមានស្នាដៃពាក្យរាយចាប់កំណើតឡើងដូចជា៖
- រឿង*កុលាបប៉ៃលិន* និពន្ធដោយញ៉ុកថែម ១៩៣៦ ។
- រឿង*សុផាត* និពន្ធដោយ រីម គីន ១៩៣៨ ។

ដូច្នេះក្នុងការឈានចូលមកសម័យកាលទំនើបនេះ អក្សរសិល្ប៍ខ្មែរបានឆ្លងកាត់វិវត្តន៍សំខាន់ៗពីរ[១៤]គឺ៖
- វិវត្តន៍គោលនិយមស្នាដៃតាមរយៈរឿងទុំទាវ។
- វិវត្តន៍ប្រភេទស្នាដៃពីពាក្យកាព្យមកពាក្យរាយតាមរយៈរឿងកុលាបប៉ៃលិន។

ចលនាខេមរនិយមបានរក្សាលក្ខណៈបរិសុទ្ធរបស់ខ្លួន តែក្នុងអំឡុងពេល ដែលចាប់មានកំណើតពាក្យរាយដំបូងនាទ.វទី៣-៤នៃស.វទី២០នោះតែប៉ុណ្ណោះ។ ពិសេសស្នាដៃទាំងនោះត្រូវបានគេទទួលស្គាល់នឹងលើកយកមកសិក្សារហូតដល់សព្វថ្ងៃដូចជា៖
- រឿងទុំទាវ ត្រូវគេរៀបចំសំដែងជាសិល្បៈយីកេ។
- រឿង កុលាបប៉ៃលិន សំដែងជាល្ខោននិយាយ...។

## សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមការបកស្រាយវិភាគវែកញែកខាងលើ អាចឱ្យយើងសន្និដ្ឋានបានថាអក្សរសិល្ប៍ខ្មែរមានការវិវត្តជាបន្តបន្ទាប់តាំងពីសម័យបុរាណកាលមក រហូតមកដល់បច្ចុប្បន្ន តាមការប្រែប្រួលរបស់សង្គម។សម័យបុរាណ និងសម័យកណ្តាលស្នាដៃអក្សរសិល្ប៍ទទួលឥទ្ធិពលពីសាសនា។ សម័យមុនអង្គរ និងអង្គរស្នាដៃអក្សរសិល្ប៍ទទួលឥទ្ធិពលពីព្រហ្មញ្ញសាសនាមាននិន្នាការទៅរកលទ្ធិព្រាហ្មណ៍ដែលគេឱ្យឈ្មោះថា***អក្សរសិល្ប៍ព្រាហ្មណ៍និយម***។ ចំណែកឯនៅសម័យកណ្តាល( លង្វែក និងឧដុង្គ)អក្សរសិល្ប៍ទទួលឥទ្ធិពលពុទ្ធសាសនា មាននិន្នាការពុទ្ធនិយមដែលត្រូវបានគេឱ្យឈ្មោះថា***អក្សរសិល្ប៍ពុទ្ធនិយម*** ។ ចាប់ពីសម័យអានិគមបារាំងរហូតមកដល់បច្ចុប្បន្នអក្សរសិល្ប៍លែងទទួលឥទ្ធិពលពីសាសនាទៀតហើយគឺ មាននិន្នាការខេមរនិយម ងាកមកឆ្លុះបញ្ចាំងពីជីវភាពជាក់ស្តែងនៃសង្គមខ្មែរ។ អក្សរសិល្ប៍នេះត្រូវបានគេឱ្យឈ្មោះថា***អក្សរសិល្ប៍ខេមរនិយម***។

[១៤] សោម សុមុនី *វិវត្តន៍អក្សរសិល្ប៍ខ្មែរសតវត្សទី២០* ភ្នំពេញ គ.ស.២០០៤ ទំព័រ៤៥។

# គន្ថនិទ្ទេស


## ភាសាខ្មែរ

១-ជួន ណាត *វចនានុក្រមខ្មែរ* ភាគទី១,២ បោះពុម្ពគ្រាទី៥ ភ្នំពេញ គ.ស.១៩៦៧។

២-ភិក្ខុ ប៉ាង ខាត់ *ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ* ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥០៤។

៣-លាង ហាប់អាន *ប្រវត្តិអក្សរសាស្ត្រខ្មែរ* ភ្នំពេញ គ.ស.១៩៦៧។

៤-ស៊ន សំណាង *ប្រវត្តិសាស្ត្រខ្មែរ* ភ្នំពេញ គ.ស.១៩៨៨ ទំព័រ។

៥-សោម សុមុនី *អក្សរសិល្ប៍ពាក្យកាយខ្មែរ* ភ្នំពេញ គ.ស.១៩៩៥ ទំព័រ។

៦-សោម សុមុនី *វិវត្តន៍អក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី២០* ភ្នំពេញ គ.ស.២០០៤ ។

៧-គឹម សែត *ប្រវត្តិអក្សរសាស្ត្រខ្មែរ* ភ្នំពេញ គ.ស.១៩៧១

៨-ឃីង ហុកឌី *អក្សរសិល្ប៍ខ្មែរ សតវត្សទី២០ កវីនិពន្ធ និងកម្រងអត្ថបទ* ភ្នំពេញ
ផ្សាយដោយសមូហកម្មអក្សរសិល្ប៍ នូ ហាច គ.ស.២០០៥។

៩-ឃីង ហុកឌី *សមូហកម្មអក្សរសាស្ត្រខ្មែរ* ភ្នំពេញ គ.ស.២០០៦។

១០-ឈឹម សុមន៍ *សង្ខេបទសជាតក៍* ការផ្សាយរបស់ពុទ្ធិសាសនបណ្ឌិត្យគ.ស.១៩០២

១១-ញ៉ុក ថែម *បញ្ញាសជាតក* មហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ គ.ស.
១៩៦៣។

១២- ភាជ ណាង *អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម* ភ្នំពេញ គ.ស.២០១៥។

១៣-ខឹម សំឱ *ប្រវត្តិអក្សរសាស្ត្រខ្មែរ* ភ្នំពេញ គ.ស.១៩៥៦។

១៤-ធ សោ *អក្សរសិល្ប៍ពុទ្ធនិយម* ភ្នំពេញ គ.ស.១៩៩៤។

១៥-ស៊ិន សុវណ្ណនិ *សិក្សាអត្ថបទអក្សរសាស្ត្រពុទ្ធសាសនាភាគ១* ភ្នំពេញ
គ.ស២០១២។

១៦-ភិក្ខុសោម *រឿងទុំទាវ* ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យគ.ស.១៩៩៨។

១៧-ព្រះបាទអង្គឌួង *រឿងកាកី* ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យគ.ស.
ឆ្នាំ១៩៩៧។

១៨-ឧកញ៉ាវង្សាធិបតីអ៊ុក *រឿងសង្ខសិល្ប៍ជ័យ* ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសន
បណ្ឌិត្យ គ.ស.១៩៦៦។

១៩-ចៅយមបុណ្យកក្តីឧក *រឿងហង្សយន្ត* ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
គ.ស.១៩៦៦។

២០-លី ធាមតេង *អក្សរសាស្ត្រខ្មែរ* ភ្នំពេញ គ.ស.១៩៥៩។

២១-ហ៊ុន គឹមសៀ មូលដ្ឋានដើម្បីយល់អក្សរសាស្ត្រ ភ្នំពេញ គ.ស.១៩៦៣។

# រៀនតាមរយៈការលេងនៅមត្តេយ្យសិក្សា

បេក្ខជនបណ្ឌិតៈ **ប្រាក់ កុសល**

## ១. ហេតុអ្វីការរៀនតាមរយៈការលេងមានសារៈសំខាន់?

កុមារភាពគឺជាវ័យមួយដែលកុមារអភិវឌ្ឍខ្លួនបន្តិចម្តងៗ តាមរយៈបទពិសោធផ្សេងៗ ដែលកុមារជួបប្រទះក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងជាវ័យដែលកុមាររីករាយជាមួយនឹងការលេងដោយក្តីសប្បាយទៅតាមអ្វីដែលគេចាប់អារម្មណ៍ ចង់ដឹង និងចង់ធ្វើ។ បទពិសោធទាំងនេះអាចជួយកុមារឱ្យមានការអភិវឌ្ឍគ្រប់ផ្នែកជាមូលដ្ឋានគ្រឹះនៃសមត្ថភាពជំនាញក្នុងយុគសម័យឌីជីថល ជួយឱ្យកុមារមាន ទំនាក់ទំនងជាមួយសង្គមខាងក្រៅ និងជួយឱ្យកុមារអភិវឌ្ឍឥរិយាបថ ដែលជាផ្នែកមួយដ៏សំខាន់ សម្រាប់ជីវិតប្រកបដោយសុខុមាលភាព។ កុមារទទួលបានការអភិវឌ្ឍពេញលេញតាមរយៈបទពិសោធជាក់ស្តែងផ្សេងៗ មិនមែនតាមរយៈចំណេះដឹងនិងបំណិនដែលគ្រូបានផ្តល់ឱ្យកុមារក្នុងថ្នាក់តែមួយផ្នែកនោះទេ។ ម៉្យាងទៀត បទពិសោធជាក់ស្តែងមានសារៈសំខាន់ណាស់សម្រាប់ការអប់រំរបស់កុមារ។ កុមារបង្កើតសកម្មភាពផ្សេងៗតាមរយៈជីវភាពរស់នៅបចាំថ្ងៃ និងតាមរយៈការលេងដោយមានទំនាក់ទំនងជាមួយមជ្ឈដ្ឋានខាងក្រៅជុំវិញខ្លួន និងទទួលបាននូវការបំពេញទៅតាមចំណង់ចំណូលចិត្តដែលពួកគេចង់បាន។ កុមារអភិវឌ្ឍភាពខ្លាំងរបស់ពួកគេតាមរយៈជីវភាពរស់នៅប្រចាំថ្ងៃ ដោយរីករាយជាមួយសកម្មភាពផ្សេងៗតាមអ្វីដែលពួកគេប្រាថ្នាចង់ធ្វើ និងការមានទំនាក់ទំនងជាមួយនឹងមជ្ឈដ្ឋានជុំវិញខ្លួន។

Investing in ECD provides high and exponential ***economic and social returns***

**1 USD$ invested in ECD generates 17 USD$ in return**







Source: Heckman (2008)

ដូចដែលបានរៀបរាប់ខាងលើ យើងឃើញថាគ្រូមត្តេយ្យសិក្សាចាំបាច់ដើរតួជាអ្នកសម្របសម្រួល និងរៀបចំបរិយាកាសជុំវិញឱ្យកុមារបានលូតលាស់សមស្រប។ បរិស្ថាននិងសម្ភារៈសម្រាប់កុមារលេងជា

ប្រចាំថ្ងៃ សុទ្ធតែអាចប្រើប្រាស់ជាធនធានសម្ភារៈសម្រាប់បម្រើឱ្យការរៀន-បង្រៀន និងជាកន្លែងសម្រាប់រៀបចំសកម្មភាពសិក្សារបស់ថ្នាក់មត្តេយ្យសិក្សាបានផងដែរ។ សកម្មភាពផ្សេងៗនិងកាលេងនៅថ្នាក់មត្តេយ្យសិក្សា នឹងកាន់តែមានភាពទាក់ទាញប្រសិនបើគ្រូមត្តេយ្យសិក្សាបានរៀបចំបរិយាកាសនិងសកម្មភាពនៅក្នុងថ្នាក់ប្រកបដោយគំនិតច្នៃប្រឌិត និងបត់បែនទៅតាមគោលបំណងនៃសកម្មភាពនីមួយៗ។ ការអភិវឌ្ឍនិងរៀបចំថ្នាក់មត្តេយ្យសិក្សាដែលមានភាពទាក់ទាញ ហើយអាចឱ្យកុមារមានអារម្មណ៍ថា **"ថ្ងៃស្អែកខ្ញុំចង់មកទីនេះម្តងទៀត"** និងជំរុញការអភិវឌ្ឍក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់កុមារ។

តើ**«ការលេង»** មានអត្ថន័យយ៉ាងដូចម្តេចសម្រាប់កុមារ? ពីមួយថ្ងៃទៅមួយថ្ងៃ កុមារចំណាយពេលវេលាជាច្រើនរីករាយជាមួយការលេង ហើយស្របពេលជាមួយគ្នានោះពួកគេបានអភិវឌ្ឍផ្នែកកាយសម្បទានិងអារម្មណ៍ជាបន្តបន្ទាប់។ តើអ្វីទៅជាអាថ៌កំបាំងនៃ**«ការលេង»** ដែលមានភាពទាក់ទាញខ្លាំងដល់កុមារ? ភាពរីករាយជាមួយការលេងគឺជាជីវិតរបស់កុមារ។ កុមារតូចជាវ័យដែលត្រូវការចង់ដឹង និងចង់សាកល្បងអ្វីផ្សេងៗ ហើយកុមារចាប់អារម្មណ៍ និងចង់បង្កើតទំនាក់ទំនងជាមួយអ្វីៗដែលនៅជុំវិញខ្លួនដូចជាវត្ថុផ្សេងៗជាដើម។ តាមរយៈការលេង ការប្រើប្រាស់ការស្រមើស្រមៃ និងការផលិតវត្ថុផ្សេងៗដោយដៃរបស់ពួកគេផ្ទាល់ កុមារអាចបង្កើនល្បឿនសមត្ថភាពនៃការគិត ឬអំណាចនៃការស្រមើស្រមៃ ហើយអាចរៀនពីរបៀបរួមរស់នៅជាមួយមិត្តភក្តិ និងទំនាក់ទំនងជាមួយបរិស្ថានជុំវិញខ្លួន។ ក្នុងដំណាក់កាលនេះ កុមារទទួលបាននូវអារម្មណ៍ច្រើនបែបច្រើនយ៉ាង ដូចជា «សប្បាយ គួរឱ្យចាប់អារម្មណ៍ ឆ្ងល់» និង «ខ្ញុំចង់សាកល្បង»។ ទាំងនេះ នាំឱ្យពួកគេមានអារម្មណ៍ថាពួកគេពេញចិត្ត និងបាននូវអ្វីដែលគេចង់បានដែលវាជាកត្តាជំរុញឱ្យពួកគេមានចំណង់ចង់ធ្វើអ្វីផ្សេងទៀត។ ពេលខ្លះ ការជួបនូវចម្ងល់និងការលំបាកផ្សេងៗ ក៏អាចជួយឱ្យកុមាររីកចម្រើន និងជំរុញឱ្យកុមារមានចំណង់ចំណូលចិត្ត ឬមានឥរិយាបថចង់ទំនាក់ទំនងជា មួយបរិស្ថានជុំវិញខ្លួនដោយខ្លួនពួកគេផ្ទាល់។ ការលេងមានបែបផែនផ្សេងៗគ្នា ហើយកុមារអាចអភិវឌ្ឍន៍ខ្លួនគេបានតាមរយៈការសប្បាយរីករាយនឹងការលេងនេះឯង។ ដូច្នេះហើយ ការលេងគឺជាការរៀនមួយដ៏សំខាន់បំផុតសម្រាប់កុមារ ហើយបណ្តុំបទពិសោធចេញពីការលេងទាំងនេះបានធ្វើឱ្យកុមារមានកម្លាំងចិត្ត និងមានឥរិយាបថចង់សិក្សានាពេលអនាគត។

ដោយប្រើប្រាស់នូវញាណដែលកុមារមានពីកំណើត និងទទួលបាននូវការប្រើប្រាស់នូវញាណទាំងនោះ ដែលនាំកុមារឆ្ពោះទៅអភិវឌ្ឍខ្លួនរបស់ពួកគេ។ តាមរយៈការឆ្លងកាត់បទពិសោធជាច្រើនពីការលេង ការមើល ការស្តាប់ ការប៉ះពាល់ ការហិតក្លិន និងការភ្លក្សរសជាតិផ្សេងដោយប្រើប្រាស់ញាណទាំង៥ កុមារ

អភិវឌ្ឍខួរក្បាលបានយ៉ាងល្អ។ ក្នុងន័យនេះ វាអាចធ្វើឱ្យកុមារយល់ដឹងពីវត្ថុផ្សេងៗនៅជុំវិញខ្លួនរបស់ពួកគេបានយ៉ាងទូលំទូលាយ។

កុមារមានសមត្ថភាពបង្កើតនូវបរិយាកាសសម្រាប់ការលេងដោយខ្លួនរបស់ពួកគេផ្ទាល់ ដែលពួកគេអាចបង្កើតបាននូវសម្ភារៈសម្រាប់លេងពីអ្វីដែលនៅជុំវិញខ្លួន ដោយមិនចាំបាច់មានរបស់របរ ឬ សម្ភារៈមានតម្លៃថ្លៃៗនោះទេ។ អ្វីដែលសំខាន់នោះគឺមានមិត្តភក្តិជាច្រើននាក់ និងគ្រូមត្តេយ្យសិក្សាជា ដែលអាចលេង និងផ្លាស់ប្តូរបទពិសោធពីគ្នាបាន។ ការចែករំលែកនូវបទពិសោធ ឬអារម្មណ៍មួយដែលកុមារម្នាក់បានជួបប្រទះទៅឱ្យមិត្តភក្តិដទៃទៀតនឹងធ្វើឱ្យកុមារកាន់តែមានបទពិសោធ។ ការធានាបានថាកុមារ អាចរីករាយជាមួយបទពិសោធផ្សេងៗក្នុងសកម្មភាពក្នុងថ្នាក់រៀននៅមត្តេយ្យសិក្សាធ្វើឱ្យពួកគេបានរៀនសូត្របានច្រើន ដែលទាំងនេះគឺចំណុចដ៏សំខាន់បំផុតក្នុងការអប់រំកុមារនៅកម្រិតមត្តេយ្យសិក្សា។

កុមារអាយុចាប់ពី ៣ឆ្នាំ រហូតដល់អាយុត្រូវចូលរៀននៅបឋមសិក្សាមានសន្ទុះនៃការអភិវឌ្ឍខ្លាំងដែលគេចាត់ទុកថាជារយៈពេលដ៏សំខាន់ក្នុងការកសាងមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍទំនាក់ទំនងរបស់មនុស្ស។ ដើម្បីបង្កើតទំនាក់ទំនងជាវិជ្ជមានជាមួយអ្នកដទៃ កុមារត្រូវការអភិវឌ្ឍនូវបំណិនផ្សេងៗ ដូចជាការច្នៃប្រឌិត ការសម្របសម្រួលខ្លួនក្នុងសង្គម សញ្ចេតនា និងបំណិនដោះស្រាយបញ្ហា ដែលបំណិនទាំងនេះមិនអាចទទួលបានតាមរយៈការបង្រៀនពីមនុស្សធំឬតាមរយៈសៀវភៅសិក្សានានានោះទេ។ វិធីសាស្ត្រដ៏មានប្រសិទ្ធភាពបំផុតសម្រាប់ទទួលបាននូវបំណិនក្នុងការទំនាក់ទំនងគឺ«ការលេង»។ កុមាររៀនពីរបៀបទំនាក់ទំនងរបស់មនុស្សតាមរយៈការលេង ហេតុនេះបានជាការលេងមានសារៈសំខាន់សម្រាប់កុមារ។ កុមារអាយុចាប់ពី ៣ឆ្នាំ ទៅ ៥ឆ្នាំ មានលក្ខណៈសម្បត្តិដូចខាងក្រោម៖



- កុមារក្នុងន័យនេះចាប់ផ្តើមចូលចិត្តអ្នកដទៃកាន់តែខ្លាំងឡើង និងមានទំនាក់ទំនងច្រើនជាមួយមិត្តភក្តិ។ ជាដំបូងកុមារសប្បាយជាមួយការលេងដាច់ដោយឡែករៀងខ្លួន បើទោះបីជាពួកគេកំពុងតែលេងនៅកន្លែងតែមួយជាមួយគ្នាក៏ដោយ។ ជាបន្តិចម្តងៗ កុមារចាប់ផ្តើមលេងជាមួយគ្នាជាក្រុមដោយមានគោលដៅរួមមួយ។
- កុមារអភិវឌ្ឍមិត្តភាពជាមួយកុមារដទៃ ប៉ុន្តែពួកគេក៏ចង់ធ្វើអ្វីមួយជាលក្ខណៈឯកជន ដូចនេះហើយដែលអាចបង្កឱ្យមានការឈ្លោះប្រកែកទាស់ទែងជាមួយគ្នា។ តាមរយៈបទពិសោធនេះ កុមារអាចស្វែងយល់ពី

អារម្មណ៍របស់កុមារដទៃ និងកត់សម្គាល់ពីគោលគំនិតខុសៗគ្នា ហើយគេអាចទទួលភាពខុសប្លែកគ្នានេះបន្តិចម្តងៗ។

- កុមាររីករាយជាមួយនឹងការលេងដដែលៗក្នុងគ្រាហ៍ដំបូង តែក្រោយមកការអភិវឌ្ឍការលេងមួយជំហានម្តងៗនេះ បានបង្កើតនូវល័ក្ខខ័ណ្ឌផ្សេងៗនៃការលេង ឬចែកតួនាទីរបស់សមាជិកក្រុមរបស់ពួកគេ។

តាមរយៈសកម្មភាពនេះ យើងសង្កេតឃើញថា កុមារមានការអភិវឌ្ឍនូវបំណិនទំនាក់ទំនងមួយជំហានម្តងៗ ដូចខាងក្រោម៖

- កុមារចេះបង្កើតនូវទំនាក់ទំនងបែបវិជ្ជមានជាមួយអ្នកដទៃ ដោយបង្ហាញនូវអារម្មណ៍ផ្ទាល់ខ្លួនរបស់ពួកគេ ចេះទទួលយកនូវអារម្មណ៍របស់អ្នកដទៃ និងសម្របសម្រួលខ្លួនទៅតាមស្ថានភាពជាក់ស្តែង។
- កុមារបង្កើតនូវទំនាក់ទំនងជាមួយមិត្តភក្តិ និងសប្បាយរីករាយនឹងការលេងជាមួយគ្នា។
- កុមារដេកជាមួយមិត្តភក្តិដទៃទៀតយ៉ាងសកម្ម និងចេះចែករំលែកនូវអារម្មណ៍សប្បាយរីករាយ និងទុក្ខសោក។
- កុមាររកឃើញនូវគោលបំណងរួមមួយនៅពេលបានលេងជាមួយមិត្តភក្តិ និងមានទឹកចិត្តចង់សម្រេចបាននូវអ្វីមួយដោយបានមកសហការជាមួយកុមារដទៃទៀត។
- កុមារធ្វើឱ្យការទំនាក់ទំនងជាមួយមិត្តភក្តិដទៃទៀតកាន់តែជិតស្និទ្ធ មានសកម្មភាពផ្សេងៗជាមួយមិត្តភក្តិដ៏ទៃទៀត និងស្វែងយល់នូវអារម្មណ៍យល់ចិត្តគ្នា និងមិត្តភាពជាមួយអ្នកដទៃ។



- កុមារស្វែងយល់ពីសារៈសំខាន់នៃការកំណត់ល័ក្ខខ័ណ្ឌគោលការណ៍ផ្សេងៗ នៅពេលពួកគេលេងជាមួយមិត្តភក្តិ និងគោរពគោលការណ៍ទាំងនោះដោយស្ម័គ្រចិត្ត។
- កុមារស្គាល់អំពីខ្លួនឯង ស្គាល់ពីចំណុចខ្លាំង និងបុគ្គលិកលក្ខណៈនៅពេលទំនាក់ទំនងជាមួយមិត្តភក្តិ និងកាន់តែមានទំនុកចិត្ត មានភាពរីករាយ និងមានសង្ឃឹមក្នុងជីវិត។

## ២. ការរៀបចំសួនកុមារនៅមត្តេយ្យសិក្សា

បច្ចុប្បន្ននេះកុមារប្រមាណ ៩០%នៅលើពិភពលោកដែលបានចូលសិក្សាសាលាបឋមសិក្សា ប៉ុន្តែភាគច្រើននៃកុមារទាំងនោះ មិនមានសមត្ថភាពតាមតម្រូវការនៃបំណិនជាមូលដ្ឋានស្របតាមស្តង់ដារវ័យរបស់ពួកគេឡើយ។ សាលារៀនជាច្រើនក្នុងប្រទេសកំពុងអភិវឌ្ឍលើពិភពលោក គ្រូបង្រៀននៅតែបន្តអនុវត្តវិធីសាស្ត្របង្រៀនតាមទន្លាប់(ឧទ្ទេស/អាន) ដែលជាហេតុនាំឱ្យបរិយាកាសនៃការអប់រំមិនមានអំណោយផលដល់តម្រូវការគុណភាពរៀនសូត្រ ឬបានផ្តល់ឱកាសតិចតួចសម្រាប់កុមារដឹកនាំការលេងឬរៀនសូត្រតាមរបៀបស្រាវជ្រាវដោយខ្លួនឯង។ បន្ថែមលើសពីនេះ ថ្នាក់រៀនភាគច្រើនបានទទួលកុមារលើសនិយាម និងស្ថានភាពថ្នាក់រៀនមានលក្ខណៈបង្រៀន និងបរិយាកាសរៀនសូត្ររបស់កុមារមិនមានអន្តរកម្មរវាងកុមារនិងកុមារ និងរវាងកុមារនិងគ្រូ ដែលនាំឱ្យគ្រូមិនអាចអនុវត្តវិធីសាស្ត្របង្រៀនបានល្អជាកត្តាប៉ះពាល់ដល់គុណភាពនៃការអប់រំ។

សាលារៀនបច្ចុប្បន្ននេះ មិនមែនមានតែកិច្ចការផ្តល់ចំណេះដឹងនិងជំនាញសម្រាប់អនាគតរបស់កុមារប៉ុណ្ណោះទេ ប៉ុន្តែលើសពីនេះសាលារៀនផ្តល់នូវបំណិនជីវិត ទម្លាប់និងអាកប្បកិរិយាល្អ ដែលនឹងជួយកុមារក្លាយជាមនុស្សជោគជ័យនាពេលអនាគត។ ក្នុងខណៈកុមារលេងនៅសួនកុមារ(Playgrounds) ពួកគេបានបង្ហាញពីបំណិនជីវិត ការដឹកនាំនិងសហការយ៉ាងមានប្រសិទ្ធភាព។ ប៉ុន្តែអ្នកអប់រំ និងមាតាបិតាមួយចំនួននៅតែដាក់សម្ពាធឱ្យកុមារចំណាយពេលច្រើនលើការរៀនសូត្រនៅក្នុងថ្នាក់។

"*នៅមានការយល់ច្រឡំជាច្រើនអំពីរបៀបរៀនសូត្ររបស់កុមារ*" ដែលឥទ្ធិពលនេះ បានបន្សល់ទុកមកជាច្រើនទសវត្សមកហើយ ដែលជាកត្តានាំឱ្យបន្តប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់គុណភាពអប់រំ និងធ្វើឱ្យកុមារបាត់បង់ឱកាសដឹកនាំការលេងនិងស្រាវជ្រាវតាមគំនិតនិងតាមការជ្រើសរើសរបស់ពួកគេផ្ទាល់។ ការពង្រីកសកម្មភាពរៀនតាមរយៈការលេងរបស់កុមារ បានរួមចំណែកយ៉ាងធំធេងក្នុងការលើកម្ពស់លទ្ធផលសិក្សា របស់កុមាររាប់លាននាក់ផងដែរ។

លទ្ធផលរយៈពេលវែង៖ សកម្មភាពលេងជាមូលដ្ឋាន គឺជាការអន្តរាគមន៍ដែលផ្តល់ផលចំណេញនិងមានតម្លៃពេញមួយជីវិត។ តាមការស្រាវជ្រាវមួយ(Heckman 2003) បានបង្ហាញថា ការចំណាយ ១ ដុល្លា សម្រាប់កុមារវ័យមុនមត្តេយ្យសិក្សានិងក្នុងវ័យមត្តេយ្យសិក្សាដែលមានអាយុក្នុងចន្លោះពី ០ឆ្នាំ ដល់ ៦ឆ្នាំ នឹងទទួលផលចំណេញរយៈពេលវែងរហូតដល់ ៨ដុល្លា ហើយការបង្កើតយុទ្ធសាស្ត្របង្កើនសកម្មភាពលេងក្នុងវ័យកុមារភាព បានបង្កើតមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍចំណេះដឹង និងជំនាញចិត្តសង្គមរបស់កុមារ ដែលនឹងជួយកំណត់បាននូវប្រាក់ចណូលពេញមួយជីវិតរបស់ពួកគេ។

សួនកុមារ ជាទីកន្លែងផ្តល់ឱកាសដល់កុមារអនុវត្តជំនាញរបស់ពួកគេ៖ សមត្ថភាពសហការជាមួយអ្នកដទៃ សមត្ថភាពក្នុងការសម្រេចចិត្ត តួនាទីនិងភាពជាអ្នកដឹកនាំ ការតស៊ូប្រឈមមុខចំពោះការ

រំខាននានា និងសមត្ថភាពក្នុងការបង្កើតគំនិតច្នៃប្រឌិត។ តាមរយៈការលេងរបស់កុមារនៅកម្រិតមត្តេយ្យសិក្សា នឹងលើកកម្ពស់ការអភិវឌ្ឍកុមារះ

- ការអភិវឌ្ឍរាងកាយនិងសុខភាពះ សកម្មភាពលេងនៅសួនកុមារ ជំរុញឱ្យមានការរីកចម្រើនកាយសម្បទា សុខភាពផ្លូវចិត្ត និងសម្រួលសរសៃរបេះដូង ព្រមទាំងរីកចម្រើនផ្នែកចលករ ភាពរហ័សរហួន និងមានសមត្ថភាពគិតបានហ្មត់ចត់។ សម្ភារៈរៀបចំផ្តោតលើឧបករណ៍ឡើងជញ្ជាំង និងឧបករណ៍ស្វាតោងរបាទៅ-មក។
- ការអភិវឌ្ឍផ្នែកសង្គមនិងអារម្មណ៍ះ សកម្មភាពកុមារលេងមានលក្ខណៈអន្តរសកម្ម ដែលការរៀបចំឧបករណ៍សម្រាប់កុមារលេងមានទម្រង់ខុសៗគ្នាះ កុមារត្រូវការលេងជាក្រុមដូចជា ការប្រើស្លាកឬនិយាយងាយៗជាមួយអ្នកផ្សេងទៀត ហើយពេលខ្លះទៀតកុមារត្រូវសហការ ធ្វើសកម្មភាពរួមគ្នា ដូចជាយោលទោងឱ្យគ្នាម្តងម្នាក់ ឬបង្វិលឱ្យគ្នាម្តងម្នាក់ជាដើម។ សម្ភារៈរៀបចំផ្តោតលើឧបករណ៍សម្រាប់យោលទោង និងឧបករណ៍បង្វិល។
- ការអភិវឌ្ឍផ្នែកចំណេះដឹងះ ផ្អែកតាមអត្ថបទ(Dr.Marie Hartwell-Walker)បានបញ្ជាក់ថា បន្ទាប់ពីកំណើត ៧៥%នៃកោសិកាខួរក្បាលរបស់កុមារមានការរីកចម្រើនខ្ពស់ណាស់ ហើយការលេងបានជំរុញដល់ការអភិវឌ្ឍជំនាញមូលដ្ឋានរបស់កុមារគ្រប់ជ្រុងជ្រោយ។ ការភ្ញោចរបស់កុមារតាមរយៈការលេង បានជួយតភ្ជាប់ប្រព័ន្ធប្រសាទខួរក្បាលដែលជួយកុមារអភិវឌ្ឍចលកធំ ដូចជា ដើរ រត់ លោត ជិះកង់ និងការសម្របសម្រួលជាមួយចលករតូច ដូចជា ការសរសេរ ការរៀបចំឧបករណ៍តូចៗ និងការប្រើប្រាស់ចលនាម្រាមដៃបានល្អ។
- តាមរយៈសកម្មភាពលេង បានបង្កើតមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ រួមទាំងចំណេះដឹង និងជំនាញចិត្តសង្គមរបស់កុមារ ដែលនឹងជួយកំណត់បាននូវភាពជោគជ័យពេញមួយជីវិតរបស់ពួកគេ។



# ការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សានៅកម្ពុជា ឆ្នាំ២០០៩-២០១៨


បេក្ខជនបណ្ឌិត ៖ **ឆាយ គឹម សុទ្ធារី**

ជំនាញ ៖ រដ្ឋបាលសាធារណៈ


## ១. សេចក្តីផ្តើម

សុខភាពគឺជាជីវិត ការអប់រំគឺជាអនាគត ទាំងពីរនេះពិតជាមិនអាចខ្វះមួយណាបានទេ។ សុខភាពនិងសុវត្ថិភាពរបស់អ្នកសិក្សា និងបុគ្គលិកអប់រំពិតជាមានសារៈសំខាន់ណាស់ដើម្បីចូលរួមចំណែកធានាបាននូវ ការសិក្សាប្រកបដោយគុណភាព កាត់បន្ថយអត្រា បោះបង់ និងកាត់បន្ថយអត្រាត្រួតថ្នាក់ ព្រមទាំងបង្កើនអត្រាបញ្ចប់ការសិក្សា។ ដោយយល់ឃើញថា គោលនយោបាយស្តីពីសុខភាពសិក្សាបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យអប់រំ ដើម្បីឱ្យការប្រែក្លាយសកម្មភាពទាំងនេះទៅជាការអនុវត្តបានប្រកបដោយប្រសិទ្ធភាពគឺ ទាមទារចាំបាច់ត្រូវមានចំនុចយុទ្ធសាស្រ្តជាច្រើនលើដំណើរការអនុវត្តគោលនយោបាយនេះ។ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំគោលនយោបាយស្តីពីសុខភាពសិក្សានៅកម្ពុជា ដែលមានចំណុចដៅជាយុទ្ធសាស្រ្តចំនួន៤គឺ (១)ការផ្តល់សេវាថែទាំសុខភាពចាំបាច់ដល់អ្នកសិក្សានិងបុគ្គលិកអប់រំ (២)ផ្តល់ការអប់រំសុខភាព (៣)ការបំពាក់សម្ភារៈរូបវន្តផ្នែកសុខភាព (៤)និងការបើកទូលាយឱ្យមានការចូលរួមពីក្រសួង ស្ថាប័ន គ្រប់ដៃគូអភិវឌ្ឍនិងសង្គមស៊ីវិលលើផ្នែកសុខភាពសិក្សា។

## ២. ទស្សនាទាននៃការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សា

### ២.១ និយមន័យ

**ក. សុខភាព៖** សុខភាព គឺជាសភាពពេញលេញនៃសុខុមាលភាពទាំងផ្លូវកាយ ចិត្ត និងសង្គម ដោយមិនត្រឹមតែអវត្តមាននៃជំងឺនិងពិការភាពនោះទេ[១]។

**ខ. សិក្សា** ឬសិក្ខាគឺការរៀន ការរៀនទន្ទេញ ការសូត្ររៀន ការហ្វឹក ការហ្វឹកហាត់ ការប្រុងប្រយ័ត្ន រក្សាមារយាទឱ្យល្អ ប្រតិបត្តិ វិជ្ជាការស្ទាត់ជំនាញ ខប្រតិបត្តិ[២]។

សុខភាពសិក្សា គឺសំដៅដល់សំណុំសកម្មភាពផ្សេងៗសម្រាប់លើកកម្ពស់សុខភាពនៅតាមគ្រឹះស្ថានសិក្សា ដែលជាសេចក្តីត្រូវការជាមូលដ្ឋាននៃផ្លូវកាយ ផ្លូវចិត្តនិងសង្គមរបស់

---

[១] អង្គការសុខភាពពិភពលោក *និយមន័យសុខភាព WHO*

[២] ជួន ណាត *វចនានុក្រមខ្មែរ* ភ្នំពេញ ឆ្នាំ១៩៦៧ ទំព័រ១៣៧៦

អ្នកសិក្សានិងបុគ្គលិកអប់រំ។ តាមរយៈសកម្មភាពលើកកម្ពស់សុខភាពអ្នកសិក្សានិងបុគ្គលិកអប់រំនៅតាមគ្រឹះស្ថានសិក្សា។

គ. **គោលនយោបាយស្តីពីសុខភាពសិក្សា** យើងឃើញថាមកពីគោលនយោបាយស្តីពីសុខភាពសិក្សា ដែលមានន័យថាគឺជាការសុំណុំផែនការសកម្មភាពដែល ត្រូវបានអនុវត្តដើម្បីសម្រេចបាននូវគោលដៅថែទាំសុខភាពជាក់លាក់នៅក្នុងសង្គម[៣]។

## ២.២ បរិស្ថានគ្របដណ្តប់សុខភាពសិក្សា

គោលនយោបាយស្តីពីសុខភាពសិក្សានេះ មានគោលបំណងចូលរួមលើកកម្ពស់គុណភាពអប់រំ ដល់អ្នកសិក្សា និងបុគ្គលិកអប់រំ ដោយផ្តល់នូវលទ្ធភាពក្នុងការទទួលបានសុខភាពល្អ និង សុខុលមាលភាព ដើម្បីក្លាយជាធនធានមនុស្សប្រកបដោយសក្តានុពល[៤]។

សុខភាពសិក្សាបានរួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់គុណភាពអប់រំ ព្រមទាំងជួយកែលម្អលទ្ធផលសិក្សារបស់សិស្ស ឱ្យទទួលបានប្រសិទ្ធផលខ្ពស់នៅគ្រប់ភូមិសិក្សាស្របតាមបរិបទកុមារចូលរៀន ប្រកបដោយសមធម៌ រៀនចេះ រៀនចប់។ សុខភាពសិក្សាបានជួយឱ្យស្ថានភាពសុខុមាលភាពរបស់គ្រូបង្រៀន និងសិស្ស មានសុខភាពល្អ បរិបូរណ៍ ពោលគឺពួកគេគ្មានជំងឺបៀតបៀន មានសមត្ថភាពខ្ពស់និងភាពវៃឆ្លាតក្នុងការរៀននិងបង្រៀន។

# ៣. ការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សានៅកម្ពុជា

ក្របខណ្ឌនៃការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សា គឺជាផែនទីចង្អុលផ្លូវមួយ សម្រាប់ចូលរួមលើកកម្ពស់គុណភាពអប់រំ ដើម្បីឱ្យកម្ពុជាសម្រេចបានគោលដៅនៃការអប់រំតាមរយៈការផ្តល់នូវចំណេះដឹងសុខភាព ស្របតាមការលូតលាស់រាងកាយ និងស្មារតីប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ បំណិន សម្រាប់បង្ការជំងឺឆ្លង ជំងឺមិនឆ្លង គ្រោះថ្នាក់ផ្សេងៗ និងវិធីជួយសង្គ្រោះបឋម គុណតម្លៃ និងឥរិយាបថដែលនាំឱ្យពួកគេអភិវឌ្ឍខ្លួនប្រកបដោយសុខភាពពេញលេញទាំងកាយទាំងប្រាជ្ញា ទាំងស្មារតី និងចេះទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន[៤]។ ក្រុបខណ្ឌអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សា មានកត្តា៤ដែលជាអ្នកជំរុញឱ្យការអនុវត្តប្រកបដោយភាពជោគជ័យគឺធនធានមនុស្ស លិខិតបទដ្ឋានគតិយុត្ត ការចូលរួម និងការទំនាក់ទំនង។

គោលនយោបាយស្តីពីសុខភាពសិក្សាត្រូវបានរៀបរៀងឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានផ្តល់អាទិភាពខ្ពស់ដល់ការផ្តល់សេវាអប់រំសុខភាពប្រកបដោយសមធម៌និងមានគុណភាពខ្ពស់ ដើម្បីចូលរួមចំណែកកែលម្អ

---

[៣] រាជរដ្ឋាភិបាលកម្ពុជា *គោលនយោបាយស្តីពីសុខភាពសិក្សា* ភ្នំពេញ ឆ្នាំ ២០១៩ទំព័រ២

[៤] រាជរដ្ឋាភិបាលកម្ពុជា *គោលនយោបាយស្តីពីសុខភាពសិក្សា* ភ្នំពេញ ឆ្នាំ ២០១៩ ទំព័រ៤

លទ្ធផលនៃការសិក្សារបស់អ្នកសិក្សានៅគ្រប់គ្រឹះស្ថានសិក្សា។ គោលនយោបាយមានចំណុចយុទ្ធសាស្ត្រ៤ គឺ៖

### ៣.១ យុទ្ធសាស្ត្រទី១៖ ការពិនិត្យសុខភាព

ផ្តល់សេវាថែទាំសុខភាពចាំបាច់ដល់សិស្សានុសិស្ស និស្សិត គរុសិស្ស គរុនិស្សិត បុគ្គលិកអប់រំគ្រប់គ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន ដើម្បីបាននូវសមធម៌ក្នុងការអភិវឌ្ឍផ្នែកកាយសម្បទា បញ្ញា ស្មារតី និងសង្គម។ សេវាសុខភាពគឺជាតម្រូវការចាំបាច់របស់មនុស្សម្នាក់ៗ ដែលរស់នៅក្នុងសង្គម។ ការផ្តល់សេវាសុខភាពសិក្សារបស់បុគ្គលិកអប់រំនិងសិស្សានុសិស្សនៅតាមសាលារៀនគឺជាគោលនយោបាយដែលរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡាកំពុងតែយកចិត្តទុកដាក់យ៉ាងខ្លាំង។

**ក្រាហ្វិកទី១ ៖ ការផ្តល់សេវាសុខភាពចាំបាច់**




(ប្រភពទិន្នន័យការសម្ភាសន៍អ្នកពាក់ព័ន្ធ)

បើផ្អែកទៅលើទិន្នន័យនៅលើក្រាហ្វិកខាងលើបានឆ្លុះបញ្ចាំងឱ្យយើងឃើញថា ២៥.៩ ភាគរយ អង្គភាពបានធ្វើការពិនិត្យសុខភាពទៅដល់បុគ្គលិកដែលបំពេញការងារ និង៧៤.១ ភាគរយគឺអង្គភាពមិនបានធ្វើការពិនិត្យសុខភាពទៅដល់បុគ្គលិក។ យើងអាចធ្វើវាយតម្លៃបានទៅលើការផ្តល់សេវាសុខភាពចាំបាច់នៅក្នុងអង្គភាព សាលារៀនដែលមានការពិនិត្យសុខភាព ប្រអប់សង្គ្រោះបឋម និងការផ្តល់អាហារពេលព្រឹក។ នៅក្នុងចំណោមសេវាសុខភាពចាំបាច់ទាំងបី មានតែប្រអប់សង្គ្រោះបឋមទេ ដែលអង្គភាពបានរៀបចំឱ្យមានភាគច្រើន ចំណែកការពិនិត្យសុខភាពទៅដល់បុគ្គលិកអប់រំ និងសិស្សានុសិស្សមានតិចតួច និងការផ្តល់អាហារ

ពេលព្រឹកស្ទើរតែគ្មាន។ នេះឆ្លុះបញ្ចាំងឱ្យឃើញថាការផ្តល់សេវាសុខភាពចាំបាច់ទៅលើផ្នែកពិនិត្យសុខភាព និងការផ្តល់អាហារពេលព្រឹក គឺអង្គភាពមិនមានលទ្ធភាព នៅក្នុងការឆ្លើយតបទៅតម្រូវការចាំបាច់ ដោយសារតែមិនទាន់មានកញ្ចប់ថវិកាគ្រប់គ្រាន់សម្រាប់ការផ្តល់សេវាសុខភាពចាំបាច់ទាំងពីរនេះ ដែលប្រទេសរបស់យើងរដ្ឋនៅមានការខ្វះខាតខ្លាំងបើប្រៀបធៀបជាមួយបណ្តាលប្រទេសជឿនលឿន រដ្ឋឬរាជរដ្ឋាភិបាលរបស់ពួកគេមានលទ្ធភាពគ្រប់គ្រាន់នៅក្នុងការពិនិត្យសុខភាពយ៉ាងទៀតទាត់ទៅដល់បុគ្គលិកសិក្សា និងសិស្សានុសិស្សរបស់គេ។ ទន្ទឹមនឹងនោះ រដ្ឋឬរដ្ឋាភិបាលប្រទេសជឿនលឿនទាំងនោះបានជានា នៅក្នុងការផ្តល់អាហារពេលព្រឹកប្រកបដោយសុខភាពទៅដល់បុគ្គលិក និងសិស្សានុសិស្សរបស់គេទទួលទានទៀតផង។

## ៣.២ យុទ្ធសាស្រ្តទី២៖ ការផ្តល់សេវាអប់រំសុខភាព

ផ្តល់ការអប់រំសុខភាព និងផ្តោតលើការប្រាស្រ័យទាក់ទងដែលនាំឱ្យមានការផ្លាស់ប្តូរការប្រព្រឹត្តគឺជាសមាសភាគដ៏សំខាន់បំផុតក្នុងការផ្តល់ព័ត៌មានចំណេះដឹងបំណិននិងបម្រែបម្រួលពីឥរិយាបថទំនួលខុសត្រូវដើម្បីទទួលបានសុខុមាលភាពនិងសុខសុវត្ថិភាព។

**ក្រាហ្វិកទី២ ៖ ការផ្តល់សេវាអប់រំសុខភាព**




(ប្រភពទិន្នន័យការសម្ភាសន៍អ្នកពាក់ព័ន្ធ)

យោងតាមក្រាហ្វិកខាងលើ បានបង្ហាញឱ្យយើងឃើញថា អង្គភាពដែលបានអប់រំបង្ការជំងឺឆ្លងទៅដល់បុគ្គលិក និងអ្នកសិក្សា ៧៧.៧ភាគរយបានឆ្លើយថាអង្គភាពរបស់ពួកគេបានអប់រំបង្ការជំងឺឆ្លងនិងការបង្ការជំងឺមិនឆ្លងវិញ យើងឃើញថា អ្នកពាក់ព័ន្ធបានផ្តល់នូវចម្លើយថា ៦៩.៦ភាគរយ អង្គភាពរបស់ពួកបានអប់រំបង្ការជំងឺមិនឆ្លង ទោះតែបីជាយ៉ាងណាក៏ដោយ អង្គភាព សាលារៀនត្រូវតែអប់រំ បង្ការជំងឺទាំងអស់នេះកុំឱ្យកើតមានចំពោះបុគ្គលិកនិងសិស្ស នៅពេលដែលមានការកើតជំងឺ ទោះឆ្លងក៏ដោយ មិនឆ្លងក៏ដោយសុទ្ធតែធ្វើបាត់បង់ថវិកា ពេលវេលា និងប៉ះពាល់ទៅដល់ខ្លួនឯង គ្រួសារ និងអង្គភាព ពិសេស៨០ភាគរយនៃជំងឺមិនឆ្លងអាចបង្ការបាន។ យើងឃើញថាការអប់រំផ្នែកអនាម័យ និងបរិស្ថាន

អង្គភាពភាគច្រើនបានចូលរួមអនុវត្តការងារអប់រំនេះបានច្រើនជាងគេ បន្ទាប់មកទៀតគឺការអប់រំអំពីការបង្ការគ្រោះថ្នាក់ផ្សេងៗ ចំណែកការអប់រំបង្ការជំងឺឆ្លង និងជំងឺមិនឆ្លងបានតិចជាងគេ។ យើងវិភាគ និងធ្វើការវាយតម្លៃបានថា ការអប់រំអំពីអនាម័យនិងបរិស្ថាន និងអប់រំបង្ការគ្រោះថ្នាក់នានា មិនមានបញ្ហាលំបាកសម្រាប់ធ្វើការអប់រំទេ ប៉ុន្តែការបង្ការជំងឺឆ្លង និងជំងឺមិនឆ្លង ទាមទារឱ្យអ្នកទៅអប់រំនោះមានជំនាញ បច្ចេកទេសផ្នែកវេជ្ជបណ្ឌិត ឬពេទ្យជំនាញឯកទេស ទើបអាចធ្វើការពន្យល់ណែនាំបាន។ ប៉ុន្តែយើងឃើញថាតួលេខក្នុងក្រាហ្វិកខាងលើ អាចឆ្លុះបញ្ចាំងថាធនធានមនុស្សផ្នែក សុខាភិបាលនៅក្នុងអង្គភាព ឬសាលារៀននៅមានតិចតួចនៅឡើយនៅក្នុងការផ្តល់សេវា អប់រំផ្នែកបច្ចេកទេសសុខភាពនេះ។

## ៣.៣ យុទ្ធសាស្ត្រទី៣៖ ហេដ្ឋារចនាសម្ព័ន្ធផ្នែកសុខភាព

លើកកម្ពស់បរិស្ថានសិក្សានិងសម្ភារបរិក្ខារផ្នែកសុខភាពឱ្យសមស្របតាមស្ថានភាពជាក់ស្តែងតាមកាលៈទេសៈ ទីតាំងភូមិសាស្ត្រ ប្រជាសាស្ត្រជានាឱ្យមានប្រសិទ្ធិភាពនិងគុណភាពអប់រំ។

**ក្រាហ្វិកទី៣ ៖ សម្ភារបរិក្ខារផ្នែកអនាម័យ**




(ប្រភពទិន្នន័យការសម្ភាសន៍អ្នកពាក់ព័ន្ធ)

បើផ្អែកទៅលើក្រាហ្វិកខាងលើនេះ បានបង្ហាញឱ្យយើងឃើញថា អង្គភាព សាលារៀន ៩៩.១ ភាគរយមានបង្គន់អនាម័យសម្រាប់ការបន្ទោរបង់។ ចំណែកការលាងសម្អាតដៃ យើងឃើញថាអង្គភាព ៥៤.ភាគរយបានរៀបចំឱ្យមាន និង៤៥.៥ភាគរយមិនទាន់មាន។ ចំពោះ

ការលាងសម្អាតដៃជាចំណុចមួយយ៉ាងសំខាន់ដែល ដែលអង្គភាពគួរគប្បីឱ្យមាន ដើម្បីរក្សានូវសុខភាពអនាម័យ បើមិនមានកន្លែងលាងសម្អាតដៃអាចនឹងបង្កឱ្យមានរោគដែល មាននៅតាមដៃ ហើយធ្វើឱ្យមានជំងឺផងដែរ។ អង្គភាពសាលារៀនបានផ្ដល់ទឹកស្អាត ៨៥.៧ភាគរយ។ ដូច្នេះយើងអាចធ្វើការវាយតម្លៃបានថា អង្គភាព សាលារៀនបានយកចិត្តទុកដាក់នៅក្នុងការរៀបចំឱ្យមានបង្គន់អនាម័យ កន្លែងលាងសម្អាតដៃ និងទឹកស្អាតសម្រាប់បរិភោគ សម្ភាររូបវន្តទាំងបីនេះគឺជាផ្នែកដ៏សំខាន់សម្រាប់ឱ្យបុគ្គលិកនិងសិស្សអាចរក្សាសុខភាពរបស់គេបានល្អសម្រាប់ការរស់នៅ។

## ៣.៤ យុទ្ធសាស្ត្រទី៤៖ ការចូលរួម

បើកទូលាយឱ្យមានការចូលរួមពីក្រសួងស្ថាប័នគ្រប់ដៃគូអភិវឌ្ឍន៍និងសង្គមស៊ីវិលលើផ្នែកសុខភាពសិក្សា គឺជាការចាំបាច់ ដើម្បីធ្វើឱ្យសាលារៀនសហគមន៍និងទីសាធារណៈផ្សេងៗមានអនាម័យសោភ័ណភាពសុវត្ថិភាពនិងផាសុកភាព។

**ក្រាហ្វិកទី៤ ៖ ប្រភពថវិកា**




(ប្រភពទិន្នន័យការសម្ភាសន៍អ្នកពាក់ព័ន្ធ)

ប្រភពថវិកាសម្រាប់គាំទ្រទៅការផ្ដល់សេវាសុខភាព មានប្រភពផ្សេងៗដូចជា ប្រភពថវិកាពីស្ថាប័នរដ្ឋ ឯកជន អង្គការដៃគូជាតិនិអន្តរជាតិ និងប្រភពផ្សេងទៀត។ ការផ្ដល់សេវាសុខភាពចាំបាច់ណាស់ត្រូវមានប្រភពថវិកាគ្រប់គ្រាន់ ទើបអាចអនុវត្តគោលនយោបាយសុខភាពឱ្យមានដំណើរការល្អ។ ប្រភពថវិកាដែលគាំទ្រខ្លាំង និងរឹងមាំគឺប្រភពថវិការដ្ឋដែលមាន៩២ភាគរយ បន្ទាប់មកទៀតថវិកាអង្គការដៃគូពាក់ព័ន្ធ ៣២ ភាគរយ ឯកជនមាន ១៦.១ ភាគរយ និងប្រភពផ្សេងទៀតមាន ៨.៩ ភាគរយ។

## ៤. សន្និដ្ឋាន

ការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សាលើយុទ្ធសាស្ត្រទាំងបួនរួមមាន៖ សេវាពិនិត្យសុខភាព កម្មវិធីអប់រំសុខភាព ការបំពាក់សម្ភារបរិក្ខានិងការគៀរគរឱ្យមានការចូលរួមពីគ្រប់ដៃគូពាក់ព័ន្ធ អង្គការដៃគូព្រមទាំងផ្នែកឯកជនបានរួមចំណែកលើកកម្ពស់គុណភាពអប់រំ និងលើកកម្ពស់សុខភាពនិងសុខុមាលភាពដល់បុគ្គលិកអប់រំនិងអ្នកសិក្សាគ្រប់រូប។ ការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សាគឺសំដៅការកែប្រែទម្លាប់ និងបណ្តុះស្មារតីកាយសម្បទា បំណិនសម្បទា ឥរិយាសម្បទា មានមនសិការស្នេហាជាតិនិងមនុស្សជាតិ។ មានរបៀបរស់នៅប្រកបដោយគុណតម្លៃ មានគុណធម៌ មានសេចក្តីថ្លៃថ្នូ និងមានសីលធម៌រស់នៅ។ អ្នកសិក្សា និងបុគ្គលិកអប់រំមានសុខភាពល្អនឹងក្លាយជាធនធានមនុស្សដ៏សកម្មសម្រាប់ការអភិវឌ្ឍជាតិមាតុភូមិ។

ដើម្បីការអនុវត្តគោលនយោបាយស្តីពីសុខភាពសិក្សាទទួលបាននូវគុណភាព គុណផលនិងប្រសិទ្ធភាពខ្ពស់៖ ក្រសួងអប់រំ យុវជន និងកីឡាគួរគប្បីរៀបចំការត្រួតពិនិត្យសុខភាពបុគ្គលិកអប់រំ និងអ្នកសិក្សាទាំងអស់ឱ្យមួយម្តងក្នុងមួយឆ្នាំ។ក្រសួង គួរគប្បីរៀបចំឱ្យមានការិយាល័យសុខភាពសិក្សានៅក្នុងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត នឹងជំរុញឱ្យការអនុវត្តការងារសុខភាពសិក្សានៅថ្នាក់ក្រោមជាតិច្បាស់លាស់ ធ្វើឱ្យការបំពេញការងារផ្នែកសុខភាពនៅតាមគ្រឹះស្ថានសាលារៀនកាន់តែមានភាពល្អប្រសើរ។ ក្រសួងគួរគប្បីបណ្តុះបណ្តាលគ្រូដែលមានជំនាញសុខភាពនៅគ្រប់កម្រិតភូមិសិក្សា។ ព្រោះការងារសុខភាពសិក្សាជាការងារដែលត្រូវការអ្នកដែលមានចំណេះដឹង និងជំនាញវេជ្ជបណ្ឌិត ពេទ្យច្បាស់លាស់ គួរតែរៀបចំផែនការបណ្តុះបណ្តាលគ្រូផ្នែកសុខភាពសិក្សាចាប់ពី មត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សា ដើម្បីឱ្យពួកគេមានជំនាញច្បាស់លាស់នៅក្នុងបង្ហាត់បង្រៀនសិស្ស និងចូលរួមចំណែកជួយពិនិត្យសុខភាពដល់បុគ្គលិកអប់រំដទៃទៀតនិងសិស្សានុសិស្ស។ រីតតែសំខាន់ជាងនេះទៅទៀតគឺ**ក្រសួងគួរគប្បីរៀបចំផែនការយុទ្ធសាស្ត្ររយៈពេលវែងស្តីពីសុខភាពសិក្សា** ដើម្បីត្រៀមទុកជាមុននៅក្នុងការថែទាំសុខភាពបុគ្គលិក និងអ្នកសិក្សាឱ្យបានល្អ ចៀសវាងការកើតឡើងនូវបញ្ហាសុខភាព និងគ្រោះថ្នាក់ផ្សេងៗ និងមានវិធានការទប់ស្កាត់ទាន់ពេលវេលា ដែលមិនធ្វើឱ្យបុគ្គលិកអប់រំ និងអ្នកសិក្សាខាតបង់ពេលវេលារបស់ពួកគេ។

# គន្ថនិទ្ទេស


## ក-ឯកសារជាភាសាខ្មែរ

1. *រដ្ឋធម្មនុញ្ញ*នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣។
2. ក្រសួងអប់រំ យុវជន និងកីឡា *ច្បាប់ស្តីពីការអប់រំ* ឆ្នាំ២០០៧។
3. ក្រសួងអប់រំយុវជននិងកីឡា*គោលនយោបាយស្តីពីសុខភាពសិក្សា* នាយកដ្ឋានសុខភាពសិក្សា ឆ្នាំ២០០៩។
4. ក្រសួងអប់រំយុវជននិងកីឡា*គោលការណ៍ណែនាំអនុវត្តលក្ខណ្ឌអប្បបរមាស្តីពី ទឹកស្អាត និង អនាម័យតាមសាលារៀន* នាយកដ្ឋានសុខភាពសិក្សា ឆ្នាំ២០១៦។
5. ក្រសួងអប់រំ យុវជន និងកីឡា សេចក្តីណែនាំអំពីវិធានការអនាម័យ សម្រាប់កម្មវិធី *អាហារ សាលារៀនបឋមសិក្សា* របស់ នាយកដ្ឋានសុខភាពសិក្សា ឆ្នាំ២០១១។
6. ក្រសួងអប់រំ យុវជន និងកីឡា សេចក្តីណែនាំលេខ១៨ អយក. សណន ចុះថ្ងៃទី២៤ ខែមិថុនាឆ្នាំ២០១៣*ស្តីពីការលើកកម្ពស់សុវត្ថិភាពចំណីអាហារ និងអាហារប្រកបដោយសុវត្ថិភាព នៅតាមគ្រឹះស្ថានសាធារណៈ និងឯកជន* របស់ នាយកដ្ឋានសុខភាពសិក្សា ឆ្នាំ២០១៣។
7. ក្រសួងអភិវឌ្ឍន៍ជនបទ *ផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទ* ឆ្នាំ២០១៦។

## ខ-ឯកសារជាភាសាបរទេស

1. Ministry of Health National Health Care Policy and Strategy for older people.
2. School of Public Health,*The assessment of Knowledge on Nutrition among primary school teacher in Phnom Penh*, Dr. Chhay Kim Sotheavy, Phnom penh.
3. United of America, *Introduction to Health Education*, Walter H. Greene Bruce G. Simon-Morton, Waveland Press, Inc. Prospect Heights, Illinois 60070 ( 708 ) 634-0081, 1999 reissued by Waveland Press, Inc. page 4-6, 24-39, 55-81, 229.
4. *The Introducing Public Administration* Edition No 07, Shafritz, Russell, Borick, copyright 2011 by Pearson Education, Inc. NYC. www. pearsonhighered.com. page 6-33.
5. https://Legal-dictionary. the freedictionary.com//policy
6. https://www.marriam-webster.com/dictionary/health
7. https://en.wikipedia.org/wiki/health policy
8. https://www.journals.elsevier.com/health policy
9. https://commons.wikimedia.org/w/index.php?curid=66543582

# ឥទ្ធិពលហ្វេសប៊ុកលើឥរិយាបថមន្ត្រីផ្តល់សេវាសាធារណៈរបស់រដ្ឋ និងការអនុវត្តច្បាប់នៅកម្ពុជា

បេក្ខជនបណ្ឌិតៈ **ឆាយ សុផល**

## ១- សេចក្តីផ្តើម

នៅក្នុងឆ្នាំ២០១១ បន្ទាប់ពីមានចលនាបដិវត្តន៍អារ៉ាប់ [Arab Spring] បណ្តាញផ្សព្វផ្សាយសង្គម ជាពិសេស ហ្វេសប៊ុក ក៏បានរីករាលដាលនៅទូទាំងពិភពលោក។ បន្ទាប់មក ទំនាក់ទំនងតាមហ្វេសប៊ុក ក៏បានរីករាលដាលមកក្នុងបណ្តាប្រទេសនៅតំបន់អាស៊ី ក្នុងនោះក៏មាន ប្រទេសកម្ពុជាផងដែរ។ ពីមួយថ្ងៃទៅមួយថ្ងៃ នៅចន្លោះឆ្នាំ២០០៨-២០២១ ទំហំអ្នកប្រើប្រាស់ហ្វេសប៊ុក នៅក្នុងពិភពលោកមានកាន់តែធំ ដែលអាចឱ្យមនុស្សនៅគ្រប់ទិសទី អាចប្រាស្រ័យទាក់ទងគ្នាបាន។ នៅក្នុងប្រទេសកម្ពុជា នាការបោះឆ្នោតជាតិឆ្នាំ២០០៨ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបែបប្រពៃណី រួមមានកាសែត ទស្សនាវដ្តី ព្រឹត្តិបត្រព័ត៌មាន ជាពិសេសការផ្សាយតាមរលកអាកាសរួមមានវិទ្យុ និងទូរទស្សន៍ គឺជាមធ្យោបាយទី១ សម្រាប់អ្នកចលនាសង្គម និងប្រជាពលរដ្ឋបានបញ្ចេញមតិពីបញ្ហាសង្គមទូទៅ និងពិភាក្សាពីការអនុវត្តច្បាប់ជាដើមទៅកាន់មហាជន ក្រៅពីការចូលរួមជជែកវែកញែកដោយផ្ទាល់នៅក្នុងវេទិកានិងកិច្ចប្រជុំនានា ខណៈដែលហ្វេសប៊ុកនៅមិនទាន់ពេញនិយមនៅឡើយ។ ប៉ុន្តែ ចាប់តាំងពីការបោះឆ្នោតជាតិនាឆ្នាំ២០០៨ មកដល់ឆ្នាំ២០២១ ក៏ដូចជាឆ្នាំបន្ទាប់ៗមក ដោយសារប្រព័ន្ធទូរគមនាគមន៍ មានដូចជាសេវាអ៊ីនធឺណិត និងឧបករណ៍ទូរស័ព្ទវៃឆ្លាត បានគ្របដណ្តប់ស្ទើរទូទាំងប្រទេស និងមានតម្លៃសមរម្យ ហ្វេសប៊ុក បានចាប់ផ្តើមពេញនិយម និងបានដើរតួនាទីយ៉ាងសកម្មលើកិច្ចការនយោបាយ និងបញ្ហាសង្គម។ ហ្វេសប៊ុក អាចត្រូវបានបញ្ចូលដោយងាយនៅក្នុងទូរស័ព្ទវៃឆ្លាត ហើយបើទោះជាអ្នកប្រើប្រាស់ទូរស័ព្ទវៃឆ្លាតមិនអាចដំឡើង(Install) ហ្វេសប៊ុកបានដោយខ្លួនឯងក៏ដោយ ក៏អ្នកប្រកបរបររកស៊ីលក់ដូរ និងអ្នកជួសជុលទូរស័ព្ទវៃឆ្លាត ព្រមទាំងអ្នកចេះបច្ចេកវិទ្យាព័ត៌មានដទៃទៀតជួយដំឡើងឱ្យបានដែរ ដែលប្រការនេះបានធ្វើអ្នកប្រើប្រាស់ទូរស័ព្ទវៃឆ្លាតបានប្រើប្រាស់ហ្វេសប៊ុកកាន់តែច្រើនឡើង និងមានគោលបំណងផ្សេងៗគ្នា ទាំងក្នុងបរិបទនយោបាយ និងបញ្ហាសង្គម។

ជាងនេះទៅទៀត កំណើននៃការប្រើប្រាស់ហ្វេសប៊ុកបែបនេះ បានធ្វើឱ្យប្រជាពលរដ្ឋហ៊ានបញ្ចេញមតិនៅតាមទំព័រហ្វេសប៊ុកពីកិច្ចការនយោបាយនិងបញ្ហាសង្គមទូទៅ ខណៈដែលអ្នកប្រើប្រាស់ហ្វេសប៊ុកមួយចំនួនក៏ធាប់មានកំហឹងចំពោះសារមិនល្អនៅលើហ្វេសប៊ុក។ ប្រការនេះអាចនាំមានឥទ្ធិពលលើការផ្លាស់ប្តូរឥរិយាបថមន្ត្រីផ្តល់សេវាសាធារណៈរបស់រដ្ឋអាចជួយកាត់បន្ថយការិយាធិបតេយ្យ និងអំពើពុករលួយជាដើម ព្រមទាំងមានការឆ្លើយតបពីថ្នាក់ដឹកនាំជាដើម ចំពោះការផ្តល់ សេវាសាធារណៈរបស់រដ្ឋ។ ហ្វេសប៊ុក ក៏ត្រូវបានគេមើលឃើញដែរថា បានជះឥទ្ធិពលលើការអនុវត្តច្បាប់ និងឥរិយាបថមន្ត្រីអនុវត្តច្បាប់ ព្រមទាំងឥរិយាបថរបស់ពលរដ្ឋចំពោះការគោរពច្បាប់ផងដែរ។

## ២- វិធីសាស្ត្រនៃការស្រាវជ្រាវ

នៅក្នុងដំណើរការនៃការសិក្សាដើម្បីប្រមូលទិន្នន័យ វិធីសាស្ត្រពីរត្រូវបានធ្វើឡើង។ វិធីសាស្ត្រទី១ បានផ្តោតលើបរិមាណវិស័យ ដោយផ្អែកលើទិន្នន័យនៃការសម្ភាសសកលគំរូគោលដៅចំនួន៥០០នាក់ (ព្រះសង្ឃចំនួន១២អង្គ)។ ផ្អែកលើគោលបំណងនៃការស្រាវជ្រាវ កម្រងសំណួរត្រូវបានរៀបចំឡើងយ៉ាងហ្មត់ចត់។ ដើម្បីឈរលើមូលដ្ឋានយេនឌ័រ ការសិក្សាក៏បានជ្រើសរើសយកស្ត្រីចំនួន៣០% ក្នុងចំណោមសកលគំរូគោលដៅចំនួន៥០០នាក់ រស់នៅនិងធ្វើការនៅក្នុងរាជធានីភ្នំពេញ។ ទន្ទឹមនឹងនោះ សកលគំរូគោលដៅក៏ត្រូវបានចែកជាព័ត៌មានប្រជាសាស្ត្រ ដោយមានអាយុ ភេទ កម្រិតសិក្សា និងមុខរបរផងដែរ។

វិធីសាស្ត្រទី២បានវិភាគដោយផ្អែកលើគុណវិស័យ ដោយប្រមូលទិន្នន័យតាមរយៈការសិក្សាលើខ្លឹមសារដែលបានមកពីការអានឯកសារចំនួន៣៩១ មកធ្វើជាគន្លងនិទ្ទេស ដែលក្នុងនោះ ឯកសារស្រាវជ្រាវជាភាសាខ្មែរ មានសៀវភៅចំនួន១២ច្បាប់ របាយការណ៍មានចំនួន៦៣ឯកសារ សុទ្ធរកថាចំនួន២អត្ថបទ សារព័ត៌មានចំនួន២០១អត្ថបទ និងបណ្តាញផ្សព្វផ្សាយសង្គមហ្វេសប៊ុកចំនួន១៤គណនី ព្រមទាំងបទសម្ភាសន៍ចំនួន២ករណី/នាក់ ហើយឯកសារភាសាបរទេស មានសៀវភៅចំនួន១២ច្បាប់ របាយការណ៍ស្រាវជ្រាវចំនួន៤៤អត្ថបទ សារព័ត៌មានចំនួន៣៨អត្ថបទ ខណៈបណ្តាញផ្សព្វផ្សាយសង្គមហ្វេសប៊ុកចំនួន៣គណនី។

ដើម្បីឱ្យលទ្ធផលនៃការសិក្សាទទួលបានភាពសុក្រឹត ទិន្នន័យទាំងអស់ដែលបានមកពីទិន្នន័យបឋម (Secondary Data) និង ទិន្នន័យទុតិយតា (Primary Data) ត្រូវបានវិភាគដោយប្រកាន់យកវិធីអធិប្បាយ (Discritive mean) វិធីរុករក (Explortive mean) តាមរយៈរូបមន្តក្នុងកម្មវិធី Windows Excel និង SPSS។

## ៣- ទំនោរនៃការប្រើប្រាស់ហ្វេសប៊ុក

នៅក្នុងចំណោមសកលគំរូគោលដៅចំនួន៥០០នាក់សម្រាប់ការសិក្សានេះ គឺមានចំនួនដល់ទៅ៩៩% (៤៩៥នាក់) មានគណនីហ្វេសប៊ុក ខណៈមានតែ ១% (៥នាក់) ប៉ុណ្ណោះ ដែលមិនមានគណនីហ្វេសប៊ុកដោយផ្ទាល់ខ្លួនឯង ប៉ុន្តែសកលគំរូគោលដៅចំនួន១%នោះដែលជាកម្មករ បានបញ្ជាក់ថា ពួកគេបានប្រើប្រាស់ហ្វេសប៊ុករួមគ្នាជាមួយប្តី និងប្រពន្ធ ហើយថា ពួកគេត្រូវមានគណនីហ្វេសប៊ុកមួយដោយខ្លួនឯងនៅពេលបន្ទាប់។




គិតត្រឹមឆមាសទី១ ក្នុងឆ្នាំ២០២០ ប្រទេសកម្ពុជា មានអ្នកប្រើប្រាស់ហ្វេសប៊ុក សរុបមានចំនួនប្រមាណ ១០ ៩៥០ ០០០គណនី[១] ខណៈអត្រាប្រជនមានចំនួន១៥ ៥៥២ ២១១នាក់[២] ហើយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បាននិងកំពុងប្រែក្លាយទៅជាក្រសួងនាំមុខខាងផ្នែកឌីជីថលនាឆ្នាំ២០២២[៣] ហើយមកដល់ខែធ្នូ ឆ្នាំ២០២១ មានអ្នកប្រើប្រាស់ហ្វេសប៊ុកសកម្មចំនួន១២ ៨៤៥ ៤០០ នៅក្នុងប្រទេសកម្ពុជា ឬ ៧៤,៦% នៃចំនួនប្រជាជនសរុបរបស់ប្រទេស ក្នុងនោះ ៥៥,៣% ជាបុរស ហើយក្រុមអ្នកប្រើប្រាស់ធំបំផុតគឺមានអាយុចន្លោះពី២៥ ទៅ ៣៤ឆ្នាំ។[៤] តួលេខនេះបង្ហាញថា ប្រជាជនកម្ពុជា និយាយដោយឡែកអ្នករាជធានីភ្នំពេញមានគណនីហ្វេសប៊ុកភាគច្រើន។

## ៤- លទ្ធផលនៃការសិក្សា

ក្រៅពីការយកទំព័រហ្វេសប៊ុកធ្វើជាវេទិកាពិភាក្សានយោបាយ និងការបោះឆ្នោត អ្នកប្រើប្រាស់ហ្វេសប៊ុកក៏ហ៊ានបញ្ចេញមតិជាទូទៅពីការផ្តល់សេវាសាធារណៈរបស់រដ្ឋ និងបញ្ហាច្បាប់ផងដែរ ដែលប្រការនេះបានជះឥទ្ធិពលលើសង្គម ដែលនាំឱ្យការិយាធិបតេយ្យត្រូវបានកាត់បន្ថយ អំពើពុករលួយត្រូវបានកាត់បន្ថយ និងការទទួលខុសមានកាន់តែច្រើនសម្រាប់ការផ្តល់សេវាសាធារណៈរបស់រដ្ឋជូនមហា

[១] ប្រាជ្ញ សុវណ្ណារ៉ា : ***កម្ពុជាមានអ្នកប្រើអ៊ីនធឺណិតជាង១៥លាននាក់ និងអ្នកប្រើប្រាស់គណនី Facebook ជាង១០លានគណនី គិតត្រឹមឆមាសទី១ឆ្នាំនេះ***, (សារព័ត៌មានខ្មែរប៉ុស្តិ៍, ភ្នំពេញ ២០ កក្កដា ២០២០), https://khmerpostasia.com/archives/56736, (Accessed at 09:59 am on 9 March 2023)។

[២] វិទ្យាស្ថានស្ថិតិ : ***ជំរឿនទូទៅប្រជាជននៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩***, (ក្រសួងផែនការ តុលា ២០២០), ទំព័រ ix, http://www.nis.gov.kh/nis/Census2019/Final%20General%20Population%20Census%202019-Khmer.pdf, (Accessed at 11:59 am on 12 March 2023)។

[៣] គង់ សូរិយា : ***ចំនួនអ្នកប្រើប្រាស់Internetនៅកម្ពុជាកើនឡើងប្រមាណ១៦លាននាក់ និង facebook ជាង១០លាននាក់***, (Property Area February 3, 2021), https://propertyarea.asia/archives/63359, (Accessed at 03:41pm on 11 March 2023)។

[៤] Surya Narayan: ***Most popular social media platforms in Cambodia***, (The Better Cambodia, 2022), https://thebettercambodia.com/most-popular-social-media-platforms-in-cambodia/, (Accessed at 05:44pm on 14 April 2023).

ជន ខណៈឥរិយាបថរបស់មន្ត្រីផ្តល់សេវាសាធារណៈរបស់រដ្ឋ មន្ត្រីអនុវត្តច្បាប់ និងឥរិយាបថនៃការគោរពច្បាប់របស់ប្រជាពលរដ្ឋមានការផ្លាស់ប្តូរបែបវិជ្ជមានជាងមុន។ ទន្ទឹមនឹងនោះ អ្នកប្រើប្រាស់ហ្វេសប៊ុកមួយចំនួនក៏ធាប់មានកំហឹងផងដែរ នៅពេលដែលពួកគេបានឃើញសារមិនល្អនៅលើទំព័រហ្វេសប៊ុក។

### ៤.១- អ្នកប្រើប្រាស់ហ្វេសប៊ុក និងការធាប់មានកំហឹងចំពោះសារមិនល្អ

នៅកម្ពុជា បើទោះជាមិនមានរបាយការណ៍ និងការសិក្សាលម្អិតណាមួយបញ្ជាក់ពីការធាប់ខឹងរបស់អ្នកប្រើប្រាស់ហ្វេសប៊ុក នៅពេលឃើញសារក៏ដោយ ក៏មានអត្ថបទសារព័ត៌មានមួយចំនួនបានចុះផ្សាយពីករណីនេះខ្លះដែរ ហើយការខឹងនេះក៏ឈានទៅការប្តឹងផ្តល់គ្នានៅតុលាការទៀតផង។ ទាក់ទិននឹងការធាប់មានកំហឹងចំពោះសារមិនល្អនៅលើហ្វេសប៊ុក ការសិក្សាក៏បានរកឃើញថា សកលគំរូគោលដៅភាគច្រើនមានរហូតដល់ទៅ ៨៩,៦% (៤៤៨នាក់) ឆ្លើយថា អ្នកប្រើប្រាស់ហ្វេសប៊ុកធាប់ខឹង នៅពេលដែលពួកគេឃើញសារប៉ះអារម្មណ៍របស់ខ្លួននៅតាមហ្វេសប៊ុក ហើយមានតែ៤,៦% (២៣នាក់) ប៉ុណ្ណោះ ឆ្លើយថា មិនធាប់ខឹងទេ ខណៈ ៥,៨% (២៩នាក់) មិនបានផ្តល់ចម្លើយ។




ជារៀងរាល់ថ្ងៃ អ្នកប្រើប្រាស់ហ្វេសប៊ុកជាប្រចាំ ក្រៅតែពីមានអារម្មណ៍សប្បាយរីករាយសាទរនូវសារល្អៗ ឬក៏មានអារម្មណ៍ថា ខ្លួនមិនឯកោ នៅពេលខ្លួនបង្ហោះ ឬចែករំលែកសារពីបញ្ហាផ្ទាល់ខ្លួននៅលើទំព័រហ្វេសប៊ុក នាំឱ្យមានការឆ្លើយតបបែបលើកទឹកចិត្ត កោតសរសើរ ក៏ដោយ ក៏អាចធ្វើឱ្យអារម្មណ៍របស់ពួកគេប្រែប្រួលមួយរំពេច នៅពេលដែលពួកគេលើកទូរស័ព្ទវៃឆ្លាត ឬមើលកុំព្យូទ័រ ឬក៏ឧបករណ៍ផ្សេងៗទៀត ដោយមានភ្ជាប់អ៊ីនធឺណិត ហើយពិនិត្យមើលសារនៅលើទំព័ហ្វេសប៊ុក។ ហ្វេសប៊ុកពិតជាមានឥទ្ធិពលលើអារម្មណ៍របស់អ្នកប្រើប្រាស់ ដោយឥទ្ធិពលនោះគឺអាស្រ័យលើសារដែលពួកគេបានទទួលនិងបានឃើញ។ ក្តីទុក្ខកង្វល់ទាំងឡាយអាចបាត់បង់មួយរំពេច និងមួយរយៈពេលខ្លីដោយជំនួសមកវិញនូវភាពសប្បាយរីករាយ បន្ទាប់ពីពួកគេបានឃើញសារល្អៗទាំងសំណេរ រូបភាព វីដេអូ និងរូបថ្លុកជាដើម។ ប៉ុន្តែ នៅពេលដែលពួកគេបានទទួលទាំងផ្ទាល់និងប្រយោលនូវសារអាក្រក់ៗច្រើនពេកនៅលើទំព័រហ្វេសប៊ុក នោះអាចនាំឱ្យប៉ះពាល់សុខភាពផ្លូវចិត្តរបស់អ្នកប្រើប្រាស់ហ្វេសប៊ុកដែរ។ នៅក្នុងការសិក្សានេះយើងបានរកឃើញទិន្នន័យដែលក្រុមគោលដៅបានឆ្លើយតបដោយបង្ហាញ

ថា ពួកគេធាប់ខឹង ដោយមិនសប្បាយចិត្ត នៅពេលដែលពួកគេបានឃើញសារមិនល្អនៅលើហ្វេសប៊ុក ដែលសារមិនល្អទាំងនោះមានដូចជា ឬក៏ការជេរប្រមាថ ឌឺដង ចំអក ឡកឡឺយ ការរំលោភបំពានផ្សេងៗ ការប្រព្រឹត្តបទឧក្រិដ្ឋ ការប្រៀបធៀបជីវិតរស់នៅខុសគ្នារវាងអ្នកមានជីវភាពធូរធារ និងអ្នកមានជីវភាពទន់ខ្សោយ រវាងអ្នកទីក្រុង និងអ្នកជនបទ អ្នកមានបុណ្យសក្តិ និងអ្នកគ្មានបុណ្យសក្តិជាដើម។ ទន្ទឹមនឹងនោះ សារទាក់ទិននឹងនយោបាយ នារដូវការបោះឆ្នោតម្តងៗ ក៏នាំឱ្យពួកគេមានអារម្មណ៍មិនល្អ និងខឹងសម្បាដែរ ជាពិសេសសារដែលធ្វើឱ្យប៉ះពាល់ដល់គណបក្សនយោបាយ និងមេដឹកនាំនយោបាយដែលពួកគេគាំទ្រ។ សូម្បីតែអ្នកនយោបាយ សកម្មជននយោបាយ និងអ្នកគាំទ្រនយោបាយ រួមទាំងអ្នកប្រើប្រាស់ហ្វេសប៊ុកខ្លះទៀត នៅពេលខ្លួនបង្ហោះសារណាមួយ ហើយបើគ្មានអ្នកចុចចូលចិត្ត (LIKE) បញ្ចេញយោបល់ (Comment) និងចុចមើល (VIEW) ទេ នោះពួកគេក៏អន់ចិត្ត និងឈានទៅខឹងសម្បាទៀតផង។

នៅឆ្នាំ២០១៧ ដើម្បីទាក់ទាញប្រជាប្រិយភាពឱ្យកាន់ខ្លាំងឡើង ក្រុមហ៊ុនហ្វេសប៊ុកបានផ្តល់ឱ្យអ្នកប្រើប្រាស់នូវទម្រង់ថ្មីចំនួន៥ ក្នុងការប្រតិកម្ម ឬឆ្លើយទៅនឹងការបង្ហោះសារ ដែលក្នុងនោះមានការបង្ហាញរូបសញ្ញាដូចជា 'ក្តីស្រឡាញ់' (Love) 'សើចហាហា' (Haha) 'អស្ចារ្យ' (wow) 'កម្សត់' (Sad) និង 'ខឹង' (Angry) ជាដើម។[៥] នេះគឺជាសញ្ញាសម្រាប់ឱ្យអ្នកប្រើប្រាស់ហ្វេសប៊ុកបង្ហាញពីអារម្មណ៍របស់ខ្លួនក្នុងការធ្វើប្រតិកម្មឆ្លើយតបទៅនឹងសារដែលខ្លួនបានបង្ហោះ ឬក៏សារដែលខ្លួនបានទទួលពីអ្នកដទៃ ហើយ «ទិន្នន័យរបស់ក្រុមហ៊ុនហ្វេសប៊ុកនៅឆ្នាំ២០១៩ បានបង្ហាញពីអារម្មណ៍ប្រតិកម្មខឹងសម្បាច្រើន ទំនងជាពាក់ព័ន្ធនឹងព័ត៌មានមិនត្រឹមត្រូវ ព័ត៌មានបំពុល និងព័ត៌មានគ្មានគុណភាពជាដើម។[៦]

យ៉ាងណាក៏ដោយ ការប៉ះទង្គិចអារម្មណ៍ ឬក៏ផ្លូវចិត្តវាក៏អាស្រ័យលើគតិ និងពុទ្ធិ ព្រមទាំងសមត្ថភាពនៃការវិភាគផងដែរ ដូចជាឧទាហរណ៍ថា នៅពេលដែលអ្នកប្រើប្រាស់ហ្វេសប៊ុកមានប្រាជ្ញាខ្សោយ មានកម្រិតនៃការវិភាគមិនស៊ីជម្រៅ នោះពួកគេពិតជាឆាប់ច្រឡោតខឹងមួយរំពេច បន្ទាប់ពីបានទទួលសារមិនល្អ ពិសេសសារដែលប៉ះពាល់ ឬក៏មានទំនោរប្រហាក់ប្រហែលនឹងរឿងរ៉ាវរបស់ខ្លួន។ ម្យ៉ាងវិញទៀត ទម្លាប់នៃការប្រើប្រាស់ហ្វេសប៊ុក នៅក្នុងសម័យឌីជីថលនៅក្នុងពិភពលោកគឺជះឥទ្ធិពលផ្សេងៗគ្នាដល់អារម្មណ៍របស់អ្នកប្រើប្រាស់ ក្នុងនោះមាន «ការខឹងសម្បា ការផ្ទុះកំហឹងនាំឱ្យបាត់បង់សីលធម៌ ដែលបង្កឱ្យមានហានិភ័យដល់ឯកជនភាព និងការបែងចែកនិន្នាការនយោបាយ ដែលហ្វេសប៊ុកបានបង្កើត ដោយទម្លាប់បែបនេះក៏អាចនាំប៉ះពាល់ដល់សុខភាពផ្លូវចិត្តផងដែរ»[៧]។

---

[៥] Jeremy B. Merrill and Will Oremus: ***Five points for anger, one for a 'like': How Facebook's formula fostered rage and misinformation***, (The Washington Post, 26 October 2021), https://www.washingtonpost.com/technology/2021/10/26/facebook-angry-emoji-algorithm/, (Accessed at 02:17pm on 29 April 2023).

[៦] - ដ -

[៧] Benedict Carey: ***This Is Your Brain Off Facebook***, (The New York, 30 January 2019 Times), https://ww w.nytimes.com/2019/01/30/health/facebook-psychology-health.html, (Accessed at 08:01am on 30 April 2023).

### ៤.២- ការបញ្ចេញមតិតាមហ្វេសប៊ុក

នៅពេលនិយាយអំពីការបញ្ចេញមតិ ឬ « *សេរីភាពបញ្ចេញមតិ គេនឹងនឹកឃើញទៅដល់ការប្រើប្រាស់បណ្ដាញសង្គមក្នុងការបញ្ចេញមតិពាក់ព័ន្ធនឹងបញ្ហាសង្គម បរិស្ថាន វប្បធម៌ និងអក្សរសាស្ត្រជាដើម។* »[៨] នៅក្នុងចន្លោះឆ្នាំ២០០៨-២០២១ ការប្រើប្រាស់បណ្ដាញផ្សព្វផ្សាយសង្គម និយាយដោយឡែក ហ្វេសប៊ុក នៅក្នុងចំណោមប្រជាជន ជាពិសេសយុវជន គឺមានការវិវត្តកាន់តែទូលំទូលាយនៅក្នុងសង្គមកម្ពុជា ហើយពួកគេតែងតែបង្ហាញទស្សនៈ ឬមតិយោបល់លើគណនីផ្ទាល់ខ្លួនផង និងលើគណនីរបស់អ្នកដទៃផង នៅពេលដែលពួកគេមានបំណង។

បើទោះជាអ្នកឃ្លាំមើលសិទ្ធិមនុស្សរបស់អង្គការសង្គមស៊ីវិលមួយចំនួនប្រកាសថា មានបញ្ហានៃការរឹតត្បិតនៃការបញ្ចេញដែល « *បានធ្វើឱ្យយុវជនខ្មែរមួយចំនួនមានអារម្មណ៍ថា មិនមានសុវត្ថិភាពនៅពេលដែលពួកគេនិយាយ ឬបញ្ចេញមតិនៅលើបណ្ដាញសង្គមជាដើម* »[៩] ក៏ដោយ ក៏មានប្រជាពលរដ្ឋជាច្រើនបានបញ្ចេញមតិនៅលើទំព័រហ្វេសប៊ុករបស់ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ដែរ។ ជាការពិត ប្រទេសកម្ពុជាបាន « *អនុវត្តនយោបាយប្រជាធិបតេយ្យ សេរី ពហុបក្ស* »[១០] ដែលធ្វើឱ្យពលរដ្ឋមានសិទ្ធិបញ្ចេញមតិទាំងនៅទីសាធារណៈ និងនៅក្នុងបណ្ដាញសង្គម និយាយដោយឡែកគឺ ហ្វេសប៊ុក ដែលពេលខ្លះ ហ្វេសប៊ុក បានក្លាយជាវេទិកាចំហមួយ» *ដែលបុគ្គលភាគច្រើនអាចសម្ដែងអារម្មណ៍ផ្ទាល់ខ្លួន មតិផ្ទាល់ខ្លួន មតិពាក់ព័ន្ធនឹងរឿងរ៉ាវសង្គម ឬនយោបាយជាដើម។ មិនត្រឹមតែប៉ុណ្ណោះ បុគ្គលមួយចំនួនបានប្រើប្រាស់បណ្ដាញសង្គម ដើម្បីឌឺដងដាក់គ្នា ហែកកេរ្តិ៍គ្នា ឬជេរប្រមាថគ្នាក៏មានដែរ* »។[១១]

ទាក់ទិននឹងការបញ្ចេញមតិតាមហ្វេសប៊ុករបស់អ្នកប្រើប្រាស់ហ្វេសប៊ុក លទ្ធផលនៃការសិក្សាសម្រាប់និក្ខេបបទនេះបានបង្ហាញថា សកលគំរូគោលដៅភាគច្រើនលើសលប់មានរហូតដល់ទៅ ៨៨,៨% (៤៤៤នាក់) ឆ្លើយថា ពួកគេហ៊ានបញ្ចេញមតិតាមហ្វេសប៊ុក នៅពេលឃើញសារផ្សេងៗ ហើយមានតែ ៥,៦% (២៨នាក់) ប៉ុណ្ណោះ ដែលបញ្ជាក់ថា ពួកគេមិនហ៊ានបញ្ចេញមតិឡើយ ខណៈ ៥,៦% (២៨នាក់) មិនបានផ្ដល់ចម្លើយ។

---

[៨] ឃី ចន្ទក្រឹះស្នា, ពៅ ណាទី និង សុខ សុម៉ា : ***អត្ថបទទស្សនៈ តើគេត្រូវធ្វើដូចម្ដេចទើបអនុវត្តសេរីភាពបញ្ចេញមតិបានពេញលេញនិងស្របច្បាប់?***, (Politikoffee, ភ្នំពេញ ១៦ កុម្ភៈ ២០២២), https://politikoffee.com/en/koffee/42358, (Accessed at 7:33pm on 22 October 2022)។

[៩] ហាន ណូយ : ***បទយកការណ៍៖ យុវជនមិនសូវហ៊ានបញ្ចេញមតិពីបញ្ហាសង្គមលើអ៊ិនធឺណិតដោយសារបារម្ភពីសុវត្ថិភាព, (វីអូឌី ភ្នំពេញ ២៥ មករា ២០២១***(, https://www.vodkhmer.news/2021/01/25/youth-worry-about-freedom-on-the-internet/, (Accessed at 8:37pm on 22 October 2022)។

[១០] មាត្រា៥១នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

[១១] លឹម វាសនា : ***តើគួរបញ្ចេញមតិយ៉ាងដូចម្ដេចឱ្យមានតម្លៃ?***, (ថ្មីៗ ភ្នំពេញ ១៧ មីនា ២០២១), https://thmeythmey.com/?page=detail&id=101615, (Accessed at 8:49pm on 22 October 2022)។




សូម្បីតែទំព័រហ្វេសប៊ុករបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ក៏មានពលរដ្ឋចូលទៅបញ្ចេញមតិ និងសំណូមពរផ្សេងៗផងដែរ នៅពេលដែល សម្តេចតេជោ បានបង្ហោះសារណាមួយដែលពាក់ព័ន្ធនឹងបញ្ហារបស់គេ។ ចំណែកឯទំព័រហ្វេសប៊ុករបស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក៏បានទទួលមតិពីប្រជាពលរដ្ឋផងដែរ ហើយបើ « *យោងរបាយការណ៍បូកសរុបស្តីពីការទទួលមតិ-យោបល់ ឬសំណូមពររបស់មហាជនដែលបានបញ្ចេញមតិ និងផ្ញើសារក្នុងគេហទំព័រហ្វេសប៊ុករបស់លោក ស ខេង បានឱ្យដឹងថា ចំពោះគណនីដែលនៅសល់ក្នុងឆ្នាំ២០២១ ក្រុមការងារបានធ្វើការបូកសរុបតាមដាន ហើយដោយឡែកមានចំនួន៦៥០គណនី ក្នុងនោះដោះស្រាយបាន១២៨គណនីនិងកំពុងដោះស្រាយចំនួន៥២២គណនី*»។[១២]

សរុបមក អ្នកប្រើប្រាស់ហ្វេសប៊ុកហ៊ានបញ្ចេញមតិ ឬសំណូមពរផ្សេងៗពាក់ព័ន្ធនឹងផលប្រយោជន៍របស់ពួកគេនៅតាមហ្វេសប៊ុក សូម្បីតែនៅលើទំព័រហ្វេសប៊ុករបស់ថ្នាក់ដឹកនាំ។ ហ្វេសប៊ុកបានក្លាយជាវេទិកា ឬថាជាទីលានលម្អមួយដែលបុគ្គលគ្រប់រូបអាចបញ្ចេញទស្សនៈ និងសម្តែងអារម្មណ៍ផ្ទាល់ខ្លួនពាក់ព័ន្ធនឹងរឿងរ៉ាវផ្សេងៗនៅក្នុងគ្រប់ទម្រង់និងគ្រប់វិស័យ។

### ៤.៣- ហ្វេសប៊ុក និងការិយាធិបតេយ្យ

ការិយាធិបតេយ្យគឺជាគោលគំនិតមួយដែលត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅក្នុងសង្គមវិទ្យា និងនៅក្នុងការសិក្សាទ្រឹស្តីអង្គការចាត់តាំង ហើយបច្ចុប្បន្ន ការិយាធិបតេយ្យនេះត្រូវបានគេបង្ហាញជាញឹកញាប់ថាមានទិដ្ឋភាពបែបអវិជ្ជមាន។[១៣] ការិយាធិបតេយ្យជាទម្រង់អង្គការចាត់តាំងមួយ

---

[១២] ឡាយ សាមាន : *ក្រុមការងារហ្វេសប៊ុកលោក ស ខេង ទទួលដោះស្រាយ យោបល់ និងសំណូមពរពលរដ្ឋបាន ៨ គណនី*, (ភ្នំពេញប៉ុស្តិ៍, ភ្នំពេញ ១៤ មិថុនា ២០២២), https://www.postkhmer.com/national/2022-06-14-1527-237692.html, (Accessed at 9:00pm on 22 October 2022)។

[១៣] Sandro Serpa and Carlos Miguel Ferreira, *The Concept of Bureaucracy by Max Weber*, (January 18, 2019), file:///C:/Users/User/Downloads/The_Concept_of_Bureaucracy_by_Max_Weber.pdf, (Accessed at 1:45pm on 3 November 2021).

ដាក់លាក់ ដោយត្រូវបានកំណត់នូវភាពស្មុគស្មាញ ការបែងចែកការងារ មានលក្ខណៈអចិន្ត្រៃយ៍ ការគ្រប់គ្រងប្រកបដោយវិជ្ជាជីវៈ មានការគ្រប់គ្រង និងការសម្របសម្រួលតាមឋានានុក្រម និងមានខ្សែចង្វាក់បញ្ជាតឹងរ៉ឹង ព្រមទាំងសិទ្ធិអំណាចតាមផ្លូវច្បាប់។[១៤] យ៉ាងណាក៏ដោយ អ្នករិះគន់ជាច្រើនបកស្រាយថា ការិយាធិបតេយ្យជា *«ទម្រង់មួយដែលបង្កើតឱ្យមានភាពខ្សោយ គ្មានការស្ដាប់បង្គាប់ ខ្វះគំនិតស្វាហាប់ ធ្វើការងារតាមបែបស្មុគស្មាញ ភាពអន់ខ្សោយគ្មានប្រាជ្ញា គ្មានសក្ដិសិទ្ធ មានជំងឺក្នុងស្ថាប័នសាធារណៈ។ ម្យ៉ាងទៀត ពាក្យ ការិយាធិបតេយ្យ ក្នុងពេលបច្ចុប្បន្ន ត្រូវបានគេប្រដូចទៅនឹងពាក្យគ្មានសក្ដិសិទ្ធ»*។[១៥]

សរុបមក *«ការិយាធិបតេយ្យមែនទែនទៅគឺជាការគ្រប់គ្រងដោយមន្ត្រី។...សព្វថ្ងៃនេះ ការិយាធិបតេយ្យគឺសំដៅលើមន្ត្រីដែលមានប្រាក់បៀវត្សរ៍ ធ្វើបំពេញកិច្ចការដ៏លម្អិតលើរដ្ឋបាលសាធារណៈដោយផ្ដល់ប្រឹក្សា និងអនុវត្តការសម្រេចចិត្តផ្នែកគោលនយោបាយ»*។[១៦]

ចំពោះការិយាធិបតេយ្យនៅកម្ពុជា សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៅពាក់កណ្ដាលខែមីនា ឆ្នាំ២០១៥ បានលើកឡើងពី *«បញ្ហាការិយាធិបតេយ្យដែលជាការជាប់ពាក់ព័ន្ធរបស់ក្រសួងមន្ទីរជាច្រើន ឬគណៈកម្មការច្រើន នៅក្នុងកិច្ចការមួយ ហើយគ្មានអ្នកទទួលខុសត្រូវជាក់លាក់លើបញ្ហាមួយនោះ ខណៈសង្គមស៊ីវិល បក្សប្រឆាំងនៅកម្ពុជា បានលើកឡើងថា បញ្ហាការិយាធិបតេយ្យក្នុងជួររដ្ឋាភិបាល និងរាជការនេះ គឺជាចំណុចដែលត្រូវការឆន្ទៈនយោបាយ ព្រោះថា ដើម្បីកែទម្រង់ចំណុចនេះ សមត្ថភាពមន្ត្រីរាជការ អំពើពុករលួយ និងបក្សពួកនិយមគឺត្រូវតែលាងជម្រះ»*។[១៧]

ទាក់ទិននឹងហ្វេសប៊ុកជួយកាត់បន្ថយការិយាធិបតេយ្យចំពោះការផ្ដល់សេវាសាធារណៈ លទ្ធផលនៃការសិក្សាបង្ហាញថា សកលគំរូគោលដៅចំនួន ៧៣,៦% (៣៦៨នាក់) ឆ្លើយថា ហ្វេសប៊ុកបានជួយកាត់បន្ថយការិយាធិបតេយ្យចំពោះការផ្ដល់សេវាសាធារណៈរបស់រដ្ឋ ហើយ ១២,៤% (៦២នាក់) ឆ្លើយថា មិនឯកភាពឡើយ ខណៈ ១៤% (៧០នាក់) មិនបានផ្ដល់ចម្លើយ។

---

[១៤] Bert Rockman, *"bureaucracy"*, (Encyclopedia Britannica, 4 Jul. 2021), https://www.britannica.com/topic/bureaucracy, (Accessed at 1:34pm on 3 November 2021).

[១៥] កៅ យុយថង : ***រដ្ឋបាលសាធារណៈទំនើប*** (បោះពុម្ពផ្សាយដោយបណ្ណាគារអង្គរ ២០០៧) ទំព័រ៣០។

[១៦] Rod Hague and Martin Harrop, *Comparative Government and Politics 6th Edition*, (China, 2004), P.290.

[១៧] ស៊ុន មេសា : ***កំណែទម្រង់ការិយាធិបតេយ្យនៅកម្ពុជានៅតែជាសំណួរដល់រដ្ឋាភិបាល***, (ភ្នំពេញ ២៥ មីនា ២០១៥), https://www.rfi.fr/km/cambodia/hun-sen-democratic-office-25-03-2015, (Accessed at 11:09am on 2 November 2021)។




សរុបសេចក្តីមក ហ្វេសប៊ុកបានរួមចំណែកក្នុងការជួយកាត់បន្ថយការិយាធិបតេយ្យចំពោះការផ្តល់សេវាសាធារណៈរបស់រដ្ឋជូនមហាជន។

### ៤.៤- ហ្វេសប៊ុក និងការទទួលខុសត្រូវលើការផ្តល់សេវាសាធារណៈរបស់រដ្ឋ

នៅក្នុងការសិក្សានេះ លទ្ធផលបានរកឃើញថា សកលគំរូគោលដៅចំនួនដល់ទៅ ៨៦,៦% (៤៣៣នាក់) បានឯកភាពថា ហ្វេសប៊ុកពិតជាបានជួយកែលម្អ និងបង្កើនការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈរបស់រដ្ឋជូនដល់មហាជន ហើយ ៨,៦% (៤៣នាក់) មិនបានឯកភាពលើចំណុចនេះទេ ខណៈ ៤,៨% (២៤នាក់) មិនបានផ្តល់ចម្លើយ។




លទ្ធផលនៃការសិក្សានេះបានបង្ហាញយ៉ាងច្បាស់ថា ហ្វេសប៊ុកពិតជាមានឥទ្ធិពលលើការបង្កើនការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈរបស់រដ្ឋ ដើម្បីមានតម្លាភាព ដោយមានការកែលម្អការលើការផ្តល់សេវាឱ្យកាន់ប្រសើរឡើង និងកាន់តែមានគុណភាពចំពោះការផ្តល់សេវាទៅតាម

ប្រភេទសេវានីមួយៗ «*ដោយប្រើប្រាស់បរិធានចម្រុះដែលគិតចាប់ពីការធ្វើឯកជនូបនីយកម្ម និងការធ្វើកិច្ចសន្យាក្រៅ រហូតដល់ការធ្វើវិមជ្ឈការ និងវិសហមជ្ឈការ រួមទាំងការប្រើប្រាស់នូវរបៀបផ្តល់សេវាផ្សេងៗទៀត ជាពិសេសការរៀបចំបង្កើត និងដាក់ឱ្យដំណើការទីភ្នាក់ងារប្រតិបត្តិការពិសេស។*»[១៨]

នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ ថ្លែងទៅកាន់មន្ត្រីរាជការថ្មីប្រមាណ៧០០នាក់ ដែលបានបញ្ចប់ការសិក្សានៅវិទ្យាស្ថានជាតិអប់រំ ក្នុងរាជធានីភ្នំពេញ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីបានក្រើនរំឭកដល់មន្ត្រីទាំងនោះឱ្យយកចិត្តទុកដាក់បម្រើប្រជាពលរដ្ឋ ដោយបញ្ជាក់ថា មានកន្លែងតិចតួចណាស់សម្រាប់មន្ត្រីរាជការ ដែលកុហក។[១៩] សម្តេចតេជោ បានផ្តល់ដំបូន្មានថា «*ដំបូងត្រូវយល់ឱ្យបានច្បាស់ថា យើងជាខ្ញុំបម្រើដ៏ស្មោះត្រង់របស់ប្រជាជន មិនមែនជាចៅហ្វាយនាយរបស់ប្រជាជនទេ។ នេះជាចំណុចសំខាន់លើកដំបូងបំផុត ដែលមន្ត្រីទាំងអស់ត្រូវយល់ឱ្យច្បាស់អំពីតួនាទីរបស់ខ្លួន មិនមែនជាចៅហ្វាយទេ តែគឺជាខ្ញុំបម្រើរបស់ប្រជាជន។...ពួកគាត់ (ប្រជាពលរដ្ឋ) គឺជាចៅហ្វាយ យើងគឺជាខ្ញុំបម្រើ*» ដោយ សម្តេចតេជោ លើកយកសុភាសិតខ្មែរដែលពោលថា «*ដើមស្លក ឱនដាក់គ្រាប់*» សម្រាប់ជាគតិរបស់មន្ត្រីរាជរដ្ឋាភិបាលនៅក្នុងការបម្រើប្រជាពលរដ្ឋ។[២០] សម្តេចតេជោ បានបញ្ជាក់ថា «*ត្រូវចាំឱ្យច្បាស់ថា ខ្លួនមិនមែនជាចៅហ្វាយរបស់ប្រជាជននោះទេ គឺអ្នកបម្រើដ៏ស្មោះត្រង់របស់ប្រជាពលរដ្ឋ។ មន្ត្រីមិនត្រូវដើរពើងទ្រូងនោះទេ ការពើងទ្រូងនឹងនាំដល់ក្តីវិនាស។ មន្ត្រីត្រូវចាំថា ប្រជាពលរដ្ឋជាគោលដៅត្រូវយកចិត្តទុកដាក់ មិនមែនជាគោលដៅត្រូវបំផ្លាញនោះឡើយ។ ពេលនៅឱ្យប្រជាពលរដ្ឋស្រឡាញ់ និងពេលចេញត្រូវឱ្យប្រជាពលរដ្ឋនឹក។ កន្លែងណាមានបញ្ហា គឺត្រូវតែមានមុខរបស់មន្ត្រី។ កុំធ្វើជាមន្ត្រីជើង១០ គឺត្រូវធ្វើជាមន្ត្រីជើង២....*»។[២១]

### ៤.៥- ហ្វេសប៊ុក និងការឆ្លើយតបពីថ្នាក់ដឹកនាំ

ចំពោះ ហ្វេសប៊ុក អាចជួយឱ្យមានការឆ្លើយតបពីថ្នាក់ដឹកនាំចំពោះអំពើអសកម្មរបស់មន្ត្រីផ្តល់សេវាសាធារណៈ លទ្ធផលនៃការសិក្សាបានបង្ហាញថា សកលគំរូគោលដៅភាគច្រើនមានរហូតដល់៨៦,៨% (៤៣៤នាក់) ឆ្លើយថា ពិតជាត្រឹមត្រូវ ហើយមានតែ ៨,២% (៤១ នាក់) ប៉ុណ្ណោះដែលមិនឯកភាព ខណៈ ៥% (២៥នាក់) ទៀតមិនបានផ្តល់ចម្លើយ។

---

[១៨] ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល : ***កម្រងព័ត៌មានសេវាសាធារណៈ*** (រាជរដ្ឋាភិបាលកម្ពុជា សីហា ២០២១០) ទំព័រ២។

[១៩] Touch Sokha and Ananth Baliga, ***Hun Sen says no room for lying civil servants***, (Phnom Penh Post, Phnom Penh, 27 June 2017), https://www.phnompenhpost.com/national/hun-sen-says-no-room-lying-civil servants, (Accessed at 3:02pm on 3 November 2021)។

[២០] បណ្តាញព័ត៌មាន Fresh News : ***សម្តេចតេជោ ហ៊ុន សែន ទូន្មានមន្ត្រីឱ្យធ្វើជាខ្ញុំបម្រើដ៏ស្មោះត្រង់របស់ប្រជាពលរដ្ឋ និងត្រូវរួមសុខទុក្ខជាមួយប្រជាពលរដ្ឋ*** (២៦ មិថុនា ២០១៧), (Accessed at 4:22pm on 3 November 2021)។

[២១] អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល : ***ប្រសាសន៍សំខាន់ៗរបស់សម្តេចតេជោ ហ៊ុន សែន ផ្តល់ដំបូន្មាននិងក្រើនរំលឹកដល់មន្ត្រីក្នុង ឱកាសអញ្ជើញប្រគល់សញ្ញាបត្រ និងវិញ្ញាបនបត្រ ជូននិស្សិតភូមិន្ទរដ្ឋបាល*** (២៥ កុម្ភៈ ២០២០), (Accessed at 3:18pm on 3 November 2021)។




ដោយសារតែ ហ្វេសប៊ុក នេះហើយ ទើបអំពើអសកម្មមួយចំនួនត្រូវបានកាត់បន្ថយ ខណៈថ្នាក់ដឹកនាំប្រទេសបានលើកទឹកចិត្តឱ្យមន្ត្រីរបស់ខ្លួនតាមដានមតិយល់ និងសំណូមពររបស់ប្រជាពលរដ្ឋនៅលើទំព័រហ្វេសប៊ុក ហើយត្រូវជួយដោះស្រាយបញ្ហាជូនពួកគាត់នៅនឹងកន្លែង ឬត្រូវដោះស្រាយនៅក្រៅប្រព័ន្ធតុលាការ។ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ នៅវិមានសន្តិភាព សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ជាថ្មីម្តងទៀត បានប្រាប់ឱ្យបណ្តាក្រសួង ស្ថាប័ន ចូលពិនិត្យ និងឆ្លើយតបចំពោះការបញ្ចេញមតិរបស់ប្រជាពលរដ្ឋក្នុង ហ្វេសប៊ុក របស់លោក ដោយសារតែពលរដ្ឋដែលមានបញ្ហាតែងតែចូលមកបញ្ចេញមតិ ដែលរឿងនោះមានការពាក់ព័ន្ធទៅនឹងក្រសួងស្ថាប័នមានសមត្ថកិច្ចនានាត្រូវឆ្លើយតប។[២២] សម្តេចតេជោ បានថ្លែងថា «ពេលដែលខ្ញុំបង្ហោះ គឺមានការចូលមកខមម៉ិន [បញ្ចេញយោបល់] ច្រើន ហើយពេលខ្លះខ្ញុំក៏ឆ្លើយ ក៏ប៉ុន្តែមានពេលខ្លះ គឺស្ថាប័នមានសមត្ថកិច្ចគួរឆ្លើយនៅក្នុងហ្នឹងតែម្តង គឺជាការល្អព្រោះប្រជាពលរដ្ឋគាត់ចូលមកខមម៉ិនក្នុងហ្នឹង [ហ្វេសប៊ុក]។ នៅក្នុងនេះខ្ញុំគ្រាន់តែចង់បញ្ជាក់នៅក្នុងហ្នឹងមានតាំងពីរឿងបុណ្យសពអីជាដើម។ នៅក្នុងនេះគឺទាល់តែយើងឆ្លៀត ដើម្បីមើលអាក្នុងហ្នឹង ព្រោះនេះជួនកាលខមម៉ិនទៅវាប៉ះ ព្រោះយើងជានាយករដ្ឋមន្ត្រីចូលមកវាប៉ះក្រសួងនេះក្រសួងនោះ»។[២៣]

នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានសរសេរនៅលើទំព័រហ្វេសប៊ុករបស់លោកថា លទ្ធផលការងារប្រចាំខែតុលា ឆ្នាំ

---

[២២] វ៉ន ដារ៉ា : *នាយករដ្ឋមន្ត្រីប្រាប់ឱ្យស្ថាប័ននានាពិនិត្យ ឆ្លើយតបការបញ្ចេញមតិពីពលរដ្ឋក្នុងហ្វេសប៊ុកលោក* (ភ្នំពេញប៉ុស្តិ៍ ២ វិច្ឆិកា ២០២១) https://www.postkhmer.com/national/2021-11-02-0909-226053.html, (Accessed at 6:28pm on 15 November 2021)។

[២៣] ដ.ឯ.ម.

២០២១ របស់ក្រុមការងារតាមដានអំពីការដោះស្រាយចំពោះមតិយោបល់ ឬសំណូមពររបស់ប្រជាពលរដ្ឋ នៅក្នុងទំព័រហ្វេសប៊ុករបស់លោក គឺបានទទួលសំណូមពរ និងសំណួររបស់ប្រជាពលរដ្ឋចំនួន ១៩៥គណនី ហើយក្នុងនោះ ក្រុមការងារបានឆ្លើយតបទៅម្ចាស់គណនី និងដោះស្រាយចំនួន៥២ គណនី។[២៤]

សរុបសេចក្ដីមក ហ្វេសប៊ុកបានក្លាយជាមធ្យោបាយមួយដែលធ្វើឱ្យថ្នាក់ដឹកនាំប្រទេសឆ្លើយតបយ៉ាងឆាប់រហ័ស ដែលជាចំណុចវិជ្ជមានសម្រាប់មហាជនក្នុងការទទួលបាននូវប្រយោជន៍ផ្សេងៗ។

### ៤.៦- ហ្វេសប៊ុក និងអំពើពុករលួយក្នុងការផ្ដល់សេវាសាធារណៈរបស់រដ្ឋ

មិនខុសពីគុណភាពនៃការផ្ដល់សេវាឡើយ គឺអំពើពុករលួយក្នុងការផ្ដល់សេវាសាធារណៈរបស់រដ្ឋត្រូវបានកាត់បន្ថយ ដោយសារតែអ្នកទទួលសេវាមិនសប្បាយចិត្តបង្ហោះសារនៅតាមហ្វេសប៊ុកពីអំពើមិនប្រក្រតីណាមួយក្នុងការផ្ដល់សេវា។ ចំពោះចំណុចនេះ លទ្ធផលនៃការសិក្សាបានបង្ហាញថា ទាក់ក្រុមគោលដៅភាគច្រើនគឺមានដល់ទៅ ៧៣,៦% (៣៦៨នាក់) បានឯកភាពថា ហ្វេសប៊ុកពិតជាមានឥទ្ធិពលលើការកាត់បន្ថយអំពើពុករលួយក្នុងការផ្ដល់សេវាសាធារណៈរបស់រដ្ឋ ហើយមានតែ ១៥,៤% (៧៧នាក់) ប៉ុណ្ណោះ មិនឯកភាពលើចំណុចនេះ ខណៈ ១១% (៥៥នាក់)។




បញ្ហាអំពើពុករលួយត្រូវបានគេលើកយកមកពិភាក្សាយ៉ាងផុលផុសនៅក្នុងសង្គមកម្ពុជា ហើយរាជរដ្ឋាភិបាល សង្គមស៊ីវិល និងម្ចាស់ជំនួយក៏បានគិតគូរ និងរិះរកយុទ្ធសាស្ត្រនានា ដើម្បីកែច្នៃស្ថានការណ៍ឱ្យបានប្រសើរ។[២៥] រាជរដ្ឋាភិបាលកម្ពុជាបានពង្រឹងអភិបាលកិច្ចល្អដែលជា «ការវិនិច្ឆ័យសំខាន់បំផុតមួយ ដើម្បីធានាឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ច ប្រកបដោយចីរភាព មានសមធម៌ និងយុត្តិធម៌

[២៤] ស ខេង : ***បងប្អូនជនរួមជាតិជាទីគោរព!*** (Facebook ១០ វិច្ឆិកា ២០២១), https://web.facebook.com/SamdechKrola hom Sarkheng/posts/3081446835467317, (Accessed at 6:51pm on 15 November 2021)។

[២៥] វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា : ***សេវាសាធារណមូលដ្ឋាន៖ ប្រសិទ្ធភាពសេវា និងកំម្រៃក្រៅផ្លូវការ,*** (វិច្ឆិកា ២០០៦) ទំព័រទី៣។

សង្គម។...ក្នុងន័យនេះ អភិបាលកិច្ចនឹងជាធនធានបន្ថយអំពើពុករលួយឱ្យស្ថិតនៅក្នុងកម្រិតអប្បបរមា...»។[២៦] ដោយឈរលើគោលការណ៍នេះ បណ្តាញសង្គម និយាយដោយឡែក ហ្វេសប៊ុក ដែលបានរីកដុះដាលក្រោយមក ក៏បានក្លាយជាមធ្យោបាយរបស់ប្រជាពលរដ្ឋ ដើម្បីរិះគន់លើបញ្ហាពុករលួយនៃការ ផ្តល់សេវាសាធារណៈ ហើយតាមរយៈការរិះគន់លើ ហ្វេសប៊ុក នេះហើយ ទើបអំពើពុករលួយត្រូវបានកាត់បន្ថយជាបណ្តើរៗនៅក្នុងការផ្តល់សេវាសាធារណៈ។

បន្ថែមពីលើនេះដែរ ក្រុមអង្គការសង្គមស៊ីវិលក៏បានទទូចឱ្យប្រជាពលរដ្ឋកម្ពុជាប្រើប្រាស់វេទិកាបណ្តាញសង្គម ដើម្បីលើកស្ទួយអភិបាលកិច្ចល្អ និងយុត្តិធម៌សង្គម...ដោយវេទិកាបណ្តាញសង្គម ដូចជា ហ្វេសប៊ុកនេះ បានក្លាយជាប្រព័ន្ធផ្សព្វផ្សាយដ៏មានប្រជាប្រិយភាពសម្រាប់ប្រជាពលរដ្ឋកម្ពុជាក្នុងការរិះគន់អាជ្ញាធរ និងការតវ៉ាជំទាស់នឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។[២៧]

ផ្អែកលើទិន្នន័យនិងឯកសារពិគ្រោះ យើងអាចសន្និដ្ឋានថា ហ្វេសប៊ុកពិតជាមានឥទ្ធិពលជួយកាត់បន្ថយអំពើពុករលួយក្នុងការផ្តល់សេវាសាធារណៈរបស់រដ្ឋ ដែលនាំឱ្យការផ្តល់សេវាកាន់តែមានតម្លាភាព និងប្រសិទ្ធភាព។

### ៤.៧- ឥទ្ធិពលហ្វេសប៊ុកលើការអនុវត្តច្បាប់

ជាការពិត និយមន័យច្បាប់មានច្រើនបង្គួរ ក៏ប៉ុន្តែខ្លឹមសារប្រហាក់ប្រហែលគ្នា។ ច្បាប់ជាធម្មតាត្រូវបានរដ្ឋាភិបាលរៀបចំតាក់តែងឡើង ដើម្បីជាមធ្យោបាយសម្រាប់បញ្ជាឱ្យពលរដ្ឋនិងប្រទេសប្រតិបត្តិ ដោយមានវិន័យ មានរបៀបរាបរយ និងសណ្តាប់ធ្នាប់នៅក្នុងសង្គម។ វាជា *«សេចក្តីបញ្ញត្តិសម្រាប់ឱ្យអ្នកនគរប្រតិបត្តិតាម។ វិន័យ, ក្រឹត្យក្រម, ក្បួនប្រដៅមនុស្សឱ្យប្រព្រឹត្តល្អ។...»*[២៨]

ការបង្កើតច្បាប់គឺមានបំណងឱ្យទាំងមហាជន និងអ្នកអនុវត្តច្បាប់គោរពតាម ដើម្បីឱ្យពួកគេចៀសផុតពីការប្រព្រឹត្តអំពើអវិជ្ជមាននៅក្នុងសង្គម។ ចំពោះចំណោទដែលសួរថា ហ្វេសប៊ុកមានឥទ្ធិពលលើសម្រាប់ការអនុវត្តច្បាប់ដែរឬទេ ក្រុមគោលដៅចំនួន៥០០នាក់ គឺមានដល់ទៅ ៨៣,២% (៤១៦នាក់) ឆ្លើយថា ហ្វេសប៊ុកពិតជាមានឥទ្ធិពលលើការអនុវត្តច្បាប់ ហើយមានតែ ១០,២% (៥១នាក់) ប៉ុណ្ណោះដែលឯកភាពនូវសំណួរនេះ ខណៈ ៦,៦% (៣៣នាក់) មិនបានផ្តល់ចម្លើយ។

---

[២៦] ហ៊ុន សែន : *"យុទ្ធសាស្ត្រចតុកោណ" ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា* (ភ្នំពេញ ១៦ កក្កដា ២០០៤) ទំព័រ៩។

[២៧] Nem Sopheakpanha, *Cambodians Urged to Use Care on Social Media Platforms*, ( VOA Khmer, Phnom Penh 20 March 2019 ), https://www.voacambodia.com/a/cambodians-urged-to-use-care-on-social-media-platforms/48379 46.html, ( Accessed at 3:40pm on 22 October 2022 ).

[២៨] ពុទ្ធសាសនបណ្ឌិត្យ : *វចនានុក្រមខ្មែរ ភាគទី១ ភាគទី២*, (វចនានុក្រម ១៩៦៨)។




នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ សកម្មភាពគ្រឿងចក្រចំនួន៣គ្រឿងបានឈូសឆាយដីក្នុងអាងបឹងធំ ដើម្បីធ្វើផ្លូវ និងកាយក្រវាត់កំណត់ព្រំដីធ្វើជាកម្មសិទ្ធិ ស្ថិតក្នុងភូមិឈើទាល២ ឃុំឈើទាល ស្រុកកៀនស្វាយ ហើយសកម្មភាពនេះត្រូវបានផ្សព្វផ្សាយតាមបណ្តាញសង្គម ហ្វេសប៊ុក។ បន្ទាប់មកអាជ្ញាធរស្រុកកៀនស្វាយ ខេត្តកណ្តាល ក៏បានឃាត់គ្រឿងចក្រទាំងនោះយកទៅរក្សាទុកនៅសាលាស្រុក និងបានហៅម្ចាស់មកធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាពឈូសឆាយបន្តទៀត រួមទាំងការផាកពិន័យផងដែរ។[២៩]

នារាត្រីថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ នៅក្នុងរាជធានីភ្នំពេញ នារីម្នាក់បានរងរបួសក្បាលធ្ងន់ធ្ងរ ដោយចោទថា មន្ត្រីនគរបាលផ្នែកអន្តរាគមន៍មួយរូបនៃអធិការដ្ឋាននគរបាលខណ្ឌ៧មករា បានវាយនាងនឹងវិទ្យុទាក់ទង (អាយកូម) ហើយបានស្នើឱ្យមន្ត្រីពាក់ព័ន្ធរកយុត្តិធម៌ជូនរូបនាង និងទាមទារសំណងជំងឺចិត្តឱ្យបានសមរម្យទៅនឹងកិត្តិយសក្នុងនាមជាស្ត្រី និងដើម្បីយកប្រាក់ទៅព្យាបាលក្បាលដែលរងរបួសផង។ កម្រង់រូបភាព ក៏ដូចជាការបញ្ចេញទស្សនៈផ្សេងៗ «*ជុំវិញរឿងរ៉ាវស្រីស្រស់ និងបុរសប៉ូលិសរូបសង្ហា កំពុងបានក្លាយជាទីចាប់អារម្មណ៍ពីសំណាក់អ្នកលេងបណ្តាញសង្គមយក្សហ្វេសប៊ុក បញ្ចេញទស្សនៈជាហូរហែ និងព្រោងព្រាត នៅព្រឹកថ្ងៃទី៩ ខែកញ្ញា*»។[៣០] បើតាមរូបភាពបង្ហោះនៅលើទំព័រហ្វេសប៊ុក ស្ត្រីវ័យក្មេងរូបនោះ «*ត្រូវបានមន្ត្រីនគរបាលផ្នែកកងអន្តរាគមន៍មួយរូប... វាយឱ្យរងរបួសបែកក្បាលធ្ងន់ធ្ងរ*»[៣១] *នាយប់នោះ បើទោះជាមន្ត្រីនគរបាលរូបនោះឆ្លើយតបថា ហេតុការណ៍នោះបានកើតឡើងដោយសារនាងនិងប្អូនប្រុសបានល្មើសច្បាប់ចរាចរណ៍ ពោលគឺជិះទោចក្រយានយន្តដោយមិនពាក់មួកសុវត្ថិភាព។ ករណីហិង្សានេះ មហាជនមួយចំនួន ជាពិសេសអ្នកប្រើប្រាស់បណ្តាញសង្គមនៅតែទទូចឱ្យមានយុត្តិធម៌ពិតសម្រាប់ស្ត្រីរងគ្រោះ ដោយការប្រើអំពើហិង្សា ហើយ*

---

[២៩] យុត សុគន្ធ : ***អាជ្ញាធរស្រុកកៀនស្វាយឃាត់គ្រឿងចក្រ៣គ្រឿងក្រោយឈូសឆាយដីបឹងមួយកន្លែងដោយខុសច្បាប់*** ( VOD ភ្នំពេញ ២១ កក្កដា ២០២១ ), https://www.vodkhmer.news/2021/07/21/kien-svay-district-authorities-seize-3-vehicles-after-illegally-clearing-a-lake/, ( Accessed at 8:56am on 17 November 2021 )។

[៣០] DR103 : ***ករណីហិង្សា រវាងប៉ូលិសសង្ហា និងកញ្ញារូបស្រស់, ភាគីទាំង២ អាចត្រូវអនុវត្ត តាមច្បាប់ដូចគ្នា*** ( មជ្ឈមណ្ឌលព័ត៌មានដើមអម្ពិលភ្នំពេញ ៩ កញ្ញា ២០២១ ) https://dap-news.com/national/2021/09/09/182942/, ( Accessed at 7:45am on 17 November 2021 )។

[៣១] ប៉ា សុខេង : ***នារីរបួសក្បាលដោយសារមន្ត្រីនគរបាលវាយទាមទាររកយុត្តិធម៌និងសំណងសមរម្យ*** ( VOD ភ្នំពេញ ៩ កញ្ញា ២០២១ ), https://www.vodkhmer.news/2021/09/09/woman-suffered-head-injury-by-police-officer-demands-justice-and-fair-compensation/, ( Accessed at 7:13am on 17 November 2021 )។

*ទាមទារឱ្យមន្ត្រីនគរបាលទាំងអស់ត្រូវអនុវត្តច្បាប់ ដោយប្រកាន់ខ្ជាប់នូវក្រមសីលធម៌ត្រឹមត្រូវ ចៀសវាងបណ្តាលឱ្យបញ្ហានេះកើតឡើងបន្តទៀត*»។[៣២] ក្រោយមក ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញក៏បានឃាត់ខ្លួនមន្ត្រីនគរបាលរូបនោះ បន្ទាប់ពីមានការរិះគន់ពីមហាជននៅតាមហ្វេសប៊ុក ចំពោះសកម្មភាពប្រើប្រាស់អំពើហិង្សាទៅលើស្ត្រីរូបនោះ ក្នុងហេតុការណ៍អនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក។

សរុបសេចក្តីមក ហ្វេសប៊ុក បានជះឥទ្ធិពលលើការអនុវត្តច្បាប់របស់អាជ្ញាធរមានសមត្ថកិច្ចនៅកម្ពុជា ដោយឡែកនៅរាជធានីភ្នំពេញ។

### ៤.៨- ឥទ្ធិពលហ្វេសប៊ុកលើឥរិយាបថមន្ត្រីអនុវត្តច្បាប់

ដោយសារតែហ្វេសប៊ុកមានឥទ្ធិពលលើការអនុវត្តច្បាប់នេះហើយ ទើបមន្ត្រីអនុវត្តច្បាប់ត្រូវបានមហាជនមើលឃើញថា មានការផ្លាស់ប្តូរឥរិយាបថខ្លះ នៅពេលចុះប្រតិបត្តិការនៃការអនុវត្តច្បាប់ ដូចជា មិនប្រើហិង្សាលើជនសង្ស័យ មិនបៀតបៀនផ្លូវភេទ និងមិនប្រព្រឹត្តអំពើពុករលួយជាដើម បើមិនដូច្នោះទេ មហាជននឹងបញ្ជូនសារនៅលើទំព័រហ្វេសប៊ុក ដែលនាំឱ្យមានបញ្ហាដល់ខ្លួន។

ចំពោះឥរិយាបថមន្ត្រីអនុវត្តច្បាប់ លទ្ធផលនៃសិក្សានេះបានបង្ហាញថា អ្នកឆ្លើយតប ភាគច្រើនហួតដល់ ៨៣,៨% (៤១៩នាក់) ឆ្លើយថា ហ្វេសប៊ុកពិតជាមានឥទ្ធិពលការប្រែប្រួលឥរិយាបថរបស់មន្ត្រីអនុវត្តច្បាប់ ហើយមានតែ ៩,២% (៤៦នាក់) ប៉ុណ្ណោះ មិនបានឯកភាពលើចំណុចប្រែប្រួលនេះទេ ខណៈ ៧% (៣៥នាក់) មិនបានផ្តល់ចម្លើយ។




នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១ ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានសរសេរលើទំព័រហ្វេសប៊ុករបស់លោកថា សូមនិយាយពីរឿងមួយ «*ការអនុវត្តច្បាប់មិនមែនជាស្វ័យប្រវត្តិភ្ជាប់ជាមួយអំពើហិង្សាទេ បើអ្នកប្រព្រឹត្តខុសមិនប្រតិកម្មដោយអំពើហិង្សា។ កុំភ្លេចពាក្យ 'បម្រើប្រជាជន'។ នៅឥណ្ឌា ប៉ូលិសវ៉ៃអ្នកប្រព្រឹត្តខុស ទីបំផុតមួយសង្កាត់បះតបវិញវ៉ៃតប់បះដើង។ មនុស្សប្រព្រឹត្តខុសតិចទេ តែអាជ្ញាធរប្រើហិង្សាគឺអាជ្ញាធរជាអ្នកខុស*»។[៣៣] សំណេររបស់ឯកឧត្តម ខៀវ កាញារីទ្ធ បានធ្វើឡើង

---

[៣២] - ដដែល -

[៣៣] MC Chandarareth : ***រដ្ឋមន្ត្រីក្រសួងព័ត៌មាន បង្ហាញទស្សនៈមិនគាំទ្រលើការប្រើអំពើហិង្សា ដែលអាជ្ញាធរកំពុងធ្វើពេលនេះទេ*** (Sabay News ភ្នំពេញ ២១ មេសា ២០២១), https://news.sabay.com.kh/article/1272790, (Accessed at 8:02am on 17 November 2021)។

បន្ទាប់ពី «*នៅតាមបណ្ដាញសង្គមហ្វេសប៊ុក នាពេលថ្មីៗនេះគេសង្កេតឃើញមានសមត្ថកិច្ចនៅតាមដងផ្លូវ បានធ្វើការដេញវាយប្រជាពលរដ្ឋដោយរំពាត់ ដែលមិនគោរពតាមបម្រាមរបស់រដ្ឋាភិបាល និងឃើញសមត្ថកិច្ចដាក់រំពាត់នៅតាមប៉ុស្តិ៍ត្រួតពិនិត្យ និងកាន់ជិះម៉ូតូតាមផ្លូវនានា ដើម្បីវាយពលរដ្ឋដែលចេញក្រៅផ្ទះដោយគ្មានលិខិតអនុញ្ញាតត្រឹមត្រូវពីអាជ្ញាធរ*»។[៣៤]

ឯកឧត្តម ឃួង ស្រេង អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងលោកឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការនៅព្រឹកថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ បានចូលខ្លួនទៅបង់ប្រាក់ពិន័យទៅតាមច្បាប់ចរាចរណ៍ផ្លូវគោក នៅអធិការនគរបាលខណ្ឌដង្កោ បន្ទាប់ពីមន្ត្រីទាំងពីររូបបានជិះទោចក្រយានយន្តមិនពាក់មួកសុវត្ថិភាព ក្នុងពេលចុះអន្តរាគមន៍ត្រួតពិនិត្យស្ថានភាពទឹកជំនន់តាមស្ទឹងព្រែកត្នោតជាមួយគ្នា កាលពីថ្ងៃទី២៦ ខែតុលា។ បន្ទាប់ពីរូបភាពរបស់មន្ត្រីទាំងពីររូបបង្ហាញពីការបើកបរមិនពាក់មួកសុវត្ថិភាព ត្រូវបានផ្សព្វផ្សាយ និងចែកបន្តគ្នាតាមរយៈហ្វេសប៊ុក មហាជនក៏បានរិះគន់ ហើយនៅព្រឹកថ្ងៃទី២៧ ខែតុលា មន្ត្រីទាំងពីររូបនោះក៏បានចូលខ្លួនទៅបង់ការពិន័យចំពោះកំហុសឆ្គងដោយអចេតនានេះ។[៣៥]

កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ក៏ត្រូវបានមន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកពិន័យប្រាក់ចំនួន១៥ ០០០រៀលដែរ តាមមាត្រា៦នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ចំពោះការជិះទោចក្រយានយន្តនៅខេត្តកោះកុងដោយមិនបានពាក់មួកសុវត្ថិភាពកាលពីថ្ងៃទី១៨ ខែមិថុនា។ នៅព្រឹកថ្ងៃទី២៤ សម្ដេចតេជោ «*បានជិះម៉ូតូចេញពីផ្ទះរបស់លោកនៅក្បែរវិមានឯករាជ្យឆ្ពោះទៅប៉ុស្តិ៍នគរបាលចតុមុខដែលមានចម្ងាយប្រមាណ៥០០ម៉ែត្រ ដើម្បីបង់ប្រាក់ពិន័យចំនួន១៥ ០០០រៀល*»។ សម្ដេចតេជោ នៅក្នុងដំណើរទៅគោរពវិញ្ញាណក្ខន្ធលោក សាយ ភូថង មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជាក្នុងខេត្តត្រាត ប្រទេសថៃ និងបានឆ្លងកាត់ស្ពានស្រែអំបិលខេត្តកោះកុងនៅថ្ងៃទី១៨ ខែមិថុនា លោកបានជួបនិងចុះជិះម៉ូតូជាមួយបុរសម្នាក់ដែលលោកថា ជាអ្នករត់ម៉ូតូឌុប ហើយនៅពេលនោះ លោកក៏សុំបើកបរ ដោយឱ្យម្ចាស់ម៉ូតូ [ទោចក្រយានយន្ត] ជាអ្នកជិះពីក្រោយវិញ ហើយពួកគាត់ទាំងពីរមិនបានពាក់មួកសុវត្ថិភាពនោះទេ ខណៈម៉ូតូក៏គ្មានស្លាកលេខដែរ។[៣៦] រូបភាពនៃការជិះទោចក្រយានយន្តមិនពាក់មួកសុវត្ថិភាពនេះត្រូវបានគេបង្ហោះតៗគ្នា ហើយសកម្មជននៃគណបក្សប្រឆាំងក៏បានរិះគន់ពីបញ្ហានេះនៅក្នុងហ្វេសប៊ុកដែរ។ នៅល្ងាចថ្ងៃទី២២ ខែមិថុនា សម្ដេចតេជោបានសរសេរលើទំព័រហ្វេសប៊ុករបស់លោកថា លោកបានដឹងជាមុនហើយថា បើទោះបីលោកសុំអភ័យ

---

[៣៤] Sokhom Khon : ***សមត្ថកិច្ចនឹងប្រើរំពាត់វាយពលរដ្ឋណា ដែលធ្វើនឹងបម្រាមនៅតំបន់ក្រហម*** (កម្ពុជាថ្មី ភ្នំពេញ ២១ មេសា ២០២១), https://www.kampucheathmey.com/local-news/105817/, (Accessed at 8:25am on 17 November 2021)។

[៣៥] ចន ណារិទ្ធ : ***លោក ឃួង ស្រេង ចូលខ្លួនទៅបង់ផាកពិន័យរឿងបើកម៉ូតូមិនពាក់មួកសុវត្ថិភាព*** (កោះសន្តិភាព ភ្នំពេញ ២៧ តុលា ២០២១), https://kohsantepheapdaily.com.kh/article/1421944.html, (Accessed at 11:52am on 17 November 2021)។

[៣៦] វីអូឌី : ***លោក ហ៊ុន សែន ទៅបង់ប្រាក់ផាកពិន័យល្មើសច្បាប់ចរាចរណ៍នៅព្រឹកនេះ*** (២៤ មិថុនា ២០១៦) https://www.vodkhmer.news/2016/06/24/hun-sen-went-to-pay-fine-for-violating-the-traffic-law/, (Accessed at 12:20pm on 17 November 2021)។

ទោសជាសាធារណៈហើយក៏ដោយ ក៏នគរបាលនៅតែពិន័យលោកដដែល ព្រោះលោកបានសាងនូវកំហុសរួចស្រេចទៅហើយ ហើយលោកទទួលបង់ពិន័យសម្រាប់ខ្លួនឯងផង និងសម្រាប់ប្អូនម្ចាស់ម៉ូតូផង បើទោះបីជាទោចក្រយានយន្តអត់ស្លាកលេខជាកំហុសរបស់ម្ចាស់ទោចក្រយានយន្តក៏ដោយ ដើម្បីសម្រាលនូវការលំបាករបស់គាត់ និងទុកលទ្ធភាពឱ្យគាត់ទៅធ្វើស្លាកលេខ។[៣៧]

ជារួម ដោយសារតែហ្វេសប៊ុកស្ថិតនៅក្នុងដៃរបស់មហាជននេះហើយ ទើបមន្ត្រីអនុវត្តច្បាប់ភាគច្រើនបានចាប់ផ្ដើមផ្លាស់ប្ដូរឥរិយាបថខ្លះនៅក្នុងអនុវត្តច្បាប់។

### ៤.៩- ហ្វេសប៊ុក និងឥរិយាបថរបស់ពលរដ្ឋចំពោះការគោរពច្បាប់

ការមិនគោរពច្បាប់ គឺជាឥរិយាបថដែលកើតមានស្ទើរគ្រប់វិស័យ និងគ្រប់ទីកន្លែង នៅទូទាំងប្រទេសកម្ពុជា ដោយហេតុហើយ បានជារៀងរាល់ឆ្នាំ រដ្ឋសភាបានអនុម័តច្បាប់ជាច្រើន ដើម្បីដាក់ឱ្យអនុវត្ត ប៉ុន្តែជាទូទៅមនុស្សមួយចំនួនហាក់ដូចជាមិនសូវយកច្បាប់ជាធំឡើយ តែបែរជានាំគ្នាប្រព្រឹត្តតាមការនឹកឃើញ និងប្រើកម្លាំងបាយ ឬកម្លាំងអំណាចរៀងៗខ្លួនទៅវិញ។[៣៨] ឥរិយាបថមិនសូវគោរពច្បាប់បានកើតមានចាប់ពីពលរដ្ឋសាមញ្ញ រហូតដល់មន្ត្រីអាជ្ញាធរ និងអ្នកដឹកនាំមួយចំនួន ដែលជាហេតុនាំឱ្យមានបញ្ហាជាច្រើន នៅក្នុងសង្គមខ្មែរកន្លងមក។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយកំណែទម្រង់រដ្ឋជាច្រើន ក្នុងបំណងពង្រឹងនីតិរដ្ឋ ខណៈមន្ត្រីរដ្ឋាភិបាល និងមន្ត្រីថ្នាក់មូលដ្ឋានមួយចំនួនរួមទាំងមហាជនផង នៅតែប្រកាន់ឥរិយាបថអាងអំណាច និងអាងតួនាទី និងអាងបក្ខពួករំលោភបំពានច្បាប់។ បន្ទាប់ពីវត្តមានហ្វេសប៊ុក នៅកម្ពុជា ការគោរពច្បាប់ក្នុងចំណោមមហាជនក៏ដូចជាមន្ត្រីអាជ្ញាធរ និងអ្នកដឹកនាំត្រូវបានគេមើលឃើញថា មានការកើនឡើងគួរឱ្យកត់សម្គាល់។

ទាក់ទិននឹងការគោរពច្បាប់របស់ពលរដ្ឋដោយសារតែឥទ្ធិពលហ្វេសប៊ុកនោះ លទ្ធផលនៃការសិក្សាបានបង្ហាញថា សកលគំរូគោលដៅភាគច្រើនចំនួន៨១,២% (៤០៦នាក់) បានឆ្លើយឯកភាពថាហ្វេសប៊ុកពិតជាឥទ្ធិពលហ្វេសប៊ុកខ្លះក្នុងការជំរុញឱ្យពលរដ្ឋគោរពច្បាប់ ព្រោះថា ពួកគេខ្លាចខ្មាសគេប្រសិនបើការរំលោភច្បាប់របស់ខ្លួនត្រូវបានគេថតនិងបង្ហោះតាមហ្វេសប៊ុក។ មានតែ៩,៨% (៤៩នាក់) ប៉ុណ្ណោះ មិនឯកភាពឡើយ ខណៈ ៩% (៤៥នាក់) មិនបានផ្ដល់ចម្លើយ។

---

[៣៧] Khmer Times : ***នាយករដ្ឋមន្ត្រីចូលខ្លួនបង់ប្រាក់ពិន័យជិះម៉ូតូមិនពាក់មួកសុវត្ថិភាពនៅថ្ងៃនេះ*** (ភ្នំពេញ ២៤ មិថុនា), https://www.khmertimeskh.com/25154/%E2%80%8Bនាយក%E2%80%8Bរដ្ឋមន្ត្រី%E2%80%8Bចូល%E2%80%8B/, (Accessed at 12:37pm on 17 November 2021)។

[៣៨] ប៉ែន បូណា : ***ឥរិយាបថមិនគោរពច្បាប់ជាទម្លាប់ដែលត្រូវកែប្រែ***, (RFI ភ្នំពេញ ១១ សីហា ២០១០), https://www.rfi.fr/km/cambodia/20100911-ឥរិយាបថមិនគោរពច្បាប់ជាទម្លាប់ដែលត្រូវកែប្រែ, (Accessed at 5:15pm on 4 April 2023)។




សរុបមកវិញ ហ្វេសប៊ុកបានជះឥទ្ធិពលលើសង្គម ដែលនាំពលរដ្ឋបង្កើនការគោរពច្បាប់ ដើម្បីចូលរួមលើកស្ទួយតម្លៃ សុជីវធម៌ និងសេចក្តីថ្លៃថ្នូររបស់ខ្លួន និងប្រាសចាកពីការបរិហារ ការពិន័យ និងការដាក់ទោសទណ្ឌជាដើម។

## ៥- សេចក្តីសន្និដ្ឋាន

នៅក្នុងក្របខ័ណ្ឌតំបន់ និងសាកលភាវូបនីយកម្ម ប្រជាជនកម្ពុជា និយាយដោយឡែក អ្នករស់នៅនិងធ្វើការនៅរាជធានីភ្នំពេញ ក៏មិនខុសពីប្រជាជននៃប្រទេសផ្សេងទៀតដែរ គឺបានប្រើប្រាស់បណ្តាញផ្សព្វផ្សាយសង្គម ជាពិសេស ហ្វេសប៊ុក ជាមធ្យោបាយឬទីលាន ដើម្បីចូលរួមទាំងកិច្ចការនយោបាយ និយាយដោយឡែកបញ្ហាច្បាប់និងសង្គមទូទៅ។ នៅចន្លោះឆ្នាំ២០០៨-២០២១ និងឆ្នាំបន្ទាប់ៗមកទៀត ដោយសារតែ ហ្វេសប៊ុក និងបណ្តាញផ្សព្វផ្សាយសង្គមផ្សេងទៀត ងាយស្រួលប្រើប្រាស់ និងដោយទូលំទូលាយ ហើយមានតម្លៃសមរម្យ ខណៈដែលរាជរដ្ឋាភិបាលកម្ពុជាបានបើកចំហដោយសេរី ទៅតាមបរិបទសកលក្នុងសម័យបច្ចេកវិទ្យាដ៏ទំនើប និងបានដាក់ចេញនូវគោលនយោបាយស្តីពីរដ្ឋាភិបាលឌីជីថលផង ទើបអ្នកនយោបាយ និងមិននយោបាយនានា រួមទាំងអ្នកចលនាសង្គមផ្សេងៗទៀត បានប្រើប្រាស់បណ្តាញទាំងនេះ កាន់តែច្រើនឡើងៗ សម្រាប់ការងារប្រចាំថ្ងៃរបស់ខ្លួន។

ដោយសារតែហ្វេសប៊ុកនេះហើយ ទើបធ្វើឱ្យមានការផ្លាស់ប្តូរឥរិយាបថខ្លះនៅក្នុងសង្គមកម្ពុជា ដោយប្រជាពលរដ្ឋហ៊ានបញ្ចេញមតិនៅតាមទំព័រហ្វេសប៊ុកទាំងកិច្ចការនយោបាយ ច្បាប់ និងបញ្ហាសង្គមទូទៅ។ ចំណុចទាំងនេះបានជះឥទ្ធិពលលើការផ្លាស់ប្តូរឥរិយាបថមន្ត្រីផ្តល់សេវាសាធារណៈរបស់រដ្ឋ អាចជួយកាត់បន្ថយការិយាធិបតេយ្យ និងអំពើពុករលួយជាដើម ខណៈការឆ្លើយតបពីថ្នាក់ដឹកនាំចំពោះការផ្តល់សេវាសាធារណៈរបស់រដ្ឋកាន់តែលឿននិងមានប្រសិទ្ធភាព។

ជាងនេះទៅទៀត ហ្វេសប៊ុកក៏បានជះឥទ្ធិពលលើការអនុវត្តច្បាប់ និងការផ្លាស់ឥរិយាបថមន្ត្រីអនុវត្តច្បាប់ និងប្រជាពលរដ្ឋចំពោះការអនុវត្ត និងគោរពច្បាប់ផងដែរ។

យ៉ាងណាក៏ដោយ ដោយសារតែកង្វះអក្ខរកម្មព័ត៌មាន និងអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងការវិភាគមិនបានត្រឹមត្រូវ និងចំណេះដឹងទូទៅនៅមានកម្រិត ក៏នាំអ្នកប្រើប្រាស់ហ្វេសប៊ុកខ្លះឆាប់មានកំហឹងចំពោះសារមិនល្អនៅលើទំព័រហ្វេសប៊ុក បើទោះជាសារនោះពិតឬមិនពិតក៏ដោយ។

## ៦- អនុសាសន៍

ដោយប្រទេសប្រកាន់យកលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងសេរីភាពនៃការបញ្ចេញមតិ ក៏ដូចជាសេរីភាពសារព័ត៌មាន ផ្អែកតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងគោលការណ៍នានារបស់ជាតិ និងអន្តរជាតិផងនោះ ហើយរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ «គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥» នោះ ហ្វេសប៊ុក និងបណ្តាញផ្សព្វផ្សាយសង្គមផ្សេងៗទៀត ត្រូវតែត្រូវបានបន្តបើកចំហឱ្យមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីលើកទឹកចិត្តឱ្យប្រជាពលរដ្ឋបញ្ចេញមតិ និងចែករំលែកព័ត៌មានពីបញ្ហាសង្គមទូទៅ និយាយដោយឡែក គឺបញ្ហាសេវាសាធារណៈរបស់រដ្ឋ និងការអនុវត្តច្បាប់។

ទាញចេញពីលទ្ធផលនៃការសិក្សាស្រាវជ្រាវនៅក្នុងខ្លឹមសារខាងលើ យើងខ្ញុំមានអនុសាសន៍មួយចំនួនដូចខាងក្រោម៖

### មេដឹកនាំ អ្នករៀបចំគោលនយោបាយ និងមន្ត្រីសាធារណៈរបស់រដ្ឋ

ត្រូវឆក់ឱកាសប្រើប្រាស់ ហ្វេសប៊ុក ក៏ដូចជាបណ្តាញផ្សព្វផ្សាយសង្គមថ្មីៗទៀត ទៅតាមការវិវឌ្ឍនៃបច្ចេកវិទ្យាព័ត៌មានជាសកល ដើម្បីទាញប្រយោជន៍ និងផ្តល់ប្រយោជន៍ជូនប្រជាពលរដ្ឋ តាមរយៈការផ្សព្វផ្សាយ និងបញ្ជ្រាបពីការពង្រឹង និងការអនុវត្តច្បាប់នៅក្នុងប្រទេស កាត់បន្ថយការិយាធិបតេយ្យ និងអំពើពុករលួយ ព្រមទាំងឆ្លើយតប និងដោះស្រាយឱ្យទាន់ពេលវេលាជូនដល់ប្រជាពលរដ្ឋលើទិដ្ឋភាពច្បាប់ និងការផ្តល់សេវាសាធារណៈរបស់រដ្ឋ។

បន្ថែមពីលើនេះ ខណៈដែលព័ត៌មានមិនពិត ព័ត៌មានក្លែងក្លាយ បន្លំ បំភ្លៃ បាននិងកំពុងវាយលុកក្នុង ហ្វេសប៊ុក និងបណ្តាញផ្សព្វផ្សាយសង្គមនានា គឺមិនត្រូវឆាប់ច្រឡោត ខឹងសម្បា នៅពេលឃើញសារមិនល្អពាក់ព័ន្ធនឹងខ្លួន និងស្ថាប័នរបស់ខ្លួននៅលើទំព័រហ្វេសប៊ុកនោះទេ ប៉ុន្តែត្រូវពិគ្រោះយោបល់ និងវិភាគឱ្យបានស៊ីជម្រៅ មុនធ្វើប្រតិកម្មតប បើមិនដូច្នោះទេ គឺនាំឱ្យខាតប្រយោជន៍ អាសោចកេរ្តិ៍ បាត់បង់កិត្តិយស និងសេចក្តីថ្លៃថ្នូរក្នុងនាមជាថ្នាក់ដឹកនាំនិងមន្ត្រី។ បន្ទាប់មក ត្រូវសហការជាមួយស្ថាប័នខ្សែបណ្តោយ និងខ្សែទទឹងក្រោមសមត្ថកិច្ចរបស់ខ្លួន និងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល រួមទាំងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផង ជួយបញ្ជ្រាប និងបង្កើនការអប់រំដល់ប្រជាពលរដ្ឋ ពីផលអវិជ្ជមាន និងហានិភ័យដល់សង្គម ដែលបណ្តាលមកពីព័ត៌មានក្លែងក្លាយនៅលើទំព័រហ្វេសប៊ុក និងបណ្តាញផ្សព្វផ្សាយសង្គមផ្សេងទៀត។

### គណបក្សនយោបាយ និងសកម្មជននយោបាយដែលមិនកាន់អំណាច ឬប្រឆាំងនឹងរដ្ឋាភិបាល

បើទោះបីខ្លួនជាបុគ្គលនយោបាយ និងគណបក្សនយោបាយរបស់ខ្លួនមិនបានកាន់អំណាច និងជាអមិត្តនឹងគណបក្សកាន់អំណាចក៏ដោយ ក៏ត្រូវប្រកាន់យកភាពថ្លៃថ្នូរ និងក្រមសីលធម៌នយោបាយដែរ។ មិនមែនដោយសារតែចង់យកឈ្នះ និងបំបាក់គូបដិបក្ខនយោបាយ ខ្លួនប្រតិដ្ឋព័ត៌មានក្លែងក្លាយ បន្លំ បំភាន់ បំភ្លៃពីបញ្ហាសង្គមទូទៅ និយាយដោយឡែកពីការផ្តល់សេវាសាធារណៈរបស់រដ្ឋ និងការអនុវត្តច្បាប់នោះឡើយ ព្រោះថា ល្បែងប្រតិដ្ឋព័ត៌មានបែបនេះអាចបំភាន់មហាជនបានមួយគ្រាខ្លីប៉ុណ្ណោះ ប៉ុន្តែក្រោយមក ខ្លួននិងគណបក្សរបស់ខ្លួនត្រូវបាត់បង់ប្រជាប្រិយ បាត់បង់ការគាំទ្រ និងសេចក្តីថ្លៃថ្នូរ។ ជាការពិតណាស់ អ្នកនយោបាយ និងសកម្មជននយោបាយ រួមទាំងគណបក្សនយោបាយដែលមិនកាន់អំណាច ឬគណបក្សប្រឆាំងបានដើរតួនាទីដ៏សំខាន់នៅក្នុងសង្គមប្រជាធិបតេយ្យ សេរីពហុបក្ស ហើយពួកគេក៏អាចជួយបង្ហាញចំណុចអវិជ្ជមាននៅក្នុងសង្គម និងការបាត់បង់ផលប្រយោជន៍ផ្សេងៗរបស់ប្រជាពលរដ្ឋ ជូនដល់គណបក្សនយោបាយដែលកាន់អំណាច ឬរដ្ឋាភិបាលដែរ ដើម្បីជួយកែលម្អ ជាប្រយោជន៍រួមសម្រាប់ជាតិ គឺមិនមែនតែចង់ផ្ចាញ់ផ្ចាល និងផ្តួលគូប្រជែង បែរជាបង្កើតរឿងមិនពិត និងប្រើប្រាស់ហ្វេសប៊ុក និងបណ្តាញផ្សព្វផ្សាយសង្គមថ្មីៗទៀត បញ្ចេញមតិ និងការរាយការណ៍ព័ត៌មាននានា ក្នុងចេតនាទុច្ចរិត បំពុលសង្គម ចោទប្រកាន់គេឯងគ្មានភស្តុតាងពីបញ្ហាផ្សេងៗនៅក្នុងសង្គម។ មេដឹកនាំនយោបាយនិងអ្នកពាក់ព័ន្ធត្រូវចូលរួមអប់រំសកម្មជន និងអ្នកគាំទ្ររបស់ខ្លួនកុំឱ្យឆាប់ជឿ និងឆាប់ច្រឡោតចំពោះសារមិនល្អនៅលើទំព័រហ្វេសប៊ុក មុននឹងឆ្លើយតបតាមនីតិវិធី បើមិនដូច្នោះទេ អាចនាំឱ្យមានទោស និងទទួលពិន័យជាដើម ទៅតាមផ្លូវច្បាប់។

### មន្ត្រីអង្គការសង្គមស៊ីវិលជាតិនិងបរទេស និងអ្នកចលនាសង្គម

ត្រូវចូលរួមលើកទឹកចិត្តប្រជាពលរដ្ឋឱ្យប្រើប្រាស់ហ្វេសប៊ុក ក៏ដូចជាបណ្តាញផ្សព្វផ្សាយសង្គមផ្សេងៗទៀត ហើយប្រើប្រាស់ឱ្យបានត្រឹមត្រូវ ដើម្បីទាញប្រយោជន៍ឱ្យសង្គមគ្រួសារ និងសង្គមជាតិ។ ដោយសហការជាមួយបណ្តាញ និងដៃគូពាក់ព័ន្ធរបស់ខ្លួន ព្រមទាំងស្ថាប័នរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ជួយបញ្ជ្រាបពីគ្រោះថ្នាក់ដោយសារព័ត៌មានមិនពិត ក្លែងក្លាយ ក្លែងបន្លំ និងបំភ្លៃជាដើម ដល់ក្រុមគោលដៅរបស់ខ្លួន ដើម្បីជួយទប់ស្កាត់ការឆាប់ជឿ ឆាប់ខឹង និងឆាប់ប្រតិកម្មតបដោយមិនបានគិតគូរហ្មត់ចត់ ជួយបញ្ជ្រាបពីសីលធម៌ និងក្រមសីលធម៌ រួមទាំងមាត្រាច្បាប់មួយចំនួនដល់ក្រុមគោលដៅ ក៏ដូចជាមហាជនទូទៅ និយាយដោយឡែក អ្នកប្រើប្រាស់ហ្វេសប៊ុក និងបណ្តាញផ្សព្វផ្សាយសង្គមផ្សេងទៀត ចំពោះការឆ្លើយតបសារនៅលើបណ្តាញផ្សព្វផ្សាយសង្គមទាំងនោះ។

ទន្ទឹមនឹងនោះ មន្ត្រីអង្គការសង្គមស៊ីវិលជាតិនិងបរទេស រួមទាំងអ្នកចលនាសង្គមនានាក៏ត្រូវប្រកាន់យកសីលធម៌បុគ្គល និងក្រមសីលធម៌ វិជ្ជាជីវៈរបស់ស្ថាប័នខ្លួន ព្រមទាំងគោរពច្បាប់របស់ប្រទេសដែលខ្លួនកំពុងរស់នៅ និងធ្វើការផងដែរ។ ការធ្វើសេចក្តីរាយការណ៍ និងរបាយការណ៍ពីបញ្ហាផ្សេងៗនៅក្នុងសង្គម និយាយដោយឡែកពីការផ្តល់សេវាសាធារណៈរបស់រដ្ឋ និងការអនុវត្តច្បាប់ ត្រូវមានសុចរិតភាព ដោយប្រាសចាកពីការការបំភ្លៃ បំប៉ោង និងបំផ្លាញកិត្តិយសប្រទេសជាតិមួយ ដើម្បីបានជំនួយពីបរទេសមកបន្តការងារ ។

## ប្រជាពលរដ្ឋ

មិនខុសពីមេដឹកនាំ និងអ្នករៀបចំគោលនយោបាយ ព្រមទាំងមន្ត្រីពាក់ព័ន្ធខាងលើនោះឡើយ គឺក្នុងនាមជាប្រជាជន ជាពិសេសអ្នកដែលអះអាងថាខ្លួនជា «អ្នកសារព័ត៌មានប្រជាពលរដ្ឋ» ដែលរស់នៅក្នុងប្រទេសមួយដែលខ្លួនគិតថា ត្រូវតែមាននីតិរដ្ឋ គឺត្រូវចូលរួមចំណែកក្នុងការកាត់បន្ថយអំពើសកម្មនានានៅក្នុងសង្គម។ ដោយសារតែហ្វេសប៊ុក ក៏ដូចជាបណ្ដាញផ្សព្វផ្សាយសង្គមផ្សេងៗទៀត កំពុងមានប្រជាប្រិយសម្រាប់ការទទួល ការបញ្ជូន និងការចែករំលែកសារបានយ៉ាងលឿន ប្រជាពលរដ្ឋ និងអ្នកសារព័ត៌មានប្រជាពលរដ្ឋត្រូវឆក់ឱកាសប្រើប្រាស់ហ្វេសប៊ុក និងបណ្ដាញផ្សព្វផ្សាយសង្គមថ្មីៗទៀត ដើម្បីទាញប្រយោជន៍សម្រាប់ខ្លួនឯងផង និងសង្គមជាតិផង តាមរយៈការបញ្ចេញមតិ និងការរាយការណ៍ព័ត៌មានប្រកបដោយសីលធម៌ បង្ហាញការពិតដោយគ្មានចេតនាទុច្ចរិត បំណងបំពុលសង្គម និងចោទប្រកាន់គេឯងគ្មានភស្តុតាងពីបញ្ហាផ្សេងៗនៅក្នុងសង្គម ជាពិសេសបញ្ហាការិយាធិបតេយ្យ និងអំពើពុករលួយក្នុងការផ្ដល់សេវាសាធារណៈរបស់រដ្ឋ ព្រមទាំងឥរិយាបថមិនប្រក្រតីរបស់មន្ត្រី និងប្រជាពលរដ្ឋក្នុងការអនុវត្តនិងគោរពច្បាប់។ បន្ថែមពីលើនេះ ប្រជាពលរដ្ឋខ្លួនឯង បើទោះអ្នកប្រើប្រាស់ហ្វេសប៊ុក និងបណ្ដាញផ្សព្វផ្សាយសង្គមផ្សេងៗទៀត ឬក៏មិនប្រើប្រាស់ក៏ដោយ គឺត្រូវចូលរួមលើកទឹកចិត្ត និងប្រកាន់ឥរិយាបថប្រកបដោយសីលធម៌ចំពោះមន្ត្រីផ្ដល់សេវាសាធារណៈរបស់រដ្ឋ ព្រមទាំងចូលរួមគោរពច្បាប់ទាំងអស់គ្នា ដើម្បីសេចក្ដីថ្លៃថ្នូរ សុខដុមរម្យនា និងភាពសុខសាន្តក្នុងសង្គមជាតិ។

បន្ថែមពីលើនេះ គឺមិនត្រូវឆាប់ជឿ និងឆាប់ខឹងទទឹងទិស នៅពេលឃើញសារមិនល្អពាក់ព័ន្ធនឹងខ្លួនឯង គ្រួសារ និងមិត្តភក្តិរបស់ខ្លួននៅលើទំព័រហ្វេសប៊ុកនោះទេ ព្រោះថា ព័ត៌មានក្លែងក្លាយរបស់ក្រុមបំពុលសង្គម បាននិងកំពុងវាយលុកក្នុងហ្វេសប៊ុក និងបណ្ដាញផ្សព្វផ្សាយសង្គមនានា។ មុនឆ្លើយតប ត្រូវពិគ្រោះយោបល់ និងគិតគូរពិចារណាឱ្យបានល្អិតល្អន់ ដើម្បីចៀសវាងការខាតបង់ណាមួយ ដូចជាចាញ់បោកគេ ខាតបង់ទ្រព្យសម្បត្តិ ខាតបង់ប្រយោជន៍ទាំងផ្នែកនយោបាយ និងសេដ្ឋកិច្ចទៀត។

## អ្នកសារព័ត៌មានអាជីព

ដោយខ្លួនមានតួនាទីដ៏សំខាន់នៅក្នុងការផ្សព្វផ្សាយដំណឹងនិងព័ត៌មានផ្សេងៗជូនមហាជនបានគ្រប់ទីកន្លែង និងគ្រប់ពេលវេលា អ្នកសារព័ត៌មានត្រូវជួយបង្កើនការយល់ដឹងពីអក្ខរកម្មព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ តាមរយៈអត្ថបទគ្រប់ទម្រង់របស់ខ្លួន ដោយប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងវិជ្ជាជីវៈ។ ត្រូវបង្កើតព័ត៌មានពិត ដើម្បីបន្សាបព័ត៌មានក្លែងក្លាយដែលមានតាមលើទំព័រហ្វេសប៊ុក និងបណ្ដាញសង្គមផ្សេងៗទៀត ហើយជួយបញ្ជ្រាបពីសីលធម៌ និងច្បាប់ជូនមហាជន ដើម្បីឱ្យប្រទេសមាននីតិរដ្ឋ កាត់បន្ថយអំពើអសកម្មនៅក្នុងសង្គមឱ្យបានជាអតិបរិមា។

## ៧- គន្ថនិទ្ទេស

### ៧.១-ភាសាខ្មែរ

### សៀវភៅ


១. ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល : *កម្រងព័ត៌មានសេវាសាធារណៈ* (រាជរដ្ឋាភិបាលកម្ពុជា សីហា ២០២១០) ទំព័រ២ ។

២. កៅ ឃុយថង : *រដ្ឋបាលសាធារណៈទំនើប* (បោះពុម្ពផ្សាយដោយបណ្ណាគារអង្គរ ២០០៧) ទំព័រ៣០ ។

៣. ពុទ្ធសាសនសបណ្ឌិត្យ : *វចនានុក្រមខ្មែរ ភាគទី១ ភាគទី២*, (វចនានុក្រម ១៩៦៨)។

៤. ហ៊ុន សែន : *"យុទ្ធសាស្ត្រចតុកោណ" ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា* (ភ្នំពេញ ១៦ កក្កដា ២០០៤) ទំព័រ៩។

៥. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (មាត្រា៥១)។

៦. វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា : *សេវាសាធារណមូលដ្ឋានៈ ប្រសិទ្ធផាពសេវា និងកំរៃក្រៅផ្លូវការ,* (វិច្ឆិកា ២០០៦) ទំព័រទី៣។


### របាយការណ៍ស្រាវជ្រាវ


៧. ឃី ចន្ទក្រឹះស្នា, ពៅ ណាទី និង សុខ សុម៉ា : *អត្ថបទទស្សនះ តើគេត្រូវធ្វើដូចម្តេចទើបអនុវត្តសេរីភាពបញ្ចេញមតិបានពេញលេញនិងស្របច្បាប់ ?*, (Politikoffee, ភ្នំពេញ ១៦ កុម្ភៈ ២០២២), https://politikoffee.com/en/koffee/42358 ។

៨. វិទ្យាស្ថានស្ថិតិ : *ជំរឿនទូទៅប្រជាជននៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩*, (ក្រសួងផែនការ តុលា ២០២០), ទំព័រ ix, http://www.nis.gov.kh/nis/Census2019/Final%20General%20Population%20Census%202019-Khmer.pdf ។

៩. អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល : *ប្រសាសន៍សំខាន់ៗរបស់សម្តេចតេជោ ហ៊ុន សែន ផ្តល់ដំបូន្មាននិងក្រើនរំលឹកដល់មន្ត្រីក្នុងឱកាសអញ្ជើញប្រគល់សញ្ញាបត្រ និងវិញ្ញាបនបត្រ ជូននិស្សិតភូមិន្ទរដ្ឋបាល*, (ភ្នំពេញ ២៥ កុម្ភៈ ២០២០) ។


### សារព័ត៌មាន


១០. ខ្មែរ ថាមស៍ (Khmer Times) : *នាយករដ្ឋមន្ត្រីចូលខ្លួនបង់ប្រាក់ពិន័យជិះម៉ូតូមិនពាក់មួកសុវត្ថិភាពនៅថ្ងៃនេះ* (ភ្នំពេញ ២៤ មិថុនា), https://www.khmertimeskh.com/25154/%E2%80%8Bនាយក%E2%80%8Bរដ្ឋមន្ត្រី%E2%80%8Bចូល%E2%80%8B/ ។

១១. គង់ សូរិយា : *ចំនួនអ្នកប្រើប្រាស់Internetនៅកម្ពុជាកើនឡើងប្រមាណ១៦លាននាក់ និង facebook ជាង១០លាននាក់*, (Property Area February 3, 2021), https://propertyarea.asia/archives/63359 ។

១២. យុត សុគន្ធ : *អាជ្ញាធរស្រុកកៀនស្វាយឃាត់គ្រឿងចក្រ៣គ្រឿងក្រោយឈូសឆាយដីបឹង*

*មួយកន្លែងដោយខុសច្បាប់* ( VOD ភ្នំពេញ ២១ កក្កដា ២០២១ ), https://www.vodkhmer.news/2021/07/21/kien-svay-district-authorities-seize-3-vehicles-after-illegally-clearing-a-lake/ ។

១៣. ចន ណារិទ្ធ : *លោក ឃួង ស្រេង ចូលខ្លួនទៅបង់ផាកពិន័យរឿងបើកម៉ូតូមិនពាក់មួកសុវត្ថិភាព* ( កោះសន្តិភាព ភ្នំពេញ ២៧ តុលា ២០២១ ), https://kohsantepheapdaily.com.kh/article/1421944.html ។

១៤. DR103 : *ករណីហិង្សា រវាងប៉ូលីសសង្កា និងកញ្ញារូបស្រស់, ភាគីទាំង២ អាចត្រូវអនុវត្តតាមច្បាប់ដូចគ្នា* ( មជ្ឈមណ្ឌលព័ត៌មានដើមអម្ពិលភ្នំពេញ ៩ កញ្ញា ២០២១ ) https://dap-news.com/national/2021/09/09/182942/ ។

១៥. ប្រាជ្ញ សុវណ្ណារ៉ា : *កម្ពុជាមានអ្នកប្រើអ៊ីនធើណិតជាង១៥លាននាក់ និងអ្នកប្រើប្រាស់គណនី Facebook ជាង១០លានគណនី គិតត្រឹមឆមាសទី១ឆ្នាំនេះ*, ( សារព័ត៌មានខ្មែរប៉ុស្ដិ៍, ភ្នំពេញ ២០ កក្កដា ២០២០ ), https://khmerpostasia.com/archives/56736 ។

១៦. បណ្តាញព័ត៌មាន Fresh News : *សម្តេចតេជោ ហ៊ុន សែន ទូន្មានមន្ត្រីឱ្យធ្វើជាខ្ញុំបម្រើដ៏ស្មោះត្រង់របស់ប្រជាពលរដ្ឋ និងត្រូវរួមសុខទុក្ខជាមួយប្រជាពលរដ្ឋ* ( ២៦ មិថុនា ២០១៧ ) ។

១៧. ប៉ា សុខេង : *នារីបួសក្បាលដោយសារមន្ត្រីនគរបាលវាយទាមទាររកយុត្តិធម៌និងសំណងសមរម្យ* ( VOD ភ្នំពេញ ៩ កញ្ញា ២០២១ ), https://www.vodkhmer.news/2021/09/09/woman-suffered-head-injury-by-police-officer-demands-justice-and-fair-compensation/ ។

១៨. ប៉ែន បូណា : *ឥរិយាបថមិនគោរពច្បាប់ជាទម្លាប់ដែលត្រូវកែប្រែ*, ( RFI ភ្នំពេញ ១១ សីហា ២០១០ ), https://www.rfi.fr/km/cambodia/20100911-ឥរិយាបថមិនគោរពច្បាប់ជាទម្លាប់ដែលត្រូវកែប្រែ ។

១៩. សុខុម ខុន ( Sokhom Khon ) : *សមត្ថកិច្ចនឹងប្រើពោតវាយពលរដ្ឋណា ដែលធ្វើននឹងបម្រាមនៅតំបន់ក្រហម* ( កម្ពុជាថ្មី ភ្នំពេញ ២១ មេសា ២០២១ ), https://www.kampucheathmey.com/local-news/105817/ ។

២០. លឹម វាសនា : *តើគួរបញ្ចេញមតិយ៉ាងដូចម្តេចឱ្យមានតម្លៃ?*, ( ថ្មីៗ ភ្នំពេញ ១៧ មីនា ២០២១ ), https://thmeythmey.com/?page=detail&id=101615 ។

២១. វីអូឌី : *លោក ហ៊ុន សែន ទៅបង់ប្រាក់ផាកពិន័យល្មើសច្បាប់ចរាចរណ៍នៅព្រឹកនេះ* ( ២៤ មិថុនា ២០១៦ ) https://www.vodkhmer.news/2016/06/24/hun-sen-went-to-pay-fine-for-violating-the-traffic-law/ ។

២២. វ៉ន ដារ៉ា : *នាយករដ្ឋមន្ត្រីប្រាប់ឱ្យស្ថាប័ននានាពិនិត្យ ឆ្លើយតបការបញ្ចេញមតិពីពលរដ្ឋក្នុងហ្វេសប៊ុកលោក* ( ភ្នំពេញប៉ុស្តិ៍ ២ វិច្ឆិកា ២០២១ ) https://www.postkhmer.com/national/2021-11-02-0909-226053.html ។

២៣. ស៊ុន មេសា : *កំណែទម្រង់ការិយាល័យធិបតេយ្យនៅកម្ពុជានៅតែជាសំនួរដល់រដ្ឋាភិបាល*, ( RFI, ភ្នំពេញ ២៥ មីនា ២០១៥ ), https://www.rfi.fr/km/cambodia/hun-sen-democratic-office-25-03-2015 ។

២៤. ហាន ណូយ : *បទយកការណ៍៖ យុវជនមិនសូវហ៊ានបញ្ចេញមតិពីបញ្ហាសង្គមលើអ៊ិនធឺណិតដោយសារបារម្ភពីសុវត្ថិភាព*, វីអូឌី ភ្នំពេញ ) ២៥ មករា ២០២១ ( , https://www.vodkhmer.news /2021/01/25/youth-worry-about-freedom-on-the-internet/ ។

២៥. ឡាយ សាមាន : *ក្រុមការងារហ្វេសប៊ុកលោក ស ខេង ទទួលដោះស្រាយ យោបល់ និងសំណូមពរពលរដ្ឋបាន ៨ គណនី*, ( ភ្នំពេញប៉ុស្តិ៍, ភ្នំពេញ ១៤ មិថុនា ២០២២ ), https://www.postkhmer.com/national/2022-06-14-1527-237692.html ។

២៦. អឹមស៊ី ចាន់ដារ៉ារេត ( MC Chandarareth ) : *រដ្ឋមន្ត្រីក្រសួងព័ត៌មាន បង្ហាញទស្សនៈមិនគាំទ្រលើការប្រើអំពើហិង្សា ដែលអាជ្ញាធរកំពុងធ្វើពេលនេះទេ* ( Sabay News ភ្នំពេញ ២១ មេសា ២០២១ ), https://news.sabay.com.kh/article/1272790 ។

**ហ្វេសប៊ុក៖**

២៧. ស ខេង : *បងប្អូនជនរួមជាតិជាទីគោរព!* ( Facebook ១០ វិច្ឆិកា ២០២១ ), https://web.facebook.com/SamdechKrola homSarkheng/posts/3081446835467317។

### ៧.២- ភាសាបរទេស

**សៀវភៅ**

២៧. Rod Hague and Martin Harrop, *Comparative Government and Politics 6th Edition*, ( China, 2004 ), P.290.

**របាយការណ៍ស្រាវជ្រាវ**

២៨. Bert Rockman, *"bureaucracy"*, ( Encyclopedia Britannica, 4 Jul. 2021 ), https://www.britannica.com/topic/ bureaucracy .

២៩. Sandro Serpa and Carlos Miguel Ferreira, ***The Concept of Bureaucracy by Max Weber***, ( January 18, 2019 ), file:///C:/Users/User/Downloads/The_Concept_of_Bureaucracy_by_Max_Weber.pdf .

៣០. Surya Narayan: ***Most popular social media platforms in Cambodia***, ( The Better Cambodia, 2022 ), https://thebettercambodia.com/most-popular-social-media-platforms-in-cambodia/ .

**សារព័ត៌មាន**

៣១. Benedict Carey: ***This Is Your Brain Off Facebook***, ( The New York Times, 30 January 2019 ), https://www.nytimes.com/2019/01/30/health/facebook-psychology-health.html .

៣២. Jeremy B. Merrill and Will Oremus: ***Five points for anger, one for a 'like': How Facebook's formula fostered rage and misinformation***, ( The Washington Post, 26 October 2021 ), https://www.washingtonpost.com/technology/2021/10/26/facebook-

angry-emoji-algorithm/ .

៣៣. Nem Sopheakpanha, *Cambodians Urged to Use Care on Social Media Platforms*, ( VOA Khmer, Phnom Penh 20 March 2019 ), https://www.voacambodia.com /a/cambodians-urged-to-use-care-on-social-media-platforms/48379 46.html .

៣៤. Touch Sokha and Ananth Baliga, *Hun Sen says no room for lying civil servants*, ( Phnom Penh Post, Phnom Penh, 27 June 2017 ), https://www.phnompe nhpost.com/national/hun-sen-says-no-room-lying-civil servants .

# យន្តការសម្របសម្រួលរបស់អង្គការសហប្រជាជាតិ
# លើវិស័យសិទ្ធិមនុស្សនៅកម្ពុជា

បេក្ខជនបណ្ឌិតៈ **ហេង ស៊ីឡេង**

ក្រោយសង្គ្រាមលោកលើកទី២ មានសន្និសីទនៅឆ្នាំ១៩៤៥ នាទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ សហរដ្ឋអាមេរិក ដើម្បីពិភាក្សាលើអត្ថបទច្បាប់មួយដែលក្រោយមកត្រូវបានគេស្គាល់ថាធម្មនុញ្ញសហប្រជាជាតិ ពេលនោះហើយដែលអង្គការសហប្រជាជាតិបានកើតឡើងនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៤៥។ បច្ចុប្បន្នមានប្រទេសចំនួន១៩៣ ជាសមាជិករបស់អង្គការសហប្រជាជាតិ ដែលក្នុងនោះក៏មានព្រះរាជាណាចក្រកម្ពុជាផងដែរដែលបានចូលជាសមាជិកនៅឆ្នាំ១៩៥៥។ តាមរយៈធម្មនុញ្ញសហប្រជាជាតិបានកំណត់នូវវត្ថុបំណងរបស់ខ្លួនមានដូចជាសន្តិភាពនិងសន្តិសុខពិភពលោក ការគោរពសិទ្ធិមនុស្ស នីតិរដ្ឋ និងការអភិវឌ្ឍ[1]។ ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិបានចែងនូវភារកិច្ចសំខាន់នៅក្នុងបុព្វកថាគឺការពារមនុស្សជំនាន់ក្រោយៗទៅ នេះពីការរងទុក្ខឈឺចាប់នៃសង្គ្រាម ព្រោះសង្គ្រាមដែលបានកើតឡើងពីរលើកកន្លងមកនេះបាននាំមកនូវសេចក្តីទុក្ខសោកឥតគណនាដល់មនុស្សជាតិ។ ហើយបុព្វកថាក៏បានអះអាង ជាថ្មីអំពីជំនឿចិត្តរបស់យើងទៅលើសិទ្ធិមនុស្សដែលមានសារៈសំខាន់គឺនាំមកនូវសេចក្តីថ្លៃថ្នូរនិងតម្លៃជាមនុស្ស សិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រីព្រមទាំងរវាងប្រជាជាតិតូចនិងប្រជាជាតិធំ។ ជាមួយគ្នាក៏បង្កើតឱ្យមានលក្ខណៈយុត្តិធម៌ ការគោរពសិទ្ធិនិងនាំឱ្យមានកាតព្វកិច្ចដែលកើតចេញពីសន្ធិសញ្ញានិងប្រភពដទៃទៀតនៃច្បាប់អន្តរជាតិអាចត្រូវបានថែរក្សាទុក។ ជាងនេះទៅទៀត បុព្វកថាបានបង្ហាញពីការលើកស្ទួយវឌ្ឍនភាពសង្គមនិងបង្កើតលក្ខខណ្ឌជីវភាពដ៏ប្រពៃក្នុងសេរីភាពកាន់តែធំទូលាយ។

សិទ្ធិមនុស្សលែងទៅជាបញ្ហានៅក្នុងប្រទេសនីមួយៗ ទៀតហើយគឺវាបានក្លាយជាទៅផ្នែកមួយនៃបញ្ហាជាសកល។ ដូច្នេះអង្គការសហប្រជាជាតិខិតខំជំរុញឱ្យសមាជិកអនុវត្តន៍នូវតួនាទីលើវិស័យសិទ្ធិមនុស្សនៅក្នុងរដ្ឋរបស់ខ្លួន។ ដើម្បីឱ្យការងារសិទ្ធិមនុស្សអនុវត្តន៍ទៅបាន អង្គការសហប្រជាជាតិចាំបាច់ត្រូវយកចិត្តទុកដាក់លើស្ថាប័នសិទ្ធិមនុស្សដែលជាយន្តការមួយក្នុងការលើកស្ទួយ ការពារសិទ្ធិមនុស្ស និងដើរតួនាទីសំខាន់ៗ ជាច្រើនដូចជាការត្រួតពិនិត្យពីវិស័យសិទ្ធិមនុស្ស ជាមជ្ឈត្តករក្នុងដោះស្រាយវិវាទសិទ្ធិមនុស្ស ព្រមជាមួយគ្នានេះដែរ ក៏មានស្ថាប័នសិទ្ធិមនុស្សដែលបានកើតឡើងដោយសន្ធិសញ្ញាអន្តរជាតិនានាដែលរដ្ឋភាគីទាំងអស់ត្រូវមានកាតព្វកិច្ចត្រូវតែគោរពនិងអនុវត្តន៍ឱ្យបានម៉ឺងម៉ាត់ជាទីបំផុត។

អង្គការសហប្រជាជាតិមានអង្គការសំខាន់ៗចំនួនប្រាំទៀតគឺ (១)មហាសន្និបាត (២)ក្រុមប្រឹក្សាសន្តិសុខ (៣)ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម (៤)លេខាធិការដ្ឋាន (៥)ក្រុមប្រឹក្សាភិបាលនិងតុលាការ

---

[1] មាត្រា១ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ឆ្នាំ១៩៤៥ ទំព័រ៣

យុត្តិធម៌អន្តរជាតិ[២]។ នៅពេលនេះគឺលើកយកតែពីការងារសិទ្ធិមនុស្សមកនិយាយ តាមរយៈមាត្រា៥៥ និងមាត្រា៥៦នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ក៏បានចែងអំពីទស្សនៈចំពោះការបង្កើតលក្ខខណ្ឌស្ថេរភាពនិងសុខុមាលភាពដែលចាំបាច់ដល់ទំនាក់ទំនងដោយសន្តិវិធី ដោយមិត្តភាពរវាងប្រជាជាតិនានា ដោយឈរលើមូលដ្ឋានគោរពគោលការណ៍សិទ្ធិស្មើគ្នានិងសិទ្ធិស្វ័យសម្រេចរបស់ប្រជាជន ហើយអង្គការសហប្រជាជាតិនឹងលើកស្ទួយ[៣] ។

លេខាធិការដ្ឋានគឺជាសេនាធិការប្រតិបត្តិរបស់អង្គការសហប្រជាជាតិ ដែលមានតួនាទីសំខាន់ក្នុងការកំណត់របៀបវារៈការប្រជុំធ្វើសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ក្រុមប្រឹក្សាសន្តិសុខនិងក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមនិងការអនុវត្តសេចក្តីសម្រេចរបស់ស្ថាប័នទាំងនេះ។ អគ្គ-លេខាធិការរបស់អង្គការសហប្រជាជាតិ ដែលត្រូវបោះឆ្នោតជ្រើសតាំងដោយមហាសន្និបាតអង្គការសហប្រជាជាតិ គឺជាប្រធានលេខាធិការដ្ឋាននេះ[៤]។ លេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិត្រូវបានបែងចែកជា១០ការិយាល័យគឺ(១)ការិយាល័យប្រតិបត្តិរបស់អគ្គលេខាធិការ (២)ការិយាល័យត្រួតពិនិត្យសេវាផ្ទៃក្នុង (៣)ការិយាល័យកិច្ចការនីតិកម្ម (៤)ការិយាល័យកិច្ចការរំសាយអាវុធ (៥)ការិយាល័យសម្របសម្រួលកិច្ចការមនុស្សធម៌ (៦)ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស (៧)ការិយាល័យឧត្តមស្នងការជនភៀសខ្លួន (៨)ការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្ម (៩)ការិយាល័យតំណាងជាន់ខ្ពស់សម្រាប់ប្រទេសតតិយលោក ប្រទេសមិនសូវអភិវឌ្ឍន៍ និងប្រទេសជាកោះតូចៗកំពុងអភិវឌ្ឍន៍។

ជាមួយគ្នានេះ អង្គការសហប្រជាជាតិក៏មានអង្គដទៃដែលស្ថិតនៅក្រោមឆ័ត្ររបស់ខ្លួនដែរ ក្នុងពេលអនុវត្តន៍សកម្មភាពដោយគិតគូរដល់ការងារសិទ្ធិមនុស្ស ។ នៅពេលនេះ សូមបង្ហាញនូវស្ថាប័ន

---

[២] មាត្រា៧នៃ ធម្មនុញ្ញអង្គការសហប្រជាជាតិ ឆ្នាំ១៩៤៥ ទំព័រ៤

[៣]មាត្រា៥៥នៃធម្មនុញ្ញអង្គការសហប្រជាជាតិបានចែងថា ដើម្បីបង្កើតនូវលក្ខខណ្ឌខាងស្ថេរភាព និងខាងសុខុមាលភាពជាការចាំបាច់ដើម្បីជានាប់រងរវាងប្រជាជាតិទាំងឡាយនូវប្រាស្រ័យទាក់ទងជាសន្តិវិធីនិងជាមិត្តភាពដែលបង្កើតឡើងតាមសេចក្តីគោរពគោលការណ៍ច្បាប់សមភាពនៃសិទ្ធិប្រជារាស្ត្រនិងសិទ្ធិដែលឱ្យប្រជារាស្ត្រទាំងនោះអាចសម្រេចអ្វីដោយខ្លួនឯងបាន អង្គការសហប្រជាជាតិនិងជួយៈ (ក) លើកតម្កើងឋានៈជីវភាព ការប្រើសិទ្ធិដោយពេញលេញនិងលក្ខខណ្ឌនៃវឌ្ឍនភាព ព្រមទាំងការពង្រីកខាងផ្លូវសេដ្ឋកិច្ចនិងសង្គម។ (ខ) ការដោះស្រាយបញ្ហាអន្តរជាតិក្នុងសេដ្ឋកិច្ចនឹងសុខាភិបាលនិងបញ្ហាដទៃជាអនុពន្ធ ហើយប្រតិបត្តិការណ៍អន្តរជាតិក្នុងផ្លូវវប្បធម៌និងការអប់រំ។ (គ) ការគោរពជាសកលនូវសិទ្ធិមនុស្សនិងសេរីភាពជាសារវន្តចំពោះជនទូទៅ ដោយមិនគិតដល់ការបែងចែកសញ្ជាតិ ភេទ ភាសាឬសាសនាឡើយ។ មាត្រា ៥៦ នៃធម្មនុញ្ញអង្គការសហប្រជាជាតិបានចែងថា ដើម្បីឱ្យបានសម្រេចនូវគោលបំណងដែលបានចែងក្នុងមាត្រា៥៦ សមាជិកទាំងឡាយ សុខចិត្តព្រមធ្វើតាមប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ ដោយរួមគ្នាក្តី ឬដោយឡែកក្តី។

[៤]មាត្រា៩៧នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ឆ្នាំ១៩៤៥ ទំព័រ១៨។

សំខាន់ៗ របស់អង្គការសហប្រជាជាតិមានតួនាទីក្នុងវិស័យសិទ្ធិមនុស្សមានដូចជា អង្គការពលកម្មអន្តរជាតិ (International Labour Organization, ILO) អង្គការស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិ (Food and Agriculture Organization of the United Nations, FAO) អង្គការសហប្រជាជាតិសម្រាប់អប់រំវិទ្យាសាស្ត្រនិងវប្បធម៌( United Nations Educational Scientific and Cultural Organization, UNESCO) អង្គការសុខភាពពិភពលោក (World Health Organization, WHO)។ ជាមួយគ្នានោះ ក៏មានកម្មវិធីនិងមូលនិធិរបស់អង្គការសហប្រជាជាតិសម្រាប់វិស័យសិទ្ធិមនុស្សដូចជាមូលនិធិកុមាររបស់អង្គការសហប្រជាជាតិ( United Nations Children's Fund,UNICEF) កម្មវិធីរបស់អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍(United Nations Development Programme , UNDP)មូលនិធិរបស់អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ស្ត្រី( United Nations Development for Women, UNIFEM) ទីភ្នាក់ងារការងារនិងជំនួយរបស់អង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួនប៉ាឡេស្ទីននៅនៀរអឺស(United Relief and Works Agency for Palestine Refugees in the Near East, UNRWA) កម្មវិធីស្បៀងអាហារពិភពលោក (World Food Programme, WFP)។ មិនតែប៉ុណ្ណោះ អង្គការសហប្រជាជាតិមានស្ថាប័នស្រាវជ្រាវនិងបណ្តុះបណ្តាលដូចជាវិទ្យាស្ថានរបស់អង្គការសហប្រជាជាតិដើម្បីធ្វើការបណ្តុះបណ្តាលនិងស្រាវជ្រាវ( United Nations Institute for Training and Research, UNTAR) វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវជាលក្ខណៈអន្តរជាតិរបស់អង្គការសហប្រជាជាតិដើម្បីការអភិវឌ្ឍរបស់ស្ត្រី (International Research and Training Institute for The Advancement of Women, INSTRAW) វិទ្យាស្ថានស្រាវជ្រាវរបស់អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍសង្គម( United Nations Research Institute for Social Development, UNRISD)។ ស្ថាប័ននានា ដែលបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិមានដូចជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (International Criminal Tribunal for the former Yugoslavia,ICTY) តុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅរ៉ាន់ដា (United Nations International Criminal Tribunal for Rwanda, ICTR)។ ព្រមទាំងស្ថាប័នផ្សេងៗ ទៀតរបស់អង្គការសហប្រជាជាតិដូចជា ការិយាល័យនៃឧត្តមស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(Office of the UN Highs Commission for Human Rights) ការិយាល័យនៃឧត្តមស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ( United Nations High Commissioner For Refugees, UNHCR) សាកលវិទ្យាល័យអង្គការសហប្រជាជាតិ( UN University , UNU)។

អង្គការសហប្រជាជាតិមានទីស្នាក់ការនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ទីស្នាក់ការនៅទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ានិងទីស្នាក់ការនៅទីក្រុងវៀន ប្រទេសអូទ្រីស។ ក្រៅពីទីស្នាក់ការខាងទាំងនេះ អង្គការសហប្រជាជាតិក៏មានស្នាក់ការក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៅតាមតំបន់មួយចំនួនដូចជានៅទីក្រុងបាងកកជាដើម។

និយាយពីយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិត្រូវបានបង្កើតឡើង ដោយឈរលើមូលដ្ឋានពីរគឺ ស្ថាប័នដែលបង្កើតឡើងដោយឈរលើមូលដ្ឋានធម្មនុញ្ញ និងស្ថាប័នដែលបង្កើតឡើងដោយឈរលើមូលដ្ឋានសន្ធិសញ្ញាគឺស្ថាប័នសន្ធិសញ្ញា។ ស្ថាប័នដែលបង្កើតឡើងដោយឈរលើមូលដ្ឋានធម្មនុញ្ញមានដូចជាក្រុមប្រឹក្សាសិទ្ធិមនុស្សនិងនីតិវិធីពិសេស។ ក្រុមប្រឹក្សាសិទ្ធិមនុស្សបង្កើតតាមរយៈសេចក្តីសម្រេចចិត្តលេខ៦០/២៥១ របស់មហាសន្និបាតអង្គការសហប្រជាជាតិថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ ដែលជាស្ថាប័នអន្តររដ្ឋាភិបាលនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិទទួលខុសត្រូវក្នុងការពង្រឹងការលើកស្ទួយ និងការការពារសិទ្ធិមនុស្សនៅជុំវិញពិភពលោកនិងដោះស្រាយស្ថានភាពនៃការរំលោភបំពានសិទ្ធិនិងផ្តល់អនុសាសន៍ពីដំណោះស្រាយ ។

នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៧ ក្រុមប្រឹក្សាសិទ្ធិមនុស្សបានអនុម័តសេចក្តីសម្រេចចិត្តលេខ៥/១ ដើម្បីបង្កើតនីតិវិធីនិងយន្តការធ្វើការរបស់ខ្លួន រួមទាំងនីតិវិធីបណ្តឹងនិងគណៈកម្មាធិការប្រឹក្សាយោបល់។ លើសពីនេះ ក្រុមប្រឹក្សាសិទ្ធិមនុស្ស ក៏បានអនុម័តបន្តយកនីតិវិធីពិសេសរបស់អតីតគណៈកម្មការសិទ្ធិមនុស្សផងដែរ។ សព្វថ្ងៃនេះក្រុមប្រឹក្សាសិទ្ធិមនុស្សបានប្រើប្រាស់នូវយន្តការៈ (១) គណៈកម្មាធិការប្រឹក្សាយោបល់គឺបង្កើតឡើងដើម្បីបំពេញភារកិច្ចជាក្រុមផ្តល់គំនិត យោបល់ដល់ក្រុមប្រឹក្សាសិទ្ធិមនុស្សនិងធ្វើការក្រោមការណែនាំពីក្រុមប្រឹក្សាសិទ្ធិមនុស្ស ដោយសារក្រុមប្រឹក្សានេះមិនអាចមានសមាជិកសុទ្ធតែអ្នកជំនាញខាងសិទ្ធិមនុស្សនោះទេ គឺពួកគេជាឯកអគ្គរាជទូត/រដ្ឋទូតនៃប្រទេសដែលត្រូវបោះឆ្នោតជ្រើសរើសជាសមាជិកក្រុមប្រឹក្សាសិទ្ធិមនុស្ស។ គណៈកម្មាធិការប្រឹក្សាយោបល់នេះ ដើរតួនាទីយ៉ាងសំខាន់សម្រាប់ជួយសមាជិកក្រុមប្រឹក្សាសិទ្ធិមនុស្សលើគ្រប់ទិដ្ឋភាពសិទ្ធិមនុស្សនិងក្នុងគ្រប់កាលៈទេស។ គណៈកម្មាធិការនេះបង្កើតឡើងដើម្បីជំនួសអនុគណៈកម្មការស្តីពីការលើកស្ទួយនិងការការពារសិទ្ធិមនុស្សរបស់អតីតគណៈកម្មការសិទ្ធិមនុស្ស។ (២) នីតិវិធីបណ្តឹងគឺបង្កើតឡើង ដើម្បីដោះស្រាយករណីរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ ឬជាប្រព័ន្ធដែលកើតមានឡើងនៅផ្នែកណាមួយក្នុងពិភពលោកនេះ ឬក្នុងកាលៈទេសៈណាមួយ។ នីតិវិធីបណ្តឹង បើកឱ្យមានការប្តឹងផ្ទាល់ទៅក្រុមប្រឹក្សាសិទ្ធិមនុស្សដោយបុគ្គល ក្រុមបុគ្គល ឬអង្គការមិនមែនរដ្ឋាភិបាលដែលអះអាងថាខ្លួនជាជនរងគ្រោះនៃការរំលោភបំពានសិទ្ធិមនុស្ស ឬក៏ដឹងដោយផ្ទាល់ជឿជាក់ពីការរំលោភបំពានបែប

នេះ។ (៣) យន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់(UPR)គឺជាដំណើរការតែមួយគត់អំពីកំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋសមាជិកនីមួយៗទាំង១៩៣ប្រទេសនៃអង្គការសហប្រជាជាតិ។ ដោយមានគោលដៅខ្ពស់បំផុតក្នុងការធ្វើឱ្យកាន់តែ ប្រសើរដល់ស្ថានភាពសិទ្ធិមនុស្សនៅគ្រប់រដ្ឋដែលស្ថិតនៅក្រោមការពិនិត្យUPR ត្រូវបានបង្កើតឡើង ដើម្បីបង្កើនគាំទ្រ និងពង្រីកការលើកស្ទួយ និងការការពារសិទ្ធិមនុស្សនៅតាមប្រទេសនីមួយៗ។ UPR គឺជាដំណើរការខិតខំប្រឹងប្រែងរបស់រដ្ឋដែលផ្តល់ឱកាសដល់រដ្ឋនីមួយៗ ប្រកាសពីការចាត់វិធានការនានា ដើម្បីធ្វើឱ្យប្រសើរដល់ស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសនិងបំពេញកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួននៅចំពោះមុខរដ្ឋដទៃទៀត និងចំពោះមុខសាធារណៈជនទូទៅ។ UPR បង្កើតឱកាសផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋនានានិងលើកកម្ពស់សមត្ថភាពរបស់ពួកគេ ក្នុងការដោះស្រាយបញ្ហាប្រឈមទៅនឹងសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធភាព និងចែករំលែកការអនុវត្តល្អៗ នៅក្នុងវិស័យសិទ្ធិមនុស្សរវាងរដ្ឋនានានិងដៃគូដទៃទៀត។ ជាទិដ្ឋភាពចម្បងមួយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស UPR ត្រូវបង្កើតឡើងដើម្បីធានាឱ្យមានការពិនិត្យ ដោយស្មើភាពគ្នាដល់រដ្ឋទាំងអស់ នៅពេលស្ថានភាពសិទ្ធិមនុស្សរបស់ពួកគេត្រូវបានវាយតម្លៃម្តងៗ។ គ្រប់រដ្ឋទាំងអស់ត្រូវស្ថិតនៅក្រោមដំណើរការដូចគ្នានិងការពិនិត្យដូចគ្នាដោយមិនគិតពីការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សនោះទេ។ សព្វថ្ងៃនេះមិនមានយន្តការសកលដទៃណាលើសពីនេះទៀតទេ។ ទិដ្ឋភាពតែមួយគត់នៃដំណើរការ UPR គឺថាឆ្លុះបញ្ចាំងនូវការប្រមូលផ្តុំនៃទស្សនៈអន្តរជាតិអំពីស្ថានភាពសិទ្ធិមនុស្សនៅតាមប្រទេសនីមួយៗដែលស្ថិតនៅក្រោមការពិនិត្យ ហើយអនុសាសន៍ដែលជាលទ្ធផលពីការពិនិត្យនេះ ត្រូវបានទទួលយកដោយស្ម័គ្រចិត្តនិងជាសាធារណៈដោយរដ្ឋដែលស្ថិតក្រោមការពិនិត្យ។

សម័យប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សត្រូវធ្វើទៀតទាត់៣ដងក្នុងមួយឆ្នាំ ជាទូទៅក្នុងខែមីនាមានរយៈពេល៤សប្តាហ៍ ក្នុងខែមិថុនា មានរយៈពេល ៣សប្តាហ៍ និងក្នុងខែកញ្ញាមានរយៈពេល ៣សប្តាហ៍។ ក្នុងករណីមានការស្នើសុំពីរដ្ឋសមាជិកយ៉ាងតិច១/៣ ក្រុមប្រឹក្សាសិទ្ធិមនុស្សអាចសម្រេចកោះប្រជុំពិសេសនៅពេលណាក៏បាន ដើម្បីដោះស្រាយភាពអាសន្ននិងការរំលោភបំពានសិទ្ធិមនុស្ស។ (៤) នីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស គឺ ជាអ្នកជំនាញការសិទ្ធិមនុស្សឯករាជ្យ ឬក្រុមនៃអ្នកជំនាញបែបនេះដែលរាយការណ៍ និងប្រឹក្សាយោបល់អំពីសិទ្ធិមនុស្សតាមទស្សនៈវិស័យប្រធានបទ ឬទស្សនៈវិស័យតាមប្រទេសជាក់លាក់។ អ្នកជំនាញការទាំងនេះរួមមាន អ្នករាយការណ៍ពិសេស តំណាងពិសេស ក្រុមការងារ និងអ្នកជំនាញឯករាជ្យ។ កន្លងមកមានអ្នករាយការណ៍ពិសេសតាមប្រធានបទមួយចំនួនបានមកបំពេញទស្សនកិច្ចនៅកម្ពុជាក្រៅផ្លូវការឬធ្លាប់ពាក់ព័ន្ធនឹងកម្ពុជា រួមមានក្រុមការងារស្តីពីការឃុំខ្លួនតាមទំនើងចិត្ត អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស

អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពនៃការជួបជុំដោយសន្តិវិធី និងសមាគម អ្នករាយការណ៍ពិសេសស្តីពីលំនៅដ្ឋានសមរម្យនិងអ្នករាយការណ៍ពិសេសស្តីពីការបង្ការទារុណកម្ម។ អ្នកកាន់អាណត្តិតាមនីតិវិធីពិសេសត្រូវរាយការណ៍ប្រចាំឆ្នាំជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ភាគច្រើននៃអ្នកកាន់អាណត្តិនេះក៏ត្រូវរាយការណ៍ជូនមហាសន្និបាតអង្គការសហប្រជាជាតិដែរ។

ដោយឡែក ស្ថាប័នដែលបានបង្កើតឡើងដោយឈរលើមូលដ្ឋានសន្ធិសញ្ញា មានដូចជា (១) គណៈកម្មាធិការសិទ្ធិមនុស្ស (២)គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមនិងវប្បធម៌ (៣)គណៈកម្មា-ធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (៤)គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ (៥)គណៈកម្មាធិការ និងអនុគណៈកម្មការប្រឆាំងការទប់ស្កាត់អំពើទារុណកម្ម (៦)គណៈកម្មាធិការស្តីពីសិទ្ធិកុមារ ( ៧)គណៈកម្មាធិការសម្រាប់ការពារសិទ្ធិពលករទេសន្តរប្រវេសន៍គ្រប់រូបនិងសមាជិកគ្រួសាររបស់ពួកគេ (៨)គណៈកម្មាធិការស្តីពីសិទ្ធិជនពិការ និង (៩)គណៈកម្មាធិការទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ។ គណៈកម្មាធិការទាំងនេះគឺបានធ្វើការតាមឯកទេសរៀងៗខ្លួន។

យន្តការមួយដែលសំខាន់ដែរគឺ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិជាស្ថាប័នមួយដែលបានប្តេជ្ញាចិត្តពង្រឹងនូវកម្មវិធីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងផ្តល់នូវការគាំទ្រយ៉ាងសម្បើមខ្លាំងក្លាប្រកបដោយគុណភាពខ្ពស់។ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ប្តេជ្ញាធ្វើការងារយ៉ាងជិតស្និទ្ធបំផុតជាមួយដៃគូអង្គការសហប្រជាជាតិផ្សេងៗទៀតដោយធានាថា ទម្រង់គ្រឹះនៃសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិត្រូវបានបំពេញនិងអនុវត្ត។

នៅឆ្នាំ២០១៨ តាមរយៈសេចក្តីសម្រេចចិត្តលេខ ៤៨/១៤១ របស់មហាសន្និបាតនៃអង្គការសហប្រជាជាតិ បានប្រគល់ភារកិច្ចដល់ឧត្តមស្នងការសិទ្ធិមនុស្សអន្តរជាតិដូចខាងក្រោម៖

- លើកកម្ពស់សិទ្ធិមនុស្ស និងការពារសិទ្ធិមនុស្ស
- ផ្តល់អនុសាសន៍ ដើម្បីការរីកចម្រើនដល់ប្រព័ន្ធស្ថាប័ននៃការការពារ ការលើកកម្ពស់សិទ្ធិមនុស្សអន្តរជាតិ
- លើកកម្ពស់ និង ការពារសិទ្ធិអភិវឌ្ឍន៍
- ផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋសម្រាប់សកម្មភាពសិទ្ធិមនុស្ស
- សម្របសម្រួលកម្មវិធីអប់រំនិងផ្សព្វផ្សាយសាធារណៈអំពីសិទ្ធិមនុស្សជាមួយអង្គការសហប្រជាជាតិ

- បំពេញភារកិច្ចក្នុងការលុបបំបាត់នូវឧបសគ្គនៃការយល់ដឹងសិទ្ធិមនុស្ស និងការពារដល់ការរំលោភរដ្ឋធម្មនុញ្ញស្តីពីសិទ្ធិមនុស្ស
- ការចូលរួមក្នុងការពិភាក្សាជាមួយរដ្ឋាភិបាលដើម្បីធានានូវការគោរពសិទ្ធិមនុស្ស
- ពង្រឹងនូវកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីការពារនិងលើកកម្ពស់សិទ្ធិមនុស្ស
- សម្របសម្រួលសកម្មភាពទាំងអស់តាមរយៈប្រព័ន្ធអង្គការអន្តរជាតិ ដើម្បីការពារ និងលើកកម្ពស់សិទ្ធិមនុស្ស
- សនិទានកម្ម សម្របសម្រួល ពង្រឹងនិង ធ្វើឱ្យមានប្រសិទ្ធភាពប្រសើរឡើងនៃយន្តការសិទ្ធិអន្តរជាតិ។

ជារួម យន្តការរបស់អង្គការសហប្រជាជាតិគឺគ្រាន់តែជាយន្តការប្រមូលផ្តុំគ្នាដើម្បីធ្វើការពិនិត្យតាមដាននិងវាយតម្លៃទៅលើការអនុវត្តសិទ្ធិមនុស្សរបស់បណ្តាប្រទេសនៅលើពិភពលោកនេះ និងធ្វើការផ្តល់អនុសាសន៍ដល់ប្រទេសនីមួយៗ ដើម្បីឱ្យប្រទេសនោះខិតខំប្រឹងប្រែងកែលម្អបញ្ហាសិទ្ធិមនុស្ស។

នៅព្រះរាជាណាចក្រកម្ពុជា មានការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ចាប់ពីឆ្នាំ១៩៩៣ ក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលគ្រប់ភាគីជម្លោះនៅកម្ពុជាបានព្រមពៀងបញ្ចប់សង្គ្រាមនៅកម្ពុជា។ បន្ទាប់ពីការបោះឆ្នោតដែលរៀបចំដោយអ៊ុនតាក់នៃអង្គការសហប្រជាជាតិរួចមក ដោយយោងលើមាត្រា១៧ នៃកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជាបានចែងថា "ក្រោយពីសម័យអន្តរកាលត្រូវបានបញ្ចប់ គណៈកម្មការអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស គប្បីបន្តតាមដានឱ្យបានជិតដល់ពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ហើយបើចាំបាច់រួមមានទាំងការតែងតាំងអ្នកធ្វើកំណត់ហេតុពិសេសម្នាក់ ដែលត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីលទ្ធផលនៃការរកឃើញរបស់ខ្លួនជូនទៅគណៈកម្មការនិងមហាសន្និបាត"[៥]។ នៅខែតុលាឆ្នាំ១៩៩៣ បានបង្កើតឱ្យមានការិយាល័យសិទ្ធិមនុស្ស តាមរយៈសេចក្តីសម្រេច១៩៩៣/០៦ នៃគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ។

ហេតុដល់ឆ្នាំ១៩៩៨ ការិយាល័យសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ បានកែប្រែទៅជាឧត្តមស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិសម្រាប់ឃ្លាំមើល ការពារនិងលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា។ ដូច្នេះហើយបានមានតំណាងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិនៅកម្ពុជា។

---

[៥]មាត្រា១៧ កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជំលោះកម្ពុជា១៩៩១ ទំព័រ១២

នៅការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ បាននឹងកំពុងបន្តកិច្ចខិតខំប្រឹងលើវិស័យសិទ្ធិមនុស្ស គាំទ្រការអភិវឌ្ឍនូវក្របខណ្ឌច្បាប់និងស្ថាប័នដែលការពារការអនុវត្តសិទ្ធិមនុស្ស ដោយអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា។ ឃ្លាំមើលការអនុវត្តច្បាប់ និងសកម្មភាពនានារបស់ស្ថាប័នរដ្ឋដែលទទួលបន្ទុកគោរព និងលើកកម្ពស់សិទ្ធិធ្វើសេចក្តីរាយការណ៍ពីវិស័យដែលមានបញ្ហាដល់រាជរដ្ឋាភិបាលនិងតួអង្គពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យមានវិធានការកែតម្រូវនិងរួមគ្នាស្វះស្វែងរកដំណោះស្រាយ។ គាំទ្រកិច្ចសហប្រតិបត្តិការរបស់រាជរដ្ឋាភិបាល ជាមួយនឹងក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងយន្តការរបស់ក្រុមប្រឹក្សានេះនិងលើកស្ទួយការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ។ គាំទ្រសមត្ថភាពរបស់តួអង្គសង្គមស៊ីវិល (អង្គការសិទ្ធិមនុស្សមិនមែនរដ្ឋាភិបាល សមាគមស្ត្រី ប្រព័ន្ធផ្សព្វផ្សាយ សហជីពកម្មករ និងស្ថាប័នដទៃទៀត) ដើម្បីឃ្លាំមើលនិងតស៊ូមតិដើម្បីសិទ្ធិមនុស្ស និងការការពារសកម្មភាពរបស់ពួកគេទាំងនោះ តាមរយៈការជំរុញឱ្យមានបរិយាកាសមួយគោរពគ្នាទៅវិញទៅមកកិច្ចសន្ទនានិងកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាល។

ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិប្រចាំកម្ពុជារក្សាទុកការិយាល័យកណ្តាលមួយនៅរាជធានីភ្នំពេញនិងការិយាល័យប្រចាំតំបន់មួយនៅខេត្តបាត់ដំបង។ ការិយាល័យនេះផ្តល់នូវសេវាដល់រាជរដ្ឋាភិបាល សង្គមស៊ីវិលនិងភាគីពាក់ព័ន្ធផ្សេងៗទៀត វាយតម្លៃជាបន្តនូវស្ថានភាពសិទ្ធិមនុស្សដែលត្រូវបានផ្លាស់ប្តូរព័ត៌មានជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីជួយឱ្យការវាយតម្លៃនេះមានលក្ខណៈប្រសើរឡើង។ វិភាគផ្នែកច្បាប់នូវសេចក្តីព្រាងច្បាប់នានានិងផ្តល់យោបល់លើអនុលោមភាពតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ គាំទ្រការផ្តល់យោបល់និងការបណ្តុះបណ្តាល ដើម្បីជួយរដ្ឋាភិបាលក្នុងការធ្វើរបាយការណ៍ទៅអង្គភាពត្រួតពិនិត្យសន្ធិសញ្ញាអន្តរជាតិនិងដើម្បីជំរុញឱ្យអនុវត្តអនុសាសន៍របស់អង្គភាពទាំងនោះ។ បណ្តុះបណ្តាលនិងណែនាំអំពីបញ្ហាសិទ្ធិមនុស្សច្បាប់ជាតិនិងការប្រើប្រាស់យន្តការសិទ្ធិមនុស្សអន្តរជាតិ។ កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីការពារបុគ្គល ឬក្រុមជាក់លាក់ ដែលសិទ្ធិរបស់ពួកគេកំពុងស្ថិតនៅក្រោមការគំរាមកំហែង។ ផ្តល់ជំនួយទ្រង់ទ្រាយតូចដល់តួអង្គសង្គមស៊ីវិលនិងសហគមន៍ដើម្បីជួយពួកគេដោះស្រាយបញ្ហាសិទ្ធិមនុស្ស។

ជាមួយគ្នានេះដែរ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ មានស្មារតីរបស់ខ្លួនក្នុងការអនុវត្តការងាររបស់ខ្លួន។ ចំពោះរដ្ឋ ជាពិសេសរាជរដ្ឋាភិបាលវិញក៏ត្រូវមានទំនួលខុសត្រូវក្នុងនាមអ្នកការពារសិទ្ធិមនុស្ស ដើម្បីពង្រឹងការពារសិទ្ធិមនុស្ស គឺទាមទារឱ្យមានការវាយតម្លៃ

ដោយស្មោះត្រង់លើបញ្ហាដែលជាកង្វល់ផ្សេងៗ គួបផ្សំជាមួយនឹងកិច្ចសន្ទនាដែលមានលក្ខណៈស្ថាបនា រវាងរាជរដ្ឋាភិបាល សង្គមស៊ីវិលនិងតួអង្គអន្តរជាតិដើម្បីកំណត់និងអនុវត្តដំណោះស្រាយ។ ដើម្បីសម្រេចគោលដៅនេះ ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាធ្វើការឆ្ពោះទៅរកការជំរុញឱ្យមានកិច្ចសន្ទនា និងកិច្ចខិតខំប្រឹងប្រែងប្រកបដោយកិច្ចសហប្រតិបត្តិការគ្នាក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ និងធ្វើការឆ្ពោះទៅរកការបង្កើតនូវបរិយាកាសមួយដែលទស្សនចម្រុះគ្រប់ទិសទីអាចត្រូវបានសម្តែងចេញដោយសេរីនិងសន្តិវិធី។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានជួយដល់រាជរដ្ឋាភិបាលនិងប្រជាជនកម្ពុជាក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្សដូចជាបន្តសកម្មភាពកិច្ចសហប្រតិបត្តិការបច្ចេកទេសជាមួយស្ថាប័នតុលាការ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម ក្រុមប្រឹក្សាសកម្មភាពជនពិការនិងតួអង្គរាជរដ្ឋាភិបាលនិងសង្គមស៊ីវិលដទៃទៀត។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាបានបន្តឃ្លាំមើលស្ថានភាពសិទ្ធិមនុស្ស រួមទាំងសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន ការប្រើប្រាស់សិទ្ធិសេរីភាពជាមូលដ្ឋាន សិទ្ធិចូលរួមក្នុងជីវភាពពលរដ្ឋ និងនយោបាយ ដំណើរការជំនុំជម្រះក្តីនិងស្ថានភាពនៅកន្លែងឃុំឃាំង ហើយបានបន្តពង្រឹងសមត្ថភាពអង្គការសង្គមស៊ីវិលនៅកម្ពុជា តាមរយៈវគ្គបណ្តុះបណ្តាលចំនួន៦លើក ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិបានបណ្តុះបណ្តាលសមាជិកអង្គការសង្គមស៊ីវិលជាបុរសចំនួន១៣៩នាក់ ស្រី៧៦នាក់ អ្នកប្តូរយេនឌ័រចំនួន១០នាក់ ក្នុងនោះរាប់បញ្ចូលទាំងសកម្មភាពនៅតាមមូលដ្ឋាន សកម្មជនដីធ្លីនិងសកម្មជនសហជីពមកពីខេត្តក្រចេះ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង ព្រះវិហារ សៀមរាប កំពង់ស្ពឺ ស្វាយរៀង កំពង់ចាមនិងកោះកុង។ អ្នកចូលរួម ត្រូវបានបណ្តុះបណ្តាលអំពីវិធីសាស្ត្រឃ្លាំមើលការរៀបចំដាក់របាយការណ៍ទៅកាន់យន្តការអន្តរជាតិនិងការតស៊ូមតិ[៦]។ ជុំវិញការពង្រឹងនីតិរដ្ឋ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានបន្តធ្វើជាអ្នកសម្របសម្រួលដៃគូម្ចាស់ជំនួយដល់ក្រុមការងារបច្ចេកទេសស្តីពីកំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការដែលសហការដឹកនាំដោយក្រសួងយុត្តិធម៌។

[៦] របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ថ្ងៃទី៣១ខែកក្កដាឆ្នាំ២០១៩ ទំព័រ៧

ចំពោះយន្តការ នៃអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជាគឺបានអនុវត្តន៍ពីឆ្នាំ១៩៩៣។ ប៉ុន្តែនៅមុនឆ្នាំ២០០៨ អាណត្តិរបស់ប្រទេសកម្ពុជា ត្រូវបាន ដឹកនាំដោយតំណាងពិសេសនៃអគ្គលេខាធិការសិទ្ធិមនុស្សនៅកម្ពុជា។ អ្នកកាន់អាណត្តិជាតំណាង ពិសេសនេះគឺត្រូវបានតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ បើទោះបីជាត្រូវរាយការណ៍ ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សក៏ដោយ។ តំណាងពិសេសក៏រាយការណ៍ទៅមហាសន្និបាត និងគណៈ កម្មាធិការសិទ្ធិមនុស្សផងដែរ។

ភារកិច្ចរបស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ គឺធ្វើការដោយវាយតម្លៃអំពីស្ថានភាព សិទ្ធិមនុស្ស ហើយរាយការណ៍ជាសាធារណៈ ដោយធ្វើការងារជាមួយរាជរដ្ឋាភិបាល សង្គមស៊ីវិល និង ភាគីពាក់ព័ន្ធ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យសិទ្ធិមនុស្សនេះ។ អ្នករាយការណ៍ ពិសេសត្រូវធ្វើទស្សនកិច្ចជាទៀងទាត់ ហើយរាយការណ៍ជារៀងរាល់ឆ្នាំទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដោយមានការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជាជា ជំនួយការផ្នែកភស្តុភារ និងបច្ចេកទេស។ អ្នករាយការណ៍ពិសេសគឺមានតួនាទីដាច់ដោយឡែកពី ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ដែលជាស្ថាប័ន ផ្លូវការនៃលេខាធិដ្ឋានអង្គការសហប្រជាជាតិ។ តែយ៉ាងណាក៏ដោយស្ថាប័នទាំងពីរមានអាណត្តិបំពេញ បន្ថែមនិងធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា។ ឧត្តមស្នងការអង្គការសហប្រជាជាតិគឺមានតួនាទីផ្តល់សេវា លេខាធិការដ្ឋាន ដល់អ្នករាយការណ៍ពិសេសក្នុងកំឡុងពេល បេសកកម្មមកកម្ពុជា។ កម្ពុជាធ្លាប់បាន ទទួលនូវអ្នករាយការណ៍ពិសេសចំនួន៧រូបចាប់ពីឆ្នាំ១៩៩៣ ដល់ពេលបច្ចុប្បន្ននេះ។ អ្នករាយការណ៍ ពិសេសទាំងអស់រួមមាន៖ លោក Michael Kirby ជនជាតិអូស្ត្រាលីដែលមានអាណត្តិការងារចាប់ពី ឆ្នាំ១៩៩៣ ដល់ ១៩៩៦ , លោក Thomas Hammarber ជនជាតិស៊ុយអែតដែលមានអាណត្តិ ការងារចាប់ពីឆ្នាំ១៩៩៦ដល់ឆ្នាំ២០០០, លោក Peter Leuprech ជនជាតិអូទ្រីសដែលមានអាណត្តិ ការងារចាប់ពីឆ្នាំ២០០០ដល់ឆ្នាំ២០០៥ , លោក Yash Ghai ជនជាតិកេនយ៉ាដែលមានអាណត្តិ ការងារចាប់ពីឆ្នាំ២០០៥ដល់ឆ្នាំ២០០៨, លោក សុរិយា ស៊ូប៊ែឌី ជនជាតិនេប៉ាល់ដែលមានអាណត្តិ ការងារចាប់ពីឆ្នាំ ២០០៨ដល់ឆ្នាំ២០១៥ , លោកស្រី Rhona Smith ជនជាតិអង់គ្លេសដែលមាន អាណត្តិការងារចាប់ឆ្នាំ២០១៥ដល់ឆ្នាំ២០២១ និងលោក វីទីតមុនតាប៊ិន ជនជាតិថៃដែលមាន អាណត្តិការងារចាប់ពីឆ្នាំ២០២១ដល់បច្ចុប្បន្ននេះ។

នៅថ្នាក់តំបន់ ដោយព្រះរាជាណាចក្រកម្ពុជា ជាសមាជិកអាស៊ាន ហើយអង្គការអាស៊ានមាន យន្តការសិទ្ធិមនុស្សដែលគេហៅថា គណៈកម្មការអន្តរដ្ឋាភិបាលស្តីពីសិទ្ធិមនុស្សសហគមន៍អាស៊ាន

(AICHR) ដែលមានសារៈសំខាន់បំផុតក្នុងការលើកកម្ពស់និងការពារសិទ្ធិមនុស្សក្នុងតំបន់និងក្រៅតំបន់។ អង្គការAICHR កំពុងតែដើរតួនាទីក្នុងការលើកកម្ពស់សិទ្ធិមនុស្សតាមរយៈកម្មវិធីអប់រំ និងផ្សព្វផ្សាយនូវគោលការណ៍និងយុទ្ធសាស្ត្រនៃការពង្រឹងនូវការចូលរួមពីគ្រប់មជ្ឈដ្ឋានទាំងអស់។

ប្រទេសកម្ពុជាមានអង្គការមិនមែនរដ្ឋាភិបាលចំនួនសរុប៥,៣៨៦អង្គការ ឆ្នាំ២០២០ ក្នុងនោះមានអង្គការប្រហែលជាង ១០០អង្គការ ដែលធ្វើសកម្មភាពលើវិស័យសិទ្ធិមនុស្សដោយសេរីនៅកម្ពុជា។ ក្នុងចំណោមអង្គការទាំងនោះមានអង្គការចំនួន ២៣ បានប្រមូលផ្តុំគ្នាបង្កើតគណៈកម្មការមួយឈ្មោះថា គណៈកម្មាធិការប្រព្រឹត្តកម្មដែលមានទិសដៅនិងតួនាទីសំខាន់លើវិស័យសិទ្ធិមនុស្សដូចជាអប់រំ ផ្សព្វផ្សាយ ហ្វឹកហ្វឺន បណ្តុះបណ្តាលដល់មន្ត្រី កងកម្លាំងប្រដាប់អាវុធ និងការពារសិទ្ធិមនុស្សដល់ប្រជាពលរដ្ឋ។ ក្នុងពេលនេះមានអង្គការចំនួន៤ កំពុងមានសកម្មភាពលេចធ្លោលើផ្នែកសិទ្ធិមនុស្សគឺសមាគមអាដហុក អង្គការលីកាដូ អង្គការវិហ្សីឡែន និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។ ទន្ទឹមនឹងនេះក៏មានអង្គការមួយចំនួនកំពុងបំពេញការងារទៅលើវិស័យសិទ្ធិមនុស្សរួមមាន OHCHR, UDNP, UNICEF។ល។ ជាមួយគ្នានេះដែរ ប្រទេសជាមិត្តដែលដាក់ស្ថានទូតប្រចាំនៅកម្ពុជាបានផ្តល់មូលនិធិ និងជំនួយគ្រប់បែបយ៉ាងដល់អង្គការទាំងដែលបំពេញការងារលើវិស័យសិទ្ធិមនុស្សដូចជាស្ថានទូតអាមេរិក ចក្រភពអង់គ្លេស សហគមន៍អឺរ៉ុប។ ល។

សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ដែលធ្វើការងារពាក់ព័ន្ធនឹងវិស័យសិទ្ធិមនុស្សដោយមានទស្សនៈធ្វើឱ្យសង្គមមានការគោរពនូវសិទ្ធិមនុស្ស ច្បាប់ មានបេសកកម្មអប់រំ ពង្រឹងដល់ការយល់ដឹងរបស់ប្រជាពលរដ្ឋឱ្យចេះអំពីសិទ្ធិ ការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ចេះតស៊ូមតិជាមួយអំណាចរដ្ឋ ដើម្បីជំរុញអភិបាលកិច្ចល្អ។ អង្គការទាំងនោះតែងប្រកាសខ្លួនថាឯករាជ្យមិនចូលបក្ស និងស្វែងរកប្រាក់ចំណេញដូចអ្វីដែលកំណត់ដោយច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

អង្គការក្រៅរដ្ឋាភិបាលបង្កើតគម្រោងកម្មវិធីនីមួយៗ ដែលរមែងចែងក្នុងគោលការណ៍សិទ្ធិមនុស្សដែលស្ថិតនៅក្នុងច្បាប់អន្តរជាតិទាំងឡាយ និងស្របគោលការណ៍នៃច្បាប់ជាតិ។ កម្មវិធីនោះត្រូវតែស្របនឹងគោលការណ៍នៃកតិកាសញ្ញាដែលបានទទួលស្គាល់ដោយសហគមន៍អន្តរជាតិ។ ការធ្វើយ៉ាងនេះ ដើម្បីចូលរួមជំរុញតួនាទីរបស់រដ្ឋក្នុងវិស័យសិទ្ធិមនុស្សឱ្យមានដំណើរការល្អប្រសើរ ដើម្បីលើកកម្ពស់ជីវភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ ដូចនេះការចូលរួមរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា គឺជាធាតុចូលមួយសម្រាប់យកមកត្រិះរិះពិចារណា ក្នុងការរៀបចំគោលនយោបាយទាក់ទងសិទ្ធិមនុស្ស ក្នុងឆ្លើយតបទៅនឹងការរិះគន់ចំពោះការអនុវត្តជាក់ស្តែងនៃចំណុច

ខ្លះ។ ម្យ៉ាងទៀតអង្គការមិនមែនរដ្ឋាភិបាលគឺដើរតួជាផ្នែកមួយនៃការផ្ដល់របាយការណ៍ស្រមោលទៅក្រុមប្រឹក្សាសិទ្ធមនុស្សអន្តរជាតិផងដែរ។

យន្តការសម្របសម្រួលរបស់អង្គការសហប្រជាជាតិលើវិស័យមនុស្សនៅកម្ពុជា គឺពិតជាជួយដល់ការងារសិទ្ធិមនុស្ស ដើម្បីឱ្យរដ្ឋអាចបំពេញភារកិច្ចរបស់ខ្លួនកាន់តែមានប្រសិទ្ធភាព ក្នុងគោលបំណងឱ្យប្រជាពលរដ្ឋមានសេចក្ដីថ្លៃថ្នូរនិងរស់នៅសមរម្យក្នុងសង្គម។ ការងារសិទ្ធិមនុស្សគួរតែមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីរួមគ្នាពង្រឹងវិស័យសិទ្ធិមនុស្សឱ្យកាន់តែល្អប្រសើរ ក្នុងគោលបំណងតែមួយគត់ ដើម្បីធ្វើឱ្យជីវភាពរបស់ប្រជាជនទទួលបានភាពរុងរឿង។

# យុត្តិធម៌ក្នុងប្រព័ន្ធតុលាការកម្ពុជា

ដោយនិស្សិត ៖ **ខេង សុវណ្ណតារា**

## ១.១.លក្ខណៈទូទៅនៃយុត្តិធម៌សង្គម

ពាក្យយុត្តិធម៌សំដៅទៅលើឧត្តមគតិសកលផងទៅលើគុណធម៌នៃជនម្នាក់ៗផង។ គេអាចនិយាយអំពីយុត្តិធម៌ផង និង មនុស្សធម៌ផង។ ប៉ុន្តែគំនិតនេះតែងបញ្ជាក់ ឱ្យឃើញជានិច្ច នូវគំនិត នៃភាព ត្រូវ ល្អិតល្អន់ស្របទៅតាមវិចារណញ្ញាណ( rigueur rationnelle )។ មនុស្សយុត្តិធម៌ គឺមនុស្សប្រកបដោយគំនិតត្រឹមត្រូវស្ទើរតែមានលក្ខណៈជាទ្រឹស្តីបទគណិតវិទ្យាទៅហើយ មនុស្សនេះតែងបំពេញករណីយកិច្ចរបស់ខ្លួនដោយឥតខ្ចោះ[១]។

យុត្តិធម៌អាចមានន័យថា «ការគោរពយ៉ាងទៀងទាត់នូវសិទ្ធិរបស់ជនម្នាក់ៗពោលគឺការបើកឱ្យជនម្នាក់ៗមានសិទ្ធិរបស់ខ្លួន»។ ដូចនេះភាពត្រូវល្អិតល្អន់នៃគណិតវិទ្យា តែងតែមានជានិច្ចនៅក្នុងសញ្ញាណនៃយុត្តិធម៌។ ម្យ៉ាងទៀតគំនិតនៃយុត្តិធម៌ក៏ដូចជាសិទ្ធិដែរ មានមូលដ្ឋានផ្អែកទៅលើតម្លៃនៃមនុស្ស[២]។

លោក សូប៉ិនហាវរ៍ (Schopenhawer) បានមានប្រសាសន៍ថាមនុស្សម្នាក់ៗស្មានថាខ្លួនអាចរស់នៅបានតាមចិត្ត ពោលគឺខិតលើផលប្រយោជន៍អ្នកដទៃ ប៉ុន្តែយុត្តិធម៌ចូលមកលំអកដល់សញ្ចេតនា ដែលកើតឡើងដោយឯកឯងនៃជីវិតនេះដោយចែងថា ម្នាក់ៗ ត្រូវបានចំណែករៀងៗខ្លួន។ គេត្រូវតែគិតដល់អ្នកដទៃ ហើយចែកប្រយោជន៍ជាមួយ អ្នកទាំងនោះតាមសមាមាត្រដ៏ត្រឹមត្រូវ (une juste proportion)។ ដូចនេះយុត្តិធម៌ប្រឆាំងនឹងទំនោរដ៏ខ្លាំងក្លានៃអត្តទត្ថភាពមុនអ្វីៗទាំងអស់។

តាំងពីសម័យអារីស្តូតម្ល៉េះ គេតែតែងសម្គាល់ឃើញថា មានយុត្តិធម៌បីសណ្ឋាន គឺ ទី១ យុត្តិធម៌ក្នុងការប្តូរ( justice coinutative ) គឺជា យុត្តិធម៌ដែលជាអធិបតីនៃការប្តូរនិយាមរបស់យុត្តិធម៌នេះជាសមភាពនៃគណិតវិទ្យា។ ការប្តូរមួយអាចត្រឹមត្រូវបានលុះត្រាតែវត្ថុដែលគេប្តូរទៅមកទាំងពីរមានតម្លៃដូចគ្នា។ ពីក្រោយសមមូល (equivalerice)តម្រូវទៅតាមយុត្តិធម៌នៃវត្ថុដែលគេ ប្តូរ យើងតែងសម្គាល់ឃើញថាមានសមភាពរវាងមនុស្សដែលជាអ្នកប្តូរ។ ដោយសារមនុស្សម្នាក់ៗមានសិទ្ធិដូចគ្នានេះហើយបានអ្នកប្តូរម្នាក់ៗ

---

[១] ខ្លូត ធីតា៖ *មូលដ្ឋានគ្រឹះនៃសីលវិទ្យាសកលលោក* ភ្នំពេញ, ២០០៩ ទំព័រ៤៨

[២] ទស្សវិជ្ជា ថ្នាក់បញ្ចប់៖ *ការផ្សាយរបស់មជ្ឈមណ្ឌលទស្សនវិជ្ជាអនុវត្តន៍និងសីលធម៌* ភ្នំពេញ, ឆ្នាំ២០១៨ ទំព័រ២៨០

មិនត្រូវខូចប្រយោជន៍ក្នុងការប្តូរនេះឡើយ។ ទី២ យុត្តិធម៌ក្នុងការចែក នៅកន្លែងនេះ ការតម្រូវនៃសមភាពមានភាពផ្សេង ព្រោះថា វាហាក់ដូចជាអយុត្តិធម៌ បើគេឱ្យរង្វាន់ស្មើគ្នាទៅមនុស្សដែលមានសមត្ថភាពមិនស្មើគ្នា។ បេក្ខជនពូកែត្រូវទទួលពិន្ទុល្អចំណែកឯបេក្ខជនខ្សោយត្រូវទទួលពិន្ទុអាក្រក់ៗ។ និងទី៣ យុត្តិធម៌ក្នុងការបង្រាប ទោះជាក្នុងភាពដើម និង ក្នុងភាពសាមញ្ញបំផុតក៏ដោយ ក៏ការបង្ក្រាបរបស់យុត្តិធម៌តែងយកសមាមាត្រនៃគណិតវិទ្យាមកគិតដែរ។ ច្បាប់តាលុង(loice Talon)«យកភ្នែកទៅសងភ្នែក ធ្មេញទៅសងធ្មេញ» គឺជាសមមូលមួយពិតប្រាកដ។ នៅក្នុងសណ្ឋានជឿនលឿនបំផុតនៃយុត្តិធម៌ក្នុងការបង្ក្រាប យើងជួបប្រទះការតម្រូវនៃសមភាពទៀត។

ពិតមែនតែអ្នកមានពិរុទ្ធមិនបានទទួលទោស ដែលមានធម្មជាតិដូចគ្នាសុទ្ធសាធ នឹងកំហុសដែលខ្លួនបានធ្វើក៏ដោយ ក៏គេនៅតែថ្លឹងទម្ងន់ទោសនោះឱ្យបានស្មើនឹងទម្ងន់នៃកំហុចខាតដែរ។ នៅក្នុងការថ្លឹងនេះគេតែងយកពិរុទ្ធភាពនៃអ្នកប្រព្រឹត្តបទល្មើសមកពិនិត្យដែរ ដោយគេគិតថាតើអ្នកប្រព្រឹត្តបទល្មើសនោះប្រព្រឹត្តដោយឆន្ទៈឬទេ។

ការប្រកាសសិទ្ធិមនុស្សថ្លែងថា «មនុស្សទាំងអស់កើតឡើងមានសិទ្ធិស្មើៗគ្នា» យើងនឹងយករូបមន្តនេះមកពិចារណាឱ្យច្បាស់លាស់ ដើម្បីបំបាត់ការមន្ទិល។ គេមិនអះអាងថាមនុស្សទាំងអស់ស្មើគ្នាគ្រប់លក្ខណៈនោះទេ ប៉ុន្តែ ទោះជាមានភាពផ្សេងៗគ្នា និងវិសមភាពក្នុងការពិតក៏ដោយក៏មនុស្សទាំងអស់មានសិទ្ធិស្មើគ្នាដោយសារខ្លួនមានវិចារណញ្ញាណដែលជាសេចក្តីថ្លៃថ្នូរនៃមនុស្សទូទៅ។

វិសមភាពមែនទែនរវាងមនុស្ស គឺមួយផ្នែកជាវិសមភាពធម្មជាតិ (inégalité naturelle) ដូចជាវិសមភាពនៃកោសល្យនិងសម្បទា ឧទាហរណ៍៖ មនុស្សមានសុខភាពល្អ ឬ មិនសូវល្អ បញ្ញាវៃ ឬ មិនសូវវៃ លំនឹងនៃគំនិតទៀងឬមិនសូវទៀង សីលចរិយាល្អឬមិនសូវល្អជាដើម។ ក្រៅពីមនុស្សយុត្តិធម៌និងសន្តិបុគ្គល នៅមាន«មនុស្សខូចតាំងពីកំណើត»(des pervers constitutionnels) ដែរ។ មួយផ្នែកទៀតគឺវិសមភាពនិមិត្ត(inégalités artificielles) ដែលកើតឡើងដោយសារលក្ខខណ្ឌនៃសង្គម និងដោយសារប្រាក់កាស អ្នកខ្លះមានភោគផលសម្ភារៈយ៉ាងច្រើនមានពេលលំហែ អ្នកខ្លះទៀតស្ទើរតែគ្មានអ្វីបង្គ្រប់ការចាំបាច់ផង។

ដូចនេះអ្នកខ្លះត្រូវរងទុក្ខតាំងពីដំបូងដោយសារភាពក្រីក្រចំណែកឯអ្នកខ្លះទៀតគ្រាន់តែកើតឡើងក៏ត្រូវបានសប្បាយតែម្តង។ ទោះជានៅក្នុងសង្គមដែលគ្មានវណ្ណៈ គ្មានកម្មសិទ្ធិឯកជន គ្មានមរតកអ្វីក៏ដោយ ក៏វិសមភាពពីដើមទីនៅតែមានជានិច្ច។

ដំបូងរដ្ឋដែលកាន់លទ្ធិប្រជាធិបតេយ្យ មានបំណងចង់ឱ្យមានសមភាពនៃពលរដ្ឋ គេត្រូវតែតម្រូវឱ្យពលរដ្ឋទាំងអស់ ទោះជានរណាក៏ដោយ ចូលទៅក្នុងប្រព័ន្ធតែមួយនៃសិទ្ធិ និង ករណីយកិច្ច។ ឥឡូវនេះ ពលរដ្ឋម្នាក់ៗត្រូវមានករណីយកិច្ចចូលទៅបម្រើកងទ័ព។ ទោះក្របុមាន អ្នកប្រព្រឹត្តទោសកម្មនឹងត្រូវគេប្ដឹងឱ្យតុលាការជំនុំជំរះដូចគ្នា។ ពលរដ្ឋម្នាក់ៗមានសិទ្ធិបោះឆ្នោត កុមារម្នាក់ៗមានសិទ្ធិចូលរៀនក្នុងគ្រឹះស្ថានបឋមសិក្សា។ បេក្ខជននៅក្នុងសម័យប្រឡងមួយត្រូវឋិតនៅក្នុងលក្ខខណ្ឌដូចគ្នា។ នេះជាសមភាពដែលគេឃើញច្បាស់ជាញឹកញយដោយសារអនាមិកភាពនៃកិច្ចការរបស់បេក្ខជន(កូនរដ្ឋមន្ត្រី ក៏ដូចជាកូនអ្នកបោសថ្នល់ដែរ អាចប្រឡងធ្លាក់មធ្យមសិក្សាប័ត្រ(baccalaureat) ដូចគ្នា)។ ការតម្រូវនៃសមភាពនេះគ្មានបំណងនឹងធ្វើមនុស្សឱ្យដូចគ្នាទេឬក៏ធ្វើឱ្យកោសល្យ និងភាពខុសគ្នាពីធម្មជាតិមានកម្រិតស្មើគ្នាឡើយ។ ផ្ទុយទៅវិញក្នុងការធ្វើឱ្យភ័ព្វសំណាងពីដើមទីស្មើគ្នា គេចង់អនុញ្ញាតឱ្យម្នាក់ៗ អាចបញ្ចេញនិស្ស័យធម្មជាតិ(dons naturels)របស់ខ្លួន។

គេជឿថានឹងមានយុត្តិធម៌ហើយនឹងមានគុណប្រយោជន៍សម្រាប់សហគមន៍ទាំងមូលបើឱ្យមនុស្សមានសមត្ថភាពច្រើនជាងគេមានមុខងារខ្ពស់ជាងគេ។ ជួនកាល វិវត្តន៍នៃតិចនិចនិងបញ្ហាសង្គមហើយនិងបញ្ហាជាតិតម្រូវឱ្យមានដូចនេះតែម្តង។ បើយុត្តិធម៌ក្នុងការចែកតម្រូវឱ្យបុគ្គលដែលមានលក្ខណៈមិនស្មើគ្នាពីធម្មជាតិ រក្សាទុកដដែលនូវវិសមភាពរបស់ខ្លួនដូចជា នាយករោងចក្រមានប្រាក់បៀវត្សច្រើនជាងកម្មករ ការបំបាត់អយុត្តិធម៌សង្គម និងការបំបាត់វិសមភាពនិមិត្ត មុខជានឹងធ្វើឱ្យឃើញកាន់តែច្បាស់ឡើងនូវភាពឃោរឃៅនៃវិសមភាពធម្មជាតិ។ នៅក្នុងពិភពមួយដែល ប្រាក់កាស សេចក្តីគាប់គួរចែជន្យ មានគុណប្រយោជន៍ច្រើនម្នាក់ៗអាចលួងលោមចិត្ត ខ្លួនឯងអំពីភាពក្រីក្រនៃការរស់នៅរបស់ខ្លួនបាន ដោយចោទប្រកាន់អយុត្តិធម៌ នៃមនុស្ស។ ក៏ប៉ុន្តែនៅក្នុងពិភពលោកមួយដែលមាន «យុត្តិធម៌» ដែលម្នាក់ៗអាចនៅកន្លែងរបស់ខ្លួនអាស្រ័យទៅតាម សម្បទាពិតប្រាកដ។

## ១.២.សញ្ញាណនៃយុត្តិធម៌ក្នុងសង្គម

មនុស្សដើមរស់នៅជាមួយគ្នាជាក្រុមៗ ក៏ដូចជា នាកាលជំនាន់យើងនេះ ក្នុងកិច្ចផលិតកម្មសម័យទំនើប ដើម្បីស្វែងរកជីវភាពខ្ពង់ខ្ពស់ មនុស្សរស់នៅជាមួយគ្នាជាសង្គម ដែលមានសមាជិកប្រជុំគ្នា ជាក្រុមបក្សសម្ព័ន្ធ ឬ កុលសម្ព័ន្ធ ដើម្បីប្រមូល កម្លាំងកាយការពារជីវិត តទល់ និង ការអត់ឃ្លាន និងសត្វសាហាវ ឬ និង បាតុភូតធម្មជាតិ ដូចជាទឹកជំនន់ ទឹក ភ្លៀង ព្យុះ ។ល។ ការចិញ្ចឹមជីវិតនៃមនុស្សដើម ប្រកបដោយការបេះផ្លែឈើព្រៃ និងទៅចាប់សត្វល្អិតតូចៗ មានក្តាម ខ្យង ជាដើម។ ឃើញថាការចិញ្ចឹមជីវិតរបៀបនេះមិនទៀងទាត់ទេ។ ថ្ងៃនេះផ្លែឈើច្រើន ឬចាប់បានក្តាប ខ្យង់ច្រើន ថ្ងៃស្អែករកមិនបាន ក៏គ្មានអ្វីបំពេញក្រពះទេ។

មិនតែប៉ុណ្ណោះ មនុស្សដើម ត្រូវការពារខ្លួនចំពោះសត្វសាហាវ ដោយកម្លាំងកាយ ឥតមាន សាស្ត្រាវុធគ្រាន់ពឹងលើទេ ។ ព្រោះតែលំបាកដូច្នេះហើយបានជាមនុស្សដើមនៅជុំគ្នាជាក្រុម។ សមាជិកម្នាក់ៗ ចេញទៅរកអាហារបានមក យកទៅប្រគល់ឲ្យក្រុមទុកជាទ្រព្យរួម សម្រាប់សមូហភាព។ សមាជិកណារកមិនបានឯព្រៃត្រឡប់មក ក្រុមវិញ បានទទួលផល រួមពីសមូយភាព ដើម្បី ចំអែតពោះបំបាត់ឃ្លាន។

ក្រោយដែលគេចេះបង្កាត់ភ្លើង ដោយសង្កៀតឈើ និងឈើ ឈើនិងថ្ម គេចេះចំអិនអាហារ បរិភោគ។ ចំណេះនេះ បានជំរុញការស្វែងរកអាហារដោយ ថ្នាក់បរបាញ់ និង នេសាទ ជាហេតុបណ្តាលឱ្យគេចេះធ្វើធ្នូ និង ព្រួញ ។ ដល់ត្រឹមនេះ មានចែកការងារ គ្នាធ្វើម្តង រវាង សមាជិកក្រុម ។ ការចែកការងារគ្នានេះ បានធ្វើទៅតាមភេទ ប្រុសៗមាន កម្លាំងពលំជាង ចេញទៅបាញ់ ឬនេសាទ ស្រីៗខ្សោយជាងចេញទៅចេះផ្លែឈើ ឬនៅចាំទីកន្លែង។ ប៉ុន្តែយ៉ាងណាក៏ដោយ រហូតមកដល់ពេលនេះ សេដ្ឋកិច្ចនៃសមូហភាពឋិតលើការយកពីធម្មជាតិ មិនលើការបង្កើតលើខ្លួនឯងទេ។ ដូច្នេះហើយបើក្នុងព្រៃ ឬ ក្នុងបឹង ជិតខាង វិនាសអស់សត្វអស់ត្រីកាលណាសមូហភាពត្រូវតែចាកចោលទីកន្លែងចាស់ ហួតហែង ទៅរកនៅទីកន្លែងថ្មី សម្បូណ៌ជាងវិញ។ ដូច្នេះហើយលក្ខខណ្ឌសម្បត្តិសេដ្ឋកិច្ច មិនអាចនាំឱ្យមនុស្សជំនាន់នោះនឹកឃើញចង់បានកម្មសិទ្ធិឯកជនទេ ក្រៅពីកម្មសិទ្ធិចំពោះគ្រឿងប្រដាប់ប្រើប្រាស់ផ្ទាល់ ដូចជា ធ្នូ ពូថៅ លំពែង។

មកក្នុងកាលសម័យដាំដំណាំ និង ចិញ្ចឹមសត្វ មានការផ្លាស់ប្តូរមួយសំខាន់ក្នុង សេដ្ឋកិច្ច ដោយសេដ្ឋកិច្ចលែងកើតពីការយកពីធម្មជាតិទៀតហើយ សេដ្ឋកិច្ចបែរមកស្ថិតលើការបង្កើតផលវិញ។ ការដាំដំណាំ និងការចិញ្ចឹមសត្វនាំឱ្យមានការប្រែប្រួលមួយក្នុងសង្គម។ ពីដើមគេទៅរកអាហារពីព្រៃ ពីបឹង ពីទន្លេដែលបានស្រាប់ៗក្នុងធម្មជាតិ ឥឡូវនេះគេចេះបង្កើតអាហារខ្លួនឯង។ ការបង្កើតផលខ្លួនឯងដូច្នេះ នាំឱ្យមនុស្សលែងខ្វល់បារម្ភនិងអាហារ។ការដាំដំណាំ និង ចិញ្ចឹមសត្វ នាំឱ្យបានផលលើសហួសពីការត្រូវការសម្រាប់ខ្លួនឯង។ ចាប់ពីពេលនេះទៅការរស់នៅនៃជនមួយរួចៗ មិនចាំបាច់ពឹងពាក់ជាដាច់ខាតលើសមាជិកក្រុមទៀតនៃក្រុមទេ គេរកបានសេសសល់ សម្រាប់ទុកនៅថ្ងៃក្រោយទៀត។ ហើយដូច្នេះហើយក៏កម្មសិទ្ធិ ចាប់មានកំណើតឡើង[៣]។ សម្រាប់លោក ហ្សង់ ហ្សាក់រូសូ(Jean-Jacques Rousseau)យល់ឃើញថា បើគ្មានកម្មសិទ្ធិឯកជននោះក៏គ្មានចោរដែរ[៤]។

---

[៣] លី គឹមសុខ៖ *គំនិតនយោបាយ* ភ្នំពេញ, ទំព័រ៥៩។

[៤] កា ម៉ាធុល៖ *ប្រវត្តិគំនិតនយោបាយ* ភ្នំពេញ, ឆ្នាំ២០០៨ ទំព័រ២៨៣។

ក្នុងកិច្ចផលិតកម្ម ការទាក់ទងរវាងមនុស្សគឺ ម្ចាស់ទៅ ទាសាទាសី។ ម្ចាស់មានទាំងអស់ផ្ទះសម្បែង ស្រែចំការ គោក្របី ប្រដាប់ប្រដាប្រើប្រាស់។ ទាសជនគ្មានអ្វីទាល់តែសោះ ក្រៅអំពីកម្លាំងកាយសម្រាប់ធ្វើការឱ្យម្ចាស់។ ជីវិតទាសជន ម្ចាស់ទុកដាក់តាមទំនើងចិត្តនិងសម្លាប់ចោលថ្ងៃណាក៏បានរូបកាយគេលក់ដូរ ផ្ទេរ ពីម្ចាស់មួយទៅម្ចាស់មួយទៀតដូចគោក្របី។ សាច់ឈាមគេឥតត្រាប្រណី តែធ្វើការមិនពេញចិត្តគេ គេវាយដំច្រំធាក់បង្ខំឱ្យប្រឹងធ្វើឱ្យបានផលច្រើនដល់គេ។ អាស្រ័យការទាក់ទងរវាងមនុស្សក្នុងកិច្ចផលិតដូច្នេះហើយ បានជាការពលកម្មគេទុកជារបរថោកទាបជាទីបំផុត មានតែមនុស្សខ្ញុំកំដរគេទើបធ្វើពលកម្ម ក៏អាស្រ័យការទាក់ទងរវាងមនុស្ស ក្នុងកិច្ចផលិតកម្មដូច្នេះឯងដែរបានសេដ្ឋកិច្ចពុំបានជឿនលឿនរីកចំរើនទៅមុខសោះឡើយ ធ្វើការព្រោះតែគេបង្ខំឱ្យធ្វើផលកម្លាំងកាយខ្លួនបានទៅនៅលើតែដៃ ធ្វើការមិនដឹងជាបានអ្វីបានតែសេចក្ដីក្ដៅក្រហាយឈឺចាប់ពិបាកវេទនា។

យុត្តិធម៌របស់លោកប្លាតុង ស្ថិតនៅត្រង់ទទួលស្គាល់ថា មានវិសមភាពសង្គម មានការបែកមនុស្សឱ្យចេញជាមនុស្សថ្នាក់លើ និងមនុស្សថ្នាក់ក្រោមតាំងពីកំណើត[៥]។ អារីស្តូតមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះវិសមភាពដ៏សែនជ្រៅនៅក្នុងសង្គម ព្រោះលោកយល់ថា វាជាមូលហេតុដែលនាំឱ្យមាននូវសេចក្ដីតូចចិត្ត ទំនាស់សង្គម និងការធ្វើរដ្ឋប្រហារក្នុងគ្រប់រូបភាព ដើម្បីផ្តួលរំលំរដ្ឋ[៦]។

លោក សៀរ៉ូ ទទួលស្គាល់ថា មនុស្សទាំងអស់ស្មើៗគ្នាចេញពីធម្មជាតិ។ ហើយគេម្នាក់សុទ្ធតែអាចធ្វើខ្លួនឲ្យក្លាយជាអ្នកចេះដឹងបាន បើសិនជាគេឆ្លងកាត់ការសិក្សាអប់រំ ចំពោះបញ្ហាវិសមភាពនៅក្នុងសង្គមវិញលោកយល់ថា នេះមិនមែនកើតចេញមកពីកំណើតនោះទេ។ តែជាវិសមភាពដែលកើតឡើង ដោយកម្លាំងនៃការទំនាក់ទំនងក្នុងសង្គម។ លោកបានប្រកាសថាកម្មសិទ្ធិឯកជន មិនដែលចេញពីធម្មជាតិឡើយ។ តាមពិតវាអាច កើតចេញមកពីការមានបានតៗគ្នាមកតាំងពីយូរលង់ណាស់មកហើយ ឬកើតមកពីការទទួលជ័យជំនះ ក្នុងសង្គ្រាម ឬបាន មក ពីច្បាប់និងការឯកភាពគ្នាក្នុងសង្គម។ ចំពោះបញ្ញត្តិទាសករ លោកបានបដិសេធចោលចំពោះទស្សនៈថា ទាសករ ជាឧបករណ៍ ចេះនិយាយហើយ លោកបានបញ្ជាក់យ៉ាងច្បាស់ថា នៅក្នុងទំនាក់ទំនងរវាងមនុស្សនិងមនុស្ស ពុំមានអ្វីគួរឱ្យខុសគ្នានោះឡើយ មនុស្សទាំងអស់ដូចៗគ្នា ស្មើៗគ្នា ហើយមនុស្សទាំងអស់ជាពលរដ្ឋផែនដីទាំងមូលតែម្តង។

[៥] លី គឹមសុខ៖ *គំនិតនយោបាយ* ដ.ឯ.ម ទំព័រ១៧៥។

[៦] កា ម៉ាធុល៖ *ប្រវត្តិគំនិតនយោបាយ* ដ.ឯ.ម ទំព័រ១៨៦។

តាមទស្សនៈរបស់ស៊ីសៀរ៉ូ ច្បាប់និងយុត្តិធម៌ មាននៅក្នុងធម្មជាតិ បានន័យថា ចេញពីធម្មជាតិអ្វីៗទាំងអស់ ហាក់ដូចជារៀបចំឱ្យមាន សណ្តាប់ធ្នាប់ហើយជាស្រេច។ យុត្តិធម៌លោកមើលឃើញត្រង់ចំណុចថា មិនត្រូវបង្កផលអាក្រក់ដល់អ្នកដទៃ និង មិនបំពានលើកម្មសិទ្ធិអ្នកដទៃ។

## ១.៣.ទ្រឹស្តីស្តីពីការបែងចែកអំណាច និង ច្បាប់

តាំងពីសម័យបុរាណរហូតដល់សតវត្សរ៍ទី១៤ មនុស្សភាគច្រើនហាក់ដូចជា ជឿ តាមបែបព្រហ្មលិខិត (Fatalistic) ថា រដ្ឋាភិបាលជាអ្វីដែលត្រូវបានកំណត់រួចមកជាស្រេចហើយ មនុស្សយើងគ្មានជម្រើសនោះទេ។ អាទិទេព គឺជាអ្វីៗទាំងអស់ ហើយអ្វីៗទាំងអស់ គឺជាអាទិទេព។ អាទិទេព មិនមែនស្ថិតនៅក្រៅតថភាពទេ។ អាទិទេព និងពិភពលោកគឺតែមួយ។ ដូច្នេះ អ្វីៗដែលកើតឡើង គឺដោយសារ អាទិទេព។ ដូច្នេះ ទស្សនវិជ្ជាមជ្ឈជាតុនិយម ជាទស្សនវិជ្ជាដែលឈរលើមូលដ្ឋាននៃសណ្តាប់ធ្នាប់ធម្មជាតិ និងព្រហ្មលិខិតដែលព្រះបានចារមករួចស្រេចហើយ[៧]។ នៅសតវត្សរ៍ទី១៤ទស្សនវិទូ(បស្ចិមប្រទេស)ជាច្រើន បានមើលឃើញថា ប្រវត្តិសាស្ត្រប្រែប្រួលឡើងចុះបែបវដ្តចលនា រដ្ឋាភិបាលល្អច្រើនមានអាយុកាលមិនយូរប៉ុន្មានវាក៏នឹងចេះតែចុះខ្សោយបន្តិចម្តងៗ ហើយវិវត្តក្លាយទៅជារបបផ្តាច់ការ ប៉ុន្តែ របបផ្តាច់ការក៏មានអាយុកាលមិនយូរដែរ គឺនៅពេលឈានដល់ចំណុចមួយ វាត្រូវតែមានការផ្លាស់ប្តូរសង្គម ដោយប្រែប្រួល បន្តិចម្តងៗក្លាយទៅជា រដ្ឋាភិបាលល្អវិញ ដំណើរបែបនេះចេះតែវិលវល់ចុះឡើងៗ។

ដូច្នេះតាំងពីសម័យបុរាណរហូតដល់សតវត្សរ៍ទី១៤ អំណាចគ្រប់គ្រងរដ្ឋ គឺជា អំណាចរបស់អាទិទេព ដែលមានព្រះមហាក្សត្រ ឬ ស្តេច ជាតំណាងអំណាចបែបនេះគឺជាអំណាចផ្តាច់ការនៅក្នុងសង្គមនាសម័យនោះព្រោះតែអំណាចស្ថិតនៅក្នុងកណ្តាប់ដៃរបស់បុគ្គលតែម្នាក់។ ទន្ទឹមមនឹងនេះសាសនាចាប់ផ្តើមដើរតួនាទីយ៉ាងសំខាន់នៅក្នុងសង្គម តាមរយៈព្រះវិហារ ដែលជាស្ថាប័នសង្គមក្នុងការផ្តល់ចំណេះដឹង។

នៅប្រទេសអង់គ្លេស ក្នុងពាក់កណ្តាលសតវត្សទី១៧ (១៦៤០-១៦៦០) បដិវត្តន៍គហបតី (bourgeols revolution) មួយបានកើតមានឡើង។ បដិវត្តន៍នេះ ជាការតស៊ូរបស់ពួកនាយទុន និង ពួកអភិជនថ្មីដើម្បី ប្រឆាំងនឹងរាជានិយម ប្រឆាំងនឹងការគ្រប់គ្រងសង្កត់របស់ព្រះវិហារពិសេស ប្រឆាំងនឹងទ្រឹស្តីថាអំណាចរដ្ឋកើតចេញពីអាទិទេព[៨]។

---

[៧]ហង់ជួន ណារ៉ុន៖ *សិក្សាសង្ខេបស្តីពី ទស្សនវិជ្ជា* ភ្នំពេញ, បោះពុម្ពផ្សាយស៊ីប៉ា ឆ្នាំ២០១៨ ទំព័រ៥៥

[៨]កា ម៉ាធុល៖ *ប្រវត្តិគំនិតនយោបាយ* ដ.ឯ.ម ទំព័រ២៥៧

### ១.៣.១.ទស្សនៈលោក John Lock

លោក John Locke ត្រូវបានគេយល់ថា ឃើញថា ជាអ្នកសេរីនិយមមុនគេបង្អស់ ហើយជាបិតានៃទស្សនៈនយោបាយទំនើប។ John Locke បានលើកឡើងថា ប្រជាពលរដ្ឋមានសិទ្ធិ មុនការកកើតរដ្ឋាភិបាលទៅទៀត ដែលនាំឱ្យយើងហៅថា សិទ្ធិពីកំណើត។ យើងអាចមានសិទ្ធិនេះដោយមិនចាំបាច់មានរដ្ឋាភិបាល ប៉ុន្តែរដ្ឋាភិបាលដើរតួជាប្រព័ន្ធដ៏សកម្មមួយក្នុងការការពារសិទ្ធិទាំងនេះ។ ហើយក្នុងករណីដែល រដ្ឋាភិបាលបំពានលើកាតព្វកិច្ចនេះ ប្រជាពលរដ្ឋមានសិទ្ធិធ្វើបដិវត្តន៍ដ៏សមស្របមួយ។តំណាងរាស្ត្រ គឺជា អ្នកត្រួតពិនិត្យម្នាក់ដែលធានាឱ្យរដ្ឋាភិបាលគោរព និង ប្រតិបត្តិតាម គំរោងផែនការ ត្រឹមត្រូវរបស់ខ្លួន ដោយឆ្លុះបញ្ចាំងនឹងទស្សនៈ ទំនៀមទំលាប់ ដែលបានចាក់ឫសអស់ជាច្រើនសតវត្សនៅលោកខាងលិច។ Locke បានសរសេរថា រដ្ឋាភិបាលពុំមានសិទ្ធិធ្វើអ្វីតាមតែអំពើចិត្តនេះទេ ច្បាប់ធម្មជាតិបានកំណត់ យើងដាក់លាក់សំរាប់បុគ្គលគ្រប់រូប និង សមាជិកសភា រួមទាំងអ្នកដទៃទៀត[៩]។

តាម John Locke អំណាចរដ្ឋ គួរបំបែកឱ្យមានជាពីរផ្នែកដោយមួយផ្នែកជាអំណាចធ្វើច្បាប់ (Legislative Power) ដែលកាន់កាប់ដោយសភាទាំងពីរ និងមួយផ្នែកទៀតជាអំណាចនីតិប្រតិបត្តិ (Executive Power) ដែលកាន់កាប់ដោយព្រះមហាក្សត្រ។ ទ្រឹស្តីរបស់គាត់ត្រូវបានវិនិយោគដើម្បីធ្វើយុត្តិកម្មលើការលេចឡើងនូវអំណាចរដ្ឋពីរត្រួតលើគ្នា រវាងព្រះមហាក្សត្រ និង រដ្ឋសភា។ កាលនោះ John Locke មិនបានទទួលស្គាល់ឲ្យមានអំណាចតុលាការ ជាអំណាចបំបែកទី៣ទេ ពីព្រោះគាត់ចាត់ទុកតុលាការគ្រាន់តែជាផ្នែកមួយរបស់អំណាចនីតិប្រតិបត្តិតែប៉ុណ្ណោះ ប៉ុន្តែគាត់បានកំណត់ថា ចៅក្រមកាត់ក្តីត្រូវមានស្មារតីឯករាជ្យ[១០]។

John Locke បានញែកអំណាចជាបីរួមមាន អំណាចនីតិបញ្ញត្តិ ជាអំណាចមិនជាប់លាប់ ពីព្រោះវាមិនចាំបាច់ធ្វើច្បាប់ ជានិច្ចកាលនោះទេ។ អំណាចនីតិបញ្ញត្តិនេះ ត្រូវកាន់កាប់ដោយសភាមួយដែលប្រជុំគ្នា តាមកាលវេលា។ សភានេះ មិនប្រតិបត្តិច្បាប់ទេ។ អំណាចនីតិប្រតិបត្តិ ជាអំណាចជាប់លាប់ ពីព្រោះវាជាការចាំបាច់ដែលត្រូវ ប្រតិបត្តិច្បាប់នោះ។ អំណាចនីតិប្រតិបត្តិនេះត្រូវការកាប់ ដោយអង្គការផ្សេងពីអង្គការដែលកាន់អំណាចនីតិបញ្ញត្តិ និង អំណាចសហព័ន្ធ ឬ អំណាចដឹកនាំទំនាក់ទំនងអន្តរជាតិ ចុះសន្ធិសញ្ញាប្រកាសសង្គ្រាម ឫសន្តិភាព។ អំណាចនេះកាន់កាប់ ដោយអ្នកកាន់អំណាចនីតិប្រតិបត្តិ[១១]។

---

[៩]ដេវីត បូស(David Boaz)៖ ***សេរីនិយម*** ភ្នំពេញ, ឆ្នាំ ២០០៧ ទំព័រ៦២

[១០]ហោ ប៉េង៖ ***នីតិរដ្ឋធម្មនុញ្ញប្រៀបធៀប*** ភ្នំពេញ, ឆ្នាំ២០២១ ទំព័រ៤២

[១១]លី គឹមសុខ៖ ***គំនិតនយោបាយ*** ជ.ឯ.ម ទំព័រ២៦

## ១.៣.២.ឧស្សនៈលោក Montesquieu

ក្រោយមកលោក Montesquieu បានរៀបចំធ្វើនិយ័តកម្ម បន្ថែមទ្រឹស្តីរបស់ Locke ឱ្យកាន់តែមានភាពច្បាស់លាស់ និងសុក្រឹត ដោយបានពង្រីកនូវ ការបែងចែកអំណាចដាក់ឱ្យមានជាបីផ្នែកគឺ អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ ក្នុងអ្វីដែលគាត់បានអះអាងថាការធ្វើបែបនេះអាចធានាឱ្យមានរដ្ឋទំនើបមួយដែលមិន មានការបំពានអំណាច បំពានសិទ្ធិសេរីភាពរបស់ពលរដ្ឋ និងការពារកុំឲ្យអំណាចនៅរួមផ្តុំតែមួយ ដែលធ្វើឲ្យមានភាពផ្តាច់ការ[១២]។ របបផ្តាច់ការនិយម ( Despotism ) ជារបបគ្រប់គ្រងដែលដឹកនាំ និង ត្រួតពិនិត្យ ដោយបុគ្គលម្នាក់ជា ប្រជាហឹង្សា( ជាដែលមាន absolute authority ) ហើយការដឹកនាំរបស់បុគ្គលនោះ មិនលំដាប់តាមច្បាប់ និង គ្មានវិធានអ្វីទាំងអស់។ ទម្រង់នេះខុសពីរាជានិយមត្រង់ថា វាមិនគោរព ច្បាប់ និងប្រើអំណាចផ្តាច់ការ។ របបផ្តាច់ការនិយម despotism គឺជារបប ដែលពឹងផ្អែកលើគោលការណ៍ តណ្ហា និង ជាទម្រង់រដ្ឋប្រភេទមិនត្រឹមត្រូវ។គោលការណ៍របស់វាគឺការភ័យខ្លាច និង ការគោរពដោយគ្មានការតវ៉ាចំពោះអ្នកដែលចង់បានលោភលន់ត្រួតត្រា[១៣]។ លោកបន្ថែមទៀតថា រាជានិយមក៏អាចក្លាយទៅជារបបផ្តាច់ការបានដែរ នៅពេលឯករាជ្យភាពនឹងឯកសិទ្ធិរបស់បុគ្គល និងអង្គការនានាមិនត្រូវបានគោរព។ ដើម្បីធានាឱ្យបាននូវការគោរពនេះលោក ម៉ុងតេស្គីយើ បានរៀបចំ ឲ្យមានជាយន្តការពីរផ្សេងទៀត សម្រាប់បំពេញបន្ថែម ក្នុងការរៀបចំអំណាចរដ្ឋ។ យន្តការនោះលោកហៅថា ទ្រឹស្តីនៃការបែងចែកអំណាច។ ក្នុងទ្រឹស្តីនៃការបែងចែកអំណាចនេះលោកចែកចេញជាពីរប្រភេទទៅទៀត ទ្រឹស្តីនៃការបែងចែកអំណាចបញ្ឈប់ និង ទ្រឹស្តីនៃការបែងចែកអំណាចផ្តេក។

លោកបញ្ជាក់ទៀតថា ដើម្បីឱ្យមានស្ថេរភាពក្នុងសាធារណរដ្ឋ ក៏ ដូចជានៅក្នុងរាជនិយម ចាំបាច់ត្រូវតែមានការបែងចែកអំណាចរដ្ឋព្រោះថា ការបែងចែកអំណាចរដ្ឋ អាចធ្វើឱ្យសមាជិកនៃសង្គមទទួលបាននូវសេរីភាព សុវត្ថិភាព យុត្តិធម៌ ពិសេសគឺស្ថេរភាពសង្គមតែម្តង។ ក្នុងទ្រឹស្តីនៃការបែងចែកអំណាចបញ្ឈរ លោកតម្រូវឱ្យមានជាអង្គកណ្តាលមួយ ដែលស្ថិតនៅចន្លោះស្តេចនិងប្រជារាស្ត្រ។ អង្គកណ្តាលនេះលោករៀបរៀងឡើង ក្នុងគោលបំណងប្រឆាំងនឹង របបផ្តាច់ការ របស់រាជាធិបតេយ្យផ្តាច់ការ ( absolute monarchy ) អង្គនេះរៀបចំឡើងដើម្បីឱ្យអំណាចរបស់ស្តេចមានព្រំដែន មានរបាំង ជាន់ក្រោម។ តែទ្រឹស្តីនេះមិនអាចមានប្រសិទ្ធិភាពឡើយ ប្រសិនបើ មិនមានការចូលរួមពីសំណាក់ទ្រឹស្តីនៃការបែងចែកអំណាច

---

[១២]ហោ ប៉េង៖ ***នីតិរដ្ឋធម្មនុញ្ញប្រៀបធៀប*** ដ.ឯ.ម ទំព័រ៤២

[១៣]កា ម៉ាធុល៖ ***ប្រវត្តិគំនិតនយោបាយ*** ដ.ឯ.ម ទំព័រ២៣៤

ផ្ដេកទេនោះ និង ជាកម្លាំងសម្រាប់ទប់ទល់នឹងអំណាចស្ដេច សម្រាប់ការពារស្ថាប័ននៅក្នុងទ្រឹស្ដីនៃការបែងចែកអំណាចផ្ដេក លោកម៉ុនតេស្គីយើ បានចែកអំណាចនៅក្នុងរដ្ឋចេញជាបីយ៉ាងគឺ អំណាចនីតិបញ្ញត្តិជាអំណាចធ្វើច្បាប់ កែច្បាប់និងលុបច្បាប់។ អំណាចនីតិបញ្ញត្តិ ត្រូវប្រគល់ទៅឱ្យសភាពីរជាអ្នកកាន់កាប់ សភារបស់អភិជន (សភាជាន់ខ្ពស់) និងសភារបស់ប្រជារាស្ត្រ(សភាជាន់ទាប)។ ក្រៅពីបង្កើតនិងលុបច្បាប់ អំណាចនេះនៅមាននាទីជាអ្នកតាមដានត្រួតពិនិត្យការប្រតិបត្តិរបស់ព្រះរាជា និងមាននាទីជាអ្នកកាត់ក្ដី វិនិច្ឆ័យទៅលើសកម្មភាពប្រតិបត្តិក្នុងសង្គមទាំងមូល។

អំណាចនីតិប្រតិបត្តិ ជាអំណាចប្រតិបត្តិតាមឆន្ទៈរបស់អំណាចនីតិបញ្ញត្តិ សម្រាប់រៀបចំដឹកនាំសង្គមទាំងផ្ទៃក្នុងប្រទេសទាំងលើឆាកអន្តរជាតិ។ ជាអំណាចដែលមានសិទ្ធិប្រកាសសង្គ្រាមនិងសន្តិភាព។ អំណាចនេះមានបង្កប់នូវចរឹកជាអំណាចនៃច្បាប់អន្តរជាតិផងដែរ តាមនីតិវិធីនៃសិទ្ធិរបស់ប្រធាន(ស្ដេច)។

អំណាចតុលាការ ជាអំណាចវិនិច្ឆ័យដែលត្រូវបានប្រើប្រាស់នៅក្នុងក្របខណ្ឌនៃច្បាប់រដ្ឋប្បវេណី។ អំណាចនេះត្រូវប្រគល់ឱ្យទៅសភាតាម ខេត្ត ក្រុងនីមួយៗ ដែលកាន់កាប់តុលាការជាន់ខ្ពស់។ លោកបានលើកបញ្ហាប្រទេសអង់គ្លេសមកបញ្ជាក់ជាគំរូថា នៅអង់គ្លេសអំណាចនីតិបញ្ញត្តិជាអំណាចរបស់សភា អំណាចនីតិប្រតិបត្តិជាអំណាចរបស់ព្រះមហាក្សត្រ និង អំណាចតុលាការជា អំណាចរបស់ក្រុមប្រឹក្សាតុលាការ។

គោលការណ៍នៃការបែងចែកអំណាចនេះ ធ្វើឡើងក្នុងគោលបំណងទប់ស្កាត់មិនឱ្យអំណាចដែលស្ថិតក្នុងដៃរបស់បុគ្គលណាម្នាក់នេះអាចនឹង នាំទៅរកក្ដីវិនាសដល់ប្រទេសជាតិបាន។ ដើម្បីឱ្យទ្រឹស្ដីក្នុងការបែងចែកនេះមានដំណើរការចាំបាច់ត្រូវឱ្យអំណាចនីមួយៗ អាចទប់ស្កាត់ដំណើរនៃអំណាចមួយផ្សេងទៀត ដំណើរការតាមរូបភាពជាប្រព័ន្ធទាញ និង ទប់ទម្ងន់ ដើម្បីរក្សានូវតុល្យភាពនៃអំណាចទាំងបី។

គោលដៅនៃគោលការណ៍នៃការបែងចែកអំណាចនេះធ្វើឡើង ដើម្បីប្រឆាំងនឹងរបបរាជានិយមផ្ដាច់ការ ហើយសម្របសម្រួលទំនាស់រវាង របបមូលធននិយម និងពួកអភិជននិងការគ្រោងទុកជាមុន ដើម្បីការពារ គ្រោះថ្នាក់ ជៀសវាងការដណ្ដើមយកអំណាចផ្ដាច់មុខ ព្រោះលោកយល់ថា សារជាតិរបស់មនុស្ស បើកាលណាបានអំណាចនៅក្នុងដៃរបស់ខ្លួនហើយ មនុស្សនោះតស៊ូដើម្បីរក្សាអំណាចនេះលុះដំណាក់កាលឈាមចុងក្រោយ[១៤]។

[១៤] កា ម៉ាធុល៖ *ប្រវត្តិគំនិតនយោបាយ* ដ.ឯ.ម ទំព័រ២៤០

## ១.៤.ការបែងចែកអំណាចនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា

របបនាសម្ព័ន្ធនៃរបបរាជានិយមនៅកម្ពុជា មានប្រភពតាំងពីយូរលង់ ណាស់មកហើយពីអរិយធម៌ ឥណ្ឌាបូរាណក្សត្រ ដែលមានន័យថា "ម្ចាស់ទឹកដី" ដោយផ្ដើមចេញពីទស្សនៈ «មេនិយម» របស់ជនជាតិខ្មែរ បូរាណតាំងពីយូរលង់ណាស់មកហើយ គេបានលើកព្រះនាងនាគី (ព្រះនាងសោមា) ឱ្យធ្វើជាស្ដេចដឹកនាំនគរ នៅក្នុងសតវត្សរ៍ទី១ នៃគ្រិស្តសករាជ។

ព្រះរាជាខ្មែរនាសម័យដើម គឺជាប្រមុខរដ្ឋ និង ជាមេទ័ព។ នៅពេលធ្វើសង្គ្រាម ម្ដងៗគឺព្រះអង្គជា អ្នកដែលត្រូវដឹកនាំទ័ពទៅប្រឈមមុខជាមួយសត្រូវលើគ្រប់សមរភូមិ។ សិលាចារឹកបានបង្ហាញឱ្យឃើញ វិរៈភាពរបស់ព្រះរាជានៅលើសមរភូមិ ឬ ក្នុងនាមជាអ្នក រំដោះទឹកដី អ្នកការពារបូរណភាពទឹកដី និង ជា អ្នកផ្សព្វផ្សាយនូវព្រហ្មវិហារធម៌ចំពោះពួក នាហ្មឺន មន្ត្រី ចំពោះប្រជារាស្ត្រជាកូនចៅរបស់ព្រះអង្គ។

មានអង្គព្រះមហាក្សត្រខ្មែរខ្លះក៏ត្រូវបានគេចាត់ទុកដូចជាស្ដេចចក្រវាឡ ដូចជា ព្រះ បាទជ័យវរ្ម័ន ទី២ ព្រះបាទជ័យវរ្ម័នទី៧ ។ អំពីសារៈសំខាន់របស់ព្រះមហាក្សត្រ យើងក៏អាច ដឹងទៀតថា ក្នុងទស្សនៈ យល់ឃើញរបស់របស់ប្រជារាស្ត្រ ស្ដេច គឺជាអ្នកមានសិទ្ធិផ្ដាច់មុខ។ តាមឯកសាររបស់លោក **ជីវ តាខ្វាន** បាននិយាយថា ព្រះមហាក្សត្រជាបុគ្គលដែលមានអំណាចយ៉ាងលើសលប់ មានការស្នាក់នៅទីកន្លែងយ៉ាង ធំទូលាយដែលធ្វើអំពីឈើ ហើយព័ទ្ធជុំវិញដោយទាសារទាសីជាច្រើនពាន់នាក់មន្ត្រីបរិវារ និងអ្នកជំនិត។ ឯកសាររបស់លោកជីវ តាខ្វាន់ បានសរសេរផងដែរថា មានកីលាងសំរាប់ព្រះអង្គជាង៥,០០០នាក់ និងស្រី ស្នំបានរស់នៅក្នុងព្រះរាជវាំង។ ស្ដេចនៅក្នុងសម័យនោះមានមហេសីជាផ្លូវការ ៥ ព្រះអង្គ។

គួរស្វែងយល់ផងដែរអំពីកាលប្បវត្តិ នៃរបបរាជានិយមខ្មែរពីសតវត្សរ៍ទី១ ដល់សតវត្សរ៍ទី១៤ គឺជា របបរាជានិយមផ្ដាច់ការ ព្រះរាជា ជា តំណាងឱ្យព្រះអាទិទេព។ វត្ថុជានិមិត្តរូបទេវរាជ គឺ លឹង្គព្រះឥសូរ ដែលគេ តម្កល់លើ ប្រាសាទភ្នំជាតំណាងភ្នំព្រះសុមេរុ ។ ពីសតវត្សរ៍ទី១៥ ដល់សតវត្សរ៍ទី២០ គឺជារបប រាជានិយមជ្រើសរើសមានអន្តរាគមន៍របស់ពួកមន្ត្រីធំៗក្នុងការជ្រើសរើសព្រះមហាក្សត្រថ្មី សោយរាជ្យជា តំណាងវង្ស។ ចាប់តាំងពីពាក់កណ្ដាលសតវត្សរ៍ទី២០ មករបបរាជានិយមនៅកម្ពុជាអនុវត្តតាមរបបរាជា និយមអាស្រ័យរដ្ឋធម្មនុញ្ញ[១៥]។

នៅថ្ងៃទី៦ ឧសភា ឆ្នាំ១៩៤៧ រដ្ឋធម្មនុញ្ញ លើកដំបូងបង្អស់ ប្រទេសកម្ពុជា បានត្រូវប្រកាសឱ្យប្រើ នៅថ្ងៃនោះហើយ ដែលប្រទេសកម្ពុជាបានប្ដូរពីរបបរាជានិយម (ទេវរាជ មកជា របបរាជានិយមអាស្រ័យ

[១៥]ត្រឹង ងារ៖ ***អរិយធម៌ខ្មែរ*** ភ្នំពេញ, ឆ្នាំ១៩៧៥ ទំព័រ១១៥-១១៦។

រដ្ឋធម្មនុញ្ញ។ រដ្ឋធម្មនុញ្ញថ្ងៃទី៦ ឧសភា ឆ្នាំ១៩៤៧ មានលក្ខណៈប្រហាក់ប្រហែល រដ្ឋធម្មនុញ្ញសាធារណៈរដ្ឋទី៤ របស់បារាំង អំណាចធ្លាក់ទៅក្នុងកណ្តាប់ដៃសភាទាំងស្រុង ពោលគឺ ប្រព័ន្ធសភា២ ( système du bicamérisme ) រួមមានរដ្ឋសភានិងព្រឹទ្ធសភាដែលមានឈ្មោះថា ក្រុមប្រឹក្សារាជាណាចក្រ[១៦]។ ក្រុមប្រឹក្សាព្រះរាជាអាណាចក្រពិនិត្យឱ្យយោបល់អំពីសេចក្តីព្រាងនឹងសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រមមួយលើកដំបូងរួចហើយព្រមទាំងអំពីបញ្ហាទាំងពួងដែលរដ្ឋាភិបាលបានដាក់ឱ្យពិនិត្យ[១៧]។

អំណាចគ្រប់យ៉ាងមកពីព្រះមហាក្សត្រិយ៍។ អំណាចទាំងនោះត្រូវទៅតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញនេះ[១៨]។ រដ្ឋសភាជាអ្នកប្រើអំណាចនីតិបញ្ញត្តិក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍។ អ្នកដែលមានសិទ្ធិផ្តើមគំនិតតែងច្បាប់នោះ ព្រះមហាក្សត្រិយ៍ រដ្ឋមន្ត្រីសមាជិកនៃរដ្ឋសភា នឹងសមាជិកនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ[១៩]។ គណៈរដ្ឋមន្ត្រីជាអ្នកប្រើអំណាចនីតិប្រតិបត្តិក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍[២០]។ សាលាជំរះក្តីគ្រប់ជាន់គ្រប់ប៉ែក ជាអ្នកប្រើអំណាចតុលាការ ក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍[២១]។ ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការត្រូវប្រព្រឹត្តតាមបញ្ញត្តិច្បាប់ ដើម្បីឱ្យចៅក្រមទាំងឡាយរក្សាវិន័យ នឹងប្រតិបត្តិការជាឯកច្ឆន្ទបាន។ ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការមានសមាជិកដូចតទៅនេះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាអធិបតី សមាជិកពីររូបដែលព្រះមហាក្សត្រិយ៍ទ្រង់ចាត់តាំង សមាជិកពីររូបដែលរដ្ឋសភាជ្រើសតាំង សមាជិកពីររូបដែលតុលាការទាំងឡាយជ្រើសតាំង[២២]។

ព្រឹត្តិការណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ បាននាំឱ្យប្រទេសកម្ពុជា ប្រកាន់យក របបសារធារណរដ្ឋជំនួសរបបរាជានិយមវិញ។ ការប្រកាស ដាក់ប្រទេសកម្ពុជា ជាសារធារណរដ្ឋបានប្រព្រឹត្តទៅនៅថ្ងៃទី៩ ខែ

---

[១៦] វ៉ាន់ ឱកាអុនៈ *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា* ភ្នំពេញ, ឆ្នាំ២០០៨ ភាគទី១ ទំព័រ៨៦។

[១៧] រដ្ឋធម្មនុញ្ញខ្មែរឆ្នាំ១៩៤៧-ដ- មាត្រា៧៨។

[១៨] -ដ- មាត្រា២១។

[១៩] -ដ- មាត្រា២២។

[២០] -ដ- មាត្រា២៣។

[២១] -ដ-មាត្រា២៤។

[២២] រដ្ឋធម្មនុញ្ញខ្មែរឆ្នាំ១៩៤៧ មាត្រា៩៦។

តុលា ឆ្នាំ១៩៧៦ តាមច្បាប់ធម្មនុញ្ញលេខ៤៤២/៧០ប.រ.ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៧០។ ស្ថាប័នគ្រប់គ្រងរដ្ឋទាំងឡាយនៅបន្តគ្រប់គ្រងជាបណ្តោះអាសន្ន លើកលែងតែស្ថាប័នព្រះមហាក្សត្រត្រូវលុបចោល ហើយតំណែងប្រមុខរដ្ឋត្រូវ ជំនួសដោយលោក ចេង ហេង ដែលជាប្រធានរដ្ឋសភា។ លោក អ៊ិន តាំ បានទទួលតំណែងជាប្រធានរដ្ឋសភា និងលោកសេនាប្រមុខ លន់ ណុល ជានាយករដ្ឋមន្ត្រីដដែល។ ការប្រកាន់យករបបសាធារណរដ្ឋតម្រូវឱ្យមានការរៀបចំរដ្ឋធម្មនុញ្ញថ្មីមួយសម្រាប់ប្រទេសកម្ពុជា[២៣]។

អំណាចគ្រប់យ៉ាងចេញមកពីប្រជារាស្ត្រ។ អំណាចនីតិប្រតិបត្តិ អំណាចនីតិបញ្ញត្តិ និង អំណាចតុលាការត្រូវអនុវត្តតាមបទបញ្ញត្តិនៃបច្ចុប្បន្នរដ្ឋធម្មនុញ្ញ[២៤]។ រដ្ឋរ៉ាប់រងចំពោះពលរដ្ឋទាំងអស់នូវសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។ ប្រធានាធិបតីនៃសាធារណរដ្ឋ ប្រើអំណាចនីតិប្រតិបត្តិ ដែលប្រជារាស្ត្រប្រគល់ជូនលោក[២៥]។

អំណាចតុលាការជាអំណាចប្រកបដោយឥស្សរភាព អំណាចតុលាការរក្សាការពារអនាគតិ អំណាចតុលាការការពារសិទ្ធិនិងសេរីភាពពលរដ្ឋ ។ អំណាចនេះត្រូវប្រគល់ទៅតុលាការកំពូលនិងទៅសាលាជំរះក្តីគ្រប់ជាន់ថ្នាក់[២៦]។

តាមរដ្ឋធម្មនុញ្ញរបស់របបកម្ពុជាប្រជាធិបតេយ្យ បានធ្វើការបេង ចែកអំណាចជាបី ហើយអំណាចបានចែងក្នុងជំពូកនីមួយៗដាច់ៗពីគ្នា។ អំណាចធ្វើច្បាប់ អង្គការអនុវត្តច្បាប់ និង អំណាចតុលាការ។

នៅក្នុងជំពូក៥ មានបីមាត្រា បានចែងពីអំណាចធ្វើច្បាប់ជារបស់សភាតំណាងប្រជាជន កម្មករកសិករនិងពលករកម្ពុជាផ្សេងទៀតទាំងអស់។ សភារបស់កម្ពុជាប្រជាធិបតេយ្យមានតែមួយថ្នាក់ទេ ហើយឈ្មោះ ជាផ្លូវការ គឺ សភាតំណាងប្រជាជនកម្ពុជាដែលមានសមាជិក២៥០នាក់ ក្នុងនោះតំណាងឱ្យកសិករ១៥០នាក់តំណាងឱ្យកម្មករនិងពលករផ្សេងៗ ទៀត៥០នាក់ និងតំណាងឱ្យកងទ័ពបដិវត្ត៥០នាក់។

សភាតំណាងប្រជាជនកម្ពុជាត្រូវបានប្រជាជនជ្រើសតាំងឡើង ដោយការបោះឆ្នោតទូទាំងប្រទេសដោយផ្ទាល់ និងដោយសម្ងាត់ក្នុងរយៈពេល៥ឆ្នាំម្តង។ សភាតំណាងប្រជាជនកម្ពុជាមានភារកិច្ចសម្រេច

---

[២៣] សេង ប៊ុនធឿន៖ ***រដ្ឋធម្មនុញ្ញ និង ការផ្លាស់ប្តូររបបនយោបាយនៅកម្ពុជា*** ភ្នំពេញ, ឆ្នាំ២០១៥ ទំព័រ៦៤។

[២៤] រដ្ឋធម្មនុញ្ញខ្មែរឆ្នាំ១៩៧២ មាត្រា៣។

[២៥] -ដ- មាត្រា២៣។

[២៦] -ដ-មាត្រា៨១។

ច្បាប់ និង កំណត់មាគ៌ានយោបាយផ្សេងៗ ក្នុងប្រទេស និង ក្រៅប្រទេស។ សភា នេះមានតួនាទី និងមុខងារផងដែរ ក្នុងការជ្រើសរើស និងតែងតាំង តុលាការគ្រប់ជាន់ថ្នាក់។ សភាតំណាងប្រជាជនកម្ពុជាក៏ត្រូវជ្រើសតាំងរដ្ឋាភិបាលផងដែរព្រមជាមួយគ្នានេះសភាក៏ត្រូវជ្រើសតាំងគណៈប្រធាន រដ្ឋមួយសម្រាប់រយៈពេល៥ឆ្នាំម្តង។

រដ្ឋាភិបាលជាអង្គការមានភារកិច្ចអនុវត្តច្បាប់ និងអនុវត្តមាគ៌ានយោបាយទាំងអស់របស់សភាតំណាងប្រជាជនកម្ពុជាហើយទទួលខុសត្រូវទាំងស្រុងចំពោះមុខសភាតំណាងប្រជាជនកម្ពុជា ក្នុងកិច្ចដំណើរការទាំងអស់របស់ខ្លួនទាំងក្នុង និងក្រៅប្រទេស[២៧]។

ក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ មាត្រា៩ ចែងថា តុលាការជារបស់ប្រជាជន តំណាងយុត្តិធម៌របស់ប្រជាជន ការពារយុត្តិធម៌ សិទ្ធិ សេរីភាព ប្រជាធិបតេយ្យ ហើយផ្តន្ទាទោសគ្រប់សកម្មភាពប្រឆាំងនឹងរដ្ឋ របស់ប្រជាជន ឬ ដែលល្មើសនឹងច្បាប់រដ្ឋរបស់ប្រជាជន។ ក្នុងមាត្រា១០ នៃរដ្ឋធម្មនុញ្ញចែងអំពីប្រភេទល្មើសច្បាប់រដ្ឋប្រជាជនមាន២ចំណុចសំខាន់ៗ គឺប្រភេទសកម្មភាពប្រឆាំង និងបំផ្លិចបំផ្លាញដែលមានលក្ខណៈជាខ្សែសង្វាក់ ហើយគ្រោះថ្នាក់ដល់ប្រជាជនត្រូវទទួលទោសកម្រិតខ្ពស់បំផុត ហើយប្រភេទល្មើសក្រៅពីប្រភេទខាងលើត្រូវអប់រំ កសាងក្របខណ្ឌអង្គការរដ្ឋ ឬ អង្គការប្រជាជន។

ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៨១ ប្រជុំពេញអង្គលើកដំបូងបង្អស់នៃរដ្ឋសភានៃសាធារណរដ្ឋប្រជាមា-និតកម្ពុជា។ លោក ជា ស៊ីម ត្រូវបានតែងតាំងជាប្រធានរដ្ឋសភា លោក ហេង សំរិន ត្រូវបានតែងតាំងជាប្រធាន ក្រុមប្រឹក្សារដ្ឋ និងលោក ប៉ែន សុវណ្ណ ជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី (រដ្ឋមន្ត្រីទី១ ឬនាយករដ្ឋមន្ត្រី)។ ថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៩៨១ ការចេញផ្សាយរដ្ឋធម្មនុញ្ញនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា[២៨]។

យោងតាមមាត្រា២ បានចែងថា ប្រជាជនកម្ពុជា ជាម្ចាស់វាសនានៃប្រទេសរបស់ខ្លួន អំណាចទាំងអស់ជារបស់ប្រជាជន។ ប្រជាជនប្រើរដ្ឋអំណាច តាមរយៈរដ្ឋសភា និង អង្គការរដ្ឋអំណាចនានា ដែលប្រជាជនជ្រើសតាំងឡើង និងទទួលខុសត្រូវចំពោះប្រជាជន។ រដ្ឋសភា ជាអង្គការតែមួយគត់ដែលមានសិទ្ធិធ្វើច្បាប់[២៩]។

---

[២៧] រដ្ឋធម្មនុញ្ញខ្មែរឆ្នាំ១៩៧៦ មាត្រា៨។

[២៨] សេង ប៊ុនធឿន៖ *រដ្ឋធម្មនុញ្ញ និង ការផ្លាស់ប្តូររបបនយោបាយនៅកម្ពុជា* ដ.ឯ.ម ទំព័រ១៣៥។

[២៩] រដ្ឋធម្មនុញ្ញខ្មែរឆ្នាំ១៩៧៦ មាត្រា៤៥។

តុលាការប្រជាជន និងតុលាការយោធាជាអង្គការជំនុំជំរះនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។ រដ្ឋអាជ្ញាអមសាលាជំរះក្តីធ្វើការចោទប្រកាន់ប្តឹងទៅតុលាការតាមច្បាប់ ជានាការប្តឹងទៅតុលាការ ការជំនុំជំរះ និងការអនុវត្តន៍សាលក្រមឱ្យបានត្រឹមត្រូវ និងស្របច្បាប់[៣០]។

ក្រោយបិទបញ្ចប់ទំព័រប្រវត្តិសាស្រ្តនៃសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជាជាង ៣ទសវត្សរ៍កន្លងមក និងក្រោមកិច្ចខិតខំប្រឹងប្រែងស្វះស្វែងរកដំណោះស្រាយនយោបាយរួមរវាងភាគីខ្មែរ និងខ្មែរ តាមរយៈការជួបពិភាក្សាគ្នាច្រើនលើក និងច្រើនទីកន្លែងមានទាំងក្នុងតំបន់អាស៊ី និងអឺរ៉ុប។ ប្រទេសឥណ្ឌូនេស៊ីបានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំការនូវកិច្ចប្រជុំលើទី១ ដែលគេទទួលស្គាល់ថា ជាកិច្ចប្រជុំក្រៅផ្លូវការនៅទីក្រុងហ្សាកាតា( Jakarta Informal Meeting-JIM1 ) នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៨៨ ដែលនៅពេលនោះគ្រប់ភាគីកម្ពុជាបានជួប និងនិយាយទល់មុខគ្នាជាលើទី១។ កិច្ចប្រជុំ (JIM2) ត្រូវបានធ្វើឡើងនៅខែកុម្ភៈ ឆ្នាំ១៩៨៩។ តំណាងរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍( អាស៊ាន )សាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវក៏ត្រូវបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំលើកទី១ និងលើកទី២នេះផងដែរ។ នៅក្នុងខែធ្នូ ឆ្នាំ១៩៨៧ ជាកិច្ចប្រជុំលើកទី២ នៅក្នុងខែមករា ឆ្នាំ១៩៨៨ បន្ទាប់ពីការធ្វើអន្តរាគមន៍អស់រយៈពេលមួយទសវត្សរ៍ ការសម្រុះសម្រួល និងការសន្ទនានយោបាយនានា តាមរយៈការិយាល័យអគ្គលេខាធិការអង្គការសហប្រជាជាតិ **សម្តេច នរោត្តម សីហនុ** បានជួបជាមួយ **សម្តេច ហ៊ុន សែន** ជាលើកដំបូងនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៨៧ នៅហ្វែរអង់តាដឺណ័រ (Fer-en-Tardenois) ប្រទេសបារាំង[៣១]។ ការចរចាបានធ្វើទៅតាមកន្លែងយ៉ាងច្រើនស្ទើរពេញមួយចំហៀងផែនដី ដែលក្នុងនោះមានបារាំង ថៃ ឥណ្ឌូនេស៊ី ចិន ជប៉ុន និង ញូវយ៉ក[៣២] ក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា ហៅកាត់ថា អ៊ុនតាក់ (UNTAC) ត្រូវបានបង្កើតឡើងដោយមានទាំងផ្នែកយោធា និងផ្នែកស៊ីវិល ដើម្បីរៀបចំការអនុវត្តកិច្ចព្រម

---

[៣០] -ដ- មាត្រា៨០។

[៣១] គិន ភា៖ *រដ្ឋសភាកម្ពុជានិងការអនុវត្តគោលការណ៍បែងចែកអំណាច(១៩៩៣២០០៨)* និក្ខេបបទថ្នាក់បណ្ឌិតវិទ្យាសាស្រ្តនយោបាយ រាជបណ្ឌិត្យសភាកម្ពុជា ភ្នំពេញ ឆ្នាំ២០១១ ទំព័រ១០៥។

[៣២] ហ៊ុន សែន៖ *សុន្ទរកថាក្នុងពិធីបិទសន្និសីទជាតិស្តីពីសន្តិភាព ការបង្រួបបង្រួមជាតិ និង ការកសាងលទ្ធិប្រជាធិបតេយ្យ១០ឆ្នាំក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១។*

ព្រៀងសន្តិភាពនេះ។ តួនាទីដ៏ចម្បងរបស់ UNTAC គឺការរៀបចំឱ្យមានការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា ដើម្បីជាការបើកឱកាសឱ្យប្រជាជនកម្ពុជាកំណត់នូវវាសនារបស់ខ្លួនដោយខ្លួនឯង[៣៣]។

ទីបំផុតតាមរយៈអង្គការសហប្រជាជាតិតំណាងដោយអ៊ុនតាក់(UNTAC) បានរៀបចំការបោះឆ្នោតជាសកល ស្មើភាព សេរី សម្ងាត់ និងដោយចំពោះដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៣ ដោយមានគណបក្សនយោបាយខ្មែរចំនួន២០ បានចូលរួមប្រកួតប្រជែងជ្រើសរើសសមាជិកសភាធម្មនុញ្ញដើម្បីតាក់តែងពង្រាងរដ្ឋធម្មនុញ្ញថ្មីមួយឡើង។ ដូច្នោះប្រភពនៃរដ្ឋធម្មនុញជាប្រភពដែលមានឋានានុក្រមខ្ពស់បំផុតក្នុងប្រព័ន្ធច្បាប់ផ្ទៃក្នុង។

រដ្ឋធម្មនុញ្ញគឺជាច្បាប់គោល ឬច្បាប់មូលដ្ឋានរបស់ជាតិបង្កើតបានជាចរិតនិងទស្សនៈរបស់រដ្ឋាភិបាលនៃជាតិ ឬរដ្ឋនោះដាក់ចុះនូវគោលការណ៍ជាមូលដ្ឋានដែលជីវភាពផ្ទៃក្នុងរបស់ជាតិ ឬរដ្ឋនោះត្រូវបានប្រកាន់យកតាមរយៈការរៀបចំរដ្ឋាភិបាលនិងការចាត់ចែង ការបែងចែក និងការកម្រិតមុខងារនៃក្រសួងផ្សេងរបស់រដ្ឋឬរបស់ប្រទេសនោះ ដែលចែកជាបទប្បញ្ញត្តិស្តីពីទំហំនិងរបៀបរៀបរយការអនុវត្តអំណាចអធិបតេយ្យ[៣៤]។

រដ្ឋធម្មនុញ្ញ ជាច្បាប់គោល ច្បាប់គ្រឹះ ច្បាប់កំពូលរបស់រដ្ឋដែលក្នុងនោះ បានបញ្ញត្តិពីគោលការណ៍ធំៗ ដូចជាបញ្ញត្តិអំពីស្ថាប័នប្រមុខរដ្ឋ ឬព្រះមហាក្សត្រ ស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នតុលាការ បញ្ហាសេដ្ឋកិច្ច នយោបាយ សិទ្ធិ និង ករណីយកិច្ចរបស់ប្រជាពលរដ្ឋ និង ការប្រព្រឹត្តិទៅនៃស្ថាប័នរដ្ឋរបស់ប្រទេសមួយជាដើម។ ជាក់ស្តែងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ចែកចេញជា១៦ជំពូកមាន១៥៨មាត្រា ក្នុងនោះទៀតសោតត្រង់ជំពូកទី១១ថ្មីមានចែងអំពីអំណាចតុលាការដោយមាន៨មាត្រាចាប់ពីមាត្រា១២៨ថ្មីដល់មាត្រា១៣៥ថ្មី។បើយើងពិនិត្យទៅលើមាត្រាទាំង៨នៃជំពូកទី១១ថ្មីដែលមានចែងអំពីអំណាចតុលាការ អំណាចតុលាការជាអំណាចឯករាជ្យ[៣៥]។ ដោយមានព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ[៣៦]។ អំណាចតុលាការធានារក្សា អនាគតិ និង ការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ។ អំណាចតុលាការគ្រប ដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផង។ អំណាចនេះត្រូវបានប្រគល់ឱ្យតុលាការកំពូល

---

[៣៣] គិន ភា៖ *រដ្ឋសភាកម្ពុជា និង ការអនុវត្តគោលការណ៍បែងចែកអំណាច(១៩៩៣២០០៨)* ដ.ឯ.ម. ទំព័រ១០៧។

[៣៤] Black's law Dictionary revised 4 edition 1968។

[៣៥] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា១២៨ថ្មី។

[៣៦] -ដ- មាត្រា១៣២ថ្មី។

និង សាលាជម្រះក្តីគ្រប់ផ្នែក និង គ្រប់ជាន់ថ្នាក់[៣៧]។ ដើម្បីធានាទៅដល់សណ្តាប់ធ្នាប់សាធារណៈ មានតែអង្គអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា[៣៨]។ លើសពីនេះទៅទៀតក៏បានកំណត់ទៅលើតួនាទី និង មុខងាររបស់អំណាចតុលាការ ដើម្បីធានាឱ្យមានប្រសិទ្ធិភាពក្នុងការអនុវត្តនូវសិទ្ធិអំណាច និង កាតព្វកិច្ចរបស់តុលាការអោយបានល្អប្រសើរ ក្នុងការរួមចំណែកដល់ការថែក្សាសន្តិសុខសណ្តាប់ធ្នាប់ ការអភិវឌ្ឍន៍ប្រទេសជាតិក៏ដូចជាលើកកម្ពស់ដល់ការគោរពសិទ្ធិមនុស្ស សិទ្ធិប្រជាពលរដ្ឋក្នុងនាមជាប្រទេសហត្ថលេខីនៃកតិការសញ្ញាស្តីពីសិទ្ធិស៊ីវិល និង នយោបាយរបស់អង្គការសហប្រជាជាតិ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់យ៉ាងច្បាស់លាស់អំពីឯករាជ្យនៃអំណាចតុលាការ ហើយបានស្តែងឡើងតាមរូបភាពដូចជា ភាពមិនលំអៀងក្នុងការអារកាត់សេចក្តីទៅតាមច្បាប់ដែលបានកំណត់ដោយធានារក្សាអនាគតិ។ ចៅក្រមជំនុំជម្រះពិនិត្យតែទៅតាមអង្គហេតុជាសត្យានុម័តថាតើមាន ឬ ឥតមានភស្តុតាងគ្រប់គ្រាន់តែប៉ុណ្ណោះ។ គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬ នីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ[៣៩]។ ច្បាស់ណាស់ អំណាចតុលាការមិនចំណុះ អំណាចនីតិបញ្ញត្តិ ឬ អំណាចនីតិប្រតិបត្តិ ឬ អំណាចរបស់គណបក្សនយោបាយណាមួយឡើយ គឺអំណាចតុលាការត្រូវបានធានាដោយរដ្ឋធម្មនុញ្ញដោយមិនអនុញ្ញាតអោយមានការលូកដៃចូលអន្តរាគមន៍ ឬ បញ្ជាដោយផ្ទាល់ក្តី ឬ ប្រយោលក្តីពីស្ថាប័ននីតិបញ្ញត្តិ ឬ ស្ថាប័ននីតិប្រតិបត្តិនោះឡើយ។

## ១.៥.ប្រវត្តិតុលាការកម្ពុជា

កាលពីសម័យអាណាចក្រភ្នំចេនឡា សម័យអង្គរ។ ការដាក់ទោសឬការដាក់ពិន័យទៅលើជនណាម្នាក់វាប្រព្រឹត្តទៅដោយការបើសវនការក្រោមព្រះរាជអធិបតីភាពរបស់ព្រះមហាក្សត្រ គឺអំណាចវិនិច្ឆ័យទោសស្ថិតនៅលើព្រះមហាក្សត្រ ដែលព្រះអង្គជាអ្នកកាន់កាប់អំណាចគ្រប់វិស័យទាំងអស់។ សម័យនោះ ព្រះរាជាមានអំណាចធំធេងណាស់និយាយរួម គឺ អំណាចនីតិបញ្ញាត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការគឺព្រះអង្គជាអ្នកសម្រេច។

ព្រះមហាក្សត្រជាតំណាងឱ្យព្រះអាទិទេព ហេតុនេះព្រះអង្គកាន់អំណាចគ្រប់ប្រភេទទាំងអស់។ ទ្រង់ជាអ្នកមានអំណាចតុលាការ។ ជារៀងរាល់ថ្ងៃ ព្រះមហាក្សត្រប្រទានសវនាការដែលមានមន្ត្រីរាជការ

---

[៣៧] -ដ- មាត្រា១២៨ថ្មី។

[៣៨] បណ្តឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស នឹងផ្តន្ទាទោសជននោះតាមច្បាប់កំណត់។

[៣៩]-ដ- មាត្រា១៣០ថ្មី។

ក៏ដូចជា ប្រជារាស្ត្រមកបរិយាយអំពីបញ្ហារបស់ខ្លួនជូនទ្រង់ជ្រាប និងឱ្យទ្រង់ជួយដោះស្រាយ ទោះជារឿងតូចក្តីធំក្តី។ តាមលោក ជាវ តាក្វាន់ រឿងរ៉ាវក្តីក្តាំបន្តិចបន្តួចក៏អាចឡើងទៅដល់ព្រះរាជាដែរ។ ប៉ុន្តែដូចលោក ហ្សង់ អាំប៊ែរ បានបញ្ជាក់ដែរ ពិតជាមានអង្គតុលាការមួយទទួលបន្ទុកក្រសួងយុត្តិធម៌ ( យមរាជ ? ) នៅអមព្រះអង្គផង ដើម្បីជួយព្រះមហាក្សត្រក្នុងបញ្ហាតុលាការ គេឃើញមានយមរាជ ដែលគេចាត់ទុកដូចជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ យមរាជ អាចដាក់ទណ្ឌកម្មពីពិន័យរហូតដល់ទោសប្រហារជីវិត។

ទោះបីយ៉ាងណា បើតាមលោក ជីវ តាក្វាន់ ការផ្តន្ទាទោសនៅរក្សាលក្ខណៈព្រៃផ្សៃខ្លះ ដែលគេធ្លាប់បានប្រទះឃើញនៅសម័យមុនៗដែរ ដូចជាបង្ខំឱ្យជនជាប់ចោទលូកដៃក្នុងទឹក ឬប្រេងកំពុងពុះ ឱ្យឈរ ឬ អង្គុយហាលថ្ងៃ ហាលសន្សើម ឱ្យមូសខាំមួយថ្ងៃ ឬ ពីរថ្ងៃ។ ល ។ ជាទូទៅ ការផ្តន្ទាទោសមានបីយ៉ាង។ ចំពោះទោសស្រាល គេពិន័យឱ្យបង់ជាមាសប្រាក់ ឬ ជារបស់របរ ផ្សេងៗ។ ចំពោះទោសមធ្យម ឬ ធ្ងន់ល្មម គេអាចចៀរត្រចៀក កាត់ច្រមុះ ឬកៀបក្បាលក្នុងដង្កៀបជាដើម។ ចំពោះទោសធ្ងន់ ១ គេអាចយកទៅកាប់ចោលទាំងរស់។

## ១.៥.១.សម័យបុរាណដល់ឆ្នាំ១៨៦៣

ស្ថាប័នតុលាការ នាសម័យនោះ ពុំទាន់មានទេ ទើបតែមានពេលប្រទេសបារាំងមកដាក់លើអាណានិគមមកលើប្រទេសខ្មែរ។ ក្រោយពីពេលបារាំងបានមកដាក់អាណានិគមលើប្រទេសខ្មែរតាំងពីឆ្នាំ១៨៦៣មកបារាំងបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងដឹកនាំស្ថាប័នតុលាការពីរដាច់ពីគ្នា គឺតុលាការជំនុំជម្រះក្តីមនុស្សក្នុងស្រុក និង តុលាការសហភាពបារាំង។

តុលាការជំនុំជម្រះក្តីមនុស្សក្នុងស្រុក ជាតុលាការដែលវិនិច្ឆ័យតែករណីវិវាទ ដែលបង្កឡើងដោយជនជាតិខ្មែរដូចគ្នា ឬពិរុទ្ធជនជាតិខ្មែរតែប៉ុណ្ណោះ។ តុលាការសហភាពបារាំងជាតុលាការដែលវិនិច្ឆ័យសេចក្តីចំពោះវិវាទដែលបង្កដោយជនជាតិបារាំងឬបរទេស។ ប្រសិនមានអំពើល្មើសណាមួយដែលពិរុទ្ធជនច្រើននាក់ត្រូវជាប់ទោសពីបទផ្សំគំនិតដែលក្នុងនោះមានទាំងជនជាតិខ្មែរឬជនជាតិបារាំង ឬជនជាតិបរទេសផងនោះ នីតិវិធីអាណានិគមនឹងធ្វើការបំបែករឿង ព្រមទាំងជនល្មើសដោយឡែកពីគ្នាទៅតាមសមត្ថកិច្ចតុលាការផ្សេងៗពីគ្នា។ បើជនល្មើសជាជនជាតិខ្មែរនោះសមត្ថកិច្ចរបស់តុលាការក្នុងស្រុកធ្វើការវិនិច្ឆ័យសេចក្តី បើសិនបើជនជាប់ចោទជាជាតិបារាំង ឬជនបរទេសវិញនោះគឺជាសមត្ថកិច្ចរបស់ តុលាការសហភាពបារាំងធ្វើការវិនិច្ឆ័យសេចក្តីវិញ។

### ១.៥.២.សម័យអាណានិគមឆ្នាំ១៨៦៣-១៩៥៣

ស្ថាប័នតុលាការកម្ពុជាមិនត្រូវបានកែប្រែដោយសន្ធិសញ្ញាមុនថ្ងៃទី១១ ខែសីហា ឆ្នាំ ១៨៦៣ ដែលបង្កើតរបបអាណាព្យាបាលរបស់បារាំងមកលើប្រទេសកម្ពុជាឡើយ។ មាត្រា ៧ នៃសន្ធិសញ្ញា កំណត់អំពីអាណាព្យាបាលបែបលក្ខណៈសេរីមួយ ដែលបារាំងដាក់មកលើខ្មែរ។ ប្រទេសបារាំងធានាឱ្យប្រជារាស្ត្រខ្មែរនូវយុត្តាធិការ ដែលខ្លួនធ្លាប់មានពីមុនមក។ ទន្ទឹមនឹងនេះដែរ ជនមានសញ្ជាតិបារាំង ក៏ដូចជាជនបរទេសដែលរស់នៅក្នុងប្រទេសខ្មែរ ឬ គ្រាន់តែឆ្លងកាត់ប្រទេសខ្មែរ ត្រូវបានធានាដោយយុត្តាធិការដោយឡែករបស់ខ្លួន[៤០] ពោលគឺយុត្តាធិការខ្មែរមានសមត្ថកិច្ចដោះស្រាយវិវាទរវាងខ្មែរ និងខ្មែរ ចំណែកឯយុត្តាធិការបារាំងមានសមត្ថកិច្ចដោះស្រាយជំលោះរវាងជនបរទេសនិងជនបរទេស។ ផ្ទុយទៅវិញ ប្រសិនបើវិវាទមានលក្ខណៈចម្រុះមានន័យថាជំលោះរវាងខ្មែរនិងជនបរទេសយុត្តាធិការបារាំងជាអ្នកមានសមត្ថកិច្ច[៤១] ហើយពេលនោះមន្ត្រីជាន់ខ្ពស់ខ្មែរម្នាក់នឹងចូលរួមនៅក្នុងយុត្តាធិការបារាំងដើម្បីដោះស្រាយជំលោះ។ ព្រះមហាក្សត្រខ្មែរក៏បានយល់ព្រមឱ្យមានការបែងចែកសមត្ថកិច្ចបែបនេះដែរ នៅក្នុងព្រះរាជប្រកាសស្តីពីតុលាការ នៃព្រះរាជាណាចក្រដែរ។

ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ វត្តមានរបស់បារាំងនៅលើទឹកដីខ្មែរមិនមែនប្រាកដថា មិនមានឥទ្ធិពលលើប្រព័ន្ធតុលាការកម្ពុជានោះទេ។ សន្ធិសញ្ញាឆ្នាំ១៨៦៣ ចែងថា ព្រះមហាក្សត្រកម្ពុជាយល់ព្រមឱ្យមានកំណែទម្រង់តុលាការគ្រប់ប្រភេទ ដែលរដ្ឋាភិបាលនៃសាធារណៈរដ្ឋយល់ថា មានផលប្រយោជន៍នៅថ្ងៃអនាគត។ នៅថ្ងៃទី ៦ ខែឧសភា ឆ្នាំ១៨៩៨ គេឃើញមានក្រឹត្យមួយត្រូវបានអនុម័តឡើង ដើម្បីរៀបចំប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ប៉ុន្តែ ក្រឹត្យ នេះលើកឡើងតែអំពីប្រព័ន្ធយុត្តិធម៌បារាំង ប៉ុណ្ណោះ ហើយគូសបញ្ជាក់នៅក្នុងមាត្រា ៥ ថា នឹងពុំមានការកែប្រែ បទប្បញ្ញត្តិពាក់ព័ន្ធនឹងយុត្តាធិការ ដែលមានសមត្ថកិច្ច ដោះស្រាយវិវាទរដ្ឋប្បវេណី វិវាទពាណិជ្ជកម្ម និងព្រហ្មទណ្ឌរវាងខ្មែរឡើយ។

---

[៤០] លោក ឡាហ្វា (M-C LAFARGE) អង្គព្រះរាជអាជ្ញា៖របាយការណ៍សម្រាប់អគ្គភិបាលនៃឥណ្ឌូចិន សាយហ្គោន (Saigon) ចុះ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៨៩៧ ។ ដាដំបូង យុត្តាធិការបារាំងតំណាងដោយរ៉េស៊ីដង់បារាំង។ នៅពេលដែលតុលាការបារាំងពុំទាន់បង្កើតនៅឡើយ រ៉េស៊ីដង បារាំងមានអំណាចតុលាការ។ តាមក្រឹត្យ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៨៨១ តុលាការបារាំងត្រូវបានបង្កើតកម្ពុជា។ ប៉ុន្តែ តុលាការបារាំង មានសមត្ថកិច្ចដោះស្រាយតែវិវាទរវាងជនបរទេសប៉ុណ្ណោះ បានសេចក្តីថា វិវាទរវាងជន ដែលពុំមានសញ្ជាតិខ្មែរ។ ចំពោះវវិវាទចម្រុះ រ៉េស៊ីដង់ បារាំងជាអាជ្ញាធរមានសមត្ថកិច្ចដោះស្រាយ។

[៤១] យុត្តាធិការបារាំង ដែលមានសមត្ថកិច្ចអាចជាតុលាការបារាំង ឬ រ៉េស៊ីដងបារាំង អាស្រ័យទៅលើថា តើក្នុងវិវាទដែលកើតឡើងមានខ្មែរចូលរួមដែរឬទេ។

ឥទ្ធិរបស់បារាំងរកស្តែងឱ្យឃើញតាមរយៈការអនុម័តយកប្រព័ន្ធសរសេរដែលជាប្រព័ន្ធ Civil Law នៅកម្ពុជាផងដែរ។ នាពេលនោះនីតិខ្មែរត្រូវបានចាប់ផ្តើមចងក្រង ជាក្រុម ដោយនៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩២០ សម្តេចព្រះស៊ីសុវត្ថិ ព្រះមហាក្សត្រកម្ពុជាបានប្រកាសឱ្យប្រើក្រុមរដ្ឋប្បវេណីថ្មី ដែលក្នុងនោះសៀវភៅចុងក្រោយ នៃក្រមមានបទប្បញ្ញត្តិទាក់ទងនឹងនីតិវិធីរដ្ឋប្បវេណី។ បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីជាប្រភពផ្តល់នូវកំណើតដល់ក្រម នីតិវិធីរដ្ឋប្បវេណីដោយត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ១៩៣៨ ដែលក្នុងនោះស្ថាប័នតុលាការខ្មែរ មានលក្ខណៈដូចគ្នាទាំងស្រុងទៅនឹងស្ថាប័នតុលាការបារាំង។

### ១.៥.៣.ប្រព័ន្ធតុលាការឆ្នាំ១៩៥៣-១៩៩៣

នៅសម័យនោះប្រទេសកម្ពុជាមានសាលាជំនុំជំរះក្តីតិចតួចណាស់។ មកដល់ពេលដែលសម័យប្រទេសកម្ពុជាទទួលបានឯករាជ្យពីអាណានិគមបារាំងនៅថ្ងៃទី៩ វិច្ឆិកា ១៩៥៣ ប្រទេសកម្ពុជាបានរៀបចំប្រទេសខ្លួនឡើងវិញ ហើយបានធ្វើវិសោធនកម្មជាបន្តបន្ទាប់នូវរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៤៧រហូត ដល់បង្កើតរដ្ឋធម្មនុញ្ញថ្មីរបស់ប្រទេសនៅ ឆ្នាំ១៩៦៦ អនុម័ត ដោយរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាសន្តិសុខ របៀបរៀបរយ និងការអនុវត្តច្បាប់នៅកម្ពុជា។ នៅក្នុងរដ្ឋធម្មនុញ្ញ ថ្មីនេះបានចែងអំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្ថាប័នតុលាការដែលបានបញ្ញត្តិទុកក្នុងច្បាប់ពិសេស[៤២]។ ចាប់ពីពេលនោះមកប្រព័ន្ធតុលាការខ្មែរបានអភិវឌ្ឍទៅតាមតម្រូវការនៅពេលដែលកម្ពុជាមានអធិបតេយ្យភាពពេញបរិបូណ៌។

អំពីក្រុមប្រឹក្សាជាន់ខ្ពស់របស់តុលាការត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមច្បាប់ និងធានារ៉ាប់រងចំពោះ វិន័យនិងឥស្សរៈភាពនៃចៅក្រមទាំងអស់។ ក្រុមប្រឹក្សានេះ ស្ថិតនៅក្រោមអធិបតេយ្យភាពព្រះមហាក្សត្យនៃព្រះរាជាណាចក្រកម្ពុជា[៤៣]។

សាលាជំនុំជំរះក្តីជាន់ទី១ ឬ សាលាដំបូងត្រូវបានបង្កើតឡើងនៅតាមបណ្តាខេត្តមួយចំនួន ហើយមានសមត្ថកិច្ចគ្របដណ្តប់លើវិសាលភាពនៃដែនដីដែលសាលាជំនុំជំរះក្តីនោះស្ថិតនៅ។ សាលាជំនុំជំរះត្រូវបានចែកចេញជាពីរថ្នាក់គឺ សាលាជំនុំជំរះក្តីជាន់ទាប និងសាលាជំនុំជំរះក្តីជាន់ខ្ពស់។ សាលាជំនុំជំរះក្តីជាន់ទាបមាន សាលាលហុ សាលាដំបូង ឬ សាលាជំនុំជំរះក្តីលើកដំបូង សាលាទាំងពីនេះ មានទីតាំងនៅស្ទើរតែគ្រប់ខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជាហើយមានសមត្ថកិច្ចគ្របដណ្តប់លើផែនដីដែលខ្លួនរស់នៅ។

---

[៤២]រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៤៧ មាត្រា៩៥។

[៤៣]-ដ- មាត្រា៩៥។

សាលជំនុំជម្រះក្តីជាន់ខ្ពស់រួមមាន សាលាឧទ្ធរណ៍ សាលាឧក្រិដ្ឋ សាលាវិនិច្ឆ័យ។ សាលាទាំងបីនេះមានទីតាំង នៅក្រុងភ្នំពេញហើយ មានសមត្ថកិច្ចគ្របដណ្តប់លើដែនដីនៃប្រទេសទាំងមូលក្រៅពីនេះនៅមានតុលាការសឹកមួយទៀត ដែលមានទីតាំងស្ថិតនៅទីក្រុងភ្នំពេញមានសមត្ថកិច្ចលើដែនដីទាំងមូលនៃប្រទេសសម្រាប់បញ្ហាទាំងឡាយណា ដែលទាក់ទងរឿងក្តីមានលក្ខណៈយោធា។

ប្រព័ន្ធតុលាការនាសម័យសាធារណៈរដ្ឋខ្មែរ១៩៧០-១៩៧៥ បន្ទាប់ពីធ្វើការផ្លាស់ប្តូររបបមកជារបបសាធារណៈរដ្ឋខ្មែរ របបនេះនៅតែបានបន្តអនុវត្តប្រព័ន្ធតុលាការអតីតព្រះរាជាណាចក្រកម្ពុជាទី១ រហូតដល់រដ្ឋធម្មនុញ្ញថ្មីរបស់របបសាធារណៈរដ្ឋខ្មែរបានចូលជាធរមាននៅថ្ងៃទី២០ ខែ តុលា ឆ្នាំ ១៩៧២ ពេលនោះប្រព័ន្ធយុត្តាធិការត្រូវបានកែប្រែនិងវិវត្តបន្ថែមទៀត។ តុលាការកំពូល និង សាលាជំរះក្តីគ្រប់ជាន់ថ្នាក់នៃរបបសាធារណៈរដ្ឋខ្មែរត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញថ្មីដោយកំណត់ថា អំណាចតុលាការជាអំណាចប្រកបដោយឥស្សរភាព អំណាចតុលាការត្រូវតែរក្សានូវអនាគតិ ការពារសិទ្ធ និង សេរីភាពរបស់ប្រជាពលរដ្ឋ[៤៤]។ តុលាការកំពូលមាន ឧត្តមមន្ត្រីតុលាការចំនួន៩ នាក់គឺ ប្រធាន០១នាក់និងចៅក្រមប្រឹក្សាចំនួន០៨នាក់[៤៥]។ ម្យ៉ាងទៀត តុលាការកំពូលអាចផ្តើមគំនិតបង្កើតច្បាប់ទាក់ទងនឹងការរៀបចំ និងការប្រព្រឹត្តទៅនៃអំណាចតុលាការ និងមានសិទ្ធិប្រកាសរំសាយគណបក្សនយោបាយតាមមតិពីរភាគបីចំពោះ គណបក្សនយោបាយណា ដែលធ្វើសកម្មភាពបំផ្លាញរបបសាធារណៈរដ្ឋ។

នៅក្នុងសម័យសាធារណៈរដ្ឋខ្មែរយើងសង្កេតឃើញ មានតុលាការធម្មនុញ្ញនិងតុលាការជាន់ខ្ពស់។ តុលាការធម្មនុញ្ញមានសមត្ថកិច្ចសម្រេចអំពីនិយ័តភាពនៃការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងអនុប្រធានាធិបតីនៃសាធារណៈខ្មែរ ហើយប្រកាសពីលទ្ធផលនៃការបោះឆ្នោតនោះនិងមានសមត្ថកិច្ចសម្រេចពីករណីវិវាទកម្មទាក់ទងនិងការបោះឆ្នោតជ្រើសរើសសមាជិកសភា។ តុលាការ ជាន់ខ្ពស់មានអំណាចជំនុំជម្រះរឿងក្តីរបស់ប្រធានាធិបតី និងអនុប្រធានាធិបតីនៃរបបសាធារណៈរដ្ឋខ្មែរសមាជិករដ្ឋាភិបាលសមាជិកសភាសមាជិកតុលាការធម្មនុញ្ញ និងសមាជិកតុលាការកំពូលពីបទឧក្រិដ្ឋ និងបទមជ្ឈឹមដែលស្ថិតនៅក្នុងពេលបំពេញ ការងាររៀងៗខ្លួន។

ទោះបីជាមានរចនាសម្ព័ន្ធដូចបានរៀបរាប់ខាងលើក៏ដោយ ក៏ប៉ុន្តែសង្គ្រាមចេះតែបន្តនិងមូលហេតុផ្សេងៗទៀតនោះ ជាហេតុធ្វើឱ្យស្ថាប័នយុត្តាធិការថ្មីនាសម័យសាធារណៈរដ្ឋខ្មែរពុំបានដំណើការអ្វីទាំងអស់រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលរបបសាធារណៈរដ្ឋខ្មែរបានដួលរលំទាំងស្រុង។

---

[៤៤] រដ្ឋធម្មនុញ្ញសាធារណៈរដ្ឋខ្មែរ១៩៧២ មាត្រា៨១។

[៤៥] -ដ- មាត្រា៨៦។

ប្រព័ន្ធតុលាការសម័យកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៥-១៩៧៩ កម្ពុជាប្រជាធិបតេយ្យបានបង្កើតរដ្ឋធម្មនុញ្ញថ្មីមួយ ដែលមាន១៦ជំពូក និង២១មាត្រា ក្នុងនោះក៏មានចែងផងដែរអំពីស្ថាប័នតុលាការ ដោយកំណត់អំពីតួនាទីរបស់តុលាការកម្ពុជាប្រជាធិបតេយ្យ តុលាការជាតុលាការរបស់ប្រជាជន តំណាងយុត្តិធម៌របស់ប្រជាជន ការពារយុត្តិធម៌ របស់ប្រជាជន ការពារសិទ្ធិ សេរីភាពប្រជាធិបតេយ្យរបស់ប្រជាជន ហើយផ្តន្ទាទោសដល់គ្រប់សកម្មភាពដែលប្រឆាំងនឹងរដ្ឋរបស់ប្រជាជន ឬដែលល្មើសនិងច្បាប់រដ្ឋរបស់ប្រជាជន[៧]។ ប៉ុន្តែអ្វីដែលចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជាសម័យកម្ពុជាប្រជាធិបតេយ្យវាផ្ទុយស្រលះពីការអនុវត្តជាក់ស្តែង ដោយហេតុភាពយុត្តិធម៌ ឬ អយុត្តិធម៌វាសម្រេចលើមតិអង្គការទាំងអស់។ ប្រជាពលរដ្ឋស្លូតត្រង់ត្រូវគេសម្លាប់ដោយមិនដឹងពីទោសកំហុសរបស់ខ្លួនដោយគ្មានការតវ៉ា និងមិនឆ្លងការជំនុំជំរះអ្វីទាំងអស់។ សម័យនោះហើយដែលប្រទេសកម្ពុជាធ្លាក់ចុះទៅក្នុងភាពដ៏ខ្មៅងងឹត។ របបនោះបានបំផ្លិចបំផ្លាញនិងកាប់សម្លាប់មនុស្សអស់ជាច្រើនដូចជា និស្សិតបញ្ញវ័ន្ត សាស្រ្តាចារ្យ និងអ្នកច្បាប់ស្ទើរគ្មានសល់ សូម្បីតែវត្តអារាម សាលារៀន តុលាការ ក្រសួងមន្ទីរក៏ត្រូវពួកគេយកទៅធ្វើជាមន្ទីរឃុំឃាំងឬក៏កន្លែងដាក់ជីជាដើម។ ពិសេសទៅទៀតនោះធ្វើឱ្យកុមារព្រាត់ប្រាស់ពីឪពុកម្តាយ ខ្លះទៀតត្រូវអង្គការពង្វក់សតិស្មារតីឱ្យក្លាយជាឃាតករវ័យក្មេងសម្លាប់ឪពុកម្តាយខ្លួនឯង និងប្រជាជនស្លូតត្រង់។

ចាប់ពីឆ្នាំ១៩៧៩-១៩៨៥ ប្រព័ន្ធតុលាការសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជាមានតែមួយថ្នាក់ប៉ុណ្ណោះ ដែលបង្កើតឡើងដោយច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការ និង អយ្យការ ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ០២ ចុះថ្ងៃ១០ ខែកុម្ភៈ ឆ្នាំ១៩៨២ របស់ក្រុមប្រឹក្សារដ្ឋ។ តុលាការនេះជាតុលាការប្រជាជនខេត្តក្រុង ដែលជាតុលាការជាន់ដំបូងកាត់ក្តី ឬជំនុំជម្រះលើកទី១និងលើកចុងក្រោយបង្អស់ ពោលគឺបិទផ្លូវឧទ្ធរណ៍ មានន័យថា សាលក្រមដែលចេញដោយតុលាការនេះ មានប្រសិទ្ធិភាពអនុវត្តតែម្តង។ សាលក្រមដែលចេញដោយតុលាការទាំងនោះត្រូវបានត្រួតពិនិត្យឡើងវិញដោយក្រសួងយុត្តិធម៌ និងសម្រេចចុងក្រោយបំផុតដោយក្រុមប្រឹក្សារដ្ឋ។ ក្នុងករណីមានសេចក្តីស្នើពីក្រសួងយុត្តិធម៌ចំពោះសេចក្តីសម្រេចដែលក្រសួងរកឃើញថាមានកំហុស។ បើក្រុមប្រឹក្សារដ្ឋយល់ឃើញថា សំណុំរឿងបដិសេធពីក្រសួងយុត្តិធម៌លើសាលក្រមរបស់តុលាការនោះជាការត្រឹមត្រូវ នោះក្រុមប្រឹក្សារដ្ឋត្រូវបញ្ជូនសំណុំរឿងទៅឱ្យតុលាការប្រជាជនខេត្ត-ក្រុងជំនុំជម្រះឡើងវិញ។ ក្រុមប្រឹក្សារដ្ឋមាននាទីជាស្ថាប័នមួយដែលទទួលពាក្យបណ្តឹងរបស់ប្រជាជនដែរ ក្នុងនោះក្រុមប្រឹក្សារដ្ឋអាចទទួលពាក្យបណ្តឹងតវ៉ាប្រជាជនជំទាស់នឹងសាលក្រមដែលសម្រេចដោយតុលាការខេត្ត-ក្រុងដោយផ្ទាល់ ហើយចាត់ការពិនិត្យសំណុំរឿងនោះ ដើម្បីសម្រេចថា

---

[៧] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ មាត្រា៩។

សាលក្រមនោះត្រឹមត្រូវ ឬ មិនត្រឹមត្រូវ បើត្រឹមត្រូវសាលក្រមនោះត្រូវតម្កល់ បើមិនត្រឹមត្រូវទេ ត្រូវបញ្ជូនឱ្យតុលាការខេត្ត-ក្រុង ដែលចេញលសាលក្រមនោះកាត់សេចក្ដីសារជាថ្មី តាមសេចក្ដីណែនាំរបស់ក្រុមប្រឹក្សារដ្ឋដោយប្រើសមាសភាពថ្មី។

ម្យ៉ាងវិញទៀត ក្រុមប្រឹក្សារដ្ឋអនុវត្តសិទ្ធិអយ្យការរបស់ខ្លួនក្នុងករណីព្រហ្មទណ្ឌដែរ មានន័យថាក្រុមប្រឹក្សារដ្ឋមានតួនាទី ទទួល និងសម្រេចលើបណ្ដឹងតវ៉ាជំទាស់នឹងការចោទប្រកាន់របស់អយ្យការថ្នាក់ក្រោម។

សរុបសេចក្ដីមក ដោយសារក្នុងរយៈកាលនោះមិនទាន់មានតុលាការកំពូលនៅឡើយ ក្រុមប្រឹក្សារដ្ឋហាក់ដូចជាមាននាទីពីរទាក់ទងទៅរឿងក្ដីតុលាការ គឺប្រៀបដូចជាតុលាការកំពូលផង និង មហាអយ្យការអមតុលាការំពូល។ នីតិវិធីទាំងអស់នេះហើយ ទើបធ្វើឱ្យគូក្ដីមានសិទ្ធិសម្រាប់ធ្វើការប្ដឹងតវ៉ាអំពីសាលក្រម ឬសេចក្ដីសម្រេចផ្សេងៗ របស់តុលាការប្រជាជនខេត្ត-ក្រុងទៅក្រុមប្រឹក្សារដ្ឋ ដែលប្រៀបដូចជាការប្ដឹងទៅតុលាការថ្នាក់ខ្ពស់ នាពេលបច្ចុប្បន្ន។

ក្នុងឆ្នាំ១៩៨៥ តុលាការកំពូលក៏ត្រូវបានបង្កើតឡើង (ដោយច្បាប់ស្ដីពីការបង្កើតតុលាការប្រជាជនកំពូលនិងមហាអយ្យការអមតុលាការកំពូល ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ២៨ក្រ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៨៥ របស់ក្រុមប្រឹក្សារដ្ឋ)ហើយទទួលយកនាទីដែលក្រុមប្រឹក្សារដ្ឋមានពីមុន។ ក្រុមប្រឹក្សារដ្ឋត្រូវបានចប់នាទីក្នុងឋានៈជាស្ថាប័នមួយ ចាប់តាំងពីការអនុម័តរដ្ឋធម្មនុញ្ញថ្មី នៃព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ១៩៩៣។ លុះដល់អាជ្ញាធរអង្គការសហប្រជាជាតិនៅកម្ពុជា អ៊ុនតាក់បានមកដល់ប្រទេសកម្ពុជា អាជ្ញាធរអង្គការសហប្រជាជាតិបានជួយរៀបចំវិស័យច្បាប់ និង ប្រព័ន្ធតុលាការថ្មីមួយនៅប្រទេសកម្ពុជា។ ពេលនោះហើយដែលប្រព័ន្ធតុលាការកម្ពុជាបានចែកជាសាលាជម្រះក្ដីមួយជាន់ទៀតគឺ សាលាឧទ្ធរណ៍។ លើសពីនេះទៀតច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សាលាជម្រះក្ដីនៃកម្ពុជា ប្រើដោយអនុក្រឹត្យលេខ០៦ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ក៏បានបង្ហាញពីអត្ថិភាពនៃសាលាឧទ្ធរណ៍ដែរ។

### ១.៥.៤.កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌

កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានលេចជារូបរាងច្បាស់លាស់ ជាមួយនឹងរាជរដ្ឋាភិបាលឯកភាពជាតិ ចម្រុះគណបក្សអាណត្តិទី២ នៃរដ្ឋសភា បន្ទាប់ពីការបោះឆ្នោតនៅថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៩៨។ នៅក្នុងអាណត្តិទី២ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានអនុវត្ត នូវកំណែទម្រង់បួនយ៉ាង ដែលមានទំនាក់ទំនងគ្នា និងបម្រើគោលដៅរួមគ្នា គឺកំណែទម្រង់រដ្ឋបាល កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ កំណែទម្រង់កងទ័ព នគរបាលនិងការកែទម្រង់សេដ្ឋកិច្ច។ ទាក់ទងប្រព័ន្ធយុត្តិធម៌ និងតុលាការប្រមុខនៃរាជរដ្ឋាភិបាល

បានលើកឡើងអំពីភាពចាំបាច់ដែលត្រូវតែមានកំណែទម្រង់ ដើម្បីពង្រឹងឯករាជ្យភាព យុត្តិធម៌ ទំនុកចិត្ត និងការគោរពប្រតិបត្តិច្បាប់ ដោយត្រូវកែលម្អពីលើចុះក្រោម ដើម្បីសម្រេចទិសដៅនេះត្រូវមានកិច្ចសហការ រវាងរាជរដ្ឋាភិបាល និង រដ្ឋសភា ព្រមទាំងស្ថាប័នឯករាជ្យដែលពាក់ព័ន្ធដូចជា ក្រុមប្រឹក្សាធម្មនុញ្ញ ឧត្តម ក្រុមប្រឹក្សានៃអង្គចៅក្រម និង តុលាការ។

នៅចន្លោះឆ្នាំ២០០៣ និង២០០៥ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំបង្កើតឯកសារសំខាន់ចំនួនពីរ ពាក់ព័ន្ធនឹងកំណែទម្រង់ច្បាប់ និងយុត្តិធម៌ ដែលឯកសារទាំងពីរនេះមាន៖ យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ និងផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនេះ[៤៧]។ គោលដៅយុទ្ធសាស្ត្រចំនួន៧ ត្រូវ បានកំណត់ក្នុងយុទ្ធសាស្ត្រកំណែទម្រង់ដែលរួមមាន៖ ១)លើកកម្ពស់សិទ្ធិសេរីភាពបុគ្គល ២)ទំនើបកម្ម ក្របខណ្ឌច្បាប់ ៣)បង្កើនការផ្សព្វផ្សាយពត៌មានពាក់ព័ន្ធនឹងច្បាប់ និងវិស័យយុត្តិធម៌ ៤)លើកកម្ពស់ ដំណើរការច្បាប់ និងសេវាផ្សេងៗទៀត ៥)បង្កើនសេវាយុត្តិធម៌ ៦)បង្កើនដំណើរការដោះស្រាយវិវាទក្រៅ ប្រព័ន្ធតុលាការ និង ៧)ពង្រឹងអាណត្តិ និងការបំពេញការងាររបស់ស្ថាប័នច្បាប់និងយុត្តិធម៌[៤៨]។ ដើម្បី សម្រេចនូវគោលដៅទាំង៧ខាងលើ រាជរដ្ឋាភិបាលបានបង្កើតផែនការសកម្មភាពដែលមានសកម្មភាព អាទិភាពចំនួន៩៧។ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញអំពីការប្តេជ្ញាចិត្តក្នុងការបន្តការអនុវត្តគោលដៅទាំង៧ ចំណុចសម្រាប់កំណែទម្រង់ច្បាប់ និង យុត្តិធម៌។

ចក្ខុវិស័យរបស់រាជរដ្ឋានបាននីតិកាលទី ៤ ក្នុងការកែទម្រង់ច្បាប់ និង ប្រព័ន្ធធម៌ គឺការសម្រេចឱ្យ បាននូវប្រព័ន្ធច្បាប់និងប្រព័ន្ធយុត្តិធម៌មួយដែលអាចជឿទុកចិត្តបាននិងមានស្ថិរភាព សម្រាប់ការលើកស្ទួយ ការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ការពង្រឹងគោលការណ៍នីតិរដ្ឋនៅក្នុងលទ្ធិប្រជាធិបតេយ្យសេរី ការធានាយុត្តិធម៌សង្គម ព្រមទាំងការបង្កើតបរិយាកាសជឿទុកចិត្តសម្រាប់ទាក់ទាញការវិនិយោគ។

ឆ្លើយតបទៅនឹងចក្ខុវិស័យនេះ ក្នុងនីតិកាលកន្លងទៅ រាជរដ្ឋកិបាលសម្រេចបានសមិទ្ធផលធំៗជា ច្រើន រួមមាន (១)ការធ្វើទំនើបកម្មក្របខណ្ឌច្បាប់ ពិសេស ការអនុម័ត និង ការប្រកាសឱ្យប្រើនូវក្រម ព្រហ្មទណ្ឌ បន្ថែមលើក្រមសំខាន់ៗ ចំនួន ៣ ផ្សេងទៀត គឺ ក្រមរដ្ឋប្បវេណី, ក្រមនីតិវិធីរដ្ឋប្បវេណី និង

---

[៤៧] Peng, Hor,Phalla, Kong & Menzel, Jorg.2012. Phnom Penh, Introduction to Cambodian Law. Published by Konrad-Adenauer –Stiftung.p17.

[៤៨] Ibid,p20.

ក្រមនីតិវិធីព្រហ្មទណ្ឌ (២)ការបង្កើនការយល់ដឹង និង លើកកម្ពស់ការអនុវត្តច្បាប់ តាមរយៈការអប់រំ ផ្សព្វផ្សាយ និង បណ្តុះបណ្តាលច្បាប់ដល់មន្ត្រីផ្តល់សេវាយុត្តិធម៌ និង មន្ទីរ អនុវត្តច្បាប់ពាក់ព័ន្ធផ្សេងទៀត (៣) ការកែលម្អប្រព័ន្ធតុលាការ តាមរយៈការពង្រឹងសមត្ថភាព និង ការទទួលខុសត្រូវ វិជ្ជាជីវៈរបស់ចៅក្រម និង ព្រះរាជអាជ្ញា, (៤) ការផ្តល់មធ្យោបាយបន្ថែមទៀតដល់ស្ថាប័នតុលាការ តាមរយៈការបង្កើនថវិកាជាបណ្តើរៗសម្រាប់វិស័យនេះ និង (៥) ការពង្រីក និង លើកកម្ពស់យន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមរយៈការពារដំណើរការស្រួលសេវាកម្មយុត្តិធម៌ និង ការបង្កើតមជ្ឈមណ្ឌលជាតិនៃមជ្ឍត្តការពាណិជ្ជកម្ម។

ក្នុងនីតិកាលទី៥ នៃរដ្ឋសភានេះរាជរដ្ឋាភិបាលនឹងបន្តអនុវត្តឱ្យកាន់តែសកម្ម និងកាន់តែស៊ីជម្រៅថែមទៀតនូវបណ្តាសកម្មភាពសំខាន់ៗ ស្របតាមកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និង តុលាការ ដោយផ្តោតអាទិភាពពិសេសទៅលើ (១) ការបន្តជំរុញអនុម័តច្បាប់គោលសំខាន់ៗពាក់ព័ន្ធនឹងស្ថាប័នតុលាការ ជាអាទិ៍ ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គការតុលាការ និង អង្គការអយ្យការ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រមទាំង ការកសាងច្បាប់ថ្មីៗតាមការចាំបាច់នៃការគ្រប់គ្រងរដ្ឋ និងស្របតាមដំណើរការនៃការបង្កើតសហគមន៍អាស៊ានឆ្នាំ២០១៥ និងកាតព្វកិច្ចរបស់កម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក (២)ការបន្តពង្រឹងសមត្ថភាព និងការទទួលខុសត្រូវវិជ្ជាជីវៈរបស់ចៅក្រម និងព្រះរាជអាជ្ញា (៣)ការជម្រុញបង្កើតឱ្យមានរដ្ឋបាលតុលាការតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ (៤)ការបន្តផ្តល់មធ្យោបាយសមស្របដល់សាលាជម្រះក្តីសម្រាប់ប្រតិបត្តិការអនុវត្តច្បាប់ (៥) ការបន្តអនុវត្តកម្មវិធីផ្សព្វផ្សាយ និង បណ្តុះបណ្តាលច្បាប់ឱ្យបានទូលំទូលាយថែមទៀត (៦)ការបន្តសហការ និង ជួយដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ ដើម្បីការពារសិទ្ធិ និង ផលប្រយោជន៍ តាមផ្លូវតុលាការ និង (៧)ការបន្តជម្រុញលើកកម្ពស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

លើសពីនេះទៀត កាលពីថ្ងៃទី២២-២៣ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ រដ្ឋសភាបានអនុម័តច្បាប់ចំនួនបីពាក់ព័ន្ធទៅនឹងវិស័យតុលាការនៅកម្ពុជារួមមានច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមប្រឹក្សានៃអង្គចៅក្រម ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា។ច្បាប់ទាំងបីខាងលើនេះក៏ទទួលរងនូវការរិះគន់ផងដែរពីអង្គការសង្គមស៊ីវិលនៅកម្ពុជា ដោយហេតុថា មូលដ្ឋានគ្រឹះនៅក្នុងសង្គមប្រជាធិបតេយ្យ មិនអនុញ្ញាតឱ្យអំណាច

នីតិប្បញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ ជ្រៀតជ្រែក ឬ មានឥទ្ធិពលដោយផ្ទាល់ក្តី ដោយប្រយោលក្តីទៅលើអំណាចតុលាការ។ ដើម្បីជានាដល់មូលដ្ឋានគ្រឹះក្នុងសង្គមប្រជាធិបតេយ្យក្មេងខ្ចីនៅកម្ពុជាទើបអំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ[៤៩]។ ទោះជាមានការរិះគន់យ៉ាងខ្លាំងពីគណបក្សប្រឆាំង ក្រុមសង្គមស៊ីវិល និងអង្គការសហប្រជាជាតិថា ជាការអនុម័តពីតំណាងរាស្ត្រតែបក្សម្ខាងក្តី ក៏អត្ថបទពង្រាងច្បាប់ទាំងបីខាងលើបានក្លាយទៅជាច្បាប់ និងត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី២២-២៣ ខែឧសភាឆ្នាំ២០១៤នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ រួចរាល់ចប់សព្វគ្រប់ហើយដែរ។

យោងតាមព្រះរាជក្រឹត្យ លេខ នស/រកត/០៤២១/៣៤៥ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ សាលាដំបូងខេត្តកែប និងអយ្យការអមសាលាដំបូងខេត្តកែបនឹងត្រូវប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១។

លើសពីនេះទៀតមានការបង្កើតសាលាឧទ្ធរណ៍តំបន់ដោយព្រះរាជក្រឹត្យ រួមមានសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ បាត់ដំបង និងព្រះសីហនុ។

សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ ត្រូវទទួលដោះស្រាយបណ្តឹងឧទ្ធរណ៍ ចំពោះសេចក្តីសម្រេចនានារបស់សាលាដំបូងខេត្តកំពង់ចាម និងអយ្យការអមសាលាដំបូង ខេត្តកំពង់ចាម សាលាដំបូងខេត្តកំពង់ធំ និងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ សាលាដំបូងខេត្តព្រះវិហារ និងអយ្យការអមសាលាដំបូងខេត្តព្រះវិហារ សាលាដំបូងខេត្តក្រចេះ និងអយ្យការអមសាលាដំបូងខេត្តក្រចេះ សាលាដំបូងខេត្តស្ទឹងត្រែង និងអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង សាលាដំបូងខេត្តរតនគិរី និងអយ្យការ អមសាលាដំបូងខេត្តរតនគិរី សាលាដំបូងខេត្តមណ្ឌលគិរី និងអយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី សាលាដំបូងខេត្តព្រៃវែង និងអយ្យការអមសាលាដំបូងខេត្តព្រៃវែង សាលាដំបូងខេត្តស្វាយរៀង និងអយ្យការ អមសាលាដំបូងខេត្តស្វាយរៀង និងសាលាដំបូងខេត្តត្បូងឃ្មុំ និងអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ ឬករណីសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញ[៥០]។

សាលាឧទ្ធរណ៍តំបន់បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់បាត់ដំបង ត្រូវទទួលដោះស្រាយបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនានារបស់សាលាដំបូងខេត្តកំពង់ឆ្នាំង និងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង សាលាដំបូងខេត្តពោធិ៍សាត់ និងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

---

[៤៩] រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៥១ថ្មី។

[៥០] ព្រះរាជក្រឹត្យស្តីពីការដាក់ឲ្យដំណើរការសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ មាត្រា៣។

សាលាដំបូងខេត្តបាត់ដំបង និងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង សាលាដំបូងខេត្តប៉ៃលិន និងអយ្យការ អមសាលាដំបូងខេត្តប៉ៃលិន សាលាដំបូងខេត្តបន្ទាយមានជ័យ និងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ សាលាដំបូងខេត្តឧត្តរមានជ័យ និងអយ្យការអមសាលាដំបូងខេត្តឧត្តរមានជ័យ និងសាលាដំបូងខេត្ត សៀមរាប និងអយ្យការអមសាលាដំបូងខេត្តសៀមរាប ឬករណីសំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញ[៥១]។

សាលាឧទ្ធរណ៍តំបន់ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ ត្រូវទទួលដោះស្រាយបណ្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសម្រេចនានារបស់ សាលាដំបូងខេត្តតាកែវ និងអយ្យការអមសាលាដំបូងខេត្តតាកែវ សាលាដំបូងខេត្តកំពត និងអយ្យការអមសាលាដំបូងខេត្តកំពត សាលាដំបូងខេត្តកំពង់ស្ពឺ និងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ សាលាដំបូងខេត្តកោះកុង និងអយ្យការអមសាលាដំបូង ខេត្តកោះកុង និងសាលាដំបូងខេត្តព្រះសីហនុ និងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ឬ ក៏សំណុំរឿងដែលតុលាការកំពូលបានបង្វិលមកវិញ[៥២]។

## សេចក្ដីសន្និដ្ឋាន

ការសិក្សាពីយុត្តិធម៌ក្នុងសង្គម ទោះជាមានទស្សនៈយល់ឃើញខុសគ្នាយ៉ាងណាក៏ដោយ ក៏វាទាមទារឱ្យមានការយកចិត្តទុកខ្លាំងនៅក្នុងសង្គមមនុស្ស ព្រោះថា អំពើអយុត្តិធម៌សង្គមអាចនាំឱ្យមានវិបត្តិសង្គម និងឈានទៅរកការដួលរលំការគ្រប់គ្រងនៅក្នុងសង្គមយ៉ាងពិតប្រាកដ។

ដើម្បីធានានូវយុត្តិធម៌សង្គម សង្គមត្រូវបានបែងចែកអំណាចឱ្យដាច់ពីគ្នា រវាងអំណាចធ្វើច្បាប់ អំណាចប្រតិបត្តិច្បាប់ និង អំណាចតុលាការ ដើម្បីស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ។ ទន្ទឹមនឹងនេះដែរ សង្គមកម្ពុជាក៏បានពិនិត្យយ៉ាងយកចិត្តទុកដាក់ផងដែរ ដោយបង្ហាញឱ្យឃើញតាមរយៈរដ្ឋធម្មនុញ្ញរបស់ខ្លួនចាប់តាំងពីឆ្នាំ១៩៤៧ រហូតមកដល់ឆ្នាំ១៩៩៣ អំណាចត្រូវបានបែងចែកដាច់ពីគ្នា ដើម្បីធានាការពារកុំឱ្យមានអំណាចផ្ដាច់ការនៅក្នុងសង្គម។

ការបែងចែកអំណាចឱ្យដាច់ពីគ្នា បានជួយធានាឱ្យមានយុត្តិធម៌សង្គមបានក្នុងកម្រិតមួយអាចពេញចិត្តពីសំណាក់ប្រជាពលរដ្ឋដែរ ប៉ុន្តែ ក្នុងករណីអំណាចនៃស្ថាប័ននយោបាយលូកដៃជ្រៀតជ្រែកទៅក្នុងអំណាចតុលាការកំពុងតែទទួលបានរងនូវពាក្យរិះគន់ ទៅលើឯករាជ្យភាពនៃអំណាចតុលាការផងដែរ។

---

[៥១] ព្រះរាជក្រឹត្យស្ដីពីការដាក់ឲ្យដំណើរការសាលាឧទ្ធរណ៍តំបន់បាត់ដំបង មាត្រា៣។

[៥២] ព្រះរាជក្រឹត្យស្ដីពីការដាក់ឲ្យដំណើរការសាលាឧទ្ធរណ៍ព្រះសីហនុ មាត្រា៣។

# គន្ថនិទ្ទេស


១.រដ្ឋធម្មនុញ្ញខ្មែរ ឆ្នាំ១៩៤៧

២.រដ្ឋធម្មនុញ្ញខ្មែរ ឆ្នាំ១៩៧២

៣.រដ្ឋធម្មនុញ្ញខ្មែរ ឆ្នាំ១៩៧៦

៤.រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

៥.ព្រះរាជក្រឹត្យស្ដីពីការឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ

៦.ព្រះរាជក្រឹត្យស្ដីពីការឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់បាត់ដំបង

៧.ព្រះរាជក្រឹត្យស្ដីពីការឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ

៨.ខ្លូត ធីតា៖មូលដ្ឋានគ្រឹះនៃសីលវិទ្យាសកលលោក ភ្នំពេញ

៩.ទស្សវិជ្ជា ថ្នាក់បញ្ចប់៖ការផ្សាយរបស់មជ្ឈមណ្ឌលទស្សនវិជ្ជាអនុវត្តន៍និងសីលធម៌ ភ្នំពេញ

១០.កា ម៉ាធុល៖ ប្រវត្តិគំនិតនយោបាយ ភ្នំពេញ, ឆ្នាំ២០០៨

១១.លី គឹមសុខ៖ គំនិតនយោបាយ ភ្នំពេញ

១២.ហង់ជួន ណារ៉ុន៖សិក្សាសង្ខេបស្ដីពី ទស្សនវិជ្ជា ភ្នំពេញ, បោះពុម្ពផ្សាយស៊ីប៉ា ឆ្នាំ២០១៨

១៣.ដេវីត បូស(David Boaz)៖សេរីនិយម ភ្នំពេញ, ឆ្នាំ ២០០៧

១៤.ហោ ប៉េង៖ នីតិរដ្ឋធម្មនុញ្ញប្រៀបធៀប ភ្នំពេញ, ឆ្នាំ២០២១

១៥.ត្រឹង ងា៖ អរិយធម៌ខ្មែរ ភ្នំពេញ, ឆ្នាំ១៩៧៥

១៦.វ៉ាន់ ឌីកា៖អុន៖ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ភ្នំពេញ, ឆ្នាំ២០០៨ ភាគទី១

១៧.សេង ប៊ុនធឿន៖ រដ្ឋធម្មនុញ្ញ និង ការផ្លាស់ប្ដូររបបនយោបាយនៅកម្ពុជា ភ្នំពេញ, ឆ្នាំ២០១៥

១៨.គិន ភា៖ រដ្ឋភាកម្ពុជា និង ការអនុវត្តគោលការណ៍បែងចែកអំណាច (១៩៩៣-២០០៨)

១៩. Peng, Hor,Phalla, Kong & Menzel, Jorg.2012. Phnom Penh, Introduction to Cambodian Law

© ២០២៣ រាជបណ្ឌិត្យសភាកម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង
គ្មានផ្នែកណាមួយនៃទស្សនាវដ្ដីនេះនឹងត្រូវបានបោះពុម្ពឡើងវិញ
ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីរាជបណ្ឌិត្យសភាកម្ពុជាឡើយ។

---

©2023 Royal Academy of Cambodia

All rights reserved,
no part of this book may be reproduced,
in any form, by any means, without permission in writing from
Royal Academy of Cambodia.




**Royal Academy of Cambodia**

Russian Federation Blvd
P.O.Box: 531 Phnom Penh
Kingdom of Cambodia
Tel: (855) 23 890 180
Fax: (855) 23 890 180
Email: info@rac.gov.kh
Website: www.rac.gov.kh

**រាជបណ្ឌិត្យសភាកម្ពុជា**

មហាវិថីសហព័ន្ធរុស្ស៊ី
ប្រអប់សំបុត្រលេខ ៥៣១ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទលេខ: (៨៥៥)២៣ ៨៩០១៨០
ទូរសារលេខ: (៨៥៥)២៣ ៨៩០១៨០
អ៊ីម៉ែល: info@rac.gov.kh
វេបសាយ: www.rac.gov.kh